៣ ក៏ព្រះសង្ឃមានបាន ជាគ្រូជួយបង្រៀនសិស្សដែរ ។
៤ ជំនាន់នោះគេឈប់ឡើងប្រឡង ។
៥ ឡើងទៅប្រឡងនៅទេ ។
៦ កែក្តីមិនបានទេ ។
៧ ដល់គាត់ធ្លាក់ បានគេឈប់ប្រឡង ។
៨ ហើយខ្ញុំខានឡើងទៅរៀន ។
៩ គ្រូជាជួយប្រដៅមានកិរិយាល្អ ។
១០ ការរៀបការនេះជាក្តីឡើងមិនបាន ។

7. (Have the student) discuss the following situations:
១ របៀបសិក្សានៅស្រុកនេះ ។
២ ប្រឡងនៅស្រុកនេះ ។
៣ [illegible] (កូន) ។
៤ វិន័យនៅសាលា ។
៥ ចំនួនសិស្សទៅរៀនតាំងពីដើម ។
៦ រៀនទីខ្លះទៅបរទេសសិក្សា ។
៧ គេបង្រៀនដំបូន្មានទេ ?
៨ ពីគ្រូបង្រៀន ។

8. Questions for the teacher to ask:

១ អាយុប៉ុន្មាន បានក្មេងស្រុកនេះចាប់រៀនសាលា?
២ នៅបឋមសិក្សា ត្រូវរៀនប៉ុន្មានឆ្នាំ? ចុះមធ្យមសិក្សា?
៣ មានប្រឡងយកសញ្ញាប័ត្រអីខ្លះ នៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា?
៤ អ្នករៀនវិជ្ជាការគ្រូបង្រៀន ត្រូវរៀនប៉ុន្មានឆ្នាំ បានចេញធ្វើការ?
៥ ថ្នាក់នីមួយៗនៅបឋមសិក្សា និងមធ្យមសិក្សា មានសិស្សប៉ុន្មាននាក់?
៦ គ្រូមានទំលាប់វាយសិស្សទេ?
៧ សិស្សមិនធ្វើតាមគ្រូ តើគេធ្វើយ៉ាងមេច?
៨ សិស្សត្រូវប្រឡងចូលមហាវិទ្យាល័យទេ?
៩ នៅស្រុកនេះ សាលាទាំងអស់សុទ្ធតែសាលារដ្ឋការ?
១០ មួយឆ្នាំសិស្សមានវិស្សមកាលប៉ុន្មានដង?

9. Questions for the student to ask:

Find out from your teacher the answers to the following questions. Ask in Cambodian, of course. Use the questions at the end of each lesson as a guide to start conversation between yourself and your teachers, not simply as a task to be gotten through. If your teacher's answer brings up new questions in your mind, be sure to ask them; explore thoroughly every topic that comes up before going on to the next question on the list. Since different people have different experiences and different opinions, try asking these questions with more than one teacher, or try asking Cambodians who are not teachers.

a. What is the normal starting age for school children? Is it the same in the city and the country?
b. How many years do most students study? Are country and city different?
c. What kind of education is needed to get a government job?
d. Are private and public schooling considered to be equally good?
e. Does everbody take the same program, or are there special programs to meet special interests and different levels of ability?
f. How is discipline maintained in the classroom? Is there corporal punishment?
g. Does the government supply books, or must students buy them themselves?
h. Are scholarships and other forms of financial aid available to help children form poor families?
i. Does the government make provision for poor students from the provinces to come and study in the city?
j. Of all the students who start school, what percentage finish elementary school? The various stages of secondary school? University?
k. Is there anything corresponding to kindergarten in Cambodia? (You will probably have to explain the concept of kindergarten to get the idea across, since there is no single-word translated.)

LESSON TWO

KHMERIZATION

a. What is Khmerization?

b. What do the critics of Khmerization mean when they say it is really Sanskrit and Pali?

c. What is the extent of university instruction in Khmer?

បញ្ហាលុបភាសាបារាំងនៅបឋមសិក្សា

បញ្ហាលុបភាសាបារាំង នៅបឋមសិក្សានេះ លោក ហូតុងហូ ប្រធានអង្គប្រជុំនៃការលុបបំបាត់ បាន ពង្ហាញហេតុផល ជាច្រើនលើកមកហើយ ចំណែកអស់លោកជាសមាជិកនៃអង្គប្រជុំ ក៏បាន ឆ្លើយបញ្ជាក់តាម ទំព័រសារពត៌មាន ជាច្រើនណាស់ហើយដែរ ។ រីឯសេចក្ដីបញ្ជាក់ទាំងនោះឃើញថា ចង់ឲ្យសិស្សភាគច្រើន ដែលគ្មានភ័ព្វវាសនាអាចទៅបន្តវិជ្ជានៅមធ្យមសិក្សានោះ គ្នាបានចេះភាសាខ្មែរជ្រៅជ្រះគ្រាន់បើ កុំឱ្យស្ទាក់ស្ទើរ បារាំងមិនបារាំង-ខ្មែរមិនខ្មែរ ប្រើការមិនកើត ដូចមុនទៀត ។ ចំណែកសិស្សដែលបានទៅបន្តវិជ្ជា នៅមធ្យមសិក្សាសោត ក៏បានចំណេញពេលនឹងរៀនភាសាបរទេសដែរ ព្រោះបានចេះភាសាខ្មែរក្រាស់ក្រែលពីបឋមសិក្សារួចទៅហើយ ។ល។ និង ។ល។

កំណែប្រែនេះ ឃើញហុចអត្ថប្រយោជន៍ដល់កូនខ្មែរ ដ៏ធំទូលាយណាស់ គឺខ្មែរប្រាកដជាខ្មែរ-បារាំងប្រាកដជាបារាំង មិនស្ទើរភ្លើងឡើយ ។ ប៉ុន្តែអត្ថប្រយោជន៍ដ៏ធំធេងនេះ ពុំបានទាញអារម្មណ៍មនុស្សខ្លះឲ្យយល់ច្បាស់ឡើយ ត្រឡប់ជាភ័យស្លន់ស្លោហាក់ដូចជាស្រុតព្រះធរណី ហើយមានបញ្ញវ័ន្តខ្លះ ដែលសង្ឃឹមមើលតែផ្លែលើខ្ពស់ហួសពេកនោះ បានពោលថា បើមិនរៀនបារាំងទេ បានអីយកទៅនិយាយនៅអង្គការសហប្រជាជាតិ? បានអីយកទៅរៀនវិទ្យាសាស្ត្រ? (អស្ចារ្យ) ហើយមានអ្នកខ្លះទៀត បានពោលចំអកឲ្យខេមរយានកម្មថា ភាសាក្លិង្គ, ភាសាបាលី ។ល។

ចំណែកយើងវិញ យើងយល់ស្រប តាមកំណែនេះពេញទី ព្រោះយើងគិតឃើញបែបនេះយូរមកហើយ ។ ដូចយើងបានអធិប្បាយខ្លះ តាមអ្នកជាតិនិយមលេខ ៥៣១ ចេញថ្ងៃទី ២៥ តុលា ១៩៧០ ស្រាប់ ។

រីឯអង្គប្រជុំនៃបុគ្គលិកសិក្សាកាលពីថ្ងៃទី ៦-១០-៧០ ដែលយល់ព្រមឲ្យលុបបំបាត់មិនឲ្យរៀនភាសាបារាំង នៅបឋមសិក្សានោះ បានពិចារណាដោយ

មិត់ចត់ណាស់ ។ លោក ឈ្យក - ម៉ឹងម៉ៅ, លោក ហ្វ តុង ហ្វ ជាអធិការបឋមសិក្សា មានការពិសោធន៍យូរឆ្នាំហើយ ហើយបានទៅកាន់ការជានាយកទីចាត់ការ កិច្ចការគរុកោសល្យ និងបានទៅប្រជុំនៅអន្តរជាតិ អំពីវិស័យសិក្សា ក្នុងមួយឆ្នាំៗបីបួនដង ព្រមទាំងបានគិតអំពីបញ្ហានេះជារៀងរាល់ថ្ងៃ ។ ចំណែកសមាជិកអង្គប្រជុំឯទៀតៗ មានលោក ណុប - ធុំ, លោក ខ្វាន់-ស៊ីផាន់ , លោក ផៃ-ផេង ជាដើមក៏សុទ្ធតែមាន ការពិសោធន៍យ៉ាងជាក់ច្បាស់ណាស់ គ្រាន់បើជាងអ្នកប្រឆាំងដែលចេះស្ទើរ ឬចេះហួស ឬក៏អ្នកដែលមិនដែលបានគិត ។

ចំណែកអស់លោកខ្លះដែលពោលថា បើមិនរៀនបារាំងទេ តើបានអីយកទៅនិយាយនៅអង្គការសហប្រជាជាតិ , បានអីយកទៅរៀនវិទ្យាសាស្ត្រ នោះ ឃើញថា ចាកប្រធានឆ្ងាយណាស់ សូមអស់លោកស្តាប់ឲ្យច្បាស់ផងមើល? តើមាននរណាមិនឲ្យរៀនភាសាបារាំង? គេគ្រាន់តែបំបាត់មិនឲ្យរៀននៅបឋមសិក្សាទេតើ? ចំណែកមធ្យមសិក្សាវិញនៅតែរៀនដដែល ហើយខ្លាំងជាងមុនទៀតផង ។ មិនគ្រាន់តែរៀនភាសាបារាំងប៉ុណ្ណោះទេ គឺចែកមុខគ្នារៀនភាសាបរទេសដទៃទៀត មាន **ភាសាអង់គ្លេស , រុស្ស៊ី , អាល្លឺម៉ង់** ជាដើម ។

ចំពោះអស់លោកខ្លះ ដែលពោលចំអកឲ្យខេមរយានកម្មថា **ភាសាក្លឹង្គ** និង **ភាសាបាលី** នោះ យើងសូមឲ្យអស់លោកទាំងនោះ ពិចារណាឡើងវិញផងដែរថា ចុះត្រង់ភាសាបារាំង ដែលគេយកភាសាដទៃមកបញ្ចូល មាន **ភាសាឡាតាំង** , **ភាសាក្រិច** និង **ភាសាអង់គ្លេស** ជាដើមនោះ ម៉េចក៏អស់លោកមិនថាផង? ប៉ុន្តែការណ៍នេះ យើងមិនងឿងឆ្ងល់អ្វីទេ ព្រោះការស្ថាបនាអ្វីៗក៏ដោយ វាតែងតែមានយោបល់ផ្ទុយគ្នាខ្លះពុំខាន ។

NOTES FOR READING PASSAGE 1

Column 1 Line 5. Note that អស់លោក is the plural form of លោក 'sir, you.' To include members of both sexes the usual expression is អស់លោកអ្នក or អស់លោកអ្នកនាង 'ladies and gentlemen.' All of these phrases can be used either as second or third person forms; in this passage អស់លោក is third-person plural.

Column 1 Line 10. គ្នា , as you know, means 'each other.' However, it is also used as a first or third person pronoun, ordinarily with a strong connotation of familiarity or even intimacy. In the third person it has an additional connotation of sympathy.

Here, for instance, the writer is indicating that he feels compassion for students with limited opportunities to study beyond elementary school.

Column 1 Line 19. This line may be easier to understand if you read កំណែកែប្រែ នេះ បានឃើញ,...

Column 1 Line 19. The word កំណែ 'correction' is related to កែ 'to correct.' Many Cambodian words are related to other words in similar ways. The shorter word, e.g., កែ 'to correct,' is called the base, the new word, e.g., កំណែ 'correction' is called a derivative. The derivative is formed in this case by an infix, which is like a prefix or suffix, except that it comes inside the base rather than before it or after it. The infix in our present example is -ɔmn-. Some other words that you know are also derivatives formed by the infix -ɔmn-:

ចំណេញ 'profit' from ចេញ 'to go out, to emit'
ចំណេះ 'knowledge' from ចេះ 'to know how'

When the base begins with a second-series consonant (គ ឃ ង ជ ឈ ញ etc.), the infix is -umn-, e.g., គំនិត 'idea, thought' from គិត 'to think.'

When -ɔmn- -umn- is used with a base that begins with a consonant cluster, it takes the form -ɔm-/-um-, e.g., តម្លៃ 'price, value' from ថ្លៃ 'expensive, price.'

Derivatives can also include a prefix rather than an infix, e.g., បង្រៀន 'to teach' from រៀន 'to learn.' The prefix in this example is បង់ bɔŋ-.

Derivation is discussed in greater detail in N.3.1, N.3.1.1, and N.3.1.2 as well as V.3.2, V.3.2.1, and V.3.2.2. of the Grammatical Sketch. Note that both bases and derivatives can be nouns or verbs.

DRILLS FOR READING PASSAGE 1

DRILL A: Substitution

គំរូ

ក បើមិនរៀនបារាំង បានអីយកទៅ
និយាយនៅអង្គការសហប្រជាជាតិ ?
(មិនរៀនវិទ្យាសាស្ត្រ, ប្រឡងបាក់ឌុប២)

ខ បើមិនរៀនវិទ្យាសាស្ត្រទេ បានអីយកទៅ
ប្រឡងបាក់ឌុប២ ?

MODEL:

T: If we don't study French, what will we speak at the United Nations? (not study science, take the Baccalaureate II examination)

S: If we don't study science, how will we take the Baccalaureat II examination?

បើមិនរៀនវិទ្យាសាស្ត្រ បានអីយក
ទៅប្រឡងបាក់ឌុប ?

ក មិនរៀបចំឱ្យហើយ, ជម្រាបអង្គប្រជុំ
បើយើងមិនរៀបចំឱ្យហើយ បានអីយក
ទៅជម្រាបអង្គប្រជុំ ?

ខ លុបភាសាឡាតាំង, ឱ្យកូនយើងសិក្សា
បើយើងលុបភាសាឡាតាំង បានអីយក
ទៅឱ្យកូនយើងសិក្សា ?

គ បំបាត់ផ្លូវនេះ, បង្ហាញលោកប្រធាន
បើយើងបំបាត់ផ្លូវនេះ បានអីយក
ទៅបង្ហាញលោកប្រធាន ?

ឃ មិនយកសារពត៌មានមកនេះ, បញ្ជាក់អង្គប្រជុំ
បើយើងមិនយកសារពត៌មានមកនេះ
បានអីយកទៅបញ្ជាក់អង្គប្រជុំ ?

ង មិនសិក្សាភាសាខ្មែរត្រឹមត្រូវ, បន្តវិជ្ជានៅ
មុខទៀត ។
បើយើងមិនសិក្សាភាសាខ្មែរត្រឹមត្រូវ បាន
អីយកទៅបន្តវិជ្ជានៅមុខទៀត ?

ច មិនគិតគុណ, អធិប្បាយឱ្យគេស្ដាប់
បើយើងមិនគិតគុណ បានអីយកទៅ
អធិប្បាយឱ្យគេស្ដាប់ ?

DRILL B: Response

គ្រូ

ក មិនបាច់រៀនបារាំងទេ ។
(និយាយនៅអង្គការសហប្រជាជាតិ)

ស បើមិនរៀនបារាំង បានអីយកទៅ
និយាយនៅអង្គការសហប្រជាជាតិ ?

MODEL:

T: We don't need to study French.
(speak at the United Nations)

S: If we don't study French, what will
we speak at the United Nations?

ក មិនបាច់សរសេរទេ ។
(បង្រៀន)
បើមិនសរសេរ បានអីយកទៅបង្រៀន ?

ខ យើងមិនត្រូវសិក្សាភាសាបរទេសទេ ។
(បន្តការសិក្សានៅបរទេស)
បើមិនសិក្សាភាសាបរទេស បានអីយក
ទៅបន្តការសិក្សានៅបរទេស?

គ មិនបាច់ទុកសៀវភៅទេ ។
(ឱ្យក្មេងៗរៀនថ្ងៃក្រោយ)
បើមិនទុកសៀវភៅ បានអីយកទៅឱ្យ
ក្មេងៗរៀនថ្ងៃក្រោយ ?

ឃ មិនបាច់យកអាហ្វីសទេ ។
(បង្ហាញគណកម្មាធិការ)
បើមិនយកអាហ្វីសទៅ បានអីយកទៅ
បង្ហាញគណកម្មាធិការ ?

ង មិនបាច់នាំយកទៅទេ ។
(ជម្រាបសមាជិកអង្គប្រជុំ)
បើមិនយកទៅ បានអីយកទៅជម្រាប
សមាជិកអង្គប្រជុំ ?

ច មិនបាច់ឱ្យធ្វើបកទេ ។
(បញ្ជាក់សម្រាប់គេ)
បើមិនឱ្យធ្វើបក បានអីយកទៅ
បញ្ជាក់សម្រាប់គេ ?

DIALOGUE

ខេមរយានកម្ម

	នាំគ្នា	to do as a group
	ឆោឡោ	to be in a panic
	មើលទៅ	to seem, to be like
	ខ្លាចូលស្រុក	a tiger is in the neighborhood
១ តើក	រឿងខេមរយានកម្មហ្នឹង ធ្វើឲ្យនាំគ្នាឆោឡោ មើលទៅ ខ្លាចូលស្រុក ។	Khmerization is throwing people into a panic; it's as if a tiger were on the the prowl in the area.
	អីក៏មិន	of course
	និយម	to tend to, be accustomed to, to like
	verb + ទៅ	(see note)
២ កយ	អីក៏មិនឆោឡោ បើអ្នកនិយមបារាំងនិយាយទៅ ដូចមិនយល់អីសោះ ។	Of course they're in a panic, because when the Francophiles talk, they seem not to make any sense at all.
	បាន = បានជា	is the reason why
	ទៅជា	to become, to come about that
៣ តើក	ក្រុមអ្នកនិយមហ្នឹងគិតយ៉ាងម៉េច បានទៅជាមិនយល់គ្នា ។	How do those French speakers think that makes them unable to communicate?
	និយាយឡើង	to speak up
	ចាក	to depart
	ប្រធាន	subject
	ចាកប្រធាន	to miss the point
	តែម្តង təmdaŋ	directly, period, that's all
	អីសោះ	at all
៤ កយ	ពួកហ្នឹងនិយាយឡើងក៏ចាកប្រធានតែម្តង គ្មានយល់ពីរឿងខេមរយានកម្មអីសោះ ។	When that lot speak up, they just miss the point (of the conversation). They don't understand the reasons for Khmerization at all.

	ក្រែង	least, I'm concerned that, maybe
	ភ័យខ្លាច	to be afraid
	លុបចោល	to liquidate, do away with, eliminate
៥ តេក	ក្រែងពួកហ្នឹងភ័យខ្លាចគេលុប បារាំងចោលទេនេះ ?	Maybe they're afraid that French will be done away with altogether?
	ទោះបី	even (if)...
	ជា...ទៅចុះ	(see note)
	ទោះបី...ក៏	even if ...
៦ ភយ	គ្មានអ្នកណានិយាយពីរឿង លុបសោះ តែទោះបីជាលុប ទៅចុះ ក៏មិនត្រូវភ័យដែរ ។	No one's talking about eliminating it at all, but even if it were done away, they shouldn't be afraid.
	មិន...ឯណាបាន	how can not + verb be possible
	ឯណា	(cf. Introduction, lesson 54)
	មិនខ្ចី + verb	wouldn't ... under any circumstances
	ផងនោះ = តាមពិត	(see note)
៧ តេក	មិនភ័យឯណាបាន បើខ្លះមិន ខ្ចីទាំងចង់ចេះនិយាយខ្មែរផងនោះ ។	How can they not be afraid, if some of them wouldn't be caught dead wanting to know Cambodian.
	មែន	real, really
	មែនទែនទៅ	in fact, actually
	ទាំង + noun	even
	ទាំង + verb	even
	មិនត្រង់ត្រូវ	incorrect
៨ ភយ	មែនទែនទៅក្រុមបារាំងហ្នឹង និយាយទាំងបារាំងហ្នឹងមិនទាំង ត្រង់ត្រូវផង ។	In fact those French speakers don't even speak French correctly.
	ស្ទាក់ស្ទើរ	to be uncertain, to not know what to think
	ស្ទើរ	insufficient
	ក៏ ... ក៏	(see note)
	អីទាំងអស់	at all
	បានការ	to be of use, to be good, to have good result

៩ ទេក	ចំឡាកស្មើតែរអង់រស បារាំងមិនបារាំង ខ្មែរក៏មិនខ្មែរ ក្មានបានការអ្វីទាំងអស់ ។	They're all messed up: their French isn't French, and their Cambodian isn't Cambodian; they're no use at all.
	និយាយឲ្យខ្លី	In short
	ស្រុះ	(see note)
១០ កុយ	និយាយឲ្យខ្លីទៅ ស្រុកយើងបានស្រុះឯករាជ្យយូរហើយ តែភាសាមិនទាន់បានស្រុះទេ នោះ ។	In short, our country has had independence for a long time, but not our language.

NOTES FOR THE DIALOGUE

SENTENCE NO. 2

As you know, ទៅ when preceded by a verb is an imperative or exhortative particle, e.g., មើលទៅ 'read it' or 'go ahead and read (it).' In this sentence, however, ទៅ is a defenite particle, e.g.,

បើគេសរសេរទៅ គេនឹងបានផលល្អ ។

If they would write, they would get good results.

In sentence 10 ទៅ in និយាយឲ្យខ្លីទៅ is a similar particle.

SENTENCE NO. 2

The word និយម here means 'to be in favor of, pro-.' និយមបារាំង means 'Francophile, pro-French'; និយមស្តេច means 'royalist.' និយម can also be used with a noun to mean 'fond of, partial to', e.g.,

គេនិយមសាច់ជ្រូកនៅស្រុកចិន ។

They're partial to pork in China.

With a verb, និយម means 'to tend to, to accustomed to, like to,' e.g.,

នៅស្រុកស្រែ អ្នកស្រែនិយមញ៉ាំបាយថ្ងៃប៉ុន្មានដង ?

In the country, how many times a day are the farmers accustomed to eating?

SENTENCE NO. 6

The idiom ថា...ទៅចុះ indicates concession of a point of an argument. It can be translated something like 'even granted that ...', e.g.,

ថាគាត់ត្រូវការលុយមែនទែនទៅចុះ ក៏គាត់មិនត្រូវធ្វើការយ៉ាងនោះដែរ ។

Even granted that he really needs money, he wouldn't be caught dead at that kind of work.

SENTENCE NO. 7

In this sentence នោះ is not translated. Its effect is to establish distance between the speaker and the Francophiles from whom, as a nationalistic Khmer, he wished to dissociate himself.

SENTENCE NO. 9

The words ក៏...ក៏ in this sentence indicate that the two clauses in which they occur are parallel and closely coordinated. Another way of translating the sentence that shows the parallelism indicated by ក៏...ក៏ is 'neither is their French French, nor is their Cambodian Cambodian.'

SENTENCE NO. 10

ត្រូវ + noun means 'to be struck by, to be affected by.' For instance ត្រូវគ្រាប់ is 'to be hit by a bullet.' In the case of ត្រូវវិការឡៀ the concept involved is somewhat more abstract, but the basic sense of the phrase is still related to 'to be struck and affected by.'

DRILLS

DRILL ONE: Substitution (Variable)

គំរូ

ក រឿងខេមរយានកម្មហ្នឹងធ្វើឱ្យនាំគ្នាឆោឡោ
មើលតែខ្លាចូលស្រុក ។ (រឿង)

ខ រឿងហ្នឹងធ្វើឱ្យនាំគ្នាឆោឡោមើលតែខ្លា
ចូលស្រុក ។

MODEL:

T: Khmerization has them in a panic as if a tiger were around. (that matter)

S: That matter has them in a panic as if a tiger were around.

រឿងហ្នឹងធ្វើឱ្យនាំគ្នាឆោឡោមើលតែខ្លា
ចូលស្រុក ។

ក រឿងលុបបារាំងចោល
រឿងលុបបារាំងចោលធ្វើឱ្យនាំគ្នាឆោឡោ
មើលតែខ្លាចូលស្រុក ។

ខ ភ័យ
រឿងលុបបារាំងចោលធ្វើឱ្យនាំគ្នាភ័យ
មើលតែខ្លាចូលស្រុក ។

គ បញ្ហា
បញ្ហាហ្នឹងធ្វើឱ្យនាំគ្នាភ័យមើលតែខ្លាចូល
ស្រុក ។

ឃ ស្រុកព្រះធរណី
បញ្ហាហ្នឹងធ្វើឱ្យនាំគ្នាភ័យមើលតែស្រុក
ព្រះធរណី ។

ង ភ័យស្លន់
បញ្ហាហ្នឹងធ្វើឱ្យនាំគ្នាភ័យស្លន់មើលតែ
ស្រុកព្រះធរណី ។

ច ភ័យស្លោ
បញ្ហាហ្នឹងធ្វើឱ្យនាំគ្នាភ័យស្លោមើលតែ
ស្រុកព្រះធរណី ។

DRILL TWO: Transformation

គំរូ

ក គេនាំគ្នាឆោឡោ ព្រោះនិយាយបារាំង
មិនត្រូវសោះ ។ (អ្នកនិយាយបារាំង)

ខ អីក៏មិនឆោឡោ បើអ្នកនិយាយបារាំងនិយាយ
បារាំងមិនត្រូវសោះ ។

MODEL:

T: They were in a panic because they couldn't speak French right at all. (Francophiles)

S: Of course they were in a panic, if the Francophiles couldn't speak French right at all.

ក គេនាំគ្នាប្រកែក ព្រោះមិនចេះរៀបចំ
ជាការ។ (ប្រធានអង្គប្រជុំ)
អីក៏មិនប្រកែក បើប្រធានអង្គប្រជុំមិនចេះ
រៀបចំជាការ។

ខ គេនាំគ្នាលបទោស ព្រោះរៀបចំមិន
បាន។ (អ្នកនិពន្ធ)
អីក៏មិនលបទោស បើអ្នកនិពន្ធរៀបចំ
មិនបាន។

គ គេនាំគ្នាលបភាសាបារាំង ព្រោះសរសេរ
ឈ្មោះជាខ្មែរមិនត្រូវទេ។ (កូនសិស្ស)
អីក៏មិនលបភាសាបារាំង បើកូនសិស្ស
សរសេរឈ្មោះជាខ្មែរមិនត្រូវទេ។

ឃ គេនាំគ្នារៀនខ្មែរ ព្រោះសុទ្ធតែជាខ្មែរ
ទាំងអស់។ (ប្រធានប្រឡង)
អីក៏មិនរៀនខ្មែរ បើប្រធានប្រឡងសុទ្ធតែ
ជាខ្មែរទាំងអស់។

ង គេនាំគ្នាភ័យស្លន់ ព្រោះធ្វើចំណោទមិន
ដែលត្រូវសោះ។ (កូនសិស្ស)
អីក៏មិននាំគ្នាភ័យស្លន់ បើកូនសិស្សធ្វើ
ចំណោទមិនដែលត្រូវសោះ។

ច គេនាំគ្នាខឹងឆោឡោ ព្រោះមិនប្រាប់
ឱ្យដឹងមុន។ (ប្ដី)
អីក៏មិនខឹងឆោឡោ បើប្ដីមិនប្រាប់
ឱ្យដឹងមុន។

DRILL THREE: Transformation

គ្រូ

ក អ្នកនិយមបារាំងនិយាយទៅ ដូចមិន
យល់សោះ។
(គិត)

ស អ្នកនិយមហ្នឹងគិតយ៉ាងម៉េច បានទៅជា
មិនយល់គ្នា ?

MODEL:

T: The Francophiles seem to show that they don't understand anything when they talk. (think)

S: How do the Francophiles think that makes them unable to understand each other?

ក ពួកខាងប្រឆាំងតបទៅទៀង ដូចមិនគាប់
អ្នកណាសោះ។
(គិតឃើញ)
ពួកហ្នឹងគិតឃើញយ៉ាង បានទៅជាមិន
គាប់គ្នា ?

ខ ក្រុមអ្នកការពារឆ្លើយទៀង ដូចមិន
បានស្ដាប់គ្នា។
(ចង់បាន)
ក្រុមហ្នឹងចង់បានយ៉ាងម៉េច បានទៅ
ជាមិនស្ដាប់គ្នា ?

គ ក្រុមអ្នកចង់លុបនិយាយទៀង ដូចមិន
គោរពអ្នកណាសោះ។
(គិតខ្លួន)
ក្រុមហ្នឹងគិតខ្លួនយ៉ាងម៉េច បានទៅ
ជាមិនគោរពគ្នា ?

ឃ ពួកស្ទើរបារាំងស្ទើរខ្មែរនិយាយទៀង ដូច
ជាចំអកឱ្យគេ។
(នឹកឃើញ)
ពួកហ្នឹងនឹកឃើញយ៉ាងម៉េច បានទៅជា
ចំអកឱ្យគ្នា ?

ង ក្រុមអ្នកចង់តែពោលទៀង ដូចមិនគិត
ដល់អ្នកណាសោះ។
(មើលទៅគេឃើញ)
ក្រុមហ្នឹងមើលទៅគេឃើញយ៉ាងម៉េច
បានទៅជាមិនគិតដល់គ្នា ?

ច ក្រុមចង់បញ្ជាក់ភាសាបារាំងពោលទៀង
ដូចមិនយល់អ្នកណាសោះ។
(ចង់បានអត្ថប្រយោជន៍)
ក្រុមហ្នឹងចង់បានអត្ថប្រយោជន៍យ៉ាង
ម៉េច បានទៅជាមិនយល់គ្នា ?

DRILL FOUR: Substitution (variable)

គំរូ

ក អ្នកនិយាយបារាំងនិយាយទៅ ដូចមិន
យល់អ្វីសោះ ។ (សួរ)

ខ អ្នកនិយាយបារាំងសួរទៅ ដូចមិនយល់
អ្វីសោះ ។

MODEL:

T: The Francophiles seem to show that they don't understand anything when they talk. (ask)

S: The Francophiles seem to show that they don't understand anything when they are asked.

អ្នកនិយាយបារាំងសួរទៅ ដូចមិនយល់
អ្វីសោះ ។

ក កូនសិស្សខ្ញុំ
កូនសិស្សខ្ញុំសួរទៅ ដូចមិនយល់អ្វីសោះ ។

ខ បង្រៀន
កូនសិស្សខ្ញុំបង្រៀនទៅ ដូចមិនយល់
អ្វីសោះ ។

គ បានប្រយោជន៍
កូនសិស្សខ្ញុំបង្រៀនទៅ ដូចមិនបាន
ប្រយោជន៍អ្វីសោះ ។

ឃ ប្រាប់
កូនសិស្សខ្ញុំប្រាប់ទៅ ដូចមិនបាន
ប្រយោជន៍អ្វីសោះ ។

ង ប្រពន្ធខ្ញុំ
ប្រពន្ធខ្ញុំប្រាប់ទៅ ដូចមិនបានប្រយោជន៍
អ្វីសោះ ។

ច ស្តីឲ្យ
ប្រពន្ធខ្ញុំស្តីឲ្យទៅ ដូចមិនបាន
ប្រយោជន៍អ្វីសោះ ។

DRILL FIVE: Substitution

គំរូ

ក ពួកហ្នឹងនិយាយឡើង គឺចាកប្រធាន
តែម្តង ។ (គិត, ចាកប្រធាន)

ខ ពួកហ្នឹងគិតឡើង គឺចាកប្រធានតែម្តង ។

MODEL:

T: When that group speaks up they miss the point.
(think, miss the point)

S: When that group thinks, they miss the point.

ពួកហ្នឹងគិតឡើង គឺចាកប្រធានតែម្តង ។

ក ពោល, ចំអកឲ្យគេ
ពួកហ្នឹងពោលឡើង គឺចំអកឲ្យគេ
តែម្តង ។

ខ បញ្ជាក់, ឃើញតែខុស
ពួកហ្នឹងបញ្ជាក់ឡើង គឺឃើញតែខុស
តែម្តង ។

គ លើកយកនិយាយ, ធ្វើឲ្យគេស្លន់
ពួកហ្នឹងលើកយកនិយាយឡើង គឺធ្វើឲ្យ
គេស្លន់តែម្តង ។

ឃ ថា, ខុស
ពួកហ្នឹងថាឡើង គឺខុសតែម្តង ។

ង កាន់ការ, ខុសគេ
ពួកហ្នឹងកាន់ការឡើង គឺខុសគេតែម្តង ។

ច ចាត់ការ, គ្មានអ្នកណាយល់ព្រម
ពួកហ្នឹងចាត់ការឡើង គឺគ្មានអ្នកណា
យល់ព្រមតែម្តង ។

DRILL SIX: Transformation

គំរូ

ក ពួកហ្នឹងមិនភ័យខ្លាចគេលុបបារាំងចោលទេ ។

ខ ក្រែងពួកហ្នឹងភ័យខ្លាចគេលុបបារាំង
ចោលទេដឹង ?

MODEL:

T: That lot isn't afraid that French will be eliminated.

S: Maybe that lot is afraid that French will be eliminated.

ក កូនសិស្សរៀនហ្នឹងចេះបារាំង ។
ក្រែងកូនសិស្សរៀនហ្នឹងមិនចេះបារាំងទេនេះ ?

ខ អ្នកប្រជុំយល់ព្រមឲ្យលុបចោល ។
ក្រែងអ្នកប្រជុំមិនយល់ព្រមឲ្យលុបចោលទេនេះ ?

គ លោកប្រធាននិយាយទាក់ប្រធាន ។
ក្រែងលោកប្រធានមិននិយាយទាក់ប្រធានទេនេះ ?

ឃ ភាគបានគិតការណ៍ដោយប្រាកដជាក់ ។
ក្រែងភាគមិនបានគិតការណ៍ដោយប្រាកដជាក់ទេនេះ ?

ង អស់លោកខ្លះមិនចង់អោយខេមរយានកម្មទេ ។
ក្រែងអស់លោកខ្លះចង់អោយខេមរយានកម្មទេនេះ ?

ច អ្នកខ្លះមិនទៀងទូលនឹងកម្មវិធីបង្រៀនថ្មីទេ ។
ក្រែងអ្នកខ្លះទៀងទូលនឹងកម្មវិធីបង្រៀនថ្មីទេនេះ ?

DRILL SEVEN: Substitution

គំរូ

ក ទោះបីថាលុបចោលទៅចុះ ក៏មិនត្រូវភ័យដែរ ។
(គ្មានសំណាង, អស់សង្ឃឹម)

ខ ទោះបីថាគ្មានសំណាងទៅចុះ ក៏មិនត្រូវអស់សង្ឃឹមដែរ ។

MODEL:

T: Even if they eliminate it, (they) shouldn't be afraid.
(have no luck, despair)

S: Even if (they) have no luck, (they) shouldn't despair.

ទោះបីថាគ្មានសំណាងទៅចុះ ក៏មិនត្រូវអស់សង្ឃឹមដែរ ។

ក មិនចំណេញ, ស្ទាក់ស្ទើរ
ទោះបីថាមិនចំណេញទៅចុះ ក៏មិនត្រូវស្ទាក់ស្ទើរដែរ ។

ខ មិនប្រជុំ, ខាន
ទោះបីថាមិនប្រជុំទៅចុះ ក៏មិនត្រូវខានដែរ ។

គ មិនបានស្នើឲ្យ, ឈប់
ទោះបីថាមិនបានស្នើឲ្យទៅចុះ ក៏មិនត្រូវឈប់ដែរ ។

ឃ មិនយល់ស្រប, ឆោឡោ
ទោះបីថាមិនយល់ស្របទៅចុះ ក៏មិនត្រូវឆោឡោដែរ ។

ង បំបាត់ចោល, ភ័យស្លន់
ទោះបីថាបំបាត់ចោលទៅចុះ ក៏មិនត្រូវភ័យស្លន់ដែរ ។

ច យល់ផ្ទុយ, ចែកបក្សគ្នា
ទោះបីថាយល់ផ្ទុយទៅចុះ ក៏មិនត្រូវចែកបក្សគ្នាដែរ ។

DRILL EIGHT: Response

គំរូ

ក ក្រែងពួកហ្នឹងភ័យខ្លាចគេលុបបារាំងចោលទេនេះ ? (ភ័យ)

ខ ថាលុបចោលទៅចុះ គេនៅតែមិនត្រូវភ័យដែរ ។

MODEL:

T: Maybe that lot is afraid that French will be eliminated.
(to be afraid)

S: Let them eliminate French, (they) still snoundn't be afraid.

ក ក្រែងពួកហ្នឹងមិនព្រមឲ្យគេកែប្រែទេនេះ ? (គិតយ៉ាងហ្នឹង)
ថាកែប្រែទៅចុះ គេនៅតែមិនត្រូវគិតយ៉ាងហ្នឹងដែរ ។

ខ ក្រែងគេមិនយល់ស្របឲ្យគេលុបបំបាត់ទេនេះ ? (ឆោឡោ)
ថាលុបបំបាត់ទៅចុះ គេនៅតែមិនត្រូវឆោឡោដែរ ។

គ ក្រែងគេមិនចង់ឲ្យគេធ្វើព្យាសនេះ?
(ឈ្មោះខ្ចីក្រេក)
ថាធ្វើព្យាសទៅចុះ: តែនៅតែមិនត្រូវ
ឈ្មោះខ្ចីក្រេកដែរ ។

ឃ ក្រែងគេមិនឃើញថាក្នុងសង្គ្រាមកាសនា
នេះ? (ភ័យស្លាប់)
ថាក្នុងសង្គ្រាមកាសនាទៅចុះ: តែនៅតែ
មិនត្រូវភ័យស្លាប់ដែរ ។

ង ក្រែងក្មេងហ្នឹងភ័យខ្លាចបើឲ្យគេពិបាក
នេះ? (ជួលឡានហ្នឹង)
ថាពិបាកទៅចុះ: តែនៅតែមិនត្រូវ
ជួលឡានហ្នឹងដែរ ។

ច ក្រែងគេគិតរឿងនេះមិនបានប្រយោជន៍
ឲ្យនេះ? (ចង់ចំណេញគេ)
ថាមិនបានប្រយោជន៍ឲ្យទៅចុះ: តែ
នៅតែមិនត្រូវចង់ចំណេញគេដែរ ។

DRILL NINE: Substitution

គំរូ

ក មែនទែនទៅ និយាយទាំងបារាំងហ្នឹងមិន
ទាំងត្រង់ត្រូវផង ។
(សរសេរ, ខ្មែរ)

ខ មែនទែនទៅ សរសេរទាំងខ្មែរហ្នឹងមិន
ទាំងត្រង់ត្រូវផង ។

MODEL:

T: In fact, they don't even speak
French correctly.
(write, Cambodian)

S: In fact, they don't even write
Cambodian correctly.

មែនទែនទៅ សរសេរទាំងខ្មែរហ្នឹងមិនទាំង
ត្រង់ត្រូវផង ។

ក ថា, ពាក្យ
មែនទែនទៅ ថាទាំងពាក្យហ្នឹងមិនទាំង
ត្រង់ត្រូវផង ។

ខ ប្រែ, ឃ្លា
មែនទែនទៅ ប្រែទាំងឃ្លាហ្នឹងមិនទាំង
ត្រង់ត្រូវផង ។

គ និយាយ, ភាសាខ្លួនឯង
មែនទែនទៅ និយាយទាំងភាសាខ្លួនឯង
ហ្នឹងមិនទាំងត្រង់ត្រូវផង ។

ឃ ចេះ, ភាសាខ្លួនឯង
មែនទែនទៅ ចេះទាំងភាសាខ្លួនឯងហ្នឹង
មិនទាំងត្រង់ត្រូវផង ។

ង មើល, បារាំង
មែនទែនទៅ មើលទាំងបារាំងហ្នឹងមិន
ទាំងត្រង់ត្រូវផង ។

ច និយាយតាម, គេ
មែនទែនទៅ និយាយតាមទាំងគេហ្នឹង
មិនទាំងត្រង់ត្រូវផង ។

DRILL TEN: Transformation

គំរូ

ក កូនសិស្សទាំងអស់ភ័យអំពីរឿងលុបបារាំង ។
(រៀនខ្មែរ)

ខ មិនភ័យឯណាបាន បើខ្លះមិនខ្ចីរៀន
ខ្មែរផងនោះ ។

MODEL:

T: All the students are afraid about the
business of eliminating French.
(study Cambodian)

S: How could (they) not be afraid, if
(they) wouldn't be caught dead studying
Cambodian.

គ លោកប្រធានខឹងខ្លាំងណាស់អំពីរឿងហ្នឹង ។
(ជួយការពារ)
មិនខឹងឯណាបាន បើខ្លះមិនខ្ចីជួយការពារ
ផងនោះ ។

ឃ គ្រូបង្អត់ពាក់ឃ្លាយក្មេងៗអស់ហ្នឹងហើយ ។
(ឲ្យរៀនខ្មែរ)
មិនបង្អត់ឯណាបាន បើខ្លះមិនខ្ចីឲ្យកូន
រៀនខ្មែរផងនោះ ។

គ លោកគ្រូដាក់ទោសកូនសិស្សណាស់ ។
(ចង់រៀនអង់គ្លេស)
មិនដាក់ទោសឯណាបាន បើខ្លួនមិនខ្ចីចង់
រៀនអង់គ្លេសផងនោះ ។

ឃ ត្រូវលើកទឹកចិត្តកូនសិស្ស ។
(មករៀន)
មិនលើកទឹកចិត្តឯណាបាន បើខ្លួនមិនខ្ចី
មករៀនផងនោះ ។

ង ខ្ញុំត្រូវដឹងខុសត្រូវក្នុងរឿងហ្នឹង ។
(បើកភ្នែកមើល)
មិនដឹងខុសត្រូវឯណាបាន បើខ្លួនមិនខ្ចី
បើកភ្នែកមើលផងនោះ ។

ច ត្រូវរៀបចំមេរៀនឲ្យសិស្ស ។
(យកសៀវភៅមក)
មិនរៀបចំឯណាបាន បើខ្លួនមិនខ្ចីយក
សៀវភៅមកផងនោះ ។

DRILL ELEVEN: Substitution

គំរូ

ក គាត់ស្ទាក់ស្ទើរទាំងអស់ បារាំងក៏មិនបារាំង
ខ្មែរក៏មិនខ្មែរ ។ (ស្រែ, ក្រុង)

ខ គាត់ស្ទាក់ស្ទើរទាំងអស់ ស្រែក៏មិនស្រែ
ក្រុងក៏មិនក្រុង ។

MODEL:

T: He doesn't know what to think, he doesn't know either French or Cambodian. (country, town)

S: He doesn't know what to think, he doesn't know whether (to choose) the the country or the city.

គាត់ស្ទាក់ស្ទើរទាំងអស់ ស្រែក៏មិនស្រែ
ក្រុងក៏មិនក្រុង ។

ក បាទ, ទេ
គាត់ស្ទាក់ស្ទើរទាំងអស់ បាទក៏មិនបាទ ទេ
ក៏មិនទេ ។

ខ ទៅ, នៅ
គាត់ស្ទាក់ស្ទើរទាំងអស់ ទៅក៏មិនទៅ នៅ
ក៏មិននៅ ។

គ. ចូល, ចេញ
គាត់ស្ទាក់ស្ទើរទាំងអស់ ចូលក៏មិនចូល
ចេញក៏មិនចេញ ។

ឃ លុប, ទុក
គាត់ស្ទាក់ស្ទើរទាំងអស់ លុបក៏មិនលុប
ទុកក៏មិនទុក ។

ង ទៅមុខ, ថយក្រោយ
គាត់ស្ទាក់ស្ទើរទាំងអស់ ទៅមុខក៏មិនទៅមុខ
ថយក្រោយក៏មិនថយក្រោយ ។

ច ឈរ, អង្គុយ
គាត់ស្ទាក់ស្ទើរទាំងអស់ ឈរក៏មិនឈរ
អង្គុយក៏មិនអង្គុយ ។

READING PASSAGE 2

វិធានការផ្សេង ៗ ក្នុងការអនុវត្តន៍ខេមរយានកម្មក្នុងសាលា

១– មូលដ្ឋាននៃការអនុវត្តន៍

ក– ចាប់អនុវត្តខេមរយានកម្មនៅឆ្នាំសិក្សា ១៩៦៧-៦៨ នេះ ។ ការអនុវត្តន៍ត្រូវធ្វើដោយប្រុងប្រយ័ត្នបំផុត ព្រោះការនេះពុំមែនជាការពិសោធន៍ទេ ។

ខ– ក្នុងការធ្វើខេមរយានកម្ម ក្រសួងអប់រំជាតិមានករណីយកិច្ចត្រូវនឹកជានិច្ច នូវសារៈសំខាន់ខាងវិទ្យាសាស្ត្រ និងកម្មវត្ថុនៃវិជ្ជានីមួយ ៗ ។ បង្រៀនវិទ្យាសាស្ត្រ គឺត្រូវឲ្យសិស្សានុសិស្សរបស់យើងស្គាល់តម្លៃនៃវិទ្យាសាស្ត្រ ហើយយកវិទ្យាសាស្ត្រនោះមកអនុវត្តបង្កើតជាប្រយោជន៍ ដល់ខ្លួននិងដល់មនុស្សទូទៅ ពុំមែនគ្រាន់តែឲ្យសិស្សទាំងនោះ ស្គាល់ពាក្យវិទ្យាសាស្ត្រជាភាសាខ្មែរតែប៉ុណ្ណោះទេ ។

គ– ក្នុងការធ្វើខេមរយានកម្មនេះ យើងនឹងរក្សាទុកនូវពាក្យវិទ្យាសាស្ត្រអន្តរជាតិ យើងគ្រាន់តែសរសេរពាក្យទាំងនោះជាអក្សរខ្មែរ និងសរសេរជាឡាតាំងផង ។

ឃ– ស្របជាមួយនឹងខេមរយានកម្មនេះ យើងនឹងយកចិត្តទុកដាក់ធ្វើឲ្យសិស្សមានវិជ្ជាជ្រៅជ្រះ ខាងបរភាសាណាមួយជាដាច់ខាត ។

២– វិធានការសម្រាប់ពេលខ្លី.– ក្រោយពីបានពិនិត្យស្ថានភាព ក្នុងការសិក្សាកន្លងមក យើងបានកំណត់នូវវិធានការដូចតទៅ :

ក– យើងនឹងចាប់អនុវត្តន៍ខេមរយានកម្មពីថ្នាក់ទី ៦ ទៅ នៅឆ្នាំសិក្សា ១៩៦៧-៦៨ ។ ក្រសួងអប់រំជាតិជឿថាគ្មានឧបសគ្គគួរឲ្យបារម្ភទេ ព្រោះចំនួនសាស្ត្រាចារ្យជាតិខ្មែរ ក៏មានល្មមដល់សេចក្ដីត្រូវការរបស់យើងដែរ ។ សាស្ត្រាចារ្យទាំងនោះ ក៏ធ្លាប់បង្រៀនមេរៀនជាខ្មែរខ្លះមកហើយ ហើយមានការពិសោធន៍គ្រប់គ្រាន់ដែរ ។

ខ– ដើម្បីឲ្យមានឯកភាពក្នុងការប្រើពាក្យដែលត្រូវបកប្រែមកពីបារាំង ពាក្យគន្លឹះទាំងឡាយ ដែលទាក់ទងទៅនឹងមេរៀនវិទ្យាសាស្ត្រនៅថ្នាក់ទី ៦ ត្រូវរៀបចំឲ្យហើយស្រេចនៅមុនខែសីហានេះ ។

គ– នៅពេលដែលសម្ដេចព្រះសង្ឃរាជ ព្រះអង្គយល់ព្រមលើពាក្យគន្លឹះនេះហើយ ក្រសួងអប់រំជាតិនឹងផ្សាយពាក្យទាំងនោះតាមវិទ្យុ តាមទូរទស្សន៍ តាមសារពត៌មាន និងតាមព្រឹត្តិប័ត្ររបស់គណៈកម្មាធិការជាតិអចិន្ត្រៃយនៃខេមរយានកម្ម ។

ឃ– មុនបវេសនកាលឆ្នាំសិក្សា ១៩៦៧-៦៨ ក្រសួងអប់រំជាតិនឹងអញ្ជើញសាស្ត្រាចារ្យជំនាញ ៗ មកបង្រៀនបង្ហាញជាគំរូ ផ្សាយតាមវិទ្យុ តាមទូរទស្សន៍ ។ មេរៀនរបស់លោកសាស្ត្រាចារ្យទាំងនោះ នឹងត្រូវចុះផ្សាយក្នុងសារពត៌មានជាតិ និងក្នុងព្រឹត្តិប័ត្ររបស់គណៈកម្មាធិការជាតិអចិន្ត្រៃយនៃខេមរយានកម្ម ។

ង– ដោយយល់ឃើញថា មតិសាធារណៈចូលចិត្តចង់ដឹង ចង់ឮ អំពីបញ្ហាខេមរយានកម្មនេះ ទើបក្រសួងអប់រំជាតិធ្វើមហាសន្និបាតនេះ ។

ច– ការតែងសៀវភៅសិក្សាជាភាសាខ្មែរសម្រាប់ថ្នាក់ទី ៦ និងចាប់ធ្វើការរៀងទៅកល់ត្រីមាស សម្រាប់ឆ្នាំសិក្សា ១៩៦៧-៦៨ នេះ ។

ឆ– ក្រសួងអប់រំជាតិនឹងតាំងគណៈកម្មការមួយ សម្រាប់ពិនិត្យវិធីសាស្ត្រ (Méthodologie) ដែលត្រូវយកទៅប្រើ ដើម្បីធ្វើឲ្យសិស្សខ្មែរចេះដឹងភាសាណាមួយឲ្យបានច្បាស់លាស់ជាអតិបរមា ។

ជ– អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិអចិន្ត្រៃយ៍នៃខេមរយានកម្ម មានភារៈទទួលពិនិត្យនូវសេចក្ដីស្នើទាំងឡាយដែលមជ្ឈដ្ឋាននានាផ្ញើមក ។

NOTES FOR READING PASSAGE 2

Line 5. You have already been introduced to the word នូវ , which precedes an object, usually of a verb. It occurs primarily in literary usage. In this sentence នូវ is used when something comes between the main verb and the object.

Here the adverbial phrase ជានិច្ច 'always' comes between the verb នឹក 'to think of' and សារសំខាន់ 'importance.' Normal order would be នឹក(នូវ) សារសំខាន់ [illegible] ជានិច្ច . Where such inversions take place, creating what would otherwise be an unacceptable sentence, នូវ is obligatory.

Line 15. The phrase ហើយស្រេច is not redundant, although both words mean 'ready, already.' ហើយ is a resultative verb meaning 'completed' and ស្រេច is 'already.' The phrase ហើយៗ could have been used also.

Line 30. ជា is one of the words that can be used before an adjective to make an adverbial phrase (cf. A.5 in the Grammatical Sketch). In this

sentence the adverbial phrase is ជាអតិបរមា 'to the maximum extent possible' from អតិបរមា 'maximum.' Other common examples are ជាច្រើន 'many, in large quantity' and ជាយូរមកហើយ 'for a long time already.' Remember that ជា never means 'to be' when it is used before an adjective, so if you see a phrase ជា + adjective in something you are reading, you know that it must be an adverbial phrase and not the predicate of the clause it occurs in. This kind of clue will help you figure out the long sentences that are quite common in literary Cambodian.

UNE ECOLE PRIVEE CHINOISE A PHNOM PEN

VOCABULARY

កម្មវត្ថុ		objective, subject
ករណីយកិច្ច		duty, function, role
ករណីយ		duty
កាន់ការ		to be in charge
កំណែ (< កែ)		correction
ក្រសួងអប់រំជាតិ		Ministry of Education
ក្រាស់ក្រែល		many, a lot
ក្រិច		Greek
ឥណ្ឌ		Indian, India
គណកម្មការ		committee
គណ	/kənaʔ/	group, faction (formal)
គណកម្មាធិការ		committee(with administrative responsibility)
គន្លឹះ		hinge, bolt; pivotal or key component, key to a matter
គរុកោសល្យ	/kəruʔkaosəl/	profession of pedagogy
* កោសល្យ	/kaosəl/	skill, profession
គំរូ		model, example
គ្នា		he, she, they (indicates compassion)
ងឿងឆ្ងល់		to wonder, concentrating hard on the subject
* ងឿង		the mind goes blank
ចាកប្រធាន		to miss the point
ចាក		to depart, to leave
ចុះផ្សាយ		to publish
ចំណេញ (< ចេញ)		profit, gain, to profit
ចំអក		sarcastic
ច្បាស់លាស់ (លាស់ RC[1])		very clear
[illegible]		to be in a panic
ជាក់		clear
* ជីវភាសា	/ciivéʔphiasaa/	modern (living) language

ជ្រៅ		deep
ដទៃ		other
ដូចតទៅ		as follows
តម្លៃ (< ថ្លៃ)		price, value
តែង		to arrange, compose, decorate
តែង(តែ)		often
តាំង		to set up, establish
ត្រឡប់ជា		instead, to become... instead
* ត្រីមាស		three months, trimester
ទាញអារម្មណ៍	/tieñ aarom/	to attract attention, to be of interest
ទាញ		to pull
អារម្មណ៍		impression, thought
ទីចាត់ការ		headquarters
ចាត់ការ		to take charge, to run (an organization or operation)
ទូរទស្សន៍	/tuorətuoh/	television
ទូលាយ		wide, spacious
ទោះបី		even (if), although
ទំព័រ	/tumpóa/	page
ទាំងនេះ		all these
ទាំងនោះ		all those
* ធំធេង (ធេង AC)		big, large
នរណា		who, anyone
នានា		various
នាយក		chief, head
និយាយឡើង		to speak up
នៃ		of (formal)
នាំគ្នា		to do as a group
បញ្ញវន្ត	/paññəvón/	intelligentsia, intellectual
* បញ្ញា	/paññéʔ/ (H)	intelligence
បាន = បានជា		is why
បានការ		to be of use, to get result, to have effect, to be productive

---

1. RC indicates a rhyming component of a compound with no independent meaning.

បារម្ភ /baarom/	to worry
បាលី	Pali
បុគ្គលិក	employee, personnel (formal)
បំបាត់ (< បាត់)	to cause to be lost, to eliminate
បំផុត	most of all, especially, particularly
ប្រធាន	subject (of a conversation or a sentence)
ប្រុងប្រយ័ត្ន	careful
ផ្ទៃ	surface, area
ផ្សាយ	to spread, disseminate, broadcast
ពិចារណា	to ponder
ពេញទី	completely, in every respect, legal
ពោល	to say (formal)
ពុំ	not (literary)
ព្រឹត្តិបត្រ /prɨttəbat/	bulletin
*ព្រះធរណី	earth (literary)
ព្រះអង្គ	he, she (used for royalty, high-ranking clergy, and divinities)
ភ័ព្វសំណាង	luck (in the future)
ភ័ព្វ	good luck
សំណាង	fate
ភារៈ /phiaréʔ/	duty
*មជ្ឈដ្ឋាន /məcchéʔthaan/	medium (of communication)
ម៉ត់ចត់ (= ហ្មត់ចត់)	careful, close, with attention paid, meticulous
មតិ /méʔtéʔ/	opinion, idea (formal)
មហាសន្និបាត	general assembly
សន្និបាត	debate
មិនខ្ចី + verb	wouldn't + verb under any circumstances
មិនត្រឹមត្រូវ	incorrect
មើល(ទៅ)	it seems that, like
ម៉េចក៏...	how come?
មែនទែនទៅ	in fact, actually
យល់ព្រម (ឬ ស្រប)	to agree
ស្រប	parallel
រក្សា /réʔsaa/	to take care of
រៀងរាល់	each and every

រៀង	consecutively, in order
។ល។ /laʔ/	etc.
លុប	to erase, wipe off, eliminate
វិធានការ	measures, steps, action taken to solve a problem
វិធាន	a plan, program, act
វិធីសាស្ត្រ	methodology
វិស័យ	field of, scope, range
វិទ្យាសាស្ត្រ	science
វិទ្យា = វិជ្ជា	knowledge
សមាជិក	member
សម្ដេចព្រះសង្ឃរាជ	a patriach of one of the two Cambodian Buddhist orders to
សម្លឹង	to stare at, to look at
សាធារណៈ /saathiarənaʔ/	public
សារសំខាន់ /saaraʔsamkhan/	essence, core
សារព័ត៌មាន /saapóatəmian/	newspaper, the press
សេចក្ដី	matter, affair; nominalizes adjectives
សោត	furthermore, as for; thus
ស្ថានភាព	situation, state of affairs
ស្ថាបនា	to build (formal)
ស្ទាក់ស្ទើរ (ស្ទាក AC)	to be uncertain, to not know what to think
ស្ទើរក្លឹង	not enough
ស្ទើរ	insufficient
*ស្នើ	to advise, to suggest
ស្លន់ស្លោ	to panic
*ស្លន់	to panic
*ស្លោ	to be pale with fear or illness
ស្រុត	to sink, to cave in
ហាក់ដូចជា	it seems

ហុច	to hand over, to pass to
ហេតុផល	reason for a result, result
ហ្មត់ចត់	careful, with attention paid, precise, meticulous
ឡាតាំង	Latin
អគ្គលេខាធិការដ្ឋាន	secretariat general
អគ្គលេខាធិការ	secretary general
អគ្គ /aʔkéʔ/ (H)	high, exalted
អង្គការសហប្រជាជាតិ	United Nations Organization
អង្គការ	organization
សហ /səhaʔ/ (H)	united
ប្រជាជាតិ	the people
អង្គប្រជុំ /ɔŋ pacum/	the assembled participants in a conference
អចិន្ត្រៃយ៍/aʔcəntrey/	permanent

អតិបរមា /aʔteʔpaʔrəmaa/	maximum (literary)
អត្ថប្រយោជន៍ /atthaʔpəyoac/	primary interest, benefit
អធិការ /aʔthiʔkaa/	chief, director, head (formal)
អធិប្បាយ	to explain, to discuss (as in an article)
អស់លោក	all you gentlemen, all the gentlemen
អស្ចារ្យ	great, magnificent
ឥតមិន...	of course
...អីទាំងអស់	... at all
...អីសោះ	... at all
ឯកភាព	unity
ឯក	one (Sanskrit number)
អ្នកជាតិនិយម	nationalist, name of official government magazine before 1971
ជាតិនិយម	nationalistic

APPLICATIONS

1. Define or describe the following words.

បញ្ហា បង្ខម កត្តា ពិចារណា ដំណាក់ការ សិក្សា
ស្ថាបនា នរណា អធិប្បាយ

2. Give a word or phrase with meaning contradictory to the following.

ជំនឿ ស្ថាបនា បំបាក់
ហ្មត់ចត់ មិនទាន់+ verb ស្រុក

3. Fill in the blanks with the proper words provided.

១ ការស្ថាបនាអ្វីៗ... ទាល់តែមានយោបល់ស្របគ្នាខ្លះពុំខាន ។ (គ្រាន់, ផង, ក៏ដោយ)
២ ចំណែកអស់លោកជាសមាជិកនៃអង្គប្រជុំ... បានឆ្លើយបញ្ជាក់ដែរ ។ (ដែរ, ផង, ក៏)
៣ ចំណែកសិស្សដែលទៅបន្តវិជ្ជានៅមធ្យមសិក្សា ... ក៏បានចំណេញ ... ។
(នៅ, ក៏, លោក, ដែរ)
៤ សិស្សត្រូវតែចេះភាសាខ្លួន ... ជ្រៅជ្រះ ... ស្ទាក់ស្ទើរ ។ (ក៏, កុំ, ពុំ, កុំឲ្យ, ឲ្យ)
៥ ប៉ុន្តែអត្ថប្រយោជន៍ដ៏ធំនេះពុំបានទាញអារម្មណ៍មនុស្ស... យល់ច្បាស់ឡើយ ។
(ក៏, ដ៏, ឲ្យ, ហាន)
៦ គេបានគោលចំអក... ទេបរយានក្នុង ។ (នៅ, និង, ឲ្យ, សម្រាប់)

៧ គេយល់ព្រមឲ្យលុបបំបាត់បឹង... ទៀងទាត់ ។ (កុំ, ឡើយ, ដែល, បាន)
៨ ដូចយើងបានអធិប្បាយខ្លះ... ។ (ផង, ហើយ, ស្រាប់)
៩ គ្រាន់បើជាងអ្នកប្រឆាំងដែលចេះស្ដីប ចេះប្លាសប... អ្នកដែលមិនដែលបានគិត ។
(ទៀត, ដែរ, ក៏)
១០ បញ្ហានេះបាន... រៀងរាល់ថ្ងៃ ។ (នឹង, ត្រូវ, ជា)

4. Give the appropriate second-person pronoun:
   a. a young girl
   b. a committee of cabinet ministers
   c. your older brother
   d. a friend named Kim whom you know well
   e. an audience at a university lecture

5. Using the analogy of កែ 'to correct' and កំណែ 'correction,' give the indicated derivatives from the bases supplied below:

a. សួរ	'to ask'	.... 'question'
b. កើត	'to be born'	.... 'to be born'
c. ត	'to continue'	.... 'continuation'
d. ទាប	'low'	.... 'a low place'
e. ទិញ	'to buy'	.... 'merchandise'

6. Translate the following into Cambodian, using structures or words introduced in this lesson:
   a. The employees of that ministry wouldn't be caught dead working after 5.
   b. The life of those villagers is very hard. They don't know whether to sell their rice now or keep it until later.
   c. Are the students in your country accustomed to getting involved in politics?
   d. Even granted that that he has studied science for years, the book he just published is really outstanding.
   e. The bookstore has sent the books to my teacher already. (Use នូវ)
   f. When there is a meeting of the general assembly, the restaurant has to make food in great quantity.

7. Correct the following sentences by adding the proper word(s):
   ១ យើងយល់ព្រមគេលុបបារាំងចោល ។
   ២ ភាសាបារាំងបឋមសិក្សាត្រូវលុបចោល ។
   ៣ សេចក្ដីបញ្ជាក់នោះចង់សិស្សភាគច្រើនចេះភាសា ។
   ៤ ចំណែកសិស្សដែលបានសិក្សានោះក៏បានចំណេញពេល ។

៥ [illegible]
៦ [illegible]
៧ [illegible]
៨ [illegible]
៩ [illegible]
១០ [illegible]

B. Questions for the teachers to ask:

១ នៅក្នុងវិទ្យាល័យនីមួយៗ សិស្សត្រូវរៀនភាសាប៉ុន្មាន?
២ សិស្សត្រូវរៀនភាសានីមួយ ប៉ុន្មាន?
៣ ក្នុងមហាវិទ្យាល័យ គេត្រូវបង្រៀនភាសាអ្វីខ្លះ? គេរៀនភាសាសម្រាប់ធ្វើអី?
៤ សិស្សមាន[illegible]រៀនភាសាដែលគេចូលចិត្ត ឬមានបង្គាប់សាលាបង្គាប់ឱ្យរៀន?
៥ នៅស្រុកខ្មែរ មាន[illegible]ដែលមនុស្ស[illegible] ហើយគេសួរថា តើមានចេះ [illegible] បើចេះគេអោយការធ្វើទេ?
៦ [illegible] ក្រៅពីមានសិស្ស[illegible] [illegible] គេរៀនអ្វីខ្លះ?
៧ [illegible] សិស្ស[illegible]រៀនភាសា[illegible] [illegible]? គេចូលចិត្ត [illegible]?
៨ នៅស្រុកខ្មែរ គេប្រើ[illegible]ភាសាទេ?

C. Questions for the student to ask:

1. What do the critics of Khmerization mean when they say it is really Sanskrit and Pali?
2. In Reading Passage 1 (column 4 line 3) it is stated that the result of Khmerization in the elementary school was to strengthen the study of French in secondary school. How was this the case? Is it still the case?
3. How far has the school system been Khmerized so far? With what results?
4. What is the extent of university instruction in Khmer? What is your instructor's opinion on this matter?
5. To what extent is French used in commerce? In the government? Is this situation changing?
6. What degrees are available from Cambodian universities? What are the main fields that students study?
7. Are there certain courses of study for which overseas study is required? Where do most students go?
8. How do Cambodian students going to English-speaking countries deal with their lack of background in English?
9. To get a Cambodian university degree, does one have to take an examination? If so, what kind? Does one write a thesis?
10. What kinds of job require a university education?

LESSON THREE

COMMUNICATIONS ROUTES

a. Are tolls exacted at bridges and on certain roads?

b. Is mail censored in Cambodia?

c. What would be the quickest way to reach someone in a rural area?

d. What medium has the most influence on public opinion? Why?

ផ្លូវគមនាគមន៍

ក. ផ្លូវដែក

ប្រទេសខ្មែរមានផ្លូវដែកតិចណាស់ ។

* ផ្លូវដែកទី ១ ពីភ្នំពេញទៅអូរជ្រៅ មានប្រវែង ៣៨៥ គ.ម. ហើយបន្តភ្ជាប់ផ្លូវដែកប្រទេសថៃរហូតដល់ក្រុងបាងកក ។ ផ្លូវនេះប្រើសំរាប់ដឹកជញ្ជូនផលិតផលកសិកម្មនិងព្រៃឈើ ពីតំបន់ខាងលិចប្រទេសមកកាន់រដ្ឋធានី ។ ឯទំនិញនាំចេញពីភ្នំពេញទៅមានតិចណាស់ ។ ទំងន់ទំនិញនាំពីអូរជ្រៅមកភ្នំពេញ ច្រើនជាងទំងន់នាំពីភ្នំពេញទៅអូរជ្រៅ ៧ ដង ។ ហេតុដូច្នេះហើយបានជាអាជីវកម្មផ្លូវដែកទី ១ នេះមានការពិបាកយ៉ាងខ្លាំង ព្រោះការដឹកនាំឡេចលតែម្ខាង (ពីអូរជ្រៅមកភ្នំពេញ) ។ សកម្មភាពពាណិជ្ជកម្មឡើងពី ៦២ លានតោន-គីឡូម៉ែត្រ នៅឆ្នាំ ១៩៦៣ ទៅ ៨១ លានតោនគីឡូម៉ែត្រនៅឆ្នាំ ១៩៦៨ ។

* ផ្លូវដែកទី ២ ពីភ្នំពេញទៅកំពង់សោម មានប្រវែង ២៦៦ គ.ម. ទើបតែទាក់ទងគ្នាបានដល់ទីដៅក្នុងខែធ្នូ ១៩៦៩ នេះ ។

ខ. ចលនាដឹកនាំតាមអាកាស

សព្វថ្ងៃនេះ ចលនាដឹកនាំតាមអាកាសរីកចំរើនច្រើន ដោយយើងមានអាកាសយានដ្ឋានអន្តរជាតិពីរ : **ពោធិចិនតុង** ដែលនៅ ១០ គ.ម. ពីភ្នំពេញ និង **សៀមរាប** ។

អាកាសយានដ្ឋានពោធិចិនតុងមានផ្លូវយន្តហោះមួយប្រវែង ២ ៤០០ ម. ទទឹង ៤០ ម. អាចទទួលទំងន់កង់ម្នាងៗ ៣០ តោន ។ ផ្លូវយន្តហោះនេះបើកឲ្យយន្តហោះធំៗចុះតាំងពីថ្ងៃទី ២៥ កញ្ញា ១៩៥៨ ម្ល៉េះ ។ ក្រុមហ៊ុនអាកាសចរណ៍ជាច្រើនបានមកធ្វើអាជីវកម្មលើអាកាសយានដ្ឋានយើងទាំងពីរ ដើម្បីភ្ជាប់គមនាគមន៍ពីភ្នំពេញ ឬពីសៀមរាបទៅទីក្រុងអាស៊ីនិងអឺរ៉ុប ។

គ. ចលនាដឹកនាំតាមទន្លេនិងតាមសមុទ្រ

ចលនាដឹកនាំមាននៅភ្នំពេញនិងកំពង់សោម ។ កំពង់ផែផ្សេងៗរៀបចំតែបន្តិចបន្តួចសំរាប់ដឹកនាំទំនិញចេញចូលក្នុងតំបន់របស់ខ្លួន ជាពិសេស នាំផលិតផលកសិកម្មមកកាន់កំពង់ផែធំៗ ។

★ កំពង់ផែភ្នំពេញនិងចលនាដឹកនាំ.— កំពង់ផែភ្នំពេញជាកំពង់ផែទន្លេផង និងជាកំពង់ផែសមុទ្រផង ។

— ភ្នំពេញឋិតនៅចំកណ្ដាលប្រទេស ហើយត្រង់កន្លែងដែលមានទន្លេធំៗហូរមកជួបគ្នា ដែលជាលក្ខណៈមួយអាចឲ្យកំពង់ផែនេះទាក់ទងជាមួយនឹងខេត្តនៅទិសឦសាននៃប្រទេស ជាមួយនឹងទន្លេសាបនិងជាមួយនឹងយៀកណាមខាងត្បូង ។ ដូច្នេះយើងមិនគួរឆ្ងល់ទេថា ហេតុអ្វីបានជាកំពង់ផែនេះនៅតែរីកចំរើនតាំងពីដើមមក ទុកជាមានផ្លូវថ្នល់ល្អខ្វាត់ខ្វែងពាសពេញប្រទេសឬផ្លូវដែកច្រើនក៏ដោយ ។ ចាប់តាំងពីខែមីនា ១៩៤៨ មក ពេលដែលមានកប៉ាល់សមុទ្រចូលដល់កំពង់ផែភ្នំពេញ កំពង់ផែនេះក៏ឡើងថ្នាក់ជាកំពង់ផែសមុទ្រ ។

ចលនាដឹកនាំចុះយ៉ាងខ្លាំងជាលំដាប់ ចាប់តាំងពីឆ្នាំ ១៩៦៥ មក ហើយនៅឆ្នាំ ១៩៦៨ នេះទៀត ចលនាដឹកនាំនេះក៏ថយច្រើនជាងឆ្នាំ ១៩៦៧ ដោយមានផលវិបាកកើតមកពីព្រឹត្តិការណ៍នៅយៀកណាមខាងត្បូង ។

ឃ. បណ្ដាញផ្លូវថ្នល់

ផ្លូវថ្នល់សព្វថ្ងៃពុំសូវស្អាតទេ ។ ពេលរដូវទឹកជំនន់ម្ដងៗ ផ្លូវស្រុកសឹងតែគ្រប់កន្លែង ជាហេតុតំរូវយើងឲ្យជួសជុលជារៀងរាល់ឆ្នាំ ។ ផ្លូវស្រុក ផ្លូវខ្នងអណ្ដើក ផ្លូវចង្អៀតឬស្ពានតូចទ្រុឌទ្រោម សុទ្ធជារបស់ដែលយើងត្រូវថែទាំឲ្យបានល្អ ដើម្បីគួរឲ្យស្របតាមការដឹកនាំបច្ចុប្បន្ន ។ ផ្លូវភ្នំពេញ-កំពង់សោម កាត់តាមកំពង់ស្ពឺនិងផ្លូវភ្នំពេញ-កំពត កាត់តាមអង្គតាសោម មានសភាពស្អាតជាងផ្លូវឯទៀតច្រើន ។

★ ផ្លូវថ្នល់សំខាន់ៗ.— បណ្ដាញផ្លូវថ្នល់នៅទំនាបកណ្ដាល មានការលូតលាស់ជាងគេ ។ ផ្លូវទាំងនេះចែកជា : ផ្លូវជាតិប្រវែង ២ ៨០០ គ.ម. ផ្លូវខេត្តប្រវែង ១ ២០០ គ.ម. និងផ្លូវរុក្ខាបាល **(route forestière)** ប្រវែង ២ ០០០ គ.ម. ។ ក្នុងចំណោមផ្លូវទាំងនេះ មានផ្លូវជិត ២ ០០០ គ.ម. ដែលក្រាលកៅស៊ូ ផ្លូវប្រហែល ២ ០០០ គ.ម. គ្រាន់តែចាក់ថ្មឬដីក្រហម ឯផ្លូវសល់ពីនេះច្រើនជាផ្លូវលំនិងផ្លូវដីលើក ។

— ផ្លូវជាតិ (ផ.ជ.).— គឺជាផ្លូវដែលធ្វើនិងថែរក្សាដោយថវិកាជាតិ ហើយជាផ្លូវចេញពីរាជធានីទៅរកខេត្ត ។

Place Names

ស្រែជ្រៅ	S Chreev (town)	ទន្លេសាប	Tonle Sap (river and lake)
ប៉ាងកក	Bangkok		
កំពង់សោម	Kompong Som (port)	កំពង់ស្ពឺ	Kompong Speu (province)
ពោធិចិនតុង	Pochentong (airport)	កំពត	Kampot (province)
សៀមរាប	Siem Reap (province)	អង្គតាសោម	Ang Tasaom (town)

NOTES FOR READING PASSAGE 1

Line 1. Note that the headings in this article are in a script slightly different from what you are used to. There are two very similar types of script which are used for headlines, sometimes for peoples' names, and sometimes in much the same way as English uses italics. Casual usage calls

Both these styles **អក្សរមូល** 'round script', though technically អក្សរមូល is the type of script used in the headings of this particular, and **អក្សរខម** 'Cambodian script' is the type used in the title of reading lessons in the preceding lesson (Lesson 2). អក្សរខម is actually considerably more frequently used than អក្សរមូល, though both are very similar.

The more popular type of script you have been used to reading is called អក្សរជ្រៀង 'slanted script' and is the usual type of script in most publications. If អក្សរជ្រៀង is written straight up and down it is called អក្សរឈរ 'standing script', but the shapes of the letters are the same, whether slanted or upright. ជ្រៀង script is of more recent origin than មូល or ខម.

You should have little trouble learning to read អក្សរមូល and អក្សរខម. Most of the shapes of the letters are the same as those of អក្សរជ្រៀង or អក្សរឈរ; but ង, ទ, and ន have entirely different shapes, and មូល ក, គ, ង, ជ, ខម, វ, and ឡ are partially different. The vowels and subscript consonants are basically the same in the ជ្រៀង, មូល and ខម scripts.

Below is a table comparing អក្សរជ្រៀង, អក្សរខម, and អក្សរមូល consonants.

អក្សរជ្រៀង	ក	ខ	គ	ឃ	ង	ច	ឆ	ជ	ឈ	ញ	ដ	ឋ	ឌ	ឍ	ណ
អក្សរខម	ក	ខ	គ	ឃ	ង	ច	ឆ	ជ	ឈ	ញ	ដ	ឋ	ឌ	ឍ	ណ
អក្សរមូល	ក		គ		ង			ជ							
អក្សរជ្រៀង	ត	ថ	ទ	ធ	ន	ប	ផ	ព	ភ	ម	យ	រ	ល	វ	
អក្សរខម	ត	ថ	ទ	ធ	ន	ប	ផ	ព	ភ	ម	យ	រ	ល	វ	
អក្សរមូល														វ	
អក្សរជ្រៀង	ស	ហ	ឡ	អ											
អក្សរខម	ស	ហ	ឡ	អ											
អក្សរមូល															

1. can also be written ង

2. missing consonants in the អក្សរមូល are the same in the អក្សរខម.

Note that មូល **គ** is written like ជ្រៀង ក but corresponds to ក, while មូល **ត** and ឈរ **ទ** are different from their ជ្រៀង counterpart ក. Here are a few words to practice with.

ធ្វើអ្វីខ្លះដែលថាមិនពិបាក?　　គេគង់តែជួយកកាយបើកឱ្យគេ

ស្រឡាញ់កូនទារកម៉ែហើយ　　បើចង់ស្រួល ម៉េចមិនការប្រពន្ធទៅ?

In ordinary speech the names of the directions of the compass are, as you have already learned, ជើង 'north', លិច 'west' ខាងកើតឆៀងខាងត្បូង 'southeast', etc. These names are also used in writing, but as often as not the following names from Sanskrit are used in writing instead of the ordinary names, especially for the compound directions, which are quite cumbersome to write.

The word for 'southeast' you have already studied in the word for Southeast Asia អាស៊ីអាគ្នេយ៍. You should now begin to learn the other names passively: that is, you should recognize them when you read them, but you need not produce them in speech or writing.



Note that in English there are eight directions: the ones shown in the diagram above. However, in Cambodian លើ 'up, above' and ក្រោម 'down, below' are also considered members of the set of directions, so Cambodian has ten.

DIALOGUE

យ៉ាងម៉េចនៅស្រុកយើង?

		ទូរទស្សន៍	television (formal)
១	ចុល	អង្កាល់ស្រុកយើងទើបនឹងមានទូរទស្សន៍ ប្រហែលគេមិនសូវទៅមើលកុនមើលល្ខោនទេ មើលទៅ។	When our country had just gotten T.V., I've guess no one went much to see movies and plays.
		មានដល់	even to the point of ...
		ង	(see note)
២	សិន	ខ្លះមើលមានដល់ទៅភ្លេចង បាយភ្លេចទឹកទៅទៀតង។	Some even watched to the point of forgetting to eat or drink.
		ការផ្សាយពាណិជ្ជកម្ម	commercial, advertisement
		ពាណិជ្ជកម្ម	commerce
		មិនជាជាង	no more than
៣	ចុល	ការផ្សាយពាណិជ្ជកម្មនៅស្រុកយើង ប្រហែលមិនជាជាងនៅស្រុកនេះទេ មើលទៅ។	Commercials seems to be handled pretty much the same in our country and this one.
		តិចៗ + verb	frequently
៤.	សិន	គេផ្សាយតែម្តងទេ មិនមែនតិចៗផ្សាយ តិចៗផ្សាយនោះទេ។	They show their commercials all at once, not frequently.
		ស៊ូ + verb	would rather + verb ... instead
		ទូរស័ព្ទ	telephone (formal)
៥	ចុល	បងខ្ញុំនិយាយថាគាត់ស៊ូដាក់ទូរស័ព្ទ គាត់មិនទៅទិញទូរទស្សន៍ទេ។	My brother said he'd rather put in a telephone instead; he's not going to buy a T.V.
		ប៉ា	father (urban)
		ទៀបនឹង	about to
៦	សិន	ប៉ាខ្ញុំទៀបនឹងដាក់ដែរ តែគាត់មានប្រសាសន៍ថាផ្ញើ	My father was about to put one in too, but he said it's cheaper to send a

	សំបុត្រ ទៅទាក់ទង ។	letter.
	ដែលងពិនឹង	to be bound to
	ម្ដងម្កាល	once in a while
៧ ចុល	យើងសរសេរ សរសេរហើយ តែដែលងពិនឹងមានការណ៍ ប្រញាប់ម្ដងម្កាល ។	Of course we write, but sometimes there are bound to be emergencies.
៨ សីន	ត្រូវហើយ តែស្រុកយើងមាន ទៅយល់ទូរស័ព្ទជាការចាំបាច ឯណា ។	That's true, but in our country you can see that the telephone isn't a necessity.
	ចាំ(បាច)	necessary
៩ ចុល	ហ្នឹង តែបបយើងយល់ថា បើ ចង់ទាក់ទងគ្នា ចាំហៅគ្នា តាមទូរស័ព្ទនោះទេ ។	Maybe that's because we know that we don't need the telephone to communicate.
	ទូរលេខ	telegram
១០ សីន	ហ៊ឹងហើយ បើមានការ អីផ្ញើសំបុត្រទៅ វាយទូរ- លេខទៅ វាបានហើយ ។	Right. If you have business (with someone), write a letter or send a telegram, that'll do.

NOTES FOR THE DIALOGUE

SENTENCE NO. 2

The word ឯ in this sentence does not mean 'at' or 'as for.' It is used characteristically by rural people before a noun or a verb phrase for sentence rhythm. An example of ឯ before a verb phrase is:

គាត់ភ្លេចឯញ៉ាំបាយ ។
He forgot to eat.

SENTENCE NO. 7

Note that verb + verb ហើយ means 'of course (it is a fact that) (they) + verb.' It can be used as past or future as well, e.g.,

បើខ្ញុំថាខ្ញុំធ្វើ (ខ្ញុំ)ធ្វើហើយ ។
If I say I'll do it, I'll do it.

SENTENCE NO. 8

As you already know, ឯណា at the end of a sentence indicates incredulous disagreement with a previous statement or question, e.g.,

A. លោកទៅមើលកុនយប់ហ្នឹងទេ?

B. ទៅមើលកុនឯណា បើគ្មានលុយសោះ។

A. Are you going to the movies tonight?

B. What do you mean, go to the movies, if I haven't any money?!

In this lesson, ឯណា has a similar meaning. It can indicate that the proposition it follows is in some way improbable, unthinkable, or ridiculous, but in this case it simply means 'you see, it isn't the case that ....' As you can see in this dialogue, ឯណា does not have to be used as a direct response indicating disagreement.

DRILLS

DRILL ONE: Transformation

គំរូ

ក ពួកគេមិនសូវទៅមើលកុន និង ទៅមើលល្ខោនទេ មើលទៅ។

ខ ពួកគេមិនសូវទៅមើលកុន មើលល្ខោនទេ មើលទៅ។

MODEL:

T: They don't seem to go to movies or plays much, do they?

S: They don't seem to go to movies or plays much, do they?

ក គាត់មិនចូលចិត្តនៅស្រុកស្រែ ឬនៅស្រុកចំការទេ។
គាត់មិនចូលចិត្តនៅស្រុកស្រែស្រុកចំការទេ។

ខ ក្មេងៗគេមិនសូវធ្វើដំណើរតាមផ្លូវទឹក ឬតាមផ្លូវគោកទេ។
ក្មេងៗគេមិនសូវធ្វើដំណើរតាមផ្លូវទឹកតាមផ្លូវគោកទេ។

គ គាត់នាំគ្នាដើរមិនដឹងថ្ងៃ ឬមិនដឹងយប់ទេ។
គាត់នាំគ្នាដើរមិនដឹងថ្ងៃមិនដឹងយប់ទេ។

ឃ ទាហានធ្វើការមិនដឹងថែរក្សា ឬមិនដឹងថែស្រុកជាតិទេ។
ទាហានធ្វើការមិនដឹងថែរក្សាមិនដឹងថែស្រុកជាតិទេ។

ង កូនខ្ញុំដើរលេងមិនស្គាល់យប់ ឬមិនស្គាល់ថ្ងៃទេ។
កូនខ្ញុំដើរលេងមិនស្គាល់យប់មិនស្គាល់ថ្ងៃទេ។

ច គាត់ហៅខ្ញុំមិនស្គាល់ពេលទំនេរ ឬមិនទំនេរទេ។
គាត់ហៅខ្ញុំមិនស្គាល់ពេលទំនេរមិនទំនេរទេ។

DRILL TWO: Transformation

គំរូ

ក ខ្លះចូលចិត្តមើលទូរទស្សន៍ណាស់។
(ភ្លេចឯបាយភ្លេចឯទឹក)

ខ ខ្លះមើលរហូតដល់ទៅភ្លេចឯបាយភ្លេចឯទឹកទៅទៀត។

MODEL:

T: Some (people) like to watch T.V. a lot.
(forget to eat and drink)

S: Some (people) even watch to the point of forgetting to eat and drink.

ក គាត់ចូលចិត្តនិយាយទូរស័ព្ទណាស់។

(ភ្លេចធ្វើបាយធ្វើទឹកឱ្យប្ដី)
គាត់និយាយបានដល់ទៅភ្លេចធ្វើបាយធ្វើទឹកឱ្យប្ដីទៅទៀត។

ខ កូនស្រីខ្ញុំចូលចិត្តដើរលេងណាស់។
(មិនចង់ចូលផ្ទះ)
កូនស្រីខ្ញុំដើរលេងបានដល់ទៅមិនចង់ចូលផ្ទះទៅទៀត។

គ ខ្ញុំចូលចិត្តមើលទស្សនាវដ្ដីសាប្រកកណាស់។
(ភ្លេចដេកងញ្ញាន)
ខ្ញុំមើលបានដល់ទៅភ្លេចដេកងញ្ញានទៅទៀត។

ឃ ក្មេងៗចូលចិត្តសរសេរសំបុត្រណាស់។
(ភ្លេចរៀនភ្លេចសូត្រ)
ក្មេងៗសរសេរបានដល់ទៅភ្លេចរៀនភ្លេចសូត្រទៅទៀត។

ង ចាស់ៗចូលចិត្តមើលល្ខោនណាស់។
(សុខចិត្តមិនញ៉ាំម្ហូប)
ចាស់ៗមើលបានដល់ទៅសុខចិត្តមិនញ៉ាំម្ហូបទៅទៀត។

ច ក្មេងជំនាន់នេះចូលចិត្តសប្បាយណាស់។
(ភ្លេចរៀនសូត្រ)
ក្មេងជំនាន់នេះសប្បាយបានដល់ទៅភ្លេចរៀនសូត្រទៅទៀត។

DRILL THREE: Extension

គំរូ

ក គាត់មើលតែទូរទស្សន៍។
(ធ្វើបាយ)

ស គាត់មើលតែទូរទស្សន៍ ភ្លេចធ្វើបាយ។

MODEL:

T: All she does is watch T.V.
(cook)

S: She watches T.V. and forgets to cook.

ក គាត់គិតតែអំពីរឿងការ។
(ទៅស៊ីបាយស៊ីទឹក)
គាត់គិតតែអំពីរឿងការ ភ្លេចទៅស៊ីបាយស៊ីទឹក។

ខ ខ្ញុំបើកឡានរវល់តែនិយាយ។
(មើលផ្លូវ)
ខ្ញុំបើកឡានរវល់តែនិយាយ ភ្លេចមើលផ្លូវ។

គ កូនសិស្សរៀនតែសរសេរ។
(រៀននិយាយ)
កូនសិស្សរៀនតែសរសេរ ភ្លេចរៀននិយាយ។

ឃ គាត់រវល់តែបង្រៀន។
(ទៅជួបពួកម៉ាក)
គាត់រវល់តែបង្រៀន ភ្លេចទៅជួបពួកម៉ាក។

ង ស្ដាប់គេនិយាយ។
(ទៅធ្វើការ)
ស្ដាប់គេនិយាយ ភ្លេចទៅធ្វើការ។

ច ចំរកលុយ។
(បាយ)
ចំរកលុយ ភ្លេចបាយ។

DRILL FOUR: Response

គំរូ

ក យ៉ាងម៉េចទៅការផ្សាយពាណិជ្ជកម្មនៅស្រុកយើង?
(នៅស្រុកនេះ)

ស ការផ្សាយពាណិជ្ជកម្មនៅស្រុកយើងមិនដាច់ជាងនៅស្រុកនេះទេ។

MODEL:

T: How are advertisements handled in our country?
(In this country)

S: Advertisements in our country are not very different from those in this country.

ក យ៉ាងម៉េចទៅការធ្វើដំណើរនៅស្រុក
យើង?
(នៅទីក្រុងនេះ)
ការធ្វើដំណើរនៅស្រុកយើងមិនជា
ជាងនៅទីក្រុងនេះទេ។

ខ យ៉ាងម៉េចទៅ[illegible]?
(នៅបាត់ដំបង)
[illegible]មិនជាជាង
នៅបាត់ដំបងទេ។

គ យ៉ាងម៉េចទៅផ្លូវទៅខេត្តកំពង់ចាម?
(ផ្លូវបាត់ដំបង)
ផ្លូវទៅខេត្តកំពង់ចាមមិនជាជាង
ផ្លូវបាត់ដំបងទេ។

ឃ យ៉ាងម៉េចទៅស្ថានការណ៍នៅស្រុក
យួន?
(នៅស្រុកខ្មែរ)
ស្ថានការណ៍នៅស្រុកយួនមិនជា
ជាងនៅស្រុកខ្មែរទេ។

ង យ៉ាងម៉េចទៅទំនិញនៅស្រុកយើង?
(នៅស្រុកលោក)
ទំនិញនៅស្រុកយើងមិនជាជាង
នៅស្រុកលោកទេ។

ច យ៉ាងម៉េចទៅផលិតផលកសិកម្ម
ឆ្នាំនេះ?
(ឆ្នាំទៅ)
ផលិតផលកសិកម្មឆ្នាំនេះមិនជា
ជាងឆ្នាំទៅទេ។

DRILL FIVE: Substitution

គំរូ

ក គេផ្សាយតែម្ដងទេ មិនមែនតិចៗ
ផ្សាយ តិចៗផ្សាយនោះទេ។
(ហៅ)

ខ គេហៅតែម្ដងទេ មិនមែន
តិចៗហៅ តិចៗហៅនោះទេ។

MODEL:

T: They broadcast only once, not frequently.
(call)

S: They call only once, not frequently.

គេហៅតែម្ដងទេ មិនមែនតិចៗហៅ
តិចៗហៅនោះទេ។

ក ចូល
គេចូលតែម្ដងទេ មិនមែនតិចៗចូល
តិចៗចូលនោះទេ។

ខ ដាក់
គេដាក់តែម្ដងទេ មិនមែនតិចៗដាក់
តិចៗដាក់នោះទេ។

គ បើក
គេបើកតែម្ដងទេ មិនមែនតិចៗបើក
តិចៗបើកនោះទេ។

ឃ ប្រាប់
គេប្រាប់តែម្ដងទេ មិនមែនតិចៗប្រាប់
តិចៗប្រាប់នោះទេ។

ង ដឹកចេញ
គេដឹកចេញតែម្ដងទេ មិនមែនតិចៗ
ដឹកចេញ តិចៗដឹកចេញនោះទេ។

ច ផ្ញើ
គេផ្ញើតែម្ដងទេ មិនមែនតិចៗផ្ញើ
តិចៗផ្ញើនោះទេ។

ឆ ធើ
គេធើតែម្ដងទេ មិនមែនតិចៗធើ តិចៗ
ធើនោះទេ។

DRILL SIX: Response

គំរូ

ក គេផ្សាយប៉ុន្មានដង?

ខ គេផ្សាយតែម្ដងទេ មិនមែនតិចៗ
ផ្សាយ តិចៗផ្សាយនោះទេ។

MODEL:

T: How many times do they broadcast?

S: They only broadcast once, not frequently.

ក ទេះភ្លើងឈប់ច្រើនដងទេ?
ទេះភ្លើងឈប់តែម្ដងទេ មិនដែល
តិចៗឈប់ តិចៗឈប់នោះទេ។

ខ ផឹកស៊ីបទេ?
ផឹកស៊ីបតែម្ដងទេ មិនដែលតិចៗ
ស៊ីប តិចៗស៊ីបនោះទេ។

គ ថ្លៃសំបុត្រកប៉ាល់ហោះឡើងទេ?
ថ្លៃសំបុត្រកប៉ាល់ហោះឡើងតែម្ដង
ទេ មិនដែលតិចៗឡើង តិចៗ
ឡើងនោះទេ។

ឃ ស្ត្រីនេះ [illegible] ដួលសន្លប់ប៉ុន្មានដងហើយ?
ស្ត្រីនេះ [illegible] ដួលសន្លប់តែម្ដងទេ មិន
ដែលតិចៗដួលសន្លប់ តិចៗដួលសន្លប់
នោះទេ។

ង គាត់និយាយច្រើនទេ?
គាត់និយាយតែម្ដងទេ មិនដែល
តិចៗនិយាយ តិចៗនិយាយ
នោះទេ។

ច ម្ដាយខ្ញុំទៅមើលប៉ុន្មានដង?
ម្ដាយខ្ញុំទៅមើលតែម្ដងទេ មិន
ដែលតិចៗទៅមើល តិចៗទៅ
មើលនោះទេ។

DRILL SEVEN: Transformation

គំរូ

ក គាត់ទិញទូរទស្សន៍។
(ដាក់ទូរស័ព្ទ)

ខ ខ្ញុំសូវដាក់ទូរស័ព្ទ ខ្ញុំមិនទៅទិញ
ទូរទស្សន៍ទេ។

MODEL:

T: He bought a T.V.
(Install a telephone)

S: I'd rather install a telephone
than buy a T.V.

ក គេជិះឡាន។
(ដើរ)
ខ្ញុំសូវដើរ ខ្ញុំមិនទៅជិះឡានទេ។

ខ គាត់វាយតេឡេក្រាម។
(ផ្ញើសំបុត្រ)
ខ្ញុំសូវផ្ញើសំបុត្រ ខ្ញុំមិនទៅវាយតេឡេក្រាមទេ។

គ គាត់មើលកុន។
(មើលទូរទស្សន៍)
ខ្ញុំសូវមើលទូរទស្សន៍ ខ្ញុំមិនទៅមើល
កុនទេ។

ឃ គេបើកឡានទៅ។
(ជិះកប៉ាល់ហោះ)
ខ្ញុំសូវជិះកប៉ាល់ហោះ ខ្ញុំមិនទៅបើក
ឡានទៅទេ។

ង គាត់សរសេរសំបុត្រ។
(តេឡេហ្វូន)
ខ្ញុំសូវតេឡេហ្វូន ខ្ញុំមិនទៅសរសេរ
សំបុត្រទេ។

ច គេមើលទូរទស្សន៍។
(ស្ដាប់វិទ្យុ)
ខ្ញុំសូវស្ដាប់វិទ្យុ ខ្ញុំមិនទៅមើលទូរទស្សន៍
ទេ។

DRILL EIGHT: Substitution

គំរូ

ក សរសេរ សរសេរហើយ តែតែងអី
នឹងមានការប្រញាប់ម្ដងម្កាល។
(កាត់ - ត្រូវការ)

ខ កាត់ កាត់ហើយ តែតែងអីនឹង
ត្រូវការម្ដងម្កាល។

MODEL:

T: Of course you write, but sometimes
there are bound to be emergencies.
(cut - need)

S: Of course you cut (it), but sometimes (we) are bound to need (it).

កាត់ កាត់ហើយ តែតែងអីនឹង
ត្រូវការម្ដងម្កាល។

ក ស្ដាប់ - ខ្មោច
ស្ដាប់ ស្ដាប់ហើយ តែក៏លែង
ទទឹងខ្មោចបង្អង់បង្អាល។
ខ ឆ្ងាយ - ឈប់
ឆ្ងាយ ឆ្ងាយហើយ តែក៏លែង
ទទឹងឈប់បង្អង់បង្អាល។
គ មាន - ធូរ
មាន មានហើយ តែក៏លែង
ទទឹងធូរបង្អង់បង្អាល។
ឃ ដាក់ - ខុស
ដាក់ ដាក់ហើយ តែក៏លែង
ទទឹងខុសបង្អង់បង្អាល។
ង ដឹក - ខូច
ដឹក ដឹកហើយ តែក៏លែង
ទទឹងខូចបង្អង់បង្អាល។
ច ចង់ - ស្លាក
ចង់ ចង់ហើយ តែក៏លែង
ទទឹងស្លាកបង្អង់បង្អាល។

DRILL NINE: Substitution

គ្រូ
គ ស្រុកយើងមានទៅយកទូរស័ព្ទជាការចាំបាច់ឯណា។
(ប្រពន្ធខ្ញុំ - ពេលដើរលេង)
ស ប្រពន្ធខ្ញុំមានទៅយកពេលដើរលេងជាការចាំបាច់ឯណា។

MODEL:

T: You can see that the telephone isn't a necessity in our country?
(my wife - time for going out)

S: You can see that time for going out isn't a necessity for my wife.

ប្រពន្ធខ្ញុំមានទៅយកពេលដើរលេងជាការចាំបាច់ឯណា។

ក ខ្ញុំ - ឡាន
ខ្ញុំមានទៅយកឡានជាការចាំបាច់ឯណា។
ខ ខ្លួនយើង - ការដើរសំណើរឲ្យឆាប់
ខ្លួនយើងមានទៅយកការដើរសំណើរ
ឲ្យឆាប់ជាការចាំបាច់ឯណា។
គ ស្រុកយើង - ការមានផ្លូវល្អ
ស្រុកយើងមានទៅយកការមានផ្លូវល្អ
ជាការចាំបាច់ឯណា។
ឃ អ្នកលក់ទំនិញ - ទូរស័ព្ទ
អ្នកលក់ទំនិញមានទៅយកទូរស័ព្ទ
ជាការចាំបាច់ឯណា។
ង អ្នកប្រើឡាន - ផ្លូវក្រាលកៅស៊ូ
អ្នកប្រើឡានមានទៅយកផ្លូវក្រាល
កៅស៊ូជាការចាំបាច់ឯណា។
ច អ្នកភូមិខ្ញុំ - ផ្លូវក្រាលកៅស៊ូ
អ្នកភូមិខ្ញុំមានទៅយកផ្លូវក្រាលកៅ
ស៊ូជាការចាំបាច់ឯណា។

DRILL TEN: Transformation

គ្រូ
គ ហៅគាត់តាមទូរស័ព្ទទៅ។
ស ចាំហៅគាត់តាមទូរស័ព្ទធ្វើអី?

MODEL:

T: Call him on the telephone.

S: Why is it necessary to call him on the telephone?

ក ផ្ញើសំបុត្រទៅអញ្ជើញគាត់ទៅ។
ចាំផ្ញើសំបុត្រទៅអញ្ជើញគាត់ធ្វើអី?
ខ ទៅទិញសំបុត្ររទេះភ្លើងទុកឲ្យហើយ
ទៅ។
ចាំទៅទិញសំបុត្ររទេះភ្លើងទុកឲ្យ
ហើយធ្វើអី?
គ អញ្ជើញគាត់ស្ងាត់មាត់ទៅ។
ចាំអញ្ជើញគាត់ស្ងាត់មាត់ធ្វើអី?
ឃ ឲ្យអ្នកណាទៅហៅគាត់ទៅ។
ចាំឲ្យអ្នកណាទៅហៅគាត់ធ្វើអី?
ង ត្រឡប់ទៅប៉ុស្តិ៍ម្ដងទៀតទៅ។
ចាំត្រឡប់ទៅប៉ុស្តិ៍ម្ដងទៀតធ្វើអី?

READING PASSAGE 2

គមនាគមន៍ក្នុងស្រុក

នៅក្នុងស្រុកយើងសព្វថ្ងៃនេះ ផ្នែកខាងគមនាគមន៍កាន់តែកាន់បានគ្រាន់បើឡើងច្រើនហើយ។

នៅស្រុកស្រែចំការ យើងឃើញខុសពីមុនច្រើនណាស់។ អ្នកស្រុកភាគច្រើនបានទទួលដំណឹងផ្សេងៗតាមវិទ្យុ ហើយអ្នកខ្លះ បើគេគ្មានវិទ្យុទេ គេអាចទទួលដំណឹងនោះតាមកាសែតឬទស្សនាវដ្ដីផ្សេងៗដែរ។ ដូច្នេះយើងឃើញថាអ្នកស្រុកមានវិទ្យុស្ដាប់និងកាសែតមើលជិតទាំងអស់។ កាលប្រហែលជិត ២០ ឆ្នាំមុននេះ អ្នកស្រុកយើងនោះមិនដែលស្គាល់របស់ទាំងនោះយ៉ាងម៉េចទេ។ ឯឥឡូវនេះវិញ យើងឃើញថានៅសល់តែទូរទស្សន៍និងកប៉ាល់ហោះប៉ុណ្ណោះទេដែលគេមិនទាន់មាន។ តាមពិតទូរទស្សន៍យើងមានដែរ តែមាននៅតែភ្នំពេញនិងនៅជិតស្រុកយួនទេ។ អ្នកនៅជិតស្រុកយួនចាប់បុស្តិ៍នៅភ្នំពេញមិនបានទេ បានតែបុស្តិ៍យួនពីស្រុកយួន។ ឯកប៉ាល់ហោះវិញ មានតែនៅភ្នំពេញនិងទីរួមខេត្តទេ។

ចំពោះការធ្វើដំណើរទៅមកគ្នាវិញ ពីភ្នំពេញទៅទីរួមខេត្តខ្លះ យើងជិះកប៉ាល់ហោះ។ ដូច្នេះជនជាតិយើងបានស្គាល់យន្តហោះកាន់តែច្រើនឡើងៗហើយ។ កាលចំនួន ១០ ឆ្នាំមុន ជនជាតិយើងភាគច្រើន កុំថាតែជិះកប៉ាល់ហោះនោះ សូម្បីតែឃើញ ក៏មិនសូវបានឃើញផង។ ពេលនោះការធ្វើដំណើរនេះនៅមានការពិបាកច្រើន ព្រោះយើងនៅប្រើរទេះគោ រទេះសេះ និងរម៉កខ្លះ។ តាមពិតឥឡូវនេះក៏ដោយ យើងក៏នៅតែប្រើរទេះគោ និងរទេះសេះដែរ តែយើងប្រើនៅតែស្រុកស្រែចំការនិងទីប្រជុំជនតូចៗទេ។

នេះជាផ្នែកមួយខាងគមនាគមន៍ក្នុងស្រុកយើងឥឡូវ។

NOTE FOR READING PASSAGE 2

Line 15. In the clause ...យើងប្រើនៅតែស្រុកស្រែចំការ... the word តែ means 'only.' A somewhat more common paraphrase of this is ...យើងប្រើតែនៅស្រុក ... 'we use them only in the country.'



DRILLS FOR READING PASSAGE 2

DRILL A: Substitution (Variable)

គំរូ:

ក. ផ្នែកខាងគមនាគមន៍កាន់តែបានប្រសើរឡើងច្រើនហើយ។
(រីកចំរើន)

ខ. ផ្នែកខាងគមនាគមន៍កាន់តែបានរីកចំរើនឡើងច្រើនហើយ។

MODEL:

T: The field of communications is getting better and better.
(prosperous)

S: The field of communications is getting more and more prosperous.

ផ្នែកខាងគមនាគមន៍កាន់តែបានរីកចំរើនឡើងច្រើនហើយ។

ក. ការធ្វើដំណើរតាមយន្តហោះ
ការធ្វើដំណើរតាមយន្តហោះកាន់តែបានរីកចំរើនឡើងច្រើនហើយ។

ខ. រៀបចំបានល្អ
ការធ្វើដំណើរតាមយន្តហោះកាន់តែបានរៀបចំបានល្អឡើងច្រើនហើយ។

គ. ភូមិខ្ញុំ
ភូមិខ្ញុំកាន់តែបានរៀបចំបានល្អឡើងច្រើនហើយ។

ឃ. ជួសជុល
ភូមិខ្ញុំកាន់តែបានជួសជុលឡើងច្រើនហើយ។

ង. សង់ផ្ទះ
ភូមិខ្ញុំកាន់តែបានសង់ផ្ទះឡើងច្រើនហើយ។

ច. រដ្ឋការយើង
រដ្ឋការយើងកាន់តែបានសង់ផ្ទះឡើងច្រើនហើយ។

DRILL B: Substitution

គំរូ

ក. កុំថាតែជិះកប៉ាល់ហោះ សូម្បីតែឃើញក៏មិនសូវបានឃើញផង។
(ហៅ - សរសេរសំបុត្រ)

ខ. កុំថាតែហៅ សូម្បីតែសរសេរសំបុត្រក៏មិនសូវបានសរសេរផង។

MODEL:

T: They haven't even seen an airplane, let alone ride in one.
(call by telephone - write letters)

S: They haven't even written letters let alone call by telephone.

កុំថាតែហៅ សូម្បីតែសរសេរសំបុត្រក៏មិនសូវបានសរសេរផង។

ក. ដាក់ទូរស័ព្ទ - ទិញតែមប្រើ
កុំថាតែដាក់ទូរស័ព្ទ សូម្បីតែទិញតែមប្រើក៏មិនសូវបានទិញផង។

ខ. ស្តាប់ទូរទស្សន៍ - ស្តាប់វិទ្យុ
កុំថាតែស្តាប់ទូរទស្សន៍ សូម្បីតែស្តាប់វិទ្យុក៏មិនសូវបានស្តាប់ផង។

គ. មើលកាសែត - ទិញ
កុំថាតែមើលកាសែត សូម្បីតែទិញក៏មិនសូវបានទិញផង។

ឃ. ទៅលេងគាត់ - ផ្ញើសំបុត្រ
កុំថាតែទៅលេងគាត់ សូម្បីតែផ្ញើសំបុត្រក៏មិនសូវបានផ្ញើផង។

ង. បើកឡាន - ចេះជិះកង់
កុំថាតែបើកឡាន សូម្បីតែចេះជិះកង់ក៏មិនសូវចេះជិះផង។

ច. ទៅមើលកុនក្នុងរោង - មើលទូរទស្សន៍
កុំថាតែទៅមើលកុនក្នុងរោង សូម្បីតែមើលទូរទស្សន៍ក៏មិនសូវបានមើលផង។

VOCABULARY

កសិកម្ម /ka?se?kam/	agriculture
កាន់	to towards
ការផ្សាយពាណិជ្ជកម្ម	advertisement, commercial
កុំថាតែ (A) សូម្បីតែ (B)	even (B) ... let alone (A); (even) (B) ..., to say nothing of (A)
កំពង់ផែ	(water) port
កំពង់	port
ផែ	dock
ក្រាល	to cover, to pave, be paved, to be floored
ក្រុមហ៊ុន	company (commercial)
ហ៊ុន	share (e.g., of stock)
ញាក់ខ្វែង (ញាក់ AC)	reticular, like a natural network, intersecting
* ខ្វែង	to cross
គម = គីឡូម៉ែត្រ	kilometer
គមនាគមន៍	coming and going, communication
* គមន៍ (H)	act of going (literary)
ចង្អៀត	tight, narrow, constricted, cramped, crowded
ចលនា	traffic, movement
ចាប់ប៉ុស្តិ៍	to receive a channel (T.V., radio)
ចំ	right at
ចាំ : ចាំបាច់	necessary, need to
ច្នៃ	to improve, to polish, to cut (gem)
ឆ្នាំទៅ	last year
ជនជាតិ	the people of a country, nationals
ជាលំដាប់	consecutively, respectively
លំដាប់	order, sequence
ជំនន់	flood (n.)
ជន់	to flood
ដេកពួន	to go to sleep
ឋិតនៅ	to be located at
តែង + verb	frequently
តេឡេហ្វូន	telephone
តេឡេក្រាម	telegram
* តោន-គីឡូម៉ែត្រ	ton-kilometer (a measurement)
តែមប្រិ៍ /taεm/	postage stamp (French. timbre)
តម្រូវ = តំរូវ (< ត្រូវ)	to require, to enforce
ត្រង់	at, right at, sthraight
ថយ	to go backwards, pull back, withdraw
ថវិកា /thaˀviˀkaa/	budget
ថែរក្សា	to takc care of
ថែ	to take care of
រក្សា	to take care of
ថៃ	Thai
ថ្នល់	street, road
ទទឹង	width
ទន្លេសាប	Tonlé Sap (river and lake)
ទស្សនាវដ្តី /tuonsəniavədεy/	magazine, periodical
ទស្សនា /tuonsənia/	to look at, to tour, visit
ទិស	direction
ទិសដៅ	goal, destination
ដៅ	to mark, a target, marked place
ទីប្រជុំជន	population center
ទីរួមខេត្ត	provincial capital
រួម	to unite, to join
ទឹកលិច	to flood
ទោះជា... ក៏ដោយ	even though, although
ទំងន់ = ទម្ងន់	weight
ទំនាបកណ្តាល	central lowlands
ទំនាប	lowlands
ទំនិញ	goods, merchandise
ទ្រុឌទ្រោម	shabby and old

ទ្រុឌ	shabby, dented
ទ្រោម	collapsed
បណ្ដាញ (ត្បាញ)	something interwoven, a mesh
ត្បាញ	to weave, interweave
ប៉ា	father (urban)
បាត់ដំបង	Battambang (Cambodian province)
បិទ	to attach, to fasten on
ប៉ុស្តិ៍	channel, station (T.V., radio)
បុរាណ	ancient, old day
ប្រវែង	length
ផលវិបាក	event, occurence, incident
វិបាក	incident (with negative consequences)
ផលិតផល	products
ផ្ទាល់មាត់	orally
ផ្លូវក្រាលកៅស៊ូ	paved street
ផ្លូវខ្នងអណ្ដើក	rutted, potholed road
អណ្ដើក	turtle
ផ្លូវដីលើក	dirt road
ផ្លូវដែក	railroad
ដែក	metal, especially iron
ផ្លូវលំ	trail
* លំ	cleared just enough to permit passage
ពាណិជ្ជកម្ម /paanicakam/	commerce, to do commerce
* ពាណិជ្ជ	commercial (formal)
ភ្ជាប់ (<ជាប់)	to connect, to put together, to bring together
ម = ម៉ែត្រ	meter (unit of measurement)
មានដល់	even to the point of...
មិនដាក់ដាន	no more than
ម្ដងម្កាល	once in a while
យន្តហោះ	airplane
យន្ត /yŭn/	machine, engine
រដូវទឹកឡើង	flood season
រ៉ឺម៉ក	bicycle or motorcycle-drawn trailer (French: remorque)
រីកចំរើន	to expand, prosper
រីក	to expand, bloom, swell
* រុក្ខាបាល	forester
រៀនសូត្រ	to study
រៀបនឹង	about to
លក្ខណៈ	character, aspect of character
លទ្ធផល	result
លូតលាស់	to burgeon, bloom, swell, grow, prosper, progress
លាស់	to expand (leaf), progress, prosper
លូត	to grow bigger, taller
ដែលនឹងនឹង	to be bound to
សតវត្ស /sattavŏt/	century
សូត្រ	to recite, chant, to study
សូវ + verb	would rather + verb + instead
សៀមរាប	Siem Reap (Cambodian province)
ឡើងថ្នាក់	to be promoted
អាកាសចរណ៍	airline (formal)
អាកាសយានដ្ឋាន /aakaasyianathaan/	airport (formal)
អាកាសយាន	airplane (formal)
ដ្ឋាន (= ស្ថាន, ឋាន)	place (formal)
អាជីវកម្ម /aacilvakam/	a living, subsistance
ឦសាន /eysaan/	northeast (literary)
អឺរ៉ុប	Europe

APPLICATIONS

1.

1. Find synonyms for the following words. Use these words in sentences.

ស្លើដែក	រហេកផល	ស័ប្ទ	ស្រុកកន្លែង
(ទឹម)ភ្លៀកាន	តំរើប	ទកញ៉ា	ពាសពេញ
ជាសំរាប	ចំយ	ទុក្ខជាល	ក្នុងចំណោម

2. Find the word(s) that fit(s) each of the following definitions.

Example: ការធ្វើស្រែចំការ ។

Answer: កសិកម្ម

១ ផលដែលបានមកពីការធ្វើផ្សេងៗ ដូចជាកសិកម្មជាដើម ។

២ ចម្ងាយ គឺចំនួនម៉ែត្រនិងគីឡូម៉ែត្រពីកន្លែងមួយទៅកន្លែងមួយទៀត ។

៣ ប្ដូរចូលដែលចេញពីស្រុកទៅកាន់ខេត្តផ្សេងៗ ។

៤ កន្លែងដែលគេបាលសប់ដើម្បីដាក់ឬយកគេតាំង ។

៥ យន្តហោះ កប៉ាល់ហោះ ឬយានហោះ ។

៦ ការធ្វើដើម្បីយកផល ។

៧ អ្វីដែលសម្រាប់ធ្វើឱ្យស្គាល់ ។

៨ តាំងពីដើមរៀងតាំងពីកើត ។

៩ កាកញ្ញា ។

១០ អ្វីៗដែលយើងធ្វើ ។

3. Correct the following sentences by adding the proper word(s)

១ កំពង់ផែធំៗរៀបចំដែកបន្តិចបន្តួចដែលគេនាំទំនិញចេញចូល ។

២ ផ្លូវនេះបាន ១៩០ គម ។

៣ រោងចក្រច្រើនហើយនៅតែកម្ពុជាដែលគេនេះបានការគិតបាក់យ៉ាងខ្លាំង ។

៤ សកម្មភាពពាណិជ្ជកម្មឡើងពី ១០០ លាននៅឆ្នាំមុន ១៥០លាននៅឆ្នាំនេះ ។

៥ កំពង់ផែនៅភ្នំពេញជាកំពង់ផែទន្លេ និងជាកំពង់ផែសមុទ្រ ។

៦ ចលនាដឹកនាំនេះចុះយ៉ាងខ្លាំងជាសំខាន់ចាប់តាំងពីឆ្នាំ១៩៦៥ ។

៧ ចាប់តាំងពីឆ្នាំ១៩៥០ ផលិតផលកសិកម្មវានៅតែចុះ ។

៨ ផលិតផលកសិកម្មក៏ការនៅតែចុះ ចលនាដឹកនាំការនៅតែចុះដែរ ។

៩ ពេលរដូវទឹកជំនន់ឡើង ស្ទើរស្រុកសឹងតែគ្របកន្លែង ។

១០ កុំថាតែមីង តែគ្នាក៏មិនដែលស្គាល់ ។

4. Change the style of the following from ordinary to formal.

១ ខ្ញុំចង់ហៅលោកមកញ៉ាំបាយនៅផ្ទះយើង ។

២ លោកគិតចូលគេងម៉ោងប៉ុន្មាន ?

៣ តាគិតទៅនោះដើម្បីជួបអ្នកណា ?

៤ ចៅហ្វាយលោកនិយាយចាំមើលការប្រជុំ ?

៥ ខ្ញុំសុំសួរលោកអំពីរឿងនោះបន្តិច ។

A. Have the student discuss the folowing situations.

១ បញ្ហាធ្វើដំណើរតាមឡានផ្ទាល់ខ្លួននៅស្រុកផ្សេងៗ ។
២ ការធ្វើដំណើរពីភ្នំពេញទៅកំពង់ចាម និងពីភ្នំពេញទៅកំពង់សោម ។
៣ បញ្ហាបើកឡានទៅធ្វើការក្នុងទីក្រុង ។
៤ ចង់បានការសុំច្បាប់ទិញដីធ្វើផ្ទះ ។
៥ របៀបផ្ញើសំបុត្រទៅក្នុងនិងក្រៅប្រទេស ។

B. Questions for the teacher to ask.

១ ពីកន្លែងលោកមក មានការ៉ុសប៉ុន្មានដែលចេញមករាល់ថ្ងៃ?
២ ដំណើរតាមប៉ុស្តិ៍ ឬតាមអ្នកណាដែលលោកជឿជាងគេ?
៣ ទស្សនាវដ្តីណាមួយដែលលោកចូលចិត្តអានជាងគេ?
៤ នៅស្រុកនេះ មានវិទ្យុរបស់ឯកជនទេ?
៥ បើរដ្ឋាភិបាលចង់ជូនដំណឹងទៅដល់ពលរដ្ឋ គេធ្វើយ៉ាងម៉េច?
៦ ប៉ុស្តិ៍នៅស្រុកនេះជារបស់រដ្ឋការ ឬជារបស់អ្នកណាម្នាក់?
៧ នៅស្រុកនេះអ្នកមានតេឡេហ្វូន មានប៉ុន្មានភាគរយ?
៨ អ្នកស្រុកនេះចូលចិត្តធ្វើដំណើរតាមអ្វី? ហេតុអ្វី?
៩ ស្រុកនេះមានផ្លូវគមនាគមន៍ប៉ុន្មានយ៉ាង?
១០ បើប្រើផ្ញើសំបុត្រឱ្យឆាប់ដល់គេត្រូវធ្វើយ៉ាងម៉េច?

C. Questions for the student to ask.

a. Why does Cambodian use the term លើកផ្លូវ instead of សង់ផ្លូវ ?
b. Are tolls exacted at bridges and on public roads? Have they ever been in the past?
c. Who is responsible for building and maintaining the roads?
d. Ask your teacher to describe a train trip in Cambodia. Are there sleeper trains? Dining cars? Can one buy a ticket on the train?
e. Is mail censored in Cambodia? If so, what are the censors looking for? Is international mail censored?
f. What would be the quickest way to reach someone in a provincial capital if he has no telephone? In a district town? In a village?
g. Do Cambodians trust the domestic mail, or do they prefer to entrust messages and things to people they know who are going to the area they want to send to?
h. Where are newspapers published? Do small towns ever publish their own newspapers?
i. What do most Cambodians like to read? Are people in the city and country different?
j. Is there radio and television outside of Phnom Penh? In rural areas?
k. What medium of communication has the most influence on public opinion?

Why?

l. Are there both privately owned and government owned radio stations? Newspapers? Magazines?

m. What languages are publications and broadcasts in? Is the percentage of Khmer increasing?

n. Can one send a telegram or make an international phone call from a private telephone?

LESSON FOUR

TWO APPROACHES TO ILLNESS

1. Get a description of a healer from your teacher.
2. Are there special qualifications to become a medium? Special training?
3. If someone is ill, what would a "traditional" family do firts?
4. Is Western medicine considered more effective than tradional practises?

ការទាស់ចំណីអាហារក្រោយពេលឆ្លងទន្លេ

ជនខ្លះត្រូវការបរិភោគអំបិលតែល្មមទៅនឹង ជនខ្លះទៀត ត្រូវការបរិភោគអំបិលយ៉ាងច្រើន ៗ នេះជាគុណសម្បត្តិរបស់អំបិលដែលមនុស្សយើងតែងដឹង ។ ក្រៅពីនេះទៅទៀតជាតិអំបិលមានគុណសម្បត្តិសម្រាប់ទប់ជាតិទឹកឲ្យមាននៅក្នុងខ្លួនជានិច្ច ព្រោះរូបកាយមនុស្សយើង តែងត្រូវការនូវជាតិទឹកឲ្យមាននៅក្នុងសាច់ឈាមជានិច្ចកាល ។

យើងសូមបញ្ជាក់ថា រូបកាយមនុស្សយើង បើខ្វះជាតិអំបិលនិងជាតិទឹកនាំធ្វើឲ្យស្រេះស្រោះ អស់កម្លាំង, ធ្វើឲ្យអន្ទះអន្ទែង, ធ្វើឲ្យឈឺចុកចាប់ក្នុងសាច់ឈាមនិងដៃ-ជើង, ធ្វើឲ្យរមួលសាច់ដុំ ដែលខ្មែរយើងហៅថារមួលក្រពើ ៗ ល ៗ ហើយប្រសិនបើខ្វះជាតិអំបិល និងជាតិទឹកយ៉ាងច្រើន នាំធ្វើឲ្យលំបាកវេទនាយ៉ាងខ្លាំង រហូតដល់បាត់បង់ជីវិត ។ ឧទាហរណ៍ ដូចជាមនុស្ស ដែលកើតរោគរាកយ៉ាងខ្លាំងមួយថ្ងៃ ដល់ទៅ ១០ ឬ ២០ ដង បានសេចក្តីថា មនុស្សដែលរាកយ៉ាងច្រើន របៀបនេះនាំធ្វើឲ្យខ្វះជាតិអំបិលនិងជាតិទឹកនៅក្នុងខ្លួន រួចនាំឲ្យឈឺចុកចាប់រោចរោល លំបាកវេទនា យ៉ាងខ្លាំងៗ ពុំនោះសោតទេ ឧទាហរណ៍ដូចជាមនុស្សកើតជម្ងឺ អាសន្នរោគដែលចុះផងក្អួតផង ក៏ស្រេះស្រោះអស់កម្លាំង, ចុកដៃ-ជើង រមួលក្រពើ, ឈឺចុកចាប់ ក្នុងសាច់ឈាម លំបាកវេទនាជាអនេក ដោយមកពីខ្វះជាតិអំបិល និង ជាតិទឹក ។

ដោយជាតិអំបិលនិងជាតិទឹកមានគុណសម្បត្តិដ៏ធំ ដូច្នេះហើយបានជានៅបរទេស គេអាចព្យាបាលជម្ងឺអាសន្នរោគឲ្យបានជាសះស្បើយឡើងវិញ ដោយគ្រាន់តែចាក់បញ្ចូលជាតិអំបិល និងជាតិទឹកឲ្យមានគ្រប់គ្រាន់ឡើងវិញ ដែលពាក្យពេទ្យខ្មែរហៅថា ចាក់បញ្ចូលសេរ៉ូម (Sérum) គឺពុំចាំបាច់តាំងប្រើថ្នាំអ្វីផងក៏មាន ។

ឧទាហរណ៍ប៉ុណ្ណោះសឲ្យឃើញថា ជាតិអំបិលនិងជាតិទឹកមានគុណសម្បត្តិខ្លាំងក្លាណាស់ សម្រាប់រូបកាយមនុស្សគ្រប់រូប ។ ប៉ុន្តែជាតិអំបិលនិងជាតិទឹក ដែល

មានគុណសម្បត្តិជាចាំបាច់ដូច្នេះ ពុំមែនចេះតែចូលទៅក្នុងសាច់ឈាមបានតាមចិត្តនោះទេ គឺត្រូវមានកម្រិតចំនួនជាដាច់ខាត ឧទាហរណ៍ ដូចជាក្នុង ១ លីត្រឈាម ត្រូវមានជាតិអំបិលចំនួន ៣ ក្រាមកន្លះប៉ុណ្ណោះ តែបើលើសពីនេះមិនបាន ។ ត្រង់នេះប្រហែល ជាមានអស់លោកខ្លះឆ្ងល់ថា បើមនុស្សត្រូវបរិភោគអំបិលនិងទឹកយ៉ាងច្រើនក្នុងមួយថ្ងៃ ៗ តើធ្វើម្តេចឲ្យជាតិអំបិលនិងជាតិទឹក មានកម្រិតចំនួនទៀងទាត់ទៅកើត?

ចំណុចត្រង់នេះ យើងសូមបញ្ជាក់ថា ករណីយកិច្ចធំពួកនេះ ត្រូវតម្រងនោមទទួលខុសត្រូវ គឺបើជាតិអំបិលនិងជាតិទឹកមានកម្រិតលើសចំនួន ត្រូវតម្រងនោមបញ្ចេញចោលទៅវិញ ។ ឧបមាថាមនុស្សម្នាក់ ដែលមិនស្រេកទឹកសោះ ហើយត្រូវគេបង្ខំឲ្យផឹកទឹកអស់ ១ លីត្រ ឬ ១ លីត្រកន្លះ ប៉ុន្មានម៉ោងក្រោយមក គេក៏នោមអស់ទៅវិញ ។ សេចក្តីនេះមានន័យថា ជាតិទឹកដែលលើសពីសេចក្តីត្រូវការ របស់រូបកាយ ត្រូវតម្រងនោមបញ្ចេញចោលទៅក្រៅវិញ មិនទុកឲ្យសល់នៅក្នុងខ្លួនឡើយ ។ នេះចំពោះមនុស្សមានសុខភាពធម្មតា បើត្រូវការប្រើជាចាំបាច់ គេឲ្យប្រើថ្នាំណាដែលមានជាតិពុល តិចតួចស្តួចស្តើងជាទីបំផុត និងថ្នាំណាដែលមានគុណសម្បត្តិសម្រាប់ជួយឲ្យតម្រងនោម ឆាប់ជាឡើងវិញ ។

NOTES FOR READING PASSAGE 1

Line 11 This long sentence beginning at line 11, will be much clearer if it is read as three sentences, with the breaks at the end of ...បាត់បង់ជីវិត , (line 11),and at the end of ...១០ ឬ ២០ ដង។, (line 20).

Line 35 In this long sentence that starts here, the clause beginning with [illegible] at line 35, modifies អាចព្យាបាលជម្ងឺ... at line 37. The

clause at line 42, that begins with ដែល modifies ចាក់បញ្ចូលជាតិអំបិល...

Line Note that this ល្អ is the one that means 'well, healthy' as in សុខសប្បាយល្អទេ.

Line 62 You have previously learned that រាល់ 'every, each' is used only before time words. Here you see that it can be used before other classifiers, but such usage is rare. Another more common use of រាល់ is in រាល់គ្នា 'everyone.'

Line 6 In many cases ចេះតែ means 'always' when it is used before a verb. However, this is not the whole story. There are two components to the meaning of ចេះតែ that deserve further discussion. ចេះ + verb can mean 'to (verb) without being told to.'

e.g., ប្រពន្ធខ្ញុំចេះទៅរកទិញម្ហូបទុក កុំអីគ្នាអត់មានស៊ីទេថ្ងៃនេះ។
If my wife hadn't gone to get food, we wouldn't have anything to eat today.

This component of meaning occurs strongly in some cases of ចេះតែ 'always, to keep + verb.'

e.g., ប្រពន្ធខ្ញុំចេះតែទិញម្ហូបទុក។
My wife keeps buying food in advance.

The other component of meaning comes from the literal translation of ចេះតែ 'to know how to ... only.'

e.g., គាត់ចេះតែដើរលេងប៉ុណ្ណោះទេ។
All he knows how to do is go out for fun.

Thus, when ចេះតែ means 'always,' it frequently has the connotation 'to the exclusion of other activities.' In the above example, going out for fun excludes more productive activities.

Line The phrase កាលបើលើសពីនេះមិនបាន is the same in meaning as លើសពីនេះមិនបាន; កាលបើ is redundant in this sentence. A possible source for this sentence is a combination of the following two clauses into one: កាលបើលើសពីនេះ and លើសពីនេះមិនបាន.

Line and 70 Note that several auxiliaries can occur before the subject of the sentence, especially in writing. In this case the inverted sentence is:

ត្រូវតម្រងនោមទទួលខុសត្រូវ
The kidneys must take responsibility

The normal order is

តម្រងនោមត្រូវទទួលខុសត្រូវ។

Line 58 Note the sequence of verbs បញ្ចេញចោល 'to discard.' In this sequence ចោល 'to throw, to throw away, to abandon' is used as an adverbial with the meaning of 'out' or 'away' as in 'throw out, throw away.' It ordinarily follows the subject of the main verb,

e.g., ខ្ញុំចាយលុយចោល

I spend money wastefully.

As an adverbial it can also mean 'to abandon,' but in this case frequently has an object,

e.g., ប្រពន្ធគាត់រត់ចោលគាត់។

My wife ran away and abandoned him.

DRILLS FOR READING PASSAGE 1

DRILL A: Transformation

គំរូ

ក តម្រងនោមត្រូវទទួលខុសត្រូវ។

ខ ត្រូវតម្រងនោមទទួលខុសត្រូវ។

MODEL:

T: The kidneys are responsible.

S: The kidneys are responsible.

ក គ្រូពេទ្យថ្មីៗត្រូវប្រយ័ត្នរៀនឱ្យចាំ។
ត្រូវគ្រូពេទ្យថ្មីៗប្រយ័ត្នរៀនឱ្យចាំ។

[illegible] តម្រងនោមត្រូវបញ្ចេញជាតិសល់ចោល។

ត្រូវតម្រងនោមបញ្ចេញជាតិសល់ចោល។

គ អ្នកជំងឺត្រូវប្រាប់គ្រូពេទ្យឱ្យត្រង់។
ត្រូវអ្នកជំងឺប្រាប់គ្រូពេទ្យឱ្យត្រង់។

ឃ អ្នកជំងឺឈាមលើសត្រូវតមម្ហូបបន្តិច។
ត្រូវអ្នកជំងឺឈាមលើសតមម្ហូបបន្តិច។

ង ស្ត្រីមានផ្ទៃពោះត្រូវឧស្សាហ៍ទៅជួបគ្រូពេទ្យ។

ត្រូវស្ត្រីមានផ្ទៃពោះឧស្សាហ៍ទៅជួបគ្រូពេទ្យ។

ច គ្រូពេទ្យត្រូវប្រាប់អ្នកជំងឺឱ្យត្រង់។
ត្រូវគ្រូពេទ្យប្រាប់អ្នកជំងឺឱ្យត្រង់។

DRILL B: Transformation

គំរូ

ក គាត់ចាយលុយគ្មានប្រយោជន៍។

ខ គាត់ចាយលុយចោល។

MODEL:

T: He spends money to no purpose.

S: He spends money wastefully.

ក ខ្ញុំនិយាយគ្រាន់តែឲ្យគេឮទេ។
ខ្ញុំនិយាយចោលទេ។

ខ គាត់ទិញថ្នាំយកមកហើយមិនប្រើ។
គាត់ទិញថ្នាំយកមកចោល។

គ កុំប្រើទឹកឥតប្រយោជន៍។
កុំប្រើទឹកចោល។

ឃ កុំបើកភ្លើងបើមិនត្រូវការ។
កុំបើកភ្លើងចោល។

ង វាគិតហើយតែមិនធ្វើតាមគំនិតនោះទេ។
វាគិតចោល។

ច វាថាវានឹងធ្វើនេះធ្វើនោះតែមិនដែលឃើញធ្វើអ្វីសោះ។
វាថាចោល។

ឆ ធ្វើបាយតែគ្មានអ្នកណាស៊ី។
ធ្វើបាយចោល។

DIALOGUE

ខ្សែយាយម៉ៅ

១	ពូខ្មៅ	កូនបានស្រាន់បើហើយឬនៅ?	Is your child better yet?
		លៀង	to treat, give a party for (see note)
		រើក...វិញ	to relapse
២	មីងម៉ន	កាលលៀងហើយភ្លាម ឃើញបានស្រាន់បើបន្តិច។ តែឥឡូវរើកធ្ងន់វិញ។	Just after we held the ceremony for the spirit he got a little better, but now he's worse again.
		ចេះតែ	constantly
		អាម៉េច	how what's it like (spoken)
		ទៅតាម	to send for
		គ្រូ	healer, practitioner of folk medicine.
៣	ពូខ្មៅ	វាចេះតែអាម៉េច? បាន ឲ្យអ្នកណាទៅតាមគ្រូទេ?	What's wrong with him? Have you sent for the healer?
		ប្លែក	strange
		អន្ទះអន្ទែង	to show signs of severe pain or discomfort
៤	មីងម៉ន	ឲ្យទៅតាមហើយ។ ដូច ប្លែកណាស់ វាចេះតែ អន្ទះអន្ទែង។	Yes we have. It's strange, he's in constant pain.
		ត្រូវ	to be affected by, to have
		ខ្សែ	line, family line
៥	ពូខ្មៅ	មើលកូនហ្នឹងវាកើតថ្ងៃអី? ក្រែងមិនមែនត្រូវខ្សែយាយ ម៉ៅទេឬអី?	Let's see, what day was your child born? Isn't he from (grandmother) Maw's line?
		ហួស	to pass, exceed
		ថ្ងៃអន្ត្រា	the day on which death is believed to usually occur (that day is one's birthday)
		បញ្ចូល	to consult a medium

ចូល	to go into trance

៦ មីងម៉ន ហួសថ្ងៃអន្តរាយហើយ។ ខ្សែ ហ្នឹងហើយ ព្រោះកាលទៅ បញ្ចូល គេថាខាងហ្នឹង។ His dangerous day (birthday) has already passed. And that's his family line, because when they went to consult the medium, she said it was that side (of the family).

ខ្មោចចូល	to be possessed by a spirit
ខ្មោច	spirit, ghost, corpse
ចូល	to enter, to possess (e.g, spirit)
ទារ	to demand

៧ ពូខៀវ ចុះកាលខ្មោចចូលគាត់នោះ មាន ទារអ្វីខ្លះ? And when the spirit possessed him, what did it demand?

អា + verb	that which
ណុង	that (colloquial)
រៀប	to prepare (in accordance with spirit's orders))
ថ្វាយ	to give (to a god, king, or spirit)

៨ មីងម៉ន អាទារទាំងប៉ុន្មានណុង រៀប ថ្វាយអស់ហើយ រួចបាន ទាំងសៀងនោះថែមទៀត។ Whatever it asked for, we prepared to give it, and then we also performed the ceremony for it.

និមន្ត /ni ʔmún/	to invite (a Buddhist monk)
លោក	Buddhist monk
ស្រោច	to sprinkle, water
ស្រោចទឹក	to sprinkle water (here: as part of a ritual)

៩ ពូខៀវ បើរៀបមិនស្រួលអញ្ចឹង និមន្តលោកស្រោចទឹកមើល។ If your preparations don't work, invite the monks to come and sprinkle water, and see if that works.

ទឹក ហ្នឹង	even that ...

១០ មីងម៉ន មិនកើតទេ ទឹកគ្រូហ្នឹងដឹង ហ៊ានឱ្យថ្នាំមិនហ៊ានផង។ You can't do that. Even the healer doesn't know if he dares give medicines or not.

អឹម	umm (indicates indecision)
ខ្មោច	spirit, ghost
ប្រកាន់	to be hard to please, to mind, to be prejudiced
ហ្នឹង	like that

១១ ពូខ្មៅ អឹម ខ្មោចខាងខ្សែហ្នឹង ដូច មិនប្រកាន់ដល់ហ្នឹង។ — Umm, spirits from that family line aren't that hard to please.

កាច	fierce
ត្រូវមិនត្រូវ	easily (indicates warning)
កាប់	to break off, to kill
ទាំងស្រស់	in cold blood
ស្រស់	fresh

១២ មិនមែន ទេ ខ្សែហ្នឹងកាចណាស់ ត្រូវ មិនត្រូវកាប់ទាំងស្រស់ហ្នឹង។ — No, that line is really fierce. They will easily kill in cold blood.

NOTES FOR THE DIALOGUE

SENTENCE NO. 2

The ceremony of សែនខ្មោច is performed by the family of one believed to be possessed by a spirit. Food is prepared and offered to the spirit with the request that the spirit permit the affected person to recover from his illness.

SENTENCE NO. 5

As you have already seen in the case of ពូ 'uncle,' kinship terms can be used in addressing or speaking about people who are not relatives. In this case យាយទេព is probably not related to ពូខ្មៅ, the speaker, but since she is (or was) an old woman of ពូខ្មៅ's grandparents generation and someone with whom he is not on formal terms, she can be addressed and referred to as យាយ. For you as a foreigner យាយ or ដូន 'grandmother' are respectful terms for addressing an old woman for whom it would be inappropriate to use the more formal terms like លោកស្រី, អ្នកស្រី. The corresponding term for a man is តា 'grandfather.'

SENTENCE NO. 6

Most mediums (រូបអារក្ស rup ʔaaréʔ) in Cambodia are women. When consulted

they enter a trance and are possessed by a spirit, which may be male or female. While in the trance the medium speaks in a falsetto and uses many special words used only in dealing with spirits and mediums.
Mediums are used to intercede with spirits and to seek predictions of the future.

SENTENCE NO. 8

Note that a verb phrase or clause can be nominalized by អា . Here the clause is ទារទាំងប៉ុន្មានក៏ដោយ ... '(it) demands however much...' The noun(s) created by អា : អាទារទាំងប៉ុន្មានក៏ដោយ 'whatever (it) demands...' represents the otherwise unstated object of the verbs ទារ 'demand' and រៀបថ្វាយ 'prepare to offer.' The nominalized clause can have a subject, e.g.,

អាគាត់រកឃើញនោះ មានតំលៃគួរសមដែរ ។

What he found is fairly valuable.

The word ដែល can be used instead of អា with no change of meaning, e.g.,

ដែលគាត់រកឃើញនោះ មានតំលៃគួរសមដែរ ។

What he found is fairly valuable.

or

ដែលទារទាំងប៉ុន្មានក៏ដោយ យើងរៀបថ្វាយអស់ហើយ ។

Whatever it asked for, we prepared to give it.

Note also that the nominalized clause in sentence 8 is also part of a larger construction: verb$_1$ + ទាំងប៉ុន្មាន + verb$_2$ + អស់. There are two clauses, each with a different verb. Another example of the construction:

គាត់ដើរឆ្ងាយទាំងប៉ុន្មាន ខ្ញុំដើរបានអស់ ។

I can walk as far as he can.

As you can see, the most literal translation would be 'however much + verb$_1$, verb$_2$ all of it.'
This is a very important Cambodian structure. When you want to make a general statement like 'you can have anything you want' Cambodian says 'whatever you want, you can have it all,' e.g., លោកចង់បានអ្វី ខ្ញុំឲ្យទាំងអស់ ។.
The first clause has an indefinite like អ្វី , ណា etc.; the second clause has a substitute like ទាំងអស់ , ហ្នឹង , នោះ , etc. in the same position in the clause. Thus, for instance, if the indefinite is in object position in the first clause, its substitute in the second clause is also in object position, e.g.,

បើលោកទៅណា ខ្ញុំទៅនោះដែរ ។

Wherever you go, I'll go too.

Another example, with the indefinite in subject positon:

អ្នកណាបានលុយអ្នកហ្នឹងត្រូវចេញ ។

Whoever has money should pay.

SENTENCE NO. 9

និមន្ត (nimúən) is used as an honorific before verbs of motion whose subject is a Buddhist monk. It is similar to អញ្ជើញ , which is used for respected persons. Like អញ្ជើញ it also means 'to invite.' An example of និមន្ត used preverbally:

លោកនិមន្តមកដល់ពីអង្កាល់?

When did he arrive?

There are other special words which must be used in addressing or discussing monks. They will be introduced later. Most of them are also discussed in the Grammatical Sketch at U.3.2.

SENTENCE NO. [illegible]

The ceremony of sprinkling water consists of inviting monks to chant scriptures and sprinkle water on an ill person, a person on whom a blessing is asked (e.g., an examination candidate), or a thing or place that is unlucky. This ceremony is meant to bring luck and to exorcise evil spirits.

SENTENCE NO. [illegible]

The phrase ត្រូវមិនត្រូវ indicates that the actor will perform the action without thinking of whether it is right or wrong, that he will not stop to think or measure the consequences of his action. Thus in this sentence ត្រូវមិនត្រូវ warns that spirits from Maw's family are quick to kill if angered.

DRILLS

DRILL ONE: Response

គូ

ក កូនបានស្រាន់បើហើយឬនៅ?

ខ កូនមិនទាន់បានស្រាន់បើទេ។

MODEL:

T: Is your child better yet?

R: He hasn't gotten better yet.

ក បាត់ចុកពោះហើយឬនៅ?
មិនទាន់បាត់ចុកពោះទេ។

ខ ជើងបាត់ចុកហើយឬនៅ?
ជើងមិនទាន់បាត់ចុកទេ។

គ លេបថ្នាំនោះហើយឬនៅ?
មិនទាន់លេបថ្នាំនោះទេ។

ឃ ចាក់ថ្នាំការពារជំងឺអាសន្នរោគហើយឬនៅ?
មិនទាន់ចាក់ថ្នាំការពារជំងឺអាសន្នរោគទេ។

ង ថ្នាំទឹកអស់ហើយឬនៅ?
ថ្នាំទឹកមិនទាន់អស់ទេ។

ច ទឹកនោះបញ្ចេញចោលអស់ហើយឬនៅ?
ទឹកនោះមិនទាន់បញ្ចេញចោលអស់ទេ។

DRILL TWO: Transformation

Teacher and student do this drill again, reversing roles, e.g.,

ឧ.

ក កូនមិនទាន់បានធូរស្បើយទេ។

ខ កូនបានធូរស្បើយហើយឬនៅ?

MODEL:

T: My child hasn't gotten better yet?

S: Has your child gotten better yet?

DRILL THREE: Transformation

ឧ.

ក បានធូរស្បើយបន្តិច។

(សែន)

ខ កាលសែនហើយ ឃើញបាន
ធូរស្បើយបន្តិច។

MODEL:

T: He's a little better.
(appease the spirit)

S: When you appeased the spirit, he got a little better.

ក ហាក់ធូរពោះបន្តិច។
(លេបថ្នាំហ្នឹង)
កាលលេបថ្នាំហ្នឹងហើយ ឃើញ
ហាក់ធូរពោះបន្តិច។

ខ ហាក់ធូរជើងបន្តិចហើយ។
(ទឹកក្រូច)
កាលទឹកក្រូចហើយ ឃើញហាក់
ធូរជើងបន្តិចហើយ។

គ ឈប់ចេញឈាមបន្តិចដែរ។
(ដាក់ថ្នាំ)
កាលដាក់ថ្នាំហើយ ឃើញឈប់
ចេញឈាមបន្តិចដែរ។

ឃ ហាក់ស៊ីបានវិញ។
(លេបថ្នាំហ្នឹង)
កាលលេបថ្នាំហ្នឹងហើយ ឃើញ
ហាក់ស៊ីបានវិញ។

ង ឈប់ចេញឈាមទេ។
(បិទ)
កាលបិទហើយ ឃើញឈប់ចេញ
ឈាមទេ។

ច បាន*ចង់*ស៊ីបានវិញ។
(ទឹកដូង)
កាលផឹកដូងហើយ ឃើញបាន
ចង់ស៊ីបានវិញ។

DRILL FOUR: Response

ឧ.

ក វាចេះតែអាម៉េច ក្នុងខ្លួនលោក?
(អន្ទះអន្ទែង)

ខ ក្នុងខ្លួនខ្ញុំ វាចេះតែអន្ទះអន្ទែង។

MODEL:

T: What's the matter with you?
(in discomfort)

S: I'm in constant discomfort.

ក វាចេះតែអាម៉េច ចិត្តលោក?
(រសេះរសោះ)
ចិត្តខ្ញុំ វាចេះតែរសេះរសោះ។

ខ វាចេះតែអាម៉េច សាច់ជើងលោក?
(ចុកចួល)
សាច់ជើងខ្ញុំ វាចេះតែចុកចួល។

គ វាចេះតែអាម៉េច ក្នុងខ្លួនលោក?
(ស្ពាប់ស្ពល់)
ក្នុងខ្លួនខ្ញុំ វាចេះតែស្ពាប់ស្ពល់។

ឃ វាចេះតែអាម៉េច លោក?
(ចុះផងក្អកផង)
ខ្ញុំ វាចេះតែចុះផងក្អកផង។

ង វាចេះតែអាម៉េច ប៉ុន្មានថ្ងៃហ្នឹង
លោក?
(អស់កម្លាំង)
ប៉ុន្មានថ្ងៃហ្នឹង ខ្ញុំ វាចេះតែអស់កម្លាំង។

ច វាចេះតែអាម៉េច ព្រឹកៗលោក?
(ចង្អោរ)
ព្រឹកៗ ខ្ញុំ វាចេះតែចង្អោរ។

DRILL FIVE: Transformation

Do this drill again, reversing roles, e.g.,

គំរូ

ក ក្នុងខ្លួនខ្ញុំ វាចេះតែអន្ទះអន្ទែង។

ខ វាចេះតែអាម៉េច ក្នុងខ្លួនលោក?

MODEL:

T: I'm in constant discomfort.

S: What's the matter with you?

DRILL SIX: Transformation

គំរូ

ក កូនខ្ញុំឈឺអន្ទះអន្ទែងទៀតហើយ។
(ទៅតាមគ្រូ)

ខ កូនហ្នឹងចេះតែអាម៉េច? បានទៅតាមគ្រូទេ?

MODEL:

T: My child is uncomfortably sick again.
(send for the healer)

S: What's wrong with the child? Have you sent for the healer?

ក ភ្នែកខ្ញុំឈឺមើលអីមិនច្បាស់ទេ។
(ទៅមើលពេទ្យ)
ភ្នែកហ្នឹងចេះអាម៉េច? បានទៅមើលពេទ្យទេ?

ខ ស្មាខ្ញុំឈឺសើកដែរ មិនដូចទេឥឡូវ។
(ទឹកថ្នាំអី)
ស្មាហ្នឹងចេះតែអាម៉េច? បានទឹកថ្នាំអីទេ?

គ ពោះខ្ញុំ ញាំអីទៅចុក ញាំអីទៅចុក។
(ស៊ីថឹកអី)
ពោះហ្នឹងចេះតែអាម៉េច? បានស៊ីថឹកអីទេ?

ឃ ខ្លួនខ្ញុំបរតោះមិនអស់ទៀតក្រើកមិញ។
(យកឱ្យជាងមើល)
ខ្លួនហ្នឹងចេះតែអាម៉េច? បានយកឱ្យជាងមើលទេ?

ង ភ្នែកខ្ញុំបែរជាឈឺឥឡូវ។
(ទៅពេទ្យភ្នែក)
ភ្នែកហ្នឹងចេះតែអាម៉េច? បានទៅពេទ្យភ្នែកទេ?

ច ក្រចៀកខ្ញុំឈឺពីរបីថ្ងៃហើយ។
(ដាក់ថ្នាំអី)
ក្រចៀកហ្នឹងចេះតែអាម៉េច? បានដាក់ថ្នាំអីទេ?

DRILL SEVEN: Response

គំរូ

ក បានឱ្យអ្នកណាទៅតាមគ្រូទេ?
(អន្ទះអន្ទែង)

ខ ឱ្យទៅតាមហើយ ព្រោះវាចេះតែនៅអន្ទះអន្ទែង។

MODEL:

T: Have you sent for the healer?
(in pain)

S: Yes, because he's so constantly in pain.

ក បានឱ្យទៅមើលទេ?
(អស់កម្លាំង)
ឱ្យទៅមើលហើយ ព្រោះវាចេះតែនៅអស់កម្លាំង។

ខ បានឱ្យទឹកថ្នាំអីទៀតទេ?
(ចុក)
ឱ្យទឹកហើយ ព្រោះវាចេះតែនៅចុក។

គ បានឱ្យដាក់ថ្នាំម្តងទៀតទេ?
(ឈឺខ្លាំងៗ)
ឱ្យដាក់ហើយ ព្រោះវាចេះតែនៅឈឺខ្លាំងៗ។

ឃ បានបានសម្រាកទេ?
(ទទេះទទោះ)
បានសម្រាកហើយ ព្រោះវាចេះតែនៅទទេះទទោះ។

ង បានទៅដកចារមាសទេ?

(ឈឺពេក)
គេដក(ចោល)ហើយ ព្រោះវាចេះ
តែនៅឈឺពេក។

ច មានគេលេបថ្នាំដេកទៀតទេ?
(ដេកមិនលក់)
លេបហើយ ព្រោះវាចេះតែនៅ
ដេកមិនលក់។

DRILL EIGHT: Extension

គំរូ

ក កូនហ្នឹងមកពីត្រកូលណា?
(ខ្សែយាយម៉ៅ)

ខ ក្មេងមិនមែនត្រកូលខ្សែយាយម៉ៅទេឬអី?

MODEL:

T: What family is that child from?
(grandmother Maw's line)

S: Isn't he from grandmother Maw's
line?

ក លោកស្គាល់ម្នាក់នោះទេ?
(បងប្អូននឹងលោក)
ក្មេងមិនមែនត្រកូលបងប្អូននឹងលោក
ទេឬអី?

ខ មិនយល់ថាវាម៉េចពីលោកនោះ?
(កូននិងកូនស្រីខ្ញុំ)
ក្មេងមិនមែនត្រកូលកូននិងកូនស្រីខ្ញុំ
ទេឬអី?

គ ម៉េចទៅវិញលោក?
(តាកស្លូ)
ក្មេងមិនមែនត្រកូលតាកស្លូទេឬអី?

ឃ លោកនោះជាអ្នកណា?
(មាឃួន)
ក្មេងមិនមែនត្រកូលមាឃួនទេឬអី?

ង ម្នាក់ហ្នឹងមកពីណាមក?
(ពួកលោក)
ក្មេងមិនមែនត្រកូលពួកលោកទេ
ឬអី?

ច កូនហ្នឹងដូចអ្នកណា?
(ខ្សែខាងម្ដាយ)
ក្មេងមិនមែនត្រកូលខ្សែខាងម្ដាយទេឬអី?

DRILL NINE: Response

គំរូ

ក គេទារអីខ្លះ រៀបចំទុកហើយឬនៅ?

ខ អាទារទាំងប៉ុន្មានហ្នឹង រៀបចំទុក
អស់ហើយ។

MODEL:

T: What was demanded? Have you gotten
it ready yet?

S: We've prepared everything that was
demanded.

ក យើងទិញអីខ្លះ ស្ងោរទុកហើយឬនៅ?
អាទិញទាំងប៉ុន្មានហ្នឹង ស្ងោរទុក
អស់ហើយ។

ខ ធ្វើអីខ្លះ បានប្រាប់គេហើយឬនៅ?
អាធ្វើទាំងប៉ុន្មានហ្នឹង បានប្រាប់
គេអស់ហើយ។

គ ខ្ចីអីខ្លះ យកទៅសងគេហើយឬនៅ?
អាខ្ចីទាំងប៉ុន្មានហ្នឹង យកទៅសង
គេអស់ហើយ។

ឃ បណ្ដេញចោលអីខ្លះ បានគិតគូរ
មើលហើយឬនៅ?
អាបណ្ដេញចោលទាំងប៉ុន្មានហ្នឹង
បានគិតគូរមើលអស់ហើយ។

ង បង្ហាញអីខ្លះ សុំច្បាប់ហើយឬនៅ?
អាបង្ហាញទាំងប៉ុន្មានហ្នឹង សុំច្បាប់
អស់ហើយ។

ច ដាំអីខ្លះ ដុះហើយឬនៅ?
អាដាំទាំងប៉ុន្មានហ្នឹង ដុះអស់ហើយ។

DRILL TEN: Transformation

គំរូ

ក វាទារច្រើនណាស់។
(រៀបចំទុក)

ខ អាទារទាំងប៉ុន្មានហ្នឹង រៀបចំទុក
អស់ហើយ។

[illegible]

MODEL:

T: If your preparations don't work, invite the healer to sprinkle water.
(after sprinkling water he doesn't improve - get the doctor)

S: If after sprinkling water he doesn't improve, get the doctor.

បើប្រោះទឹកមិនជា អញ្ជើញគ្រូពេទ្យ
មើល។

ក ឈឺក្អះ - ទៅរកគ្រូពេទ្យ
បើឈឺក្អះមិនជា អញ្ជើញទៅរក
គ្រូពេទ្យមើល។

ខ ប្រើថ្នាំខ្មែរមិនស្រួល - ប្រើថ្នាំចិន
បើប្រើថ្នាំខ្មែរមិនស្រួល អញ្ជើញប្រើថ្នាំ
ចិនមើល។

គ ផឹក - ចាក់ម្ជុល
បើផឹកមិនស្រួល អញ្ជើញចាក់ម្ជុលមើល។

ឃ ទឹកមិនបាត់ - ក្រាំម្ជុល
បើទឹកមិនបាត់ អញ្ជើញក្រាំម្ជុលមើល។

ង លេបថ្នាំបារាំង - ចាប់ខ្យល់
បើលេបថ្នាំបារាំងមិនបាត់ អញ្ជើញ
ចាប់ខ្យល់មើល។

ច ពេទ្យមិនស្រួល - ទៅរកគ្រូខ្មែរ
បើពេទ្យមិនស្រួល អញ្ជើញទៅរកគ្រូ
ខ្មែរមើល។

DRILL TWELVE: Transformation

គំរូ

ក ខ្ញុំមិនហ៊ានឲ្យថ្នាំទេ។
(គ្រូ)

ខ តែគ្រូក៏មិនដឹងហ៊ានឲ្យថ្នាំ មិនហ៊ាន
ផង។

MODEL:

T: I didn't give any medicine.
(healer)

S: Even the healer doesn't know if he

dares give medicine or not.

ក គ្រូធំមិនហ៊ានបណ្ដេញខ្មោចទេ។
(គ្រូ)
តែគ្រូហ្នឹងដឹងហ៊ានបណ្ដេញខ្មោច មិនហ៊ានផង។

ខ ខ្មោចហ្នឹងមិនកាចទេ។
([illegible])
តែ[illegible]ហ្នឹងដឹងហ៊ានកាច មិនហ៊ានផង។

គ គាត់មិនធ្វើឲ្យទេ។
(លោកតា)
តែលោកតាហ្នឹង ដឹងហ៊ានធ្វើឲ្យ មិនហ៊ានផង។

ឃ គេមិនចាក់ថ្នាំទេ។
(គ្រូពេទ្យ)
តែគ្រូពេទ្យហ្នឹង ដឹងហ៊ានចាក់ថ្នាំ មិនហ៊ានផង។

ង ខ្ញុំមិនតាំងការទេ។
(លោក)
តែលោកហ្នឹង ដឹងហ៊ានតាំង មិនហ៊ានផង។

ច ខ្ញុំមិនទៅនឹកខ្មោចនោះទេ។
([illegible])
តែ[illegible]ហ្នឹង ដឹងហ៊ានទៅនឹកខ្មោចនោះ មិនហ៊ានផង។

DRILL THIRTEEN: Substitution

គំរូ

ក ខ្មោចខាងខ្សែហ្នឹង ដូចមិនប្រកាន់ដល់ហ្នឹង។
(មនុស្ស - ស្រុក)

ខ មនុស្សខាងស្រុកហ្នឹង ដូចមិនប្រកាន់ដល់ហ្នឹង។

MODEL:

T: The spirits of that line aren't that that hard to please.
(people, district)

S: The people of that district aren't that hard to please.

មនុស្សខាងស្រុកហ្នឹង ដូចមិនប្រកាន់ដល់ហ្នឹង។

ក ពួក - ភ្នំ
ពួកខាងភ្នំហ្នឹងដូចមិនប្រកាន់ដល់ហ្នឹង។

ខ ស្រីៗ - ភ្នំ
ស្រីៗខាងភ្នំហ្នឹង ដូចមិនប្រកាន់ដល់ហ្នឹង។

គ អ្នកមាន - ស្រុក
អ្នកមានខាងស្រុកហ្នឹង ដូចមិនប្រកាន់ដល់ហ្នឹង។

ឃ ពួក - ភូមិ
ពួកខាងភូមិហ្នឹងដូចមិនប្រកាន់ដល់ហ្នឹង។

ង អ្នក - គ្រួសារ
អ្នកខាងគ្រួសារហ្នឹងដូចមិនប្រកាន់ដល់ហ្នឹង។

ច ខ្មោច - ខ្សែ
ខ្មោចខាងខ្សែហ្នឹងដូចមិនប្រកាន់ដល់ហ្នឹង។

DRILL FOURTEEN: Substitution

គំរូ

ក ខ្សែហ្នឹងកាចណាស់ ស្រួលមិនស្រួលកាប់ ទាំងស្រស់ៗហ្នឹង។
(ខ្សែ - យក)

ខ ខ្សែហ្នឹងកាចណាស់ ស្រួលមិនស្រួលយក ទាំងស្រស់ៗហ្នឹង។

MODEL:

T: That line is really fierce. They'll easily kill in cold blood.
(line - take (someone away))

S: That line is really fierce. They'll easily take (someone away) in cold blood.

ខ្សែហ្នឹងកាចណាស់ ស្រួលមិនស្រួលយក ទាំងស្រស់ៗហ្នឹង។

ក ស្រី - ជេរ
ស្រីហ្នឹងកាចណាស់ ស្រួលមិនស្រួលជេរ ទាំងស្រស់ៗហ្នឹង។

ខ ឆ្កែ - ខាំ

[illegible]
[illegible]

គ [illegible]
[illegible]
[illegible]

ឃ [illegible]
[illegible]

[illegible]

ង [illegible]
[illegible]
[illegible]

ច [illegible]
[illegible]
[illegible]

READING PASSAGE 4

ហាងថ្នាំ សួន - ជិន

ស្ត្រីបុត្រ ថ្នាំរក្សាគភ៌

ថ្នាំនេះសម្រាប់ស្ត្រីមានផ្ទៃពោះធំក ៗ ដើម្បីការពារបានច្រើនយ៉ាង ៗ ស្ត្រីចាញ់ផ្ទៃ បណ្ដាលឲ្យរមួលចង្កោរទទួលទានបាយពុំបានក្អួតអស់ពីពោះ ៗ ស្លាបមាត់អស់កម្លាំង ដេកមិនលក់ ចុកដៃជើង ឬមួយវិលមុខ ងើបពុំរួច ដើរពុំបាន ៗ ហើយភាំងខ្លួន ដេកមិនចង់ងើប បើបានពិសាថ្នាំនេះ ជាមិនខានល់ខែនឹងបានសេចក្ដីសុខដល់ម្ដាយនិងកូន លុះដល់ពេលសំរាលកូនមិនឈឺពោះខ្លាំងទេ គឺឈឺបន្តិចៗ សំរាលរួចក្លាយ ៗ ប៉ុន្តែបើមានផ្ទៃពោះ ៦ ខែហើយត្រូវឈប់ធ្វើសេវនកិច្ចរហូតដល់កើត សំរាលមកហើយគ្មានជម្ងឺដល់កូនផង ៗ

វិធីប្រើៈ ថ្នាំ ១ ស្លាបព្រាសម្ល ទឹកក្ដៅ ១ ចានឬកែវពិសាទៅ ១ ថ្ងៃពីរបីពេល ៗ

(នៅមុខសាលារៀនវត្តមហាមន្ត្រី ផ្ទះលេខ ៤១៩ ឃុំលេខ ៥.ភ្នំពេញ)

VOCABULARY

* [illegible]	many, a lot
កម្រិត	limit
* ក្រិត	to mark
កាប់	to kill
កាលណាបើ = បើ	if
កើតរោគ	to have an illness, come down with an illness
រោគ	disease
ក្រាម	gram (measurement) (French. gramme)
តុកៗ	throbbing pain, pounding pain
ខ្មែរយើង	we Khmer
ចាប់បូល	to be possessed by a spirit
ខ្លាំងក្លា (ក្លាង)	strong, powerfull
ខ្សែ	line, string
គភ៌ kɔ́ɔ,kɔɔ/embryo	
គុណសម្បត្តិ	quality, value
សម្បត្តិ sambat/	property, asset
គ្រូ	healer, practitioner of folk medicine
ឡើង	to rise
ចង្អោរ	to dry-vomit
ចាញ់កូន	to have nausea from pregnancy
ចាប់ខ្យល់	to pinch the skin repeatedly at a single place to relieve pain elsewhere (e.g., headache)
ចុក	to have a sharp pain
ចុកចាប់	to be painful
ចុះ	to have diarrhea
ចូល	to go into a trance (of a medium), to enter, possess (e.g., spirit)
ចេះតែ	always; only know how to; to keep + verb

ចំណុច	a point
* ចុច	to push with one finger, e.g., to to push a button
ជាតិ	flavor, essence, element, trace
ជានិច្ច(ជា)កាល	always, constantly
ជាអនេក /cia ʔaneek/	very much, extremely
ជាតិទឹក	water substance
ជាតិពុល	a poisonous substance
ពុល	to be poisonous; poison
* ជាតិអំបិល	salt substance
ជួរ	row, column, line, family line
ជេរ	to curse, insult
ជំពូក	category
ដ៏	very (literary); introduces an adjective clause
តម្រងនោម	kidney
តម្រង (= ត្រង)	strainer
នោម	urine; to urinate
* ណុង	that (colloquial)
តាមចិត្ត	as one wishes, according to desire
ទាំង + noun + ហ្នឹង	even that + noun
ត្រង់នេះ	here, at this point
ត្រាំ	to soak, to pickle
ត្រូវ	to be affected, to have
ត្រូវមិនត្រូវ	easily (indicates warning)
ថ្ងៃអន្សា (= -អន្សារ)	the day on which death is believed to usually occur (that day is one's birthday)
ថ្វាយ	to give (to a god, king, spirit)
ទន់	soft

ចប	to stop, terminate, [illegible]
ទៅនិមន្ត(និមន្ត)	[illegible]
ទៅចាំ	to wait for
តាំងពីព្រេង	In olden times
និមន្ត nimɔn	to invite a Buddhist monk
បញ្ចូល	to consult a medium
ប៉ុណ្ណេះ	this much
ប៉ុណ្ណោះ	that much
បាត់បង់ជីវិត	to lose one's life, to die
បាត់សេចក្ដីចាំ	to faint
ប្រកាន់	to be hard to please, to be prejudiced, to mind, to take offense
ប្រសិនបើ	if
ប្លែក	strange, odd
ពូជ	lineage, descent, seed, breed
មានផ្ទៃពោះ	pregnant
ម្ដេច = ម៉េច	how
ម្ដុំ	region, area, vicinity
ម៉្លឹង	like that
រមួល	the stomach churns
រមួល	twisted, intertwined
រមួលក្រពើ	cramp, especially in the legs
ក្រពើ	crocodile
រសាប់រសល់	restless, uncomfortable
រាក	to have diarrhea
រឹត. រឹត(=ការ[illegible])	to [illegible]
រូបកាយ	body
កាយ	body
រូបអារក្ស rup ʔarèʔ	spirit medium
រៀប	to prepare (in accordance with spirit's orders), to meet a spirit's demands
លើស	to exceed, surpass, pass
[illegible]	[illegible]
[illegible]	[illegible]
[illegible]	[illegible]
[illegible]	[illegible]
[illegible]	[illegible]
សព្វមុខ	of every sort
* [illegible]	language, [illegible] language/ [illegible] (literally)
សាបមាត់	mouth tastes [illegible]
សុខភាព	health
សេរ៉ូម	serum
[illegible]	[illegible]
* [illegible]	[illegible] (H) [illegible]
សំរាលកូន	to deliver a child
សះស្បើយ	to be healing, well
សះ	healed
ស្បើយ	[illegible]
ស្គមស្គាំង	skinny, thin
ស្គម	skinny, [illegible]
* [illegible]	woman (in general) (literally: female-[illegible])
ស្រេកទឹក	thirsty
ស្រោចទឹក	to sprinkle, water
ស្លាបព្រាកាហ្វេ	teaspoon
ស្លាបព្រាសម្ល	tablespoon
សោះ	... at all (used [illegible] with a negative phrase)
អន់	to get a little better; [illegible], less, less
អន្ទះអន្ទែង	to show signs of [illegible] pain or discomfort, to the point of discomfort
អញ្ចាញ(=អញ្ចឹង)	[illegible]
អាម៉េច	[illegible], what's it like
អារក្ស	a kind of guardian spirit
អឺប	uhh (indicates hesitation)

ឧបមា	/ɔpəmaa, ɔpəmaa suppose that ...	អ្នកតា	guardian spirit, a patriarch

APPLICATIONS

1. Define the following words.

គាថា
បញ្ញាស្ត្រ
សាបជំ
មើលជម្ងឺ
ខ្មោចយក
ជម្ងឺរាក
ស្រេះស្រោះ
មើលខ្លួន
អ្នកតា
ជាសះស្បើយ
ស្រុះស្រឹង
គេងពេទ្យ
ខ្មោចចូល
ចុក
បាក់បង់ជីវិត

2. Find the word(s) that fit(s) each of the following definitions.

Example: ការរស់នៅ

Answer: ជីវិត

១ របស់មួយពណ៌សដូចសរដែលប្រើនៅក្បាយ ។
២ ជម្ងឺមួយដែលធ្វើឲ្យមិនស្រួលខ្លួន មកពីខ្វះជាតិអំបិល និងទឹក ។
៣ នៅក្នុងខ្លួនយើងមានសាចប្យាំងដែលធ្វើឲ្យយើងខ្លាំង ។
៤ សេចក្ដីក្រ និងលំបាក ។
៥ ជម្ងឺមួយដែលធ្វើឲ្យក្អកឈងចុះឈង អាចបណ្ដាលឲ្យស្លាប់ ។
៦ មើលជម្ងឺ ។
៧ ទៅនៅក្នុងពេទ្យដើម្បីមើលខ្លួន ។
៨ អ្នកដើរមើលជម្ងឺដេញខ្មោច ។
៩ ខ្មោចសម្លាប់មនុស្ស ។
១០ ថ្ងៃដែលត្រូវស្លាប់ ។

3. The students should complete the following sentences using his own answers.

១ ស្ថានការណ៍នៅស្រុកខ្មែរ ឲ្យឃើញថា...
២ ទាងគការរៀប ទាំនេះស ឲ្យឃើញថា...
៣ ពុកម្ដាយដែលឲ្យកូនធ្វើតាមចិត្ត ស ឲ្យឃើញថា...
៤ ទាឆាប់ភ័យណាស់ ត្រូវមិនត្រូវថា...
៥ ...ដោយសារគាត់មានផ្ទៃពោះ ។
៦ ...ចេះតែបណ្ដាលឲ្យវិលមុខ ។
៧ ...ព្រោះជាទម្លាប់មនុស្សចាស់ហ្នឹង ។

4. Fill in the blanks using the following words:

ច្រើនតែ កាន់តែ ទើបតែ ចេះតែ មុខតែ មានតែ
តែងតែ គ្រាន់តែ បានតែ

១ ខ្ញុំខឹងនឹងវាព្រោះវា ...បង្ខំសុំលុយខ្ញុំ ។
២ បើយើងមិនប្រាប់គេមុន ថ្ងៃស្អែក...គេភ្លេច ។
៣ នាង...ក្រោកពីព្រឹកជានិច្ច ។
៤ បើយើងមិនជួយប្រដៅខ្លះទេ នោះ...គេធ្វើខុសច្រើនទៀត ។
៥ គាត់បាននិយាយថាគឺ...គាត់ឃ្លាតទៅក្នុងពេលនេះ ។
៦ មនុស្សយើង កើត ចាស់ ឈឺ ស្លាប់ជាធម្មតា ។
៧ បើគាត់ ... ថាប៉ុណ្ណឹង តើខឹងនឹងគាត់ធ្វើអី ?
៨ គាត់.. ថា តែមិនដែលធ្វើម្ដងណាទេ ។
៩ ដើម្បីឲ្យបានជោគជ័យ គឺ... ប្រើបញ្ញាបាយតែមួយប៉ុណ្ណោះ ។
១០ មិនដឹងជាយ៉ាងម៉េច ...ពួកម៉ាក់ស្រីខ្ញុំ...ខឹងនឹងខ្ញុំរាល់យប់ ។

5. Translate the following into Cambodian. If necessary, refer to the note for Dialogue sentence 7.

a. You can have whatever you want.
b. Anywhere I go, he goes too.
c. It seems as if every time I call he's gone out.
d. I'll do it however you tell me to.
e. Everything he asked for, he got.

6. Correct the following sentences by adding the proper words.

១ យើងសូមបញ្ជាក់រូបកាយមនុស្សយើងត្រូវការជាតិអំបិល ។
២ ជំងឺនោះវាធ្វើអន្ទះអន្ទែង ។
៣ ជំងឺអាសន្នរោគបណ្ដាល ចុះនិងក្អួត ។
៤ អំបិលមាន មិនដូចស្ករ ។
៥ ជំងឺចុះនិងក្អួតនឹងគេហៅជំងឺអាសន្នរោគ ។
៦ កុំស៊ីអីច្រើន គ្រាន់ដាក់ជាតិទឹកអំបិលចូលបានហើយ ។
៧ គេកុំបាច់ចាំតាំងប្រើថ្នាំអីផងដែរ ។
៨ ខ្មោចចូលហើយចូល ។
៩ វាមិនគាចដល់ទេ ។
១០ យើងមិនបាច់មើលជំងឺហ្នឹងទេ តែត្រូវពេទ្យហ្នឹងមើលមិនជា ។

7. Have the student discuss the following situations.

១ ជឿខ្មោច
២ ជំងឺសំខាន់ៗនៅស្រុកអាមេរិក

៣. [illegible]
៤. [illegible]
៥. [illegible]

8. Questions for the teacher to ask.

១ [illegible] ?
២ [illegible] ?
៣ [illegible] ?
៤ [illegible] ?
៥ [illegible] ?
៦ [illegible] ?
៧ [illegible] ?
៨ [illegible] ?
៩ [illegible] ?
១០ [illegible] ? ហេតុអី ?

9. Questions for the student to ask.

a. Ask the teacher to describe the ceremony of sprinkling water.
b. Who makes the water used for sprinkling? On what other occasions is water sprinkled?
c. Get a description of a medium.
d. Is there more than one kind of medium?
e. What are the usual offerings?
f. At [illegible] ceremony is a medium necessary?
g. Is there a special type of language or certain prayers or the like used at these ceremonies?
h. How does someone become a medium? Is there special training? An apprenticeship? Are there special qualifications?
i. If someone is ill, what is the first action a traditional family takes? Are city and country different?
j. If the first action has no effect, what will the family or ill person do next?
k. What kinds of illness are Chinese medicines preferred for?
l. Are Chinese medical practitioners often consulted?
m. What are the main methods of the Khmer healers?
n. Is a prescription necessary to buy Western medicines? How are Chinese or traditional medicines obtained?
o. Is Western medicine considered more effective than traditional practises?

LESSON FIVE

HEALTH SERVICES FOR RICH AND POOR

a. Is medical treatment available to the very poor?
b. What type of training does a midwife receive?
c. Will medical personnel all work for the government?
d. Do Western-trained practitioners cooperate with mediums and healers?

អំពីរបៀបថែទាំទារក

ចាប់តាំងពីថ្ងៃកំណើតមកទល់នឹងថ្ងៃទី ៨ ឬ ១០ ជារយៈពេលដែលគួរឲ្យយើងមានការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការរស់នៅរបស់ទារក ព្រោះថា ក្នុងពេលសម្រាល ទារកបានទទួលនូវទុក្ខវេទនាយ៉ាងខ្លាំងហើយ ប្រសិនបើទារកនោះខ្សោយ ពុំសូវមានកម្លាំងពលំផង អាចនឹងបាត់បង់ជីវិត ។ ដូច្នេះ នៅក្នុងរយៈពេលនេះ ទារកត្រូវមានការថែទាំយ៉ាងម៉ត់ចត់ជាទីបំផុត ។

តាមគោលការ នៅតាមប្រទេសនានា កាលបើកើតមកបានចំនួន ៤៨ ម៉ោង ហើយ ទារកនោះត្រូវមានការពិនិត្យពីគ្រូពេទ្យជំនាញការខាងកូនក្មេង គឺពិនិត្យមើលនូវផ្នែកដែលមានទាក់ទងនឹងការដកដង្ហើម, នូវផ្នែកឈាមរត់ និងពិនិត្យមើលនូវកម្លាំងឈាមរត់ក្នុងដង្ហើមធំ ។ល។ កាលបើបានពិនិត្យមើលសព្វគ្រប់ហើយ ពុំឃើញមានឧបសគ្គអ្វីមកជ្រៀតជ្រែកនូវសុខភាពនៃកូនខ្ចីទេ គ្រូពេទ្យនោះលោកនឹងឲ្យជំបូន្មានជាចំណុចសំខាន់ៗ តាមក្បួនអនាម័យចំពោះមាតាបិតា ឬអ្នកថែទាំទារក មានការពន្យល់លើកទឹកចិត្តម្ដាយឲ្យមានចិត្តស្រឡាញ់ នូវការបំបៅកូនដោយទឹកដោះម្ដាយ និងពន្យល់ឲ្យស្គាល់នូវគុណប្រយោជន៍នៃការថែរក្សាទារកត្រឹមត្រូវ ហើយនិងឲ្យមានសេចក្ដីក្លាហាននូវ ក្នុងការពុះពារនូវឧបសគ្គតិចតួច ព្រមទាំងនិយាយពន្យល់បន្ថែមទៀតឲ្យម្ដាយចៀសវាងគ្រូព្យាបាលផ្សេងៗ ដើម្បីកុំឲ្យមានការរំខាន ដល់ទារកពីសំណាក់នៃអ្នកជិតខាង ។

«នៅប្រទេសកម្ពុជាយើង ការឲ្យជំបូន្មានចំពោះមាតាបិតា ឬចំពោះអ្នកថែទាំទារក យើងមានធ្វើនៅតាមមន្ទីរពេទ្យ, នៅតាមមណ្ឌលសុខភាព, នៅតាមឱសថាល័យមាតា ដែលមានមន្ទីរពិគ្រោះស្ត្រីមានផ្ទៃពោះ និងក្រោយមានផ្ទៃពោះ ហើយនិងនៅក្នុងតំបន់ណាដែលមានឆ្មបជនបទ» ។

NOTES FOR READING PASSAGE 1

Line 7. The word ពលំ /púlléŋ/ 'strength' is spelled according to Pali convention. In this spelling the vowel ◌ំ is read /ɑŋ/ following a first series consonant and /eŋ/ following a second series consonant. This type of spelling irregularity is very rare in ordinary Cambodian prose.

Line 19. The word [illegible] here means 'he' and refers to គ្រូពេទ្យ 'the doctor.' You should not translate it.

Line 19. The sentence that begins here and ends at line 28 is not as difficult as it looks. The main clause begins at line 19 with គ្រូពេទ្យ and ends with អ្នកថែទាំទារក 'the one who takes care of the baby.' What follows is all appositive to the word ដំបូន្មាន 'advice.' In other words, this sentence would read: គ្រូពេទ្យនឹងឲ្យដំបូន្មាន...ចំពោះ...អ្នកថែទាំទារកគឺមានការពន្យល់ etc. 'The doctor will give advice to whoever cares for the baby; that is to say, there is an explanation of ....' The long appositive has four parallel parts. The first begins at line 21 with ការលើកទឹកចិត្ត, the second is at line 23 following និង 'and' and beginning with ការរក្សាឲ្យស្អាត. The third follows ហើយនិង 'and' at line 25, begins ឲ្យបាន..., and is parallel with ឲ្យស្អាត ... in the preceding clause. The last follows ព្រមទាំង 'together with' at line 27 and begins និយាយពីការ....

Line 26. ដើម្បីកុំឲ្យ... means 'so that ... won't ...,e.g., ដើម្បីកុំឲ្យយើងខាតប្រាក់ 'so we won't lose money.'

DIALOGUE

កូនអ្នកមាននិងអ្នកធំស្អាតល្អ

១ មី	ធម្មតាគេឃើញកូនអ្នកធំនិង អ្នកមានភាគច្រើន ច្រើនតែ ស្អាតៗល្អណាស់។	Usually most of the children of important, wealthy people are very good looking.
	តែមាន	whenever
	ទឹកលុយ	money
	បុណ្យស័ក្តិ	rank and status
២ ថោង	ហេតុអី? ដឹងទេ? ព្រោះ តែមានទឹកលុយឬបុណ្យស័ក្តិ ហើយ សប្បាយ...	Do you know why? Because when one has money or status one's happy....
	មានតែ	the only way is
	ស្រស់	fresh, pretty
៣ មី	អញ្ចឹងមានតែសប្បាយហ្នឹងធ្វើ ឲ្យមនុស្សទៅជាស្រស់ល្អអញ្ចឹង។	Then it means that such happiness will make people attractive?
	ម្យ៉ាង	in a way
	អញ	I, me (familiar)
	ចង់ថា	to mean
	នៅត្រង់	to depend; just, specifically
	មានស៊ីមានចុក	to eat (familiar)
	ចុក	— to stuff, to stop up
៤ ថោង	ថាយ៉ាងហ្នឹងក៏ត្រូវម្យ៉ាង តែ អញចង់ថាគឺ នៅត្រង់មាន ស៊ីមានចុកគ្រប់គ្រាន់នោះទេ។	You could say that, but what I meant was it depends on having enough to eat (that'll do it).
	ឮៗមក	to be heard, rumored
	ម្នុះ = មនុស្ស	human being, person
	ពូជ	lineage, descent, seed, breed
៥ មី	បើតាមឮៗមក ម្នុះស្អាតល្អ នោះមានតាមពូជទេ។	From what I've heard, people inherit their attractiveness.
	ដុះ	to grow
	សាច់	flesh, skin

	ឡើងឈាម	to have good color (not pale); to have high blood pressure
	សម្រស់ (< ស្រស់)	prettiness, charm
	ទាំងគ្រប់ទាំងសព្វ	of every kind, all
	ហ្នឹង	(see note)
៦ ចោង	ត្រូវហើយ តែម្ហូបជួយឲ្យ ដុំសាច់ឡើងឈាមមានសម្រស់ ទាំងគ្រប់ទាំងសព្វហ្នឹង ។	That's true, but (proper) food helps muscles and skin and helps people look better in every way.
	មានតែមាន	there is but
៧ មី	បើនិយាយអញ្ចឹង មានតែមាន តែម្ហូបថ្លៃទេដែលធ្វើឲ្យស្អាត ល្អនោះ ។	If you put it that way, it's only expensive food that makes us look good.
៨ ចោង	ទេ តែអ្នកដែលគេមានលុយ ដូចអស់លោកនិងអ្នកមានទាំង នោះជាដើម គេមានស៊ីមាន ចុកសព្វប៉ុនជាង ។	No, but people who have money like all those rich people for instance, they eat better in every way than (ordinary).
៩ មី	អញ្ចឹងស្អីខ្លះទៅដែលធ្វើឲ្យ មានសាច់មានឈាមនោះ ?	Then what is it that gives us healthy bodies and good color?
	រាប់មិនអស់	countless
	ចំបំផុត	especially
	អីៗ	and the like, etc.
១០ ចោង	រាប់មិនអស់ទេ តែចំបំផុត យើងត្រូវការត្រី សាច់ បន្លែ និងផ្លែឈើអីៗហ្នឹង ។	Countless things, but we especially need fish, meat, vegetables, fruit and the like.

NOTES FOR THE DIALOGUE

Sentence No. 3 Note that សប្បាយ 'to be happy, to have fun' is nominalized by ហ្នឹង , so that សប្បាយហ្នឹង means 'happiness, fun.'

Sentence No. 4 Note the use of ឯង , which you have previously learned means 'you', to mean 'I, me.' Its style level is approximately midway between ខ្ញុំ , which is ordinary or formal, and អញ , which is intimate. ឯង (= ខ្ញុំ) is used between members of the same sex who are on familiar terms and between members of the opposite sex who are on intimate terms. គ្នា is also used familiarly as a first-person pronoun, and ឯង 'you' is also familiar. This last is far more common in Phnom Penh than in the provinces. The translations for English pronouns that you have learned so far, arranged by style levels, are

0%	intimate	familiar	ordinary	formal 100%
first person:	អញ	ឯង	ខ្ញុំ	ខ្ញុំ
2nd person :	អាឯង (ហ្អែង)	kinship term, name + ឯង	លោក, លោកស្រី, នាង, អ្នកស្រី,	លោក, លោក ស្រី, អ្នកស្រី
3rd person :	វា	គេ , name	គេ, គាត់	គាត់, លោក

Sentence No. 6 In this sentence ហ្នឹង means 'as we have been discussing.' The topic of the conversation so far has been the manifestations of good health, so that ហ្នឹង here marks their enumeration as a review of what has come before. Whether noun or verb, whatever is marked in this way is definite; that is, it is familiar to both participants in a conversation.

Sentence No. 9 The word ទៀត in a question like this carries the connotation 'after all that came before, what more?' Another example: a worker who has been making repeated attempts to complete a task, none of them satisfactory, might say in exasperation:

ធ្វើម៉េចទៀត ទើបបានល្អ ?...

What more should I do to make it right?

DRILLS

DRILL ONE: Substitution

គំរូ

ក អ្នកមានភាគច្រើន ច្រើនតែស្អាតៗ ល្អណាស់ ។

(កូនអ្នកធំ)

ខ កូនអ្នកធំភាគច្រើន ច្រើនតែស្អាតៗល្អណាស់ ។

MODEL:

T: Usually the wealthy are very good looking.

(children of important people)

S: Usually the children of important people are very good looking.

កូនអ្នកធំភាគច្រើន ច្រើនតែស្អាតៗ ល្អណាស់ ។

ក. មានសុខភាពល្អ

កូនអ្នកធំភាគច្រើន ច្រើនតែមានសុខភាពល្អណាស់ ។

ខ. ខ្ជិលធ្វើការ

កូនអ្នកធំភាគច្រើន ច្រើនតែខ្ជិលធ្វើការណាស់។

ក ដេកច្រើន
កូនអ្នកធំភាគច្រើន ច្រើនតែដេកច្រើនណាស់។

ខ មនុស្សធាត់
មនុស្សធាត់ភាគច្រើន ច្រើនតែដេកច្រើនណាស់។

គ អ្នកក្រ
អ្នកក្រភាគច្រើន ច្រើនតែដេកច្រើនណាស់។

ឃ កូនក្មេង
កូនក្មេងភាគច្រើន ច្រើនតែដេកច្រើនណាស់។

ង មានកូនប្រុសច្រើន។
(ពិបាកចិត្តច្រើន)
៥ ជ័យ អញហ៊ានភ្នាល់ កាលណាសិនកុំតែស្តេចខ្មែរស្លាប់ដោយជម្ងឺ កុំអីមិនចាញ់ទេ។	I'll bet that if it weren't for the fact that the Khmer king died of illness, we wouldn't have lost.
ប្រហែលៗគ្នា	very similar
ដោយសារ	because of
មេទ័ព	commander
៦ ហ៊ាន កម្លាំងទ័ពក៏ប្រហែលៗគ្នា។ ម្យ៉ាងទៀតដោយសារតែមេទ័ពធំម្នាក់ស្លាប់ក្នុងចម្បាំងទៀត។	The military strength of the two sides was very similar, and furthermore an important commander died in battle.
នាំគ្នា	to do as a group
ជាប់ + time word	for + time word
៧ ជ័យ គេនាំគ្នាច្បាំងជាប់ឆ្នាំ តពីក្សត្រមួយទៅក្សត្រមួយ។	They fought together for years, from one king's reign to another.
សុខសាន្ត	peaceful, quiet
៨ ហ៊ាន តាមខ្ញុំស្មាន មកដល់ចុងសតវត្សទី១៥ ទើបបានសុខសាន្ត ដូចក៏រើកសាងរាជធានីឡើងវិញ។	I think it wasn't until the end of the 15th century that peace was achieved, and they rebuilt the capital.
ដូច	it seems
រជ្ជកាល	period of reign
៩ ជ័យ ដូចក្នុងរជ្ជកាលព្រះពញាយ៉ាតទេះ?	Wasn't it in the reign of King Ponhe Yat?
១០ ហ៊ាន កាលណុងយើងបានសុខសាន្ត តែដូចត្រូវរត់ចេញម្តងទៀត។	At that time it was peaceful, but it seems that we had to flee once more.

DRILLS

DRILL ONE: Substitution (variable)

គ្រូ

ក ក្សត្រអង្គណា លើករាជធានី ចេញពីមហានគរលើកទីមួយ?
(រត់ចេញពី)

ខ ក្សត្រអង្គណារត់ចេញពីមហានគរលើកទីមួយ?

MODEL:

T: Which moved the capital away from Angkor the first time?
(Fled from)

S: Which king fled from Angkor the first time?

ក្សត្រអង្គណារត់ចេញពីមហានគរលើកទីមួយ?

ក យាងមកពី
ក្សត្រអង្គណាយាងមកពីមហានគរលើកទីមួយ?

ខ ក្រោយគេបង្អស់
ក្សត្រអង្គណាយាងមកពីមហានគរក្រោយគេបង្អស់?

គ យាងចូល
ក្សត្រអង្គណាយាងចូលមហានគរក្រោយគេបង្អស់?

ឃ មុនគេបង្អស់
ក្សត្រអង្គណាយាងចូលមហានគរមុនគេបង្អស់?

ង យាងចេញពី
ក្សត្រអង្គណាយាងចេញពីមហានគរមុនគេបង្អស់?

ច ចុងក្រោយបង្អស់
ក្សត្រអង្គណាយាងចេញពីមហានគរចុងក្រោយបង្អស់?

DRILL TWO: Response

គ្រូ

ក ជំនាន់មុននោះ ខ្មែរមិនទាន់បានសប្បាយឲ្យអស់ចិត្តទេ។
(សម័យអង្គរ)

ខ កុំថាតែជំនាន់នោះ សម័យអង្គរមិនទាន់បានសប្បាយឲ្យអស់ចិត្តផងទេ។

MODEL:

T: In early generations, the Khmer hadn't really had the opportunity to enjoy life yet.
(Angkor period)

S: Not only in those generations, but in the Angkor period they didn't have the opportunity to enjoy life either.

ក កាលពីមុន យើងមិនទាន់ចេះស្លៀកពាក់ទេ។
(ជំនាន់ចេនឡា)
កុំថាតែកាលនោះ ជំនាន់ចេនឡា មិនទាន់ចេះស្លៀកពាក់ផងទេ។

ខ ពេលហ្នឹង ស្ដេចអង្គៗមិនទាន់បានពង្រីកនគរទេ។
(ដល់ក្រោយមក)
កុំថាតែពេលនោះ ដល់ក្រោយមក ក៏មិនទាន់បានពង្រីកនគរផងទេ។

គ ជំនាន់មុននោះ ខ្មែរមិនទាន់បានចុះចៀនទេ។
(ឥឡូវនេះ)
កុំថាតែជំនាន់នោះ ឥឡូវនេះមិនទាន់បានចុះចៀនផងទេ។

ឃ សម័យនោះ ស្ដេចមិនទាន់បានកសាងអ្វីទេ។
(សម័យក្រោយនោះ)
កុំថាតែសម័យនោះ សម័យក្រោយនោះមិនទាន់បានកសាងអ្វីផងទេ។

ង គាត់នោះ [illegible]មិនចង់បាន
ខ្មែរទេ។
(ប្អូនស្រីខ្ញុំ [illegible]
ក៏ដូចគាត់នោះ ប្អូនស្រីខ្ញុំ
[illegible]មិនចង់បានខ្មែរដែរ។
ច [illegible]នោះ [illegible]
មួយទេ។
([illegible])
ក៏ដូច[illegible]នោះ [illegible]
[illegible]
មួយដែរ។

DRILL THREE: Substitution

គំរូ
ក ច្បាំងដល់ណាដល់ណី ហើយយើង
តាំងឈ្នះម្តងទៅហើយ។
(ប្រកែកគ្នា - វាយគ្នា)
ខ ប្រកែកគ្នាដល់ណាដល់ណី ហើយ
យើងតាំងវាយគ្នាម្តងទៅហើយ។

MODEL:

T: We fought for a long time, and we even won once.
(argued - hit each other)

S: We argued for a long time, and we even hit each other once.

ប្រកែកគ្នាដល់ណាដល់ណី ហើយ
យើងតាំងវាយគ្នាម្តងទៅហើយ។
ក និយាយគ្នា - [illegible]
និយាយគ្នាដល់ណាដល់ណី ហើយ
យើងតាំង[illegible]ម្តងទៅហើយ។
ខ [illegible] - ឲ្យលុយ
[illegible]ដល់ណាដល់ណី ហើយយើង
តាំងឲ្យលុយម្តងទៅហើយ។
គ ស្ទូច - ចាប់បាន
ស្ទូចដល់ណាដល់ណី ហើយយើង
តាំងចាប់បានម្តងទៅហើយ។

ឃ វាយលុក - យកបានខេត្តមួយ
វាយលុកដល់ណាដល់ណី ហើយយើង
តាំងយកបានខេត្តមួយម្តងទៅហើយ។
ង ផឹក - [illegible]
ផឹកដល់ណាដល់ណី ហើយយើងតាំង
[illegible]ម្តងទៅហើយ។
ច ស្តាប - សរសេរ
ស្តាបដល់ណាដល់ណី ហើយយើង
តាំងសរសេរម្តងទៅហើយ។

DRILL FOUR: Response

គំរូ
ក ហ្នឹងហើយ ច្បាំងគ្នាដល់ណាដល់ណី
ទៅហើយ។
(ឈ្នះ)
ខ ហ្នឹងហើយ ច្បាំងគ្នាដល់តាំងឈ្នះម្តង
ទៅហើយ។

MODEL:

T: Right, they fought for a long time.
(to win)

S: Right, they fought and even won once.

ក ហ្នឹងហើយ វាយគ្នាដល់ណាដល់ណី
ទៅហើយ។
(ចាញ់គេ)
ហ្នឹងហើយ វាយគ្នាដល់តាំងចាញ់គេ
ម្តងទៅហើយ។
ខ ហ្នឹងហើយ នាំគ្នា[illegible]ដល់ណាដល់ណី
ទៅហើយ។
([illegible])
ហ្នឹងហើយ នាំគ្នា[illegible]ដល់តាំង[illegible]
ម្តងទៅហើយ។
គ ហ្នឹងហើយ នាំគ្នា[illegible]ដល់ណាដល់
ណីទៅហើយ។
([illegible]ដល់[illegible])

ហ្នឹងហើយ នាំគ្នាដើរចេញដល់
ទាំងជិតដល់ភូមិថ្មីម្ដងទៅហើយ។

ឃ ហ្នឹងហើយ សម្លាប់គ្នាដល់ណាដល់
ណឹងទៅហើយ។
(ជិតអស់មនុស្ស)
ហ្នឹងហើយ សម្លាប់គ្នាដល់ទាំងជិត
អស់មនុស្សម្ដងទៅហើយ។

ង ហ្នឹងហើយ ស្រឡាញ់គ្នាដល់ណា
ដល់ណឹងទៅហើយ។
(ជិតបានកូនមួយ)
ហ្នឹងហើយ ស្រឡាញ់គ្នាដល់ទាំង
ជិតបានកូនមួយម្ដងទៅហើយ។

ច ហ្នឹងហើយ នាំគ្នាដើរលេងដល់ណា
ដល់ណឹងទៅហើយ។
(ដេកជាមួយគ្នា)
ហ្នឹងហើយ នាំគ្នាដើរលេងដល់
ទាំងដេកជាមួយគ្នាម្ដងទៅហើយ។

DRILL FIVE: Transformation

Note: Do this drill once using the pattern of student response 1. Then do it again using the pattern of student response 2.

គំរូ

ក ស្ដេចខ្មែរស្លាប់ដោយសារជំងឺ បាន
ជាចាញ់។

ខ១ កុំតែស្ដេចខ្មែរស្លាប់ដោយសារជំងឺ
កុំអីមិនចាញ់ទេ។

or

ខ២ កុំអីមិនចាញ់ទេ កុំតែស្ដេចខ្មែរ
ស្លាប់ដោយសារជំងឺ។

MODEL:

T: We lost because a Khmer king died of illness.

S1: If it weren't that a Khmer king King died of illness, we wouldn't have lost.

or S2: We wouldn't have lost if a Khmer king hadn't died of illness.

ក ខ្លាចមានចម្បាំងទៀត បានជាលើក
ទីក្រុង។
កុំតែខ្លាចមានចម្បាំងទៀត កុំអី
មិនលើកទីក្រុងទេ។

ខ នាម៉ឺនបែកឈ្លោះគ្នា បានជាគេយក
ដីអស់។
កុំតែនាម៉ឺនបែកឈ្លោះគ្នា កុំអីគេ
មិនយកដីអស់ទេ។

គ យើងត្រូវការគាត់ បានជាយើងជួយ
គាត់។
កុំតែយើងត្រូវការគាត់ កុំអីយើង
មិនជួយគាត់ទេ។

ឃ សត្រូវច្រើនពេក បានជាដកទ័ពថយ។
កុំតែសត្រូវច្រើនពេក កុំអីមិនដក
ទ័ពថយទេ។

ង គាត់ពូកែនិយាយ បានជាទៅជំនួស។
កុំតែគាត់ពូកែនិយាយ កុំអីមិន
ទៅជំនួសទេ។

ច ត្រូវការវា បានជាទិញ។
កុំតែត្រូវការវា កុំអីមិនទិញទេ។

DRILL SIX: Substitution (variable)

គំរូ

ក កងទ័ពយើងខ្លាំង ប្រហែលៗគ្នា។
(ប្រទេសទាំងពីរ)

ខ ប្រទេសទាំងពីរខ្លាំង ប្រហែលៗគ្នា។

MODEL:

T: Our forces were equally strong.
(both countries)

S: Both countries were equally strong.

ប្រទេសទាំងពីរខ្លាំង ប្រហែលៗគ្នា។

ក មានទ័ពសេះ
ប្រទេសទាំងពីរមានទ័ពសេះ ប្រហែលៗ
គ្នា។

ខ បញ្ញា
ប្រទេសទាំងពីរមានបញ្ញា ប្រហែលៗ
គ្នា។

ក ទាហានយើង
ទាហានយើងមានបញ្ញា ប្រហែលៗគ្នា។
ខ ធំ
ទាហានយើងធំ ប្រហែលៗគ្នា។
គ សាលាទាំងអស់
សាលាទាំងអស់ធំ ប្រហែលៗគ្នា។
ឃ បង្រៀនរបៀប
សាលាទាំងអស់បង្រៀនរបៀប
ប្រហែលៗគ្នា។

DRILL SEVEN: Transformation

គំរូ
ក យើងច្បាំងចាញ់គេ។
(មេទ័ពធំម្នាក់ស្លាប់)
ខ យើងច្បាំងចាញ់គេដោយសារមេទ័ពធំម្នាក់ស្លាប់។

MODEL:

T: We fought and lost.
(an important general died)
S: We fought and lost because an important general died.

ក លើកទីក្រុងចេញពីមហានគរ។
(ការច្បាំងចាញ់សៀម)
លើកទីក្រុងចេញពីមហានគរដោយសារការច្បាំងចាញ់សៀម។
ខ មិនដឹងក្សត្រអង្គណា។
(មិនបានរៀនប្រវត្តិសាស្ត្រខ្មែរ)
មិនដឹងក្សត្រអង្គណាដោយសារមិនបានរៀនប្រវត្តិសាស្ត្រខ្មែរ។
គ កាលនោះខ្មែរចាញ់។
(គេស្ទាក់ទ័ពមិនទាន់)
កាលនោះខ្មែរចាញ់ដោយសារគេស្ទាក់ទ័ពមិនទាន់។
ឃ គេជីកលេខក។
(ជាស្នាព្រះហស្តរបស់ស្តេចជំនាន់ដើម)
គេជីកលេខកដោយសារជាស្នាព្រះហស្តរបស់ស្តេចជំនាន់ដើម។

ង សម័យមហានគររុងរឿង។
(ស្នាព្រះហស្តល្អៗរបស់ស្តេច)
សម័យមហានគររុងរឿងដោយសារស្នាព្រះហស្តល្អៗរបស់ស្តេច។
ច ប្រទេសខ្មែរមានឈ្មោះល្បីល្បាញ។
(អង្គរវត្ត)
ប្រទេសខ្មែរមានឈ្មោះល្បីល្បាញដោយសារអង្គរវត្ត។

DRILL EIGHT: Substitution

គំរូ
ក គេនាំគ្នាច្បាំងរាប់ឆ្នាំ ពីក្សត្រមួយទៅក្សត្រមួយ។
(សតវត្ស - ស្រុក)
ខ គេនាំគ្នាច្បាំងរាប់សតវត្ស ពីស្រុកមួយទៅស្រុកមួយ។

MODEL:

T: They fought for years, from one king to another.
(centuries - country)
S: They fought for centuries, from one country to another.

គេនាំគ្នាច្បាំងរាប់សតវត្ស ពីស្រុកមួយទៅស្រុកមួយ។
ក ខែ - កន្លែង
គេនាំគ្នាច្បាំងរាប់ខែ ពីកន្លែងមួយទៅកន្លែងមួយ។
ខ រយឆ្នាំ - រដូវ
គេនាំគ្នាច្បាំងរាប់រយឆ្នាំ ពីរដូវមួយទៅរដូវមួយ។
គ ពាន់ឆ្នាំ - ប្រទេស
គេនាំគ្នាច្បាំងរាប់ពាន់ឆ្នាំ ពីប្រទេសមួយទៅប្រទេសមួយ។
ឃ សតវត្ស - ក្សត្រ
គេនាំគ្នាច្បាំងរាប់សតវត្ស ពីក្សត្រមួយទៅក្សត្រមួយ។

ង ខេត្ត - ភូមិ
គេនាំគ្នាប្រកាន់តាមខេត្ត គតិភូមិ
មួយទៅភូមិមួយ។

ច ឆ្នាំ - រាជ្យ
គេនាំគ្នាប្រកាន់តាមឆ្នាំ គតិរាជ្យ
មួយទៅរាជ្យមួយ។

DRILL NINE: Substitution

គំរូ:

ក: មកដល់ចុងសតវត្សរ៍ទី១៥ ទើប
បានសុខសាន្ត។
(ជំនាន់ក្រោយ - សប្បាយ)

ខ: មកដល់ជំនាន់ក្រោយ ទើប
បានសប្បាយ។

MODEL:

T: It wasn't peaceful until the end of the 15th century.
(next generation, pleasant)

S: It wasn't pleasant until the next generation.

មកដល់ជំនាន់ក្រោយ ទើប
បានសប្បាយ។

ក ចុងសតវត្សរ៍នោះ - រុងរឿង
មកដល់ចុងសតវត្សរ៍នោះ ទើប
បានរុងរឿង។

ខ ស្តេចបន្ទាប់ - សោយរាជ្យ
មកដល់ស្តេចបន្ទាប់ ទើបបានសោយ
រាជ្យ។

គ រាស្ត្រ កាលនោះ - ចេះនៅជាមួយគ្នា
មកដល់រាស្ត្រ កាលនោះ ទើបបាន
ចេះនៅជាមួយគ្នា។

ឃ រាជ្យក្សត្រអង្គនោះ - ឈប់ច្បាំងគ្នា
មកដល់រាជ្យក្សត្រអង្គនោះ ទើប
បានឈប់ច្បាំងគ្នា។

ង ពីរខែក្រោយមក - គេងជាមួយគ្នាវិញ
មកដល់ពីរខែក្រោយមក ទើប
បានគេងជាមួយគ្នាវិញ។

ឆ ស្តេចក្រោយមក - និយាយរកគ្នាវិញ
មកដល់ស្តេចក្រោយមក ទើបបាន
និយាយរកគ្នាវិញ។

DRILL TEN: Transformation

គំរូ

ក យើងមិនសប្បាយឲ្យអស់ពីដួង។
(សត្រូវចូលមកលុកលុយ)

ខ យើងមិនសប្បាយឲ្យអស់ពីដួង
ទទួលសត្រូវចូលមកលុកលុយ។

MODEL:

T: We weren't completely comfortable.
(the enemy invaded)

S: We weren't completely comfortable (before) we were unexpectedly invaded by the enemy.

ក ទ័ពស្រុកវាយជិតឈ្នះ។
(មេទ័ពរបស់ពួកនោះស្លាប់)
ទ័ពស្រុកវាយជិតឈ្នះ ទទួលមេទ័ព
របស់ពួកនោះស្លាប់។

ខ ខ្ញុំគិតទៅបង្រៀនជំនួស។
(លោកគ្រូមកដល់)
ខ្ញុំគិតទៅបង្រៀនជំនួស ទទួលលោក
គ្រូមកដល់។

គ គាត់ទៅបានពាក់កណ្តាលផ្លូវ។
(ខ្ញុំឃើញគាត់)
គាត់ទៅបានពាក់កណ្តាលផ្លូវ ទទួល
ខ្ញុំឃើញគាត់។

ឃ ខ្មាំងបំរុងដកទ័ពហើយ។
(ទ័ពយើងទៅដល់)
ខ្មាំងបំរុងដកទ័ពហើយ ទទួលទ័ព
យើងទៅដល់។

ង ខ្ញុំគ្មានសល់លុយសោះ។
(ឡានខូចទៀតផង)
ខ្ញុំគ្មានសល់លុយសោះ ទទួលឡាន
ខូចទៀតផង។

ច ទាហានកំពុងតែសប្បាយ
(នាយទាហានចូលមកដល់)
ទាហានកំពុងតែសប្បាយ [illegible]
នាយទាហានចូលមកដល់ ។

DRILL ELEVEN: Transformation

គំរូ

ក ក្នុងរជ្ជកាលព្រះពញាយ៉ាត ។

ខ ដូចក្នុងរជ្ជកាលព្រះពញាយ៉ាតនេះ?

MODEL:

T: In the reign of Ponha Yat.

S: Wasn't it like in the reign of Ponha Yat?

ក [illegible] ពាក់កណ្ដាលសតវត្សរ៍ទី១៥ ។
ដូច[illegible] ពាក់កណ្ដាលសតវត្សរ៍ទី១៥នេះ?

ខ [illegible] ។
ដូច[illegible]នេះ?

គ [illegible] ។
ដូច[illegible]នេះ?

ឃ [illegible]
[illegible] ។
ដូច[illegible]
[illegible]នេះ?

ង [illegible] ។
ដូច[illegible]នេះ?

ច គេ[illegible]ឆ្នាំ ។
ដូចគេ[illegible]ឆ្នាំនេះ?

READING PASSAGE 2

ក- ព្រះរាជានិងរបបគ្រប់គ្រង.-

ព្រះរាជាជាម្ចាស់ផែនដីនិងជាបង្គោលនៃការគ្រប់គ្រងប្រទេសជាតិ ទាំងខាងផ្នែកនយោបាយទាំងខាងផ្នែកតុលាការ ។ ព្រះមហាក្សត្រជាអ្នកកាន់អំណាចតុលាការ រកយុត្តិធម៌ឲ្យប្រជារាស្ត្រព្រះអង្គ ។ សិលាចារឹកទាំងឡាយបានបង្ហាញឲ្យឃើញថា ព្រះរាជាជាអ្នកការពារសាសនានិងគ្រប់គ្រងថែរក្សាប្រាសាទជាប្រយោជន៍ខាងសាសនាទៀតផង ។ មិនត្រឹមតែប៉ុណ្ណោះ ព្រះអង្គបានបំពេញនូវពិធីសក្ការបូជាផ្សេងៗ ខាងផ្លូវសាសនាព្រមទាំងមានភារៈការពារជាតិទប់ទល់នឹងសត្រូវពីខាងក្រៅនិងធ្វើឲ្យមានសុខសន្តិភាពខាងក្នុងប្រទេសថែមទៀត ។

ទីក្រុងរបស់ព្រះអង្គជាតំណាងពិភពលោកទាំងមូលដែលមានជួរភ្នំកណ្ដាប់ចក្រវាល និងមហាសាគរព័ទ្ធជុំវិញ ។ នៅកណ្ដាលទីក្រុង ព្រះមហាក្សត្រទ្រង់បានសាងប្រាសាទភ្នំមួយដើម្បីជាតំណាងភ្នំព្រះសុមេរុនិងដើម្បីតម្កល់លិង្គទេវរាជ ។

ក្នុងសម័យអង្គរ គេសង្កេតឃើញមានការរៀបចំយ៉ាងល្អិតល្អន់ខាងផ្នែករដ្ឋបាល មានតាំងពីរដ្ឋមន្ត្រី មេទ័ព ទីប្រឹក្សា អធិការ ចៅហ្វាយខេត្ត រហូតដល់ចៅហ្វាយស្រុក មេភូមិ មេឃុំជាដើម ។

នាម៉ឺនសព្វមុខមន្ត្រីត្រូវបានជ្រើសតាំងដោយព្រះរាជាក្នុងចំណោមឥស្សរជនដែលចេះដឹងក្នុងវណ្ណៈអភិជន ។ គណៈរដ្ឋមន្ត្រីទទួលភារៈចាត់ចែងកិច្ចការរដ្ឋជំនួសព្រះអង្គផងនិងក្រោមព្រះរាជបញ្ជាផ្ទាល់ផង ។ មិនតែប៉ុណ្ណោះ ព្រះមហាក្សត្រនិងព្រះរាជវង្សានុវង្សបានយកមកកាន់កាប់ផ្ទាល់ព្រះហស្តនូវគ្រប់កិច្ចការសំខាន់ៗ ទាំងឡាយដែលទាក់ទងនឹងអាយុជីវិតនៃប្រទេសជាតិមាតុភូមិ ។

ក្នុងសម័យនោះ ព្រះរាជាបានជ្រើសរើសព្រាហ្មណ៍បុរោហិត ដើម្បីធ្វើជាព្រះរាជគ្រូទទួលភារៈចាត់ចែងពិធីទេវរាជ (culte du Dieu-roi) ទៅតាមទស្សនៈថ្មីក្នុងសាសនា ដែលព្រះបាទជ័យវរ្ម័នទី ២ ទ្រង់បានបញ្ចូលទៅក្នុងដើមសម័យអង្គរ ។

ខ- ជីវភាព សាសនានិងជំនឿនៃប្រជារាស្ត្រ.-

ប្រជារាស្ត្រនៅប្រកបរបរកសិកម្មជាធំ ចេះធ្វើស្រែចម្ការយ៉ាងប៉ិនប្រសប់ ទាញយកផលបានច្រើនដោយសារនយោបាយទឹក (ការស្ថាបនាបារាយណ៍ជាដើម) ។ ក្រៅពីនេះ គេសង្កេត

ឃើញមានប្រជាពលរដ្ឋមួយប្រភេទដែលគេហៅថា "ពលព្រះ" ។ អ្នកទាំងនេះទទួលភារៈថែទាំបោសសម្អាតវត្តអារាម ព្រមទាំងប្រាសាទនានាដែលគេទុកដូចជាលំនៅនៃអាទិទេពនិងជាទីសម្រាប់ប្រារព្ធពិធីផ្សេងៗ ។

ក្នុងផ្នែកសាសនា ខ្មែរសម័យនោះបានគោរពពុទ្ធសាសនាផង ព្រហ្មញ្ញសាសនាផង ។ ពីស.វ.ទី ៩ ដល់ទី ១០ គេនិយមព្រហ្មញ្ញសាសនា ដោយគោរពព្រះសិវៈ ។ នៅស.វ.ទី១២ គេនិយមព្រះវិស្ណុជាធំម្ដងវិញ ដូចជានៅក្នុងរជ្យព្រះបាទសូរ្យវរ្ម័នទី ២ ជាដើម ។ សម័យនោះ មានខ្មែរភាគតិចទេដែលនិយមព្រះពុទ្ធសាសនា ហើយមានតែព្រះរាជាពីរព្រះអង្គប៉ុណ្ណោះគឺ ព្រះបាទសូរ្យវរ្ម័នទី ១ និងព្រះបាទជ័យវរ្ម័នទី៧ ដែលទ្រង់បានកាន់ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន ។

សាសនាទាំងពីរនេះ បានត្រូវគេទទួលស្គាល់តែក្នុងព្រះរាជវង្សានុវង្ស និងក្រុមគ្រួសារអភិជនតែប៉ុណ្ណោះ ព្រោះគេយល់ថា ជាវប្បធម៌មួយមានតម្លៃ ប៉ុន្តែពុំមែនជាវប្បធម៌ដែលបានជ្រួតជ្រាបដល់អ្នកស្រុកដែលរស់នៅតាមជនបទនោះឡើយ ។ ប្រជារាស្ត្រខ្មែររស់នៅតាមរបៀបខ្មែរពីបុរាណកាល ដោយពុំពឹងផ្អែកទៅលើច្បាប់បញ្ញត្តិនៃសាសនាណាមួយឡើយ ។

VOCABULARY

គន្លងចក្រវាល	encircling the world (refers to a mythical mountain range)
កាមគុណ (L)	passion, sexual desire, love
កុំតែ... កុំអី	if it were not for...
កំពូល	summit, high point
កំណត់	limit; to limit
ក្រចេះ	Kratie (Cambodian province)
ខម	name for ancient Khmer
ខ្ជាប់ខ្ជួន (ខ្ជួន C)	long-lasting, recurrent, persistent
គណៈរដ្ឋមន្ត្រី	cabinet (of ministers)
អញ	I, me (familiar)
គ្របដណ្តប់	to take care of
គ្រប	to cover, a cover
* ដណ្តប់	to cover with a blanket or clothing
ចម្ប៉ា	Champa (name of ancient empire of the Chams, neighboring the Khmer)
ចាត់ចែង	to arrange, set up
ចែង	to state, say, declare
ចាត់ទុក	to consider that
ចុងក្រោយបង្អស់	last of all
ចេះដឹង	to be knowledgeable
ជម្រក	shelter, refuge
* ជ្រក	to take refuge, take shelter
ជីវភាព	way of life, standard of living
ជួរភ្នំ	mountain range
ជ្រួតជ្រាប	to permeate, be saturated, absorbed, to be aware of
ជ្រាប	permeable; to permeate, to be saturated, absorbed

	ជ្រើសរើស	to choose, select
	ជ្រើស	to choose
	ឈូងសមុទ្រ	gulf (in an ocean, e.g., Gulf of Mexico)
	ឈូង	gulf (geographic)
	ដែន	territory, country
	ដំកល់	cf. តម្កល់
	តម្កល់-ដំកល់	to raise, prop up
*	កល់	to prop up; firmly in place
	ទទួលស្គាល់	to accept, recognize
	ទប់ទល់	to bear, support, defend, withstand
*	ទស្សនៈ tuəhsanaʔ	vision, opinion, view (literary)
	ទីប្រឹក្សា	adviser
	ប្រឹក្សា	adviser
	[illegible]	[illegible]
	ទំនាប (ទាប)	low surface; a low, flat place
	ទំហំ (ធំ)	size
	ទាំងមូល	all
	នយោបាយទឹក	water development policy
*	និម៉ឺន niʔmɨɨn, ləmɨɨn	civil servant
	នីតិវង្ស niʔtiʔvɔŋ	dynasty
*	នីតិ	identifier
	បង្គោល	a [illegible], post, support
	បញ្ញត្តិ paññat/	law, order
*	បារាយណ៍	Baray (name of lakes near Angkor)
	ប៉ិន	skillful, clever
	បុរាណកាល	ancient times
	បោស	to sweep
	ប្រកបរបរ	to earn a living, have a profession
	ប្រជារាស្ត្រ	the people
	ប្រភេទ	type, kind, class
	ភេទ	sex, gender
	ប្រវត្តិវិទូ	historian
	វិទូ	agent suffix replacing វិទ្យា in a noun, indicating a specialist in a field of study
	ប្រសប់	skillful, capable
	ប្រហែលគ្នា	similar
	[illegible]	to create, formulate, be created
	រួច	to get free of, clear of
	[illegible]	the world
*	[illegible]	disk
	ផ្ទាល់	personal, relating to, in person
	ពលព្រះ	hereditary laborers attached to a wat (in ancient times)
*	ពល	subgroup of the laborer caste (India)
	ព័ទ្ធជុំវិញ	surrounding, encircling
	ព័ទ្ធ	to surround
	ជុំវិញ	surrounding, around
	ពិភពលោក	the world
	ភព	world, planet
	ពឹងផ្អែក (លើ)	to depend on
	ផ្អែក	to lean on
	ព្រាហ្មណសាសនា prɔmmaʔnaʔsasnaa/	Brahmanism, Hinduism
	ព្រាហ្មណ៍ prɔm/	Brahman
	ព្រាហ្មណ៍[illegible]	Brahmans attached to the royal court
*	[illegible]	executive, performer of ceremonies, arranger
	ព្រំដែន	border, frontier
*	ព្រំ	border, frontier
	ដែន	up to, ending
	[illegible]	[illegible] teacher
	ព្រះរាជវង្សានុវង្ស	the royal family

	[illegible]	[illegible] (literary)
	ព្រះវិស្ណុ	Vishnu
*	ព្រះសិវៈ	Siva
*	[illegible]	property, [illegible]
	[illegible]	property, [illegible]
	[illegible]	to bet, wager
	[illegible]	Brahman, the [illegible] people
	[illegible]	people, [illegible], all, [illegible], state
*	[illegible]	[illegible] (formal)
	[illegible]	[illegible] (formal)
	[illegible]	to spread
*	[illegible]	(H) [illegible]
	[illegible]	Mekong (river)
	[illegible]	the [illegible]
	[illegible]	[illegible] one, [illegible] one
	[illegible]	Menam (river) (European name for the Chao Phraya River in Thailand)
	មេទ័ព	leader of troops, commander
	[illegible] (L)	leader, source of fire
	[illegible]	royal honorific used before verbs of motion
	[illegible]	[illegible] position
*	[illegible]	(H) [illegible] power
	[illegible]	scriptures, [illegible], truth, virtue
	រដ្ឋាភិបាល	government, administration
	រដ្ឋមន្ត្រី	cabinet minister
	របប	régime
*	រាជបញ្ជា	royal command
	បញ្ជា	to command; to command
	[illegible]	to [illegible], to [illegible]
	[illegible]	[illegible] name [illegible] given
	[illegible]	Luang Prabang (east of the River of Laos)
	[illegible]	[illegible]
	[illegible]	[illegible] in this [illegible]
	[illegible]	fine, [illegible]
	[illegible]	[illegible] state [illegible]
	[illegible]	[illegible] persons; [illegible], [illegible]
*	[illegible]	(H) [illegible], [illegible]
	[illegible]	[illegible]
	[illegible]	offering, [illegible]
*	[illegible]	present, gift, [illegible] offering
	[illegible]	to offer to a [illegible] or divinity; to present, act of offering [illegible]
	[illegible]	[illegible] publication
	[illegible]	[illegible]
*	[illegible] (H)	[illegible]
*	[illegible]	suffix to make [illegible]
	សព្វ	all, every
	សាជាថ្មី	again, another time
	សា	to do again, to repeat
	សាង	to build
	[illegible]	[illegible]
	សុខសាន្ត	peaceful, happy
	សុខោទ័យ	Sukhothai (name of first Thai kingdom)
	ហរិហរាល័យ	Hariharalaya (name of early Khmer capital)
	[illegible]	to [illegible], to [illegible]
	verb + ឡើងវិញ	again, to repeat, to do again

អង្គរវត្ត	Angkor Wat	អរិយធម្មរដ្ឋ	/ʔariyéʔthoamarŏt/ civilized country (literary)
អឌ្ឍភាគ	/ʔatthéʔphieq/ half portion	អរិយធម៌	/ʔariyéʔthoa/ civilization
អឌ្ឍ	/ʔatthéʔ/ (a)half	អាទិទេព	god
អធិការ	inspector, administrator, to administrate, inspect (formal)	ឥស្សរជន	/ʔeisaraʔcun/ dignitary
អធិរាជ	emperor	ទាំងស្រុង	completely
អាយុជីវិត	lifetime, life span	អំបូរ	family, lineage, class

APPLICATIONS

I. Fill in the blanks with the proper words provided.

១ គេបង្រួបបង្រួមឲ្យក្លាយជា ... វិញ ។
(ម្ដង ទៀត ម្ដងទៀត)

២ សម័យនោះគេបានចាត់ ... សម័យរុងរឿងបំផុត ។
(ទុកថា ទុក ទុកថាជា)

៣ ការបង្រួបបង្រួមនោះកើតឡើងដោយ... ស្នាព្រះហស្តស្ដេចមួយព្រះអង្គ ។
(ជា ការ ថា សារ)

៤ ស្ដេចខ្មែរជំនាន់នេះទៀត ...... ក៏ត្រូវបែបដូចគ្នាដែរ ។
(សោត ហើយ ដូច)

៥ ... ស្ដេចខ្មែរដើមវិញ ... គេឃើញមានសិល្បៈដែរ ។
([illegible] ក៏ សោត)

៦ គាត់បាន ... យកឱកាសទៅសាកសួរប្រជារាស្ត្រ ។
(នាំ ទាញ ឆ្លៀត)

៧ ទោះ ... បើយ៉ាងហ្នឹងក៏ដោយ ... មានព្រឹត្តិការណ៍ថ្មីទៀតដែរ ។
(ជា នោះ ក៏ ត្រូវ)

៨ ប្រជាជន... នោះនៅតែមានចំណងគ្រួសារនឹងគ្នាជានិច្ច ។
([illegible] គ្រប់ ទាំង)

៩ ក្រោយមកនេះលើសិល្បៈគេក្រុមនេះ ... ត្រូវបានគេសាងឡើង ។
(ហើយ វិញ ក៏)

១០ ~ ក្សត្រអង្គនោះសោត ... ត្រូវយាងចេញ ។
(ក៏ ហើយ ទៀត)

2. Find the antonyms of the following words.

ក្សត្រ ព្រះហស្ត យាន ទឹកដី ប្រទេស
ព្រះរាជវង្សានុវង្ស ប្រវត្តិសាស្ត្រ ងាប សម័យ
ស្រោបស្រែង ចិត្តសប្បា សត្រូវ បញ្ញាញ

3. Reconstruct as much of Khmer history as you can through the Angkor period. If you feel that there are important gaps in your knowledge, try to fill them in with your teacher's help.

4. Correct the following sentences by adding the proper words.

១ ស្ទិតពេលនៅសម័យអង្គរមេឿងដល់ណាដល់ហើយ ក្រុណាសម្លាំងក្បួន ។
២ ទឹកទន្លេរបស់ទឹករស្មោះគា កុំមិនមិនបាញ់ខាំងទេ ។
៣ ពួកគេយើងត្រូវរួបរួមនាំគ្នាយ៉ាងចេញពីស្រុក ។
៤ ខ្មាននលោកនឹងខ្មាងខ្ញុំទៅប្រទេសហ៊ាល ។
៥ កាលនោះស្រុកយើងពីបាកទេណ ហើយបានហៅបាទាំងមកជួយផង ។
៦ ស្ដេចយើងមិនគងទាំងបានសង់ប្រាសាទឱ្យបងបន់ ខ្ញុំនូវមកទៀត ។
៧ មកពាក្យយើងត្រូវសិទ្ធិកសប្បាយឱ្យបានដែរ ។
៨ ខ្ញុំមិនទេ ទៅ ... បានអង្គុយផង លោកមកដល់ ។
៩ ក្សត្រ ... ទេចញ្ញពីស្ដេចញ្ញក្រោយមកបំផុត ។
១០ ពួកអ្នកស្រុក ស្ដេចទៅនៅក្នុងកន្លែងឈើទៅហើយ ។

5. Define the following words.

អាណានិគម សង្គ្រាមបដិវត្តន៍ កំពូល រដ្ឋការ អំបូរ
ឈ្មួញសម្បុរ ការបរស្ពា ប្រវត្តិវិទូ ប្រសប់ ភាពីង

6. Have the student discuss the following situations.

១ អាមេរិកាំងនៅប្រទេសអង់គ្លេស ។
២ អំពីជនជាតិអាំងឌៀន ។
៣ ហេតុធ្វើឱ្យសហរដ្ឋអាមេរិកមាន ។
៤ ពេលដែលអាមេរិកបានឯករាជ្យ ។

7. Questions for the teacher to ask.

១ កាលពីដើម ជនជាតិសហរដ្ឋអាមេរិកនៅឯណា? ឈ្មោះទីក្រុងអ្វី?
២ ចុះឥឡូវ ជនជាតិសហរដ្ឋអាមេរិកឈ្មោះអ្វី?
៣ ហេតុអ្វីបានជាកើតជនជាតិមកទឹកដីនេះ?
៤ ហេតុអ្វីបានជនបរទេសស្គាល់ពីក្រុងនិងយកជាជនជាតិវិញ?
៥ សព្វថ្ងៃមានរដ្ឋប៉ុន្មាន? រដ្ឋណាជារដ្ឋធំ? ទីក្រុងឈ្មោះអ្វី?
៦ មានរដ្ឋខ្លះបានទិញពីគេ ។ ហេតុអ្វីបានទិញបាន?

8. Questions for the student to ask.
   a. What can your teacher tell you about life in Angkor?
   b. What were most of the buildings there built for? What does your teacher think the effect of so much building was on Khmer society of the time?
   c. What traditions that have lasted to the present day originated with the Khmers of Angkor?
   d. Do the ព្រាហ្មណ៍បុរោហិត still exist?
   e. What was their function under the monarchy? What is their function nowadays?
   f. Are there other places where Brahmanism (Hinduism) is still practised in Cambodia?
   g. Why does your teacher think Angkor fell?
   h. What does he think the main contribution of Angkor was to civilization?
   i. Ask your teacher about Chou-Ta-Kouan, who was he? Why is he important to Khmer history?
   j. Were the last kings of Cambodia (in the 19th and 20th centuries) direct descendents of the kings of Angkor?

Supplementary Reading Passage

សម័យអង្គរ

យើងអាចរៀបរាប់បាននូវរាជវង្សព្រះរាជាខ្មែរនៅសម័យអង្គរដែលជាសម័យដ៏រុងរឿងមួយក្នុងប្រវត្តិសាស្ត្រខ្មែរ ដោយសារតែសិលាចារឹកដែលជួនកាលនៅជាប់នឹងខ្លោងទ្វារប្រាសាទ ជួនកាលជាសសរស្តម្ភដាក់ក្នុងប្រាសាទនីមួយ ៗ ។ សិលាចារឹកទាំងនេះតែងតែរៀបរាប់ពីព្រះរាជវង្សព្រះរាជា ស្នាព្រះហស្តនិងគុណសម្បត្តិរបស់ព្រះអង្គ ព្រមទាំងព្រះរាជសារទុកជាបទបញ្ជានៅក្នុងប្រាសាទនីមួយ ៗ ។ ក្រៅពីនេះ ដោយសារតែសិលាចារឹកដែល យើងអាចស្គាល់ខ្លះ ៗ នូវព្រំប្រទល់ប្រទេសខ្មែរក្នុងរាជ្យនីមួយៗថែមទៀតផង ។ ឧទាហរណ៍ នៅ ៣ ឆ្នាំក្រោយដែលព្រះបាទយសោវរ្ម័នទី ១ ចូលទីវង្គតទៅ ព្រំប្រទល់ប្រទេសខ្មែរខាងជើងទល់នឹងតំបន់យុន-ណាន់និងប្រទេសភូមា ឯខាងលិចទៅទល់នឹងឈូងសមុទ្រសៀមសព្វថ្ងៃ ។

ព្រះរាជាសម័យអង្គរជាព្រះរាជាចក្រវាល (monarque universel) ។ ព្រះអង្គទ្រង់ទទួលអំណាចពីអាទិទេព ដើម្បីយកមកអនុវត្តក្នុងការគ្រប់គ្រងប្រទេស ។ ដូច្នេះ ព្រះអង្គមានករណីយកិច្ច

ក្នុងការបំពេញពិធីផ្សេងៗ សម្រាប់បង្កើតភោគផលឲ្យបានច្រើនដល់ប្រទេសជាតិ ។ ព្រះរាជាក្នុងសម័យហ្វូណនបានទទួលជាសុទ្ធតែជាប់ព្រះរាជវង្សនឹងព្រះរាជាព្រះរាជនីដើមបំផុតគឺកៅណ្ឌិន្យ-សោមា ឬព្រាហ្មណ៍កៅណ្ឌិន្យនិងព្រះនាងនាគី ។ ចំណែកឯព្រះមហាក្សត្រនៅប្រទេសចិនឡាវិញបានកត់ត្រាទុកថា សុទ្ធតែជាប់ព្រះញាតិនិងព្រះរាជវង្សថ្មីមួយទៀតគឺព្រាហ្មណ៍កម្ពុនិងព្រះនាងមេរា ។ ខ្មែរយើងក៏យកពាក្យកម្ពុនេះមកប្រើសម្រាប់ហៅជាឈ្មោះរបស់ប្រទេសខ្លួនឯងថា កម្ពុជា (កើតពីឥសីកម្ពុ) ។ លុះមកដល់សម័យអង្គរវិញ ព្រះរាជាអង្គខ្លះជាប់ព្រះញាតិនឹងកម្ពុមេរា អង្គខ្លះជាប់ព្រះញាតិទៅនឹងកៅណ្ឌិន្យ-សោមា — អង្គខ្លះជាប់ព្រះញាតិទៅនឹងរាជវង្សទាំងពីរ អង្គខ្លះទៀតសឹងតែពុំជាប់ទៅនឹងរាជវង្សទាំងពីរនោះផង ។ អ្នកខ្លះបានហៅរាជវង្សកៅណ្ឌិន្យ-សោមាថា សោមវង្ស ឬវង្សព្រះចន្ទ ឯវង្សកម្ពុមេរាវិញនោះថា សុរិយវង្សឬវង្សព្រះអាទិត្យ ។

ឯរាជវង្សក្សត្រខ្មែរសម័យអង្គរ ចាប់តាំងពីព្រះបាទជ័យវរ្ម័នទី ២ មករហូតដល់ព្រះបាទរាជេន្ទ្រវរ្ម័ន សុទ្ធសឹងជាប់ជាព្រះញាតិនឹងសោមវង្សទាំងអស់ ហើយចាប់ពីព្រះបាទជ័យវរ្ម័នទី ៥ រហូតមកដល់ព្រះបាទជ័យវរ្ម័នទី ៧ មានជាប់ព្រះញាតិនឹងសុរិយវង្សផង (ព្រះអគ្គមហេសីរបស់ព្រះបាទជ័យវរ្ម័នទី ៥ ជាប់ព្រះញាតិខាងកម្ពុមេរា) ។ ដើម្បីនឹងឲ្យបានស្រួលដល់ការសិក្សាពីព្រះរាជវង្សក្សត្រខ្មែរសម័យអង្គរនេះ យើងសូមជូនតារាងដូចតទៅ :

សេចក្តីពន្យល់



កម្ពុមេរាមានរាជបុត្រ ២ព្រះអង្គ គឺព្រះនាម x និង X' ហើយមានព្រះរាជបុត្រីព្រះនាម x ។
ព្រះរាជបុត្រ × បានព្រះមហេសី x ជាប់ជាព្រះញាតិនឹងកៅណ្ឌិន្យ-សោមា ។


កម្វុ-មេរា
ព្រះបាទកៅណ្ឌិន្យ
ព្រះនាងសោមា
ព្រះបាទជ័យវរ្ម័នទី២
ព្រះបាទជ័យវរ្ម័នទី៣
ព្រះបាទឥន្ទ្រវរ្ម័ន
ព្រះបាទយសោវរ្ម័នទី១
ព្រះបាទជ័យវរ្ម័នទី៤
ព្រះបាទរាជេន្ទ្រវរ្ម័ន
ព្រះបាទជ័យវរ្ម័នទី៥
ព្រះបាទហស៌វរ្ម័នទី១
ព្រះបាទឦសានវរ្ម័នទី២
ព្រះបាទហស៌វរ្ម័នទី២
ព្រះបាទឧទយាទិត្យវរ្ម័នទី១
ព្រះបាទធរណិន្ទ្រវរ្ម័នទី១
ព្រះបាទជ័យវរ្ម័នទី៦
ព្រះបាទសូរ្យវរ្ម័នទី១
ព្រះបាទសូរ្យវរ្ម័នទី២
ព្រះបាទធរណិន្ទ្រវរ្ម័នទី២
ព្រះបាទឧទយាទិត្យវរ្ម័នទី២
ព្រះបាទហស៌វរ្ម័នទី៣
ព្រះបាទជ័យវរ្ម័នទី៧

Names in the Supplementary Reading Passage

យសោវរ្ម័នទី១	(Khmer king)	កម្វុ	(Brahman)
កៅណ្ឌិន្យជយវរ្ម័ន	(Funanese king)	មេរា	(wife of កម្វុ)
កៅណ្ឌិន្យ	(Brahman)	រាជេន្ទ្រវរ្ម័ន	(Khmer king)
សោមា	(Funanese queen)		

VOCABULARY

កត់ត្រា	to make a note, to note	ព្រះរាជសារ	royal documents
ខ្លោងទ្វារ	gate posts in wall; a wall with a gate	ព្រះអាទិត្យ	the sun
ចូលទិវង្គត	to die (royal)	យូនណាន	Yunnan
ញាតិ	relative, family	សសរស្តម្ភ	kind of column found in temples
តារាង	list, table (on paper)	សសរ	column
បទ	matter, work, act, song	ស្តម្ភ	column, firm
ព្រះចន្ទ	moon	ហ្វូណន	Funan
ព្រះរាជិនី	queen	ឥសី	a teacher of sacred matters

LESSON TEN

AFTER ANGKOR

a. Was Cambodia ever a Thai colony?
b. How did France come to take over Cambodia?
c. Under what circumstances did the French Protectorate end?
d. How does the French colonizing of Cambodia still show up in everyday life? That is, what are the effects left by the French on Cambodian life?

– សម័យក្រោយមហានគរ

រដ្ឋខ្មែរ-មនទាំងឡាយដែលបានរួបរួមមូលគ្រប់គ្នាក្នុងសម័យមុន ក៏ត្រូវបែកខ្ញែកទៅវិញ ដោយកំណើនកម្លាំងរបស់ជនជាតិសៀម-យួននេះឯង ។

សៀមនិងយួនជាមែកធាងពីរនៃអំបូរម៉ុងហ្គោល ។ កាលដើមឡើយពួកនេះរស់នៅត្រង់វាលទំនាបទន្លេយ៉ង់សេខាងត្បូងប្រទេសចិន ក្រោយមកដោយមានការរុញច្រានពីសំណាក់ជនជាតិចិនក៏បានធ្វើដំណើរសំដៅមកភូមិភាគអាស៊ីអគ្នេយ៍តាមដងទន្លេធំៗ ។

ក្រោយរជ្ជកាលជ័យវរ្ម័នទី ៧ (ស.វ.ទី ១៣) នៅមហានគរមានការវឹកវរខ្លាំងដោយសារប្រតិកម្មរបស់ពួកកាន់សាសនាព្រាហ្មណ៍ប្រឆាំងនឹងពុទ្ធសាសនា ។ គឺក្នុងក្របខណ្ឌនេះហើយដែលគេឃើញព្រះពុទ្ធរូបជាច្រើននៅអង្គរត្រូវវាយបំបែកឬត្រូវគេកោសលុប និងមានពួកពុទ្ធសាសនិកជនភៀសខ្លួនទៅនៅសុខោទ័យ។ពួកសៀមនៅទីនោះទៀតយកឱកាសនាំគ្នាបះបោរដើម្បីបង្កើតអាណាចក្រសុខោទ័យ ។ តំណតមកសៀមបានលើកទ័ពចូលវាយមហានគរពីរលើកគឺនៅឆ្នាំ១៣៥២ម្តងនិងឆ្នាំ ១៤១០ម្តង ដោយមានគោលបំណងចង់យកប្រទេសកម្ពុជាដាក់ជាចំណុះ ។ ព្រះបាទបរមរាជាហៅពញាយ៉ាត ក្រោយពីរំដោះប្រទេសបានកាលណា ទ្រង់បានលើករាជធានីពីមហានគរទៅតាំងនៅស្រីសន្ធរ រួចមកនៅភ្នំពេញ ។ នៅស.វ.ទី១៦ព្រះបាទអង្គចន្ទទី១បានតាំងរាជធានីនៅលង្វែកតែក្រោយពីក្រុងនេះធ្លាក់ទៅក្នុងកណ្តាប់ដៃសៀមទៀតនៅឆ្នាំ១៥៩៣ទឹកដីខ្មែរមួយភាគធំដែលស្ថិតនៅឯនាយជួរភ្នំដងរែក (រយ៉ង នាងរោង ឧតរាជ សុរិន្ទ សង្កែ ស៊ីបុន) និងចន្ទបូរត្រូវបាត់បង់ជាស្ថាពរ។ទឹកដីមួយភាគធំទៀត បាត់ដំបងសៀមរាបអង្គរ ត្រូវសៀមបញ្ចូលជាអាណាខេត្តរបស់គេនៅចុងស.វ.ទី១៨ ដោយមានការផ្សំគំនិតរបស់មន្ត្រីក្បត់ខ្លះ ។ ដោយមានអន្តរាគមន៍របស់បារាំង ទឹកដីទាំងនោះត្រូវបានប្រគល់ឲ្យខ្មែរវិញក្នុងឆ្នាំ១៩០៧ ។ តែមិនយូរប៉ុន្មាន ដោយមានការគាំទ្រពីពួកជប៉ុនផងនោះ សៀម បានដណ្តើម

យកខេត្តទាំងប៉ុន្មាននេះមកក្រោមការត្រួតត្រារបស់ខ្លួនជាថ្មីទៀតចាប់ពីឆ្នាំ១៩៤១ ដល់ ឆ្នាំ១៩៤៦ទើបប្រគល់សងមកខ្មែរវិញតែក្រោយ បរាជ័យរបស់ជប៉ុនក្នុងសង្គ្រាមសកលលោកលើកទី២ ។

ស្របពេលជាមួយការរុករានទន្ទ្រានយកទឹកដីរបស់សៀម យួនក៏បានធ្វើសកម្មភាពដូចគ្នានេះដែរ ។ ជាការពិតណាស់ ក្រោយពីបានរំដោះខ្លួនជាស្វាតន្ត្រពីនឹម អាណានិគមរបស់ចិន យួនខ្លួនឯងដែលមានបណ្ដាជនចេះតែកើនឡើងយ៉ាងឆាប់រហ័ស ក៏បានអនុវត្តនយោបាយពង្រីកទឹកដីម្ដងៗ ចាប់ពីស.វ.ទី១១ យួនបានផ្ដើមលេបទឹកដីរបស់អាណាចក្រចម្ប៉ាបន្តិចម្ដងៗដោយប្រើកលល្បិចខ្លះ ដោយធ្វើសង្គ្រាមខ្លះលុះត្រាតែអស់រលីង ។ រាជធានីចុងក្រោយបង្អស់របស់ចាមត្រូវទទួលបរាជ័យនៅឆ្នាំ១៤៧១ ហើយចាប់តាំងពីពេលនោះមក អាណាចក្រចម្ប៉ាលែងមានឈ្មោះជារដ្ឋអធិបតេយ្យទៀតហើយ ។

នៅដើម.ស.វ.ទី ១៧ យួនបានចូលមកធ្វើការទាក់ទងជាមួយខ្មែរ ។ ព្រះចៅក្រុងវេក្រោយដែលបានលើកបុត្រី(ម្ចាស់ស្រីនាម៉ុនណាម្នាក់ ?)ថ្វាយទៅជ័យជេដ្ឋាទី២ ជាអគ្គមហេសីហើយបានបញ្ជូនគណៈបេសកកម្មមួយមកក្រុងឧដុង្គដើម្បីសុំទីដីខ្មែរទុកហ៊ុកហាត់ជាឋានទីងឲ្យពាណិជ្ជជនយួនចូលមករកស៊ីនៅត្រង់ភូមិភាគព្រៃគរ (ព្រៃនគរ)-កំពង់ក្របី ។ ជ័យជេដ្ឋាទី២ក៏បានយល់ព្រម ។ ចំណេរតមក ជម្លោះដណ្ដើមអំណា[illegible]ងស្ដេចខ្មែរជាឱកាសល្អបំផុតឲ្យយួនលូកដៃចូលមកជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងហើយដណ្ដើមយកបានទឹកដីខ្មែរមួយភាគធំ ។ នៅចុងស.វ.ទី១៧ ខេត្តកំពង់ស្រកាត្រី ព្រះសួគ៌ា កំពង់ក្របី-ព្រៃនគរត្រូវយួនបញ្ចូលជាអាណាខេត្តរបស់គេ ។ បន្ទាប់មកយួនយកបានខេត្តមេសរនិងលង់ហោរ ។ ដូច្នេះនៅដើមស.វ.ទី១៨ភូមិភាគខាងកើតនៃទន្លេមេគង្គត្រូវធ្លាក់ទៅក្នុងកណ្ដាប់ដៃយួនមួយរបអន្លើទៀត ដោយសារអ្នកផ្សងព្រេងចិនម្នាក់ឈ្មោះម៉ាក់គីវ(មកពីក្រុងកង់តុង) និងកូនចៅរបស់គាត់ជនជាតិយួនបានក្លាយទៅជាម្ចាស់ទឹកដីភូមិភាគកម្ពុជាក្រោមខាងលិចគឺពាម ស្វាយទង មាត់ជ្រូក បាពន់ ក្រមួនស ។ ទោះបីយ៉ាងហ្នឹងក៏ដោយ ក៏ជនជាតិខ្មែរបានប្រយុទ្ធតទល់និងយួនក្នុងខេត្តឃ្លាំង ពលលាវ ព្រះត្រពាំង ព្រែកឬស្សីរហូតដល់ពេលបារាំងមកដល់(១៨៥៨) ។

ការដែលស្ដេចយួននៅក្រុងវេបានធ្វើទុក្ខបុកម្នេញលើរូបអ្នកផ្សាយនិងអ្នកកាន់សាសនាគ្រិស្តជាលេសមួយយ៉ាងសំខាន់ឲ្យបារាំងធ្វើអន្តរាគមន៍ ។ ពួកអាណានិគមនិយមចំណូលថ្មីនេះបានវាយយកភូមិភាគព្រៃនគរ-ឧកញ៉ាចិន ដែលជាទឹកដីខ្មែរពីយួនមួយជាន់ទៀតក្នុងឆ្នាំ១៨៥៨ ។ តមកបារាំង

បានវាយយកកម្ពុជាក្រោមទាំងមូលទុកជាអាណានិគមរបស់គេហើយដែលគេឲ្យ ឈ្មោះហៅថាកូសាំងស៊ីនក្រោម (Basse Cochinchine) (១៨៦១) ។ ពីរឆ្នាំក្រោយ បារាំងបានដាក់ប្រទេសកម្ពុជាក្រោមអាណាព្យាបាលភាពរបស់គេទៀត (១៨៦៣) ។ ក្នុងសម័យនោះ បារាំងបានបញ្ចូលដោយខុសច្បាប់ខេត្តខ្មែរឈ្មោះដារទ្លាក់ (មានសុទ្ធតែជនជាតិខ្មែរ-មននៅ) ទៅក្នុងប្រទេសលាវរួច ទៅក្នុងប្រទេសយួន ។

Proper Names in Reading Passage 1

Places

ទន្លេយង់សេ		ខេត្តមេស	(My Tho, Vietnam)
ស្រីសន្ធរ		ខេត្តលង់ហោរ	(Vinh Long, Vietnam)
រយ៉ង	(in Thailand)	ពាម	(Hatien, Vietnam)
ណាងរោង	(in Thailand)	ស្វាយទង	(in Vietnam)
នគររាជ	(in Thailand)	មាត់ជ្រូក	(Chau Doc, Vietnam)
សុរិន្ទ	(in Thailand)	បាពាប	(Long Xuyen, Vietnam)
សង្គ័ក	(in Thailand)	ក្រមួនស	(Rach Gia, Vietnam)
ស៊ីបុន	(in Thailand)	ឃ្លាំង	(Soc Trang, Vietnam)
ចន្ទបូរ	(in Thailand)	ពលលាវ	(Bac Lieu, Vietnam)
ព្រៃនគរ	(in Vietnam)	ព្រះត្រពាំង	(Tra Vinh, Vietnam)
កំពង់ក្របី	(in Vietnam)	ព្រែកឫស្សី	(Can Tho, Vietnam)
ខេត្តកំពង់ស្រកាត្រី	(Bien Pha, Vietnam)	ទុកញ៉ាទិន	(in Vietnam)
ព្រះសួគ៌ា	(in Vietnam)	ដារទ្លាក់	(Da Lat Vietnam)

People

ជ័យវរ្ម័នទី៧
ព្រះបាទបរមរាជពញាយ៉ាត
ព្រះបាទអង្គចន្ទទី១
ជ័យជេដ្ឋាទី២
ម៉ាក់គីវ

NOTES FOR READING PASSAGE 1

Line 7. ក្នុងក្របខណ្ឌនេះហើយដែលគេឃើញ.. is translated 'it is in this frame- that they see ....' The structure phrase + ហើយដែល + clause is quite common both in writing and in speech.

Line 8. Note that the classifier for ព្រះពុទ្ធរូប 'Buddha image' is អង្គ , just as for monks and royalty.

DIALOGUE

ក្រោយអង្គរ

	បើ	if
	អង្កាល	when
១. ពូសៅ	បើនឹកពីច្បាំង នឹកឃើញពីអង្កាលជំនាន់អង្គរវត្តហើយ។	If we're thinking about war, we recall the Angkor period.
	មិនដល់	not as much as
២. សួន	ជំនាន់នោះ គេច្បាំងមិនដល់ជំនាន់នេះទេ! ឥឡូវនេះ មនុស្សស្លាប់រាប់មិនអស់។	They didn't fight then the way they do nowadays! Now countless people die.
៣. ពូសៅ	កយ! មិនដល់មែន តែគេ ច្បាំងរាប់រយឆ្នាំ ចាញ់ឈ្នះ ចាញ់ឈ្នះ។	It's true it's not the same, but (then) they fought for hundreds of years, won and lost, won and lost.
	ជិត	almost
	អស់រលីង	completely gone
៤. សួន	មែនទែនទៅ កាលណោះ យើងចាញ់ចង់ជិតអស់ដីរលីង។	In fact we lost so badly that we almost lost all our territory.
	កុំបាន ... កុំអី	if it were not for ...
	ដូចគេដូចឯង	like the others
៥. ពូសៅ	អានេះយកបន្តិច អានោះយកបន្តិច កុំបានគេជួយទាន់ កុំអីអស់ដីដូចគេដូចឯងដែរទៅហើយ។	These took some, those took some. If it weren't for the fact that we were helped in time, we would have lost everything like the others.
	គ្រា	time
	តាំង + verb	to start
៦. សួន	បាទ មកពីច្បាំងច្រើនដង ច្រើនគ្រាពេក ស្ដេចខ្មែរតាំងហៅបារាំងឲ្យមកជួយទៅ។	Yes, because of too much fighting, the Cambodian king then started to ask the French to come to help.
	v. + បន្តិចមិន + v.+បន្តិច	more or less
៧. ពូសៅ	បារាំងជួយបន្តិចមិនជួយបន្តិច តែធ្វើម៉េចបើមិនមែនស្រុកគេយ៉ាងហ្នឹងនោះ។	The French helped in a way and didn't help in a way, but what do you expect if it wasn't their country?

		តាមត្រូវ	In fact, logically
		អាណានិគម	colony
៨	ដួង	តាមត្រូវ ប្រទេសយើងមិនត្រូវ នៅក្រោមអាណានិគមបារាំង យូរយ៉ាងនោះទេ។	In fact our country shouldn't have been a French colony for so long.
		បើ	because
		ដែលថាមិន...ម៉េះ	certainly, why not
		សម្បូណ៌	plentiful
		សឹងសាប់	really (colloquial)
៩	ពូនៅ	ដែលថាមិនយូរម៉េះគួយ! បើ ស្រុកយើងសម្បូណ៌សប្បាយសឹង សាប់យ៉ាងហ្នឹងនោះ។	It was indeed long, because our country was really abundant and plentiful.
		ជ្រៀតជ្រែក	to interfere
		អេស្ប៉ាញ	Spanish
		ព័រទុយហ្គេ	Portuguese
		ប្រឹង	try, strive
១០	ដួង	អញ្ចឹងបានពួកអេស្ប៉ាញ ពួកព័រទុយហ្គេប្រឹងជ្រៀតជ្រែក យកស្រុកយើងធ្វើអាណានិគម ដែរ។	That's why the Spanish and Portuguese tried to interfere and get our country as a colony too.

NOTE FOR THE DIALOGUE

SENTENCE NO. 5 The pronouns ...គេ ...ឯង are often found paired with a meaning of 'people (in general), everyone, the others.' Some other examples of ...គេ ...ឯង are:

ខ្ញុំខ្មាសណាស់ ព្រោះគាត់ដើរប្រាប់គេប្រាប់ឯងអំពីរឿងនោះ។

I'm embarrassed because he went around telling everyone about that business.

គេសួរគាត់កណ្ដាលមុខគេមុខឯងតែម្ដង។

They asked him right in front of everyone.

Note that the phrase can be either មុខគេមុខឯង or មុខគេឯង, ប្រាប់គេប្រាប់ឯង or ប្រាប់គេឯង, etc., without any change in meaning.

DRILLS

DRILL ONE: Response

គំរូ

ក នឹកឃើញពីជំនាន់អង្គរទេ?
(និយាយពីចម្បាំង)

ខ បើនិយាយពីចម្បាំង នឹកឃើញពី
ជំនាន់អង្គរហើយ។

MODEL:

T: Do you recall about the Angkor Era?
(speak of war)

S: If we're talking about war, we certainly recall the Angkor Era.

ក គាត់ខឹងទេមើលទៅ?
(ប្រាប់គាត់ខុស)
បើប្រាប់គាត់ខុស គាត់ខឹងហើយ។

ខ ពួកនោះមកជួយទេ?
(ហៅគេភ្លាម)
បើហៅគេភ្លាម ពួកនោះមក
ជួយហើយ។

គ ពួកហ្នឹងរួមគំនិតគ្នាបះបោរទេ
មើលទៅ?
(និយាយពន្យល់ទៅ)
បើនិយាយពន្យល់ទៅ ពួកហ្នឹង
រួមគំនិតគ្នាបះបោរហើយ។

ឃ វាចង់ធ្វើការទេ?
(ឲ្យលុយឲ្យច្រើនទៅ)
បើឲ្យលុយឲ្យច្រើនទៅ វា
ចង់ធ្វើការហើយ។

ង គេជួយយើងទេ?
(ធ្វើការឲ្យត្រឹមត្រូវទៅ)
បើធ្វើការឲ្យត្រឹមត្រូវទៅ គេ
ជួយយើងហើយ។

ច ទាំងស្លូកដែលមកប្រៀបធៀបគេទេ?
(ភ្លេចខ្លួន)
បើភ្លេចខ្លួន ទាំងស្លូកដែលមក
ប្រៀបធៀបគេហើយ។

DRILL TWO: Transformation

គំរូ

ក គេធ្វើចម្បាំងខ្លាំងណាស់ ជំនាន់នោះ។
(ជំនាន់នេះ)

ខ គេធ្វើចម្បាំងមិនដល់ជំនាន់នេះទេ។

MODEL:

T: They fought hard in that time.
(this time)

S: They didn't fight as hard as they fight in this time.

ក ទាហានពីដើមមានការហ្វឹកហាត់ច្រើន
ណាស់។
(ទាហានសម័យនេះ)
ទាហានពីដើមមានការហ្វឹកហាត់មិន
ដល់ទាហានសម័យនេះទេ។

ខ ខ្មែរប្រសប់ប្រៀបធៀបក្នុងរឿងអន្តរ-
ជាតិណាស់។
(យួន)
ខ្មែរប្រសប់ប្រៀបធៀបក្នុងរឿងអន្តរ-
ជាតិមិនដល់យួនទេ។

គ យួនចេះធ្វើស្រែប្រាំងណាស់។
(ចិន)
យួនចេះធ្វើស្រែប្រាំងមិនដល់ចិនទេ។

ឃ ទាហានយើងចូលចិត្តប្រើកលល្បិចអា
ក្រក់ណាស់។
(ពួកខ្មាំង)
ទាហានយើងចូលចិត្តប្រើកលល្បិច
(អាក្រក់) មិនដល់ពួកខ្មាំងទេ។

ង បារាំងជំនាន់នេះកាចណាស់។
(ជំនាន់អាណានិគមនិយម)
បារាំងជំនាន់នេះកាចមិនដល់ជំនាន់
អាណានិគមនិយមទេ។

ច ទាហានធ្វើទុក្ខបុកម្នេញអ្នកស្រុកណាស់។
(ពួកខ្មាំងសត្រូវ)
ទាហានធ្វើទុក្ខបុកម្នេញអ្នកស្រុកមិន
ដល់ពួកខ្មាំងសត្រូវទេ។

DRILL THREE: Response

គំរូ

ក ច្បាំងយូរណាស់ យើងក៏មិនខាតប៉ុន្មានទេ។
(ដីអស់ស្ទើរលីង)

ខ ច្បាំងយូរណាស់ យើងខាតចង់ដីអស់ស្ទើរលីង។

MODEL:

T: The fighting was very long; we didn't lose out much.
(almost all (our) land was gone)

S: The fighting was very long; we lost out, and almost all our land was gone.

ក លោកមិនសូវ[illegible]ទេរឺ?
(លើកជើងមិនរួចហើយ)
ខ្ញុំ[illegible]ចង់លើកជើងមិនរួចហើយ។

ខ លោកពិសាស្រាដូចមិនស្រវឹង។
(ទាក់ស្ដីលម្ដងៗហើយ)
ខ្ញុំ(ញ៉ាំស្រាស្រវឹង)ចង់ទាក់ស្ដីលម្ដងៗហើយ។

គ លោកញ៉ាំដូចមិនទាន់ឆ្អែត?
(រហែកពោះទៅហើយ)
ខ្ញុំ(ញ៉ាំ)ឆ្អែតចង់រហែកពោះទៅហើយ។

ឃ ពលរដ្ឋយើងដូចមិនជួយរដ្ឋការសោះ។
(លក់ឥវ៉ាន់អស់ពីផ្ទះទៅហើយ)
ពលរដ្ឋយើងជួយរដ្ឋការចង់លក់ឥវ៉ាន់អស់ពីផ្ទះទៅហើយ។

ង ពួកឈ្លបច្បាំងដូចមិនដែលចាញ់។
([illegible]មិនឃើញទៅហើយ)
ពួកឈ្លបច្បាំងចាញ់ចង់[illegible]មិនឃើញទៅហើយ។

ច ធ្វើការឲ្យពួកហ្នឹងមិនចំណេញទេ។
(មិនដឹងយកលុយទៅណាទៅហើយ)
ធ្វើការឲ្យពួកហ្នឹងចំណេញចង់មិនដឹងយកលុយទៅណាទៅហើយ។

DRILL FOUR: Transformation

គំរូ

ក អស់ដីដូចគេដូចឯងទៅហើយ។
(គេជួយទាន់)

ខ កុំបានគេជួយទាន់ កុំអីអស់ដីដូចគេដូចឯងទៅហើយ។

MODEL:

T: To lose one's land like the others.
(they helped us in time)

S: If they hadn't helped us in time, we would have lost our land like the others.

ក មិនដឹងទៅហៅគេអ្នកណាមកជួយទេ។
(មានគ្រាប់សល់ខ្លះ)
កុំបានមានគ្រាប់សល់ខ្លះ កុំអីមិនដឹងទៅហៅគេអ្នកណាមកជួយទេ។

ខ ចាញ់គេទៅហើយ។
(កប៉ាល់ហោះជួយទម្លាក់គ្រាប់បែក)
កុំបានកប៉ាល់ហោះជួយទម្លាក់គ្រាប់បែក កុំអីចាញ់គេទៅហើយ។

គ ទ្រាំនឹងពួកវាមិនបានទេ។
(ទ័ពជំនួយមកទាន់)
កុំបានទ័ពជំនួយមកទាន់ កុំអីទ្រាំនឹងពួកវាមិនបានទេ។

ឃ មិនដឹងឈ្នះវាយ៉ាងម៉េចទេ។
(យើងមានគ្នាច្រើន)
កុំបានយើងមានគ្នាច្រើន កុំអីមិនដឹងឈ្នះវាយ៉ាងម៉េចទេ។

ង ស្រុកយើងពិបាកច្រើន។
(រំដោះខ្លួនពីអាណានិគមទាន់)
កុំបានរំដោះខ្លួនពីអាណានិគមទាន់ កុំអីស្រុកយើងពិបាកច្រើន។

ច សៀមដណ្ដើមយកខេត្តពីរបីបាត់។
(មានការគាំទ្រពីពួកជប៉ុន)
កុំបានមានការគាំទ្រពីពួកជប៉ុន កុំអីសៀមដណ្ដើមយកខេត្តពីរបីបាត់។

DRILL FIVE: Transformation

គំរូ

ក ហៅបារាំងឲ្យមកជួយទៅ។
(យើងភ័យពេក)

ខ យើងភ័យពេកក៏តាំងហៅបារាំងឲ្យមកជួយទៅ។

MODEL:

T: Call the French in to help.
(we were too afraid)

S: We were too afraid, so we called the French in to help.

ក នាំគ្នាបះបោរប្រឆាំងភ្លាមទៅ។
(យើងមិនដឹងនិយាយអីទៀត)
យើងមិនដឹងនិយាយអីទៀតក៏តាំងនាំគ្នាបះបោរប្រឆាំងភ្លាមទៅ។

ខ នាំគ្នារត់ចោលកន្លែងអស់។
(ទ្រាំនឹងគេមិនបាន)
ទ្រាំនឹងគេមិនបានក៏តាំងនាំគ្នារត់ចោលកន្លែងអស់។

គ ចាប់តែគ្នាឯងទៅ។
(មិនដឹងទៅចាប់អ្នកណា)
មិនដឹងទៅចាប់អ្នកណាក៏តាំងចាប់តែគ្នាឯងទៅ។

ឃ ដកខ្លួនថយបន្តិចម្ដងៗទៅ។
(ដល់មិនឃើញគ្នាឯងមកជួយ)
ដល់មិនឃើញគ្នាឯងមកជួយក៏តាំងដកខ្លួនថយបន្តិចម្ដងៗទៅ។

ង ចូលដៃនឹងគេទៅ។
(ដល់ឃើញគ្នាគេច្រើនពេក)
ដល់ឃើញគ្នាគេច្រើនពេកក៏តាំងចូលដៃនឹងគេទៅ។

ច លូកដៃមកជ្រៀតជ្រែកទៅ។
(ឃើញខ្មែរស្រួល)
ឃើញខ្មែរស្រួលក៏តាំងលូកដៃមកជ្រៀតជ្រែកទៅ។

DRILL SIX: Response

គំរូ

ក កាលណោះបារាំងជួយទេ?

ខ កាលណោះបារាំងជួយបន្តិច មិនជួយបន្តិច។

MODEL:

T: At that time, did the French help?

S: At that time the French helped more or less

ក ការពិតខ្មែរចង់ធ្វើចម្បាំងទេ?
ការពិតខ្មែរចង់ធ្វើចម្បាំងបន្តិច មិនចង់ធ្វើ(ចម្បាំង)បន្តិច។

ខ កម្មករខ្មែរយើងស្អប់បារាំងទេ?
កម្មករខ្មែរយើងស្អប់បារាំងបន្តិច មិនស្អប់បារាំងបន្តិច។

គ លោកយល់ទេកាលបារាំងឲ្យដីបាត់ដំបងទៅសៀម?
ខ្ញុំយល់បន្តិច មិនយល់បន្តិចកាលបារាំងឲ្យដីបាត់ដំបងទៅសៀម។

ឃ ខ្មែរយើងខឹងទេកាលស្ដេចខ្មែរយើងឲ្យដីខ្លះទៅយួន?
ខ្មែរយើងខឹងបន្តិច មិនខឹងបន្តិចកាលស្ដេចខ្មែរយើងឲ្យដីខ្លះទៅយួន។

ង ជំនាន់នោះខ្មែរចូលចិត្តស្ដេចទេ?
ជំនាន់នោះខ្មែរចូលចិត្តស្ដេចបន្តិច មិនចូលចិត្តស្ដេចបន្តិច។

ច កូនសិស្សភាគច្រើនចង់បះបោរទេ?
កូនសិស្សភាគច្រើនចង់បះបោរបន្តិច មិនចង់បះបោរបន្តិច។

DRILL SEVEN: Response

គំរូ

ក ប្រទេសយើងមានអ្នកចេះច្រើនណាស់។
(នៅក្រោមអាណានិគមបរទេស)

ឆ តាមត្រូវ ប្រទេសយើងមិនត្រូវនៅក្រោមអាណានិគមគេទេ។

MODEL:

T: Our country has many educated people.
(under the colonial rule of others)

S: In fact, our country should not be under the colonial rule of others.

ក ខ្មែរបេះបែកគ្នាណាស់។
(ដណ្ដើមអំណាចគ្នា)
តាមត្រូវ ខ្មែរមិនត្រូវដណ្ដើមអំណាចគ្នាទេ។

ខ យើងមានទាហានច្រើនណាស់ដើម្បីការពារកន្លែងនោះ។
(ឲ្យបាត់បង់កន្លែងនោះ)
តាមត្រូវយើងមិនត្រូវឲ្យបាត់បង់កន្លែងនោះទេ។

គ កន្លែងនោះសំខាន់ណាស់។
(ឲ្យគេមកទន្ទ្រានបាន)
តាមត្រូវ កន្លែងនោះមិនត្រូវឲ្យគេមកទន្ទ្រានបានទេ។

ឃ ពួកនោះខ្លាំងជាងគេទាំងអស់។
(ចាញ់គេ)
តាមត្រូវ ពួកនោះមិនត្រូវចាញ់គេទេ។

ង ទីស្ថានចាស់នោះសប្បាយណាស់។
(រើកចេញពីកន្លែងនោះ)
តាមត្រូវ ទីស្ថានចាស់នោះមិនត្រូវរើកចេញពីកន្លែងនោះទេ។

ច ជនជាតិខ្មែរស្រឡាញ់គ្នាណាស់។
(ច្បាំងគ្នាយ៉ាងនេះ)
តាមត្រូវ ជនជាតិខ្មែរមិនត្រូវច្បាំងគ្នាយ៉ាងនេះទេ។

DRILL EIGHT: Transformation

NOTE: There are two possible student responses. The first time through the drill use one type of response, then repeat the drill for the second time.

គំរូ.

គ: ប្រទេសយើងមិននៅក្រោមអាណានិគមបារាំងយូរទេ។

ស១. ប្រទេសយើងនៅក្រោមអាណានិគមបារាំងដែលថាមិនយូរនេះ។

ឬ:

ប្រទេសយើងដែលថាមិននៅក្រោម

ស២: អាណានិគមបារាំងយូរនេះ។

MODEL:

T: Our country was not a French colony for long.

S: Our country was certainly a French colony for a long time.

ក កាលណោះបារាំងវាយមិនចាញ់ជប៉ុនទេ។
កាលណោះបារាំងវាយដែលថាមិនចាញ់ជប៉ុននេះ។

ខ កាលណោះបារាំងមិនអនុញ្ញាតិឲ្យសៀមយកខេត្តខ្មែរទាំងបីទេ។
កាលណោះបារាំងដែលថាមិនអនុញ្ញាតិឲ្យសៀមយកខេត្តខ្មែរទាំងបីនេះ។

គ ពួកនោះមិនជ្រុំកំនិតនិងយួនទេ។
ពួកនោះដែលថាមិនជ្រុំកំនិតនិងយួននេះ។

ឃ. គាត់មិនទិញនិងទៀងប៉ុណ្ណឹងទេ។
គាត់ដែលថាមិនទិញនិងទៀងប៉ុណ្ណឹងនេះ។

ង មុនយួនមិនយកចិត្តបារាំងទេ។
មុនយួនដែលថាមិនយកចិត្តបារាំងនេះ។

ច បារាំងដូចមិនបង្វិលខេត្តទាំងបីនោះមកខ្មែរវិញទេ។
បារាំងដែលថាមិនបង្វិលខេត្តទាំងបីនោះមកខ្មែរវិញនេះ។

READING PASSAGE 2

" ភូមិតិរច្ឆាន "

រឿង "ភូមិតិរច្ឆាន" *"ព្រឹត្តិការណ៍ ១៨ មេសា"* ពុំមែនជារឿងយល់សប្តិរបស់អ្នកនិពន្ធទេ ប៉ុន្តែគឺជារឿងពិតនៅដើមសតវត្សទី ២០ នេះ ។

" ព្រឹត្តិការណ៍ ១៨ មេសា " នឹងបង្ហាញលោកអ្នកអានបានជ្រាបអំពីចលនាមហាបាតុកម្មមួយ ប្រឆាំងទល់នឹងអាណានិគមនិយមបារាំងសែស នៅឆ្នាំ ១៩២៨ ។ ចលនានេះមានសភាពឃោរឃៅ គួរឲ្យរំភើបក្រៃលែង ដែលបានផ្ទុះឡើងពីចំណោមកសិករខ្មែរដ៏សុទ្ធសាធ នៅភូមិក្រាំងលាវ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ក្រោមការដឹកនាំរបស់អ្នកក្លាហានពីរនាក់ គឺឈ្មោះ *ជួន* ខ និងឈ្មោះ *នៅ* ខ ដែលមានដើមកំណើតនិងទីលំនៅ នៅភូមិបន្ទាយអំពិល ឃុំព្រៃខ្មែរ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ពួកបាតុករបានសម្លាប់លោកបារាំងម្នាក់ឈ្មោះ *បារ ដេស* ដែលធ្វើជារ៉េស៊ីដង់ត៍ នៅខេត្តកំពង់ឆ្នាំង ហើយនឹងអ្នកបកប្រែភាសាម្នាក់ទៀតឈ្មោះ *សួន* ព្រមទាំងទាហានរក្សាស្រុកម្នាក់ឈ្មោះ *ឡាច* ដែលបានទៅតាមបារាំងនៅពេលនោះ ។

ពិតមែនតែអ្នកសិក្សាខ្មែរភាគច្រើន មិនសូវបានដឹងឮព្រឹត្តិការណ៍នេះ ប៉ុន្តែបើតាមយោបល់ផ្ទាល់យើងខ្ញុំយល់ថា រឿងដែលយើងខ្ញុំបានសរសេរជម្រាបនៅទំព័រខាងមុខនេះ ចាត់ទុកជាជាព្រឹត្តិការណ៍ដ៏ធំមួយនៅក្នុងប្រវត្តិសាស្ត្រជាតិយើង ។ ហើយព្រឹត្តិការណ៍នៅថ្ងៃ ១៨ មេសា ១៩២៨ ក៏បានពន្យល់ទុកនូវអនុស្សាវរីយ៍ដ៏ជូរចត់មួយដែរ ដល់អ្នកស្រុកក្រាំងលាវ ។

ចាស់ទុំនៅភូមិក្រាំងលាវសព្វថ្ងៃ ដែលមានអាយុ ៦០ បាយឆ្នាំឡើងទៅ គាត់នៅមិនទាន់ភ្លេច ព្រឹត្តិការណ៍ថ្ងៃ ១៨ មេសា នេះ នៅឡើយទេ ។ កាលណាគាត់នឹកឃើញដល់រឿងនេះ គាត់ហាក់ដូចជាចង់ញញឹមផង ចង់យំមិនចេញទឹកភ្នែកផង :–

១- គាត់ញញឹម ព្រោះគាត់យល់ថា មហាបាតុកម្មរបស់ប្រជាកសិករនៅក្រាំងលាវ នាថ្ងៃទី ១៨ មេសា ១៩២៥ នោះ គឺជាចម្លើយដ៏សមរម្យមួយចំពោះរដ្ឋការអាណាព្យាបាលបារាំងសម័យនោះឯង ដែលបានចងក្រៀកកូនខ្មែរ នៅក្រោមនឹមដែករបស់ខ្លួន អស់រយៈពេលជិតកន្លះសតវត្សមកហើយ ។ ជាពិសេសខ្មោចលោកធំបារាំង ដែលស្លាប់នៅភូមិក្រាំងលាវ ក្នុងថ្ងៃ ១៨ មេសា ១៩២៥ គឺស្លាប់នៅចំពោះមុខអ្នកទោសខ្មែរកប់រយនាក់ ដែលជើងទាំងពីរជាប់ខ្នោះឃ្នាងយ៉ាងរដោករង្វើយ អត់បាយក្រហាយទឹក ដោយសារតែគ្មានប្រាក់បង់ពន្ធដារជូនលោកធំ ។

២ - គាត់យំមិនចេញទឹកភ្នែក ព្រោះគាត់នឹកឃើញដល់អំពើសងសឹក យ៉ាងអមនុស្សធម៌របស់បារាំងទៅលើបណ្ដារាស្ត្រ ភូមិក្រាំងលាវ ដែលឥតវិញ្ញាណសោះនោះ ដោយបានចាត់ទាហានឲ្យដេញចាប់អ្នកស្រុកក្រាំងលាវទាំងប្រុសទាំងស្រី ផ្អើលកោលាហលជ្រួលច្របល់អស់ ១ ស្រុក រួចចងតម្រៀបគ្នាជាជួរ យកមកសួរចម្លើយនៅឯទីក្រុងកំពង់ឆ្នាំង បង្អត់បាយទឹកយ៉ាងវេទនា រួចកន្លងមកមិនដល់១០ថ្ងៃផង ស្រាប់តែមានចេញប្រកាសមួយ ចុះថ្ងៃទី ២៧ មេសា ១៩២៥ បង្គាប់ឲ្យហៅឈ្មោះភូមិក្រាំងលាវថា " *ភូមិតិរច្ឆាន* " ព្រោះគេបានសន្មតពួកបាតុករជាជាសត្វតិរច្ឆាន មិនស្គាល់ខុសត្រូវ ហ៊ានសម្លាប់លោកដ៏ជាធំ ! !

" *ភូមិតិរច្ឆាន* " គឺជាចំណាងដៃដល់អ្នកស្រុកក្រាំងលាវ បន្ទាប់ពីបានសម្លាប់បារាំងម្នាក់នោះមក ! ។ " *ភូមិតិរច្ឆាន* " គឺជាកេរ្តិ៍មរតករបស់អាណានិគមនិយមបារាំងសែស បន្ទាប់ពីបានចូលមកទឹមកប្រជាជនខ្មែរ នៅចុងសតវត្សទី ១៩ ។ ប៉ុន្តែបើតាមយោបល់យើងខ្ញុំបាទយល់ថា " *ភូមិតិរច្ឆាន* " គឺជាភូមិតិរច្ឆានជាន់ខ្ពស់ ដែលសត្វតិរច្ឆាននៅក្នុងភូមិនេះបានខិតខំរើបម្រះពីក្រោមនឹមដែក ដើម្បីទាមទារនូវអ្វីមួយដែលមនុស្សលោកត្រូវការចង់បានគ្រប់ៗគ្នា ប្រយោជន៍ឲ្យបានរស់នៅសមរម្យនឹងពេញលក្ខណៈជាមនុស្សឡើងវិញ ។

Reading Passage 2

Proper Names

Places	People
ភូមិក្រាំងលាវ	ស៊ិន
ស្រុកទេសារប្លៀរ	សៅ
ខេត្តកំពង់ឆ្នាំង	ប៉ាសេរិស
ភូមិបន្ទាយអំពិល	ស៊ុន
ឃុំព្រៃតាខ្ទរ	ម៉ាច

NOTE FOR READING PASSAGE 2

Line 1. This sentence may be more familiar to you if you insert ឲ្យ between បង្ហាញ and សេចក្ដីក្លាហាន.

VOCABULARY

កងតង	Canton
កណ្ដាប់ដៃ	grip
កម្ពុជាក្រោម	Lower Cambodia (portion of South Vietnam that was formerly Cambodian territory)
កលល្បិច	trick
ល្បិច	trick
កាលដើមឡើយ	originally, before
កូនចៅ	descendants
* កូសាំងស៊ីនក្រោម	Lower Cochin China (the Mekong Delta area)
កើន	to increase, to become more
កេរ្តិ៍មរតក /kee moradɔ?/	inheritance, heritage
កោលាហល	tense and angry
កោស	to scrape off
កុំបាន... កុំអី	if it were not for
ក្របខណ្ឌ	framework
ក្រប	frame
ខណ្ឌ /khan/	limit, period, partition
ក្រហាយ	to be painful (burning sensation)
*ក្រៀក	to be tied or to tie to something;
ក្រៃលែង	extremely, very much
ក្រោយពី	after
ក្លាយ	to change, to change into
ខិតខំ	to try, strive
ខិត	to move closer to; to move over
ខុសច្បាប់	against the law, illegal
*ខ្នោះឃ្នាង(ឃ្នាងAC)	shackles
ខ្នោះ	shackles
គាំទ្រ	to support, to back
គាំ	to support
ទ្រ	to support, to carry from the bottom

គ្រប់ៗគ្នា	all, everyone
ឃោរឃៅ	savage
ងុយដេក	sleepy (nonformal)
ចង់ (= ជិត)	about to, almost
ចត់	chalky-tasting, acrid
ចាស់ទុំ	old or mature person
ចំណងដៃ	gift (usually for a wedding)
ចំណុះ (< ចុះ)	to be subordinated, something dominated, subject, capacity (volume)
ចំណូល (< ចូល)	entry, act of entering
* ចំណេរមក	later, next
ជម្លោះ (< ឈ្លោះ)	quarreling, fighting
ជាស្ថាពរ	definite, permanently (formal)
* ជ្រួលច្របល់	to be mixed up
ច្របល់	to mix
ដងទន្លេ	the body or length of a river
ដងរែក = ដង្រែក	Dang Rek (name of a mountain range along the northwest border of Cambodia)
ដណ្តើម	to quarrel over, compete for
ដូចគេដូចឯង	like the others
ដែលចាំមិន +verb	certainly + verb
ត (នឹង)	to oppose, fight against
តមក	next, later
តាមត្រូវ	in fact, logically
តិរច្ឆាន	beast
បើ	if
តំណតមក (តំណ < ត + ត + មក)	next, later
ត្រួតត្រា (ត្រា AC)	to govern, supervise, run
ទន្ទ្រាន	to do illegally, to enter by other than established paths, to trespass

ទាមទារ	to claim, demand repeatedly
*ទាហាន[illegible]	soldiers with police powers
*ទឹម	to yoke
នា	at, in (literary)
នាយ	apart from (here: beyond)
នឹម	yoke (noun)
បង្វិល (< វិល)	to cause to turn, to return
បង្អត់	to deprive of
បណ្តាជន	populace, the people, population
បណ្តា	all the ..., the group of ,..
បណ្តារាស្ត្រ	the people
verb + បន្តិច មិន + V. + បន្តិច	more or less
*បម្រះ	to get out of, to escape from the grasp of, to move
*បវរ	high, noble
បរាជ័យ	defeat
បាត់បង់	to lose, be lost
បាតុករ	demonstrator
បារាំងសែស	France, French (français)
បុក[illegible]	to stir up trouble
បះបោរ	to riot, strike, have an uprising
ប្រគល់	to hand over, to give
ប្រយុទ្ធ	to fight
* យុទ្ធ (H)	to fight
ប្រយោជន៍	for the purpose of
ប្លាយ	more than, - odd (used with numbers)
ផ្តើម	to begin
ផ្ទៃក្នុង	internal, domestic
ឃុបឃិត	to collaborate, conspire
ផ្អើល	to be startled, scared
ពង្រីក (< រីក)	to expand (transitive)

ពន្ធដារ	tax
ព័រទុយហ្គ	Portuguese
ពុទ្ធសាសនិកជន /putthəsasnɨkəcún/	Buddhist (excluding clergy)
ពេញលក្ខណៈជា /-lé'khəna'-/	in full status as...
ព្រៃនគរ	Saigon
*ព្រះពុទ្ធរូប	image of Buddha
មានឋានៈជា	to have the status of
* ម៉ុងហ្គោល	Mongol
មូលគ្នា	to get together, to assemble
* មែកធាង	branches
មែក	branch
* ធាង	branch (of a palm tree)
យល់សប្តិ /yúl sɔp/	to dream
យើងខ្ញុំ	we
រកស៊ី	to earn a living
* រងាក់រងើយ	lethargic
រហ័ស	fast, rapid
រុករាន	to invade
រេស៊ីដង់	Résident (French provincial governor)
រំដោះ	to liberate
រំភើប	to be moved emotionally
* លង្វែក	Lovek (former Cambodian capital)
លូកដៃ	to reach out
លើកទ័ព	to raise or muster an army
លេស	pretext, excuse
លោកអ្នកអាន	readers
វិញ្ញាណ	consciousness, soul, spirit
* វេ	Huế (ancient Vietnamese capital)
សងសឹក	to take revenge
សមរម្យ /sɔmrúm/	good, logical (some what formal)
សម្បូរណ៍	plentiful, abundant
សាកលលោក	the whole world, universe
សឹងងាប់	really, extremely (colloquial)
សុទ្ធសាធ	true, real, pure
* ស្ថាពរ	definite, permanent (formal)
ហ្វឹកហាត់	to train, practise
number + ឡើងទៅ	from (number) up, (number) or more
អធិបតេយ្យ	sovereign
អនុស្សាវរីយ៍ /anu'saavərii/	souvenir, memento
អន្តរាគមន៍ /ɔntərəakum/	intervention
អន្លើ	region, part
អមនុស្សធម៌ /a'mənusəthóa/	inhumanity; inhumane
មនុស្សធម៌ /mənusəthóa/	humanity
អស់រលីង	completely gone
រលីង	barren
អាណាខេត្ត	subject territory
អាណាព្យាបាលភាព	protection
អាណាព្យាបាល	protectorate
អាណិកជន	resident alien
* អាណិក (H)	foreign, alien
*ឧដុង្គ	Oudong (former Cambodian capital)
អេស្ប៉ាញ	Spanish
អ្នកផ្សងព្រេង	adventurer
ផ្សងព្រេង	to have adventures
អ្នកផ្សាយសាសនា	missionary

APPLICATIONS

1. Find the word(s) that fit(s) the following definitions.

១ ពូជឬគ្រួសារដើម
២ កាលពីមុនយូរមកហើយ
៣ បន្ទាប់មក
៤ ឆ្ពោះទៅមុខទៅ
៥ ពេល ឬសម័យដែលតាំងស្តេចមួយអង្គៗ
៦ មើលការខុសត្រូវលើស្រុក ឬ ពួកមួយក្រុមៗ
៧ សាសនាមួយនៅស្រុកខ្មែរ ដែលខ្មែរនិយមថាជាព្រះពុទ្ធសាសនាដែរ
៨ ធ្វើឲ្យរួចពីអំណាច ក្រុមឬស្រុកណាមួយ
៩ ឈើឬរបស់មួយដែលគេដាក់កគោ ឬសត្វឯទៀតដើម្បីអូស
១០ របៀបពិសេសដែលធ្វើឲ្យសត្រូវចាញ់
១១ ព្រមឲ្យគេត្រួតត្រា

2. Correct the following sentences by adding the proper words.

១ កាលដើមពួកយើងរស់នៅទីនោះ។
២ ក្រោយមក មានការពិបាកច្រើនពេក យើងក៏គេចេញពីទីនោះ។
៣ ក្រោយពីពេលនោះ ក៏ធ្លាក់កណ្ដាប់ដៃយើង។
៤ តងណាទីបីក៏ស្ថិតកន្លែងដដែលវិញ។
៥ មិនយូរប៉ុន្មានយើងត្រួតត្រាបីម្ដងទៀត។
៦ គេបានប្រគល់យើងត្រួតត្រាវិញ។
៧ គេចូលមកធ្វើការទាក់ទងខ្មែរ។
៨ ពួកនោះមកស្រុកយើងឋានៈភ្ញៀវ។
៩ ពួកយើងក៏ក្លាយទៅម្ចាស់ទឹកដីស្រុកនោះទៅ។
១០ បន្ទាប់យើងក៏យកបានខេត្តនោះវិញ។

3. Define or describe the following words in Cambodian.

ត្រកូល របប សុខោទ័យ ទ័ព ខ្ញុំ ប្រាន
ទាស ស្លៀក លើកទ័ព ស្ថាពរ [illegible]
ដណ្ដើម សាង [illegible] [illegible] ទើប
ព្រឹត្តិការណ៍ យំមិនចេញ ឆ្ងល់ តាមទារ ប្រតិកម្ម ទឹកដៃ

4. Give a synonym for each of the following words.

ត្រកូល កាលដើមឡើយ សំដៅ [illegible] [illegible]
ត្រួតត្រា ឃោរឃៅ ក្លាយ កន្លងមក បង្ក្រាប
បន្ទាប់ពី ឱកាស ព្រាះទៅ បាត់បង់ដីទឹក
មិនយូរប៉ុន្មាន ក្រោយពី

5. Make short speeches or stories using the following sets of words.
   ១ បណ្ដាក្រុង អធិបតី ទំនាស់ អំណាចបក គាំទ្រ
   ២ ប្រយុទ្ធ ចំណុះ ការពារ ប្រកាស បញ្ជា អស់ទំលឹង
   ៣ សង្សឹក ស្ដេច អនុសញ្ញាសង្គ្រាម គ្រប់គ្រា កណ្ដាប់ដៃ
   ៤ កងស្បៀង នគរ ទឹកចិត្ត បារាំង ជាតិ ប្រកបេញ
   ៥ មានបានការ ក្រោយមក អន្ដរជាតិ អាណានិគម សេរី ដណ្ដើម

6. Have the student discuss the following subjects.
   ១ ជនជាតិដើមបំផុតនៅស្រុកនេះ។
   ២ សង្គ្រាមប្រជាជននៅស្រុកនេះ។
   ៣ ការកំសាន្តសប្បាយនៅស្រុកនេះជំនាន់ដើម។
   ៤ ការរស់នៅនៅក្រោមអាណានិគមអង់គ្លេស។
   ៥ Effects of English colonialism on American culture (e.g., religion, protestant ethnic, law etc.)

7. Questions for the teacher to ask.
   ១ ប្រជាជនស្រុកនេះមកពីណាខ្លះ?
   ២ ដំបូងបំផុត មានមនុស្សនៅកន្លែងណាមុនជាងគេ នៅស្រុកនេះ?
   ៣ តាំងពី២០០ឆ្នាំមុន មកដល់ឥឡូវនេះ ស្រុកនេះដែលមានសង្គ្រាមទេ?
   ៤ មនុស្សជំនាន់ដើមពិបាកយ៉ាងម៉េចខ្លះ?
   ៥ មនុស្សជំនាន់ដើមរកស៊ីធ្វើអីខ្លះ? គេសប្បាយយ៉ាងម៉េចខ្លះ?
   ៦ ហេតុអ្វីខ្លះបានជាស្រុកតាំងយ៉ាងនេះ?
   ៧ តំបន់ណាខ្លះដែលជាដើមកំណើតនៃស្រុកនេះ?
   ៨ មានដែលស្រុកណាគ្រប់គ្រងស្រុកនេះទេ? បើយ៉ាងម៉េចខ្លះដើម្បីរំដោះស្រុកនេះ?
   ៩ ហេតុអីខ្លះបានជាស្រុកនេះទៅជាសហរដ្ឋ?
   ១០ ឈ្មោះស្រុកនេះយកតាមស្រុកណាខ្លះ? ហេតុអី?

8. Questions for the student to ask.
   a. How does the French colonizing of Cambodia still show up in everyday life? That is what are the effects left by the French on Cambodians life?
   b. In what ways has Thai influence been felt in Cambodian life and customs? Vietnamese influence? Chinese?
   c. Was Cambodia ever a Thai colony?
   d. How did France come to take over Cambodia?
   e. How did they govern the country?
   f. Did they have troops occupying Cambodia?
   g. How much authority did the king have under the French?

h. Under what circumstances did the French Protectorate in Cambodia end? When?

i. Who were the major Cambodians in the effort to win independence?

j. Did Cambodia maintain a special relationship with France after independence? If so, of what kind?

k. Does your teacher feel that the Protectorate was a good thing for Cambodia? Why or why not?

l. What is the attitude of Cambodians toward the French nowadays?

LESSON ELEVEN

THE BUDDHIST RELIGION

a. Did the Buddha teach that there is any life after death?
b. What is the consequence of evil deeds in Buddhist theology? In popular belief?
c. What is done on ថ្ងៃសីល ?
d. Is fasting a frequent pratice for laymen?

ពុទ្ធប្រវត្តិ

- ព្រះពុទ្ធជាមនុស្ស បុត្រក្សត្រ កើតនៅប្រទេសឥណ្ឌា ។

- ព្រះពុទ្ធប្រសូត នៅថ្ងៃសុក្រ ១៥ កើត ខែវិសាខ ឆ្នាំច មុន គ.ស ៦២៤ ឆ្នាំ ក្នុងឧទ្យានលុម្ពិនី ក្រុងកបិលពស្តុ ទ្រង់ព្រះនាមថា «សិទ្ធត្ថ» (អ្នកធ្វើឲ្យសម្រេចប្រយោជន៍គ្រប់យ៉ាង, សំ - សិទ្ធាថ៌) ក្នុងវង្ស គោតម ។

- ព្រះបិតា ព្រះនាម សុទ្ធោទន៍, ព្រះមាតា ព្រះនាម សិរីមហាមាយា សោយរាជ្យនៅនគរកបិលពស្តុ (ប្រទេសនេប៉ាល់ សព្វថ្ងៃ) នាសតវត្សទី ៧ មុន គ.ស ។

- ព្រះសិទ្ធត្ថ បានសិក្សាវិជ្ជាផ្សេង ៗ ព្រមទាំងសិក្សាចេះចប់គម្ពីរត្រៃវេទ តាមលទ្ធិព្រាហ្មណ៍ក្នុងសំណាក់ព្រះគ្រូពិស្វាមិត្រ ។

- លុះព្រះជន្ម បាន ១៦ វស្សា ទ្រង់បានរៀបអភិសេកជាមួយនឹងព្រះនាងពិម្ពាយសោធរា (ដែលត្រូវជាបងប្អូនជីដូនមួយ បុត្រីស្តេចសុប្បពុទ្ធ) ។

- ព្រះសុទ្ធោទន៍ ជាបិតា បានឲ្យគេសង់ប្រាសាទ ៣ ថ្វាយព្រះសិទ្ធត្ថ សម្រាប់ទៅតាមរដូវទាំង ៣ : ក្តៅ ត្រជាក់ រំហើយ ។

- ទ្រង់បានជួបប្រទះឃើញ មនុស្ស ៤ ពួក គឺមនុស្សចាស់ ឈឺ ស្លាប់ និងអ្នកបួស នៅពេលដែលព្រះអង្គបានយាងចេញក្រៅពីវាំង ធ្វើទស្សនកិច្ច ជុំវិញទីក្រុង ។ មនុស្សទាំង ៤ ប្រភេទនេះ បានធ្វើឲ្យព្រះអង្គកើតសង្វេគយល់បញ្ហាជីវិត និងការឈឺចាប់ ទុក្ខវេទនា នៃមនុស្សសត្វ ។

- ព្រះសិទ្ធត្ថមានបុត្រមួយ នាមរាហុល ។

- លុះព្រះជន្មបាន ២៩ វស្សា , ក្រោយដែលបានវិលត្រឡប់អំពីឧទ្យាន ដែលទ្រង់បានទតឃើញភេទអ្នកបួស អំពីថ្ងៃ, ពេលកក្រើស្ងាត់ ព្រះសិទ្ធត្ថបានបោះបង់ចោលកផលសម្បត្តិ មហេសីនិងបុត្រ យាងចេញសាងផ្នួស ចម្ងាយផ្លូវ ៣០ យោជន៍ នៅទៀបឆ្នេរស្ទឹងអនោមានទី ក្នុងថ្ងៃព្រហស្បតិ៍ ១៥ កើត ខែអាសាឍ ឆ្នាំថោះ ។

- លុះបួសរួច ព្រះអង្គបានទៅសិក្សារៀនសូត្រ ក្នុងសំណាក់តាបស ពីររូប ដែលបានសម្រេចឈានជាន់ខ្ពស់ គឺ ឧទកតាបស និង អាឡារតាបស តែពុំបានរកឃើញនូវសច្ចធម៌ ដែលជាមាគ៌ារំលត់ទុក្ខសោះឡើយ ។ ម្ល៉ោះហើយ ព្រះអង្គចាំបាច់ត្រូវតែសុំលាតាបសទាំងពីររូប ចេញទៅស្វែងរកសិក្សា ស្រាវជ្រាវតែរក តទៅទៀត នូវសច្ចធម៌ ។

- ព្រះអង្គបានខំប្រឹងព្យាយាម តស៊ូ ស្វែងរកមោក្ខធម៌ មាគ៌ារំលត់ទុក្ខ ដោយធ្វើទុក្ករកិរិយា អស់រយៈកាល៦ឆ្នាំ លុះត្រាតែទ្រង់បានសម្រេចសម្មាសម្ពោធិញ្ញាណ ចេះដឹង

យល់ ស្គាល់ សច្ចៈគ្រប់ទាំងអស់ ដែលហៅថា ត្រាស់ដឹង ។

– ទ្រង់បានត្រាស់ដឹង ជាព្រះពុទ្ធ នៅថ្ងៃពុធ ១៥ កើត ខែវិសាខ ឆ្នាំរកា ក្នុងព្រះជន្មាយុ ៣៥ ឆ្នាំ (៥៨៩ ឆ្នាំមុន គ.ស) នៅក្រោមដើមពោធិព្រឹក្ស ខេត្ត ពិហារ សព្វថ្ងៃ ។

– ព្រះពុទ្ធបានយាងទៅទេសនា លើកទី ១ « បឋមទេសនា » មានឈ្មោះថា «ធម្មចក្រ ឬ ធម្មចក្កប្បវត្តនសូត្រ» ប្រោសភិក្ខុបញ្ចវគ្គិយ ចំនួន ៥ រូប, ដែលជាសហការីចាស់ នៅក្នុងព្រៃឥសិបតនមិគទាយវ័ន ក្បែរក្រុងពារាណសី ។

– ទ្រង់បានយាងទេសនា ប្រោស សត្វ ដោយពុំមាន ប្រកាន វណ្ណៈ ឋានៈ សោះឡើយ ជាពិសេស ទ្រង់បានប្រកាសផ្សាយរំលាយ វណ្ណៈ ផងទៀត ។

– ព្រះពុទ្ធ ទ្រង់ ទេសនា ទូន្មាន ប្រៀនប្រដៅ មនុស្ស សត្វអស់រយៈកាល ៤៥ ឆ្នាំ មានពុទ្ធវចនៈ ទាំងអស់ ចំនួន ៨៤០០០ ធម្មក្ខន្ធ ។

– ព្រះពុទ្ធ បរិនិព្វាន ក្នុងព្រះជន្មាយុ ៨០ ឆ្នាំ ត្រូវនៅថ្ងៃអង្គារ ១៥ កើតខែវិសាខ ឆ្នាំម្សាញ់ មុន គ.ស ៥៤៣ ឆ្នាំ ក្រោមដើមសាលព្រឹក្សទាំងគូ បណាទៀបក្តិ នាក្រុង កុសិនារា (សព្វថ្ងៃហៅឧត្តរប្រទេស) ។

Proper Names in Reading Passage 1

People

សិទ្ធត្ថ	/sɨthoat/	(Siddhartha)
គោតម	/koodɑm/	(family name)
សុទ្ធោទន៍	/sutho̍ot/	(Buddha's father)
សិរីមហាមាយា	/sereymɑhaa mlayia/	(Buddha's mother)
ពិស្វាមិត្រ	/piʔsvnamɨt/	
ពិម្ពាយសោធរា	/pɨmpiaysaothoria/	(Buddha's wife)
សុប្បពុទ្ធ	/sopoput/	
រាហុល	/riahol/	(son of Buddha)

Places

ឧទ្យានលុម្ពិនី		
ក្រុងកបិលពស្តុ	/kəbəl pŏh/	
ស្ទឹងអនោមានទី	/aʔnaomaantii/	
ខេត្តពិហារ	/piʔhia/	(Bihar)
ឥសិបតនមិគទាយវ័ន	/εysɨptɔnəmɨkətiayəvŏn/	
ក្រុងពារាណសី	/piarianəsεy/	
ក្រុងកុសិនារា	/koʔsənəria/	
ឧត្តរប្រទេស		(Uttar Pradesh, India)

NOTES FOR READING PASSAGE 1

Line 3. In lesson 30 of the Introduction mention was made of the fact that two types of calendar are used in Cambodia. The calendar based on the sun is used in the cities for most secular activities; the calendar based on the phases of the moon is used in the Buddhist religion and for most activities in the country.

The months of the lunar calendar begin with the new moon. The full moon is in the middle of the month, and the old moon is at the end. Each month is divided into two two-week segments: ខ្នើត 'period of the waxing moon' and រនោច 'period of the waning moon.' Lunar dates give the day, and the phase of the moon (កើត 'waxing moon' or រោច 'waning moon'), and the name of the month, e.g., ᧣ ៦ៈ ថ្ងៃចន្ទ បីកើត ខែពិសាខ 'Monday the third day of the waxing moon in the month of Pisak). Note that in a lunar calendar date the number written above the symbol ᧠ indicates a day in the two weeks of waxing moon, while a number under the symbol ᧠ indicates one of the fifteen days of waning moon, e.g.,

១ក្ខ ៦: ថ្ងៃចន្ទ បីរោចខែពិសាខ Monday the third day of the waning moon in the month of Pisak.' Also note that Monday is the first day of the Cambodian week).

The first month of the lunar year is មិគសិរ , which corresponds to the last half of November and the first half of December. The first day of this month is not celebrated as the Cambodian New Year; instead the new year celebration occurs on the first day of ពិសាខ , which is really the sixth month. This date coincides with the season that the rice harvest is finished and a new farm cycle is ready to begin. The lunar months are presented below. You do not need to learn to produce them at this point, but you should be able to recognize them when you see them.

1.	មិគសិរ	/mɨkkəsee/	mid November - mid December
2.	បុស្ស	/boh/	mid December - mid January
3.	មាឃ	/miak/	mid January - mid February
4.	ផល្គុន	/phɔlkún/	mid February - mid March
5.	ចេត្រ	/caɛt/	mid March - mid April
6.	ពិសាខ	/pisaak/	mid April - mid May
7.	ជេស្ឋ	/ceeh/	mid May - mid June
8.	អាសាឍ	/aasaat/	mid June - mid July
9.	ស្រាពណ៍	/sraap/	mid July - mid August
10.	ភទ្របទ	/phóttəbót/	mid August - mid September
11.	អាស្សុជ	/aasoc/	mid September - mid October
12.	កត្តិក	/kədək/	mid October - mid November

Line 4. Traditional Cambodian dates are figured in terms of a 12-year cycle, each year of which is named for an animal. The cycle is the same as that used by the Chinese and Vietnamese.

It is extremely important to astrological calculations and is more widely used in Cambodia than the Zodiac with which we are familiar. Horoscope sections in newspapers, for instance, are arranged by year of birth in the 12-year cycle.

The years and their names, in order, are:

	year name	common equivalent		years in which it falls
1.	ជូត	កណ្ដុរ	rat	1936, 48, 60, 72
2.	ឆ្លូវ	គោ	cow, ox	1937, 49, 61, 73
3.	ខាល	ខ្លា	tiger	1938, 50, 62, 74
4.	ថោះ	ទន្សាយ	rabbit	1939, 51, 63, 75

5.	រោង	នាគ	dragon	1940, 52, 64, 76
6.	ម្សាញ់	ពស់	snake	1941, 53, 65, 77
7.	មមី	សេះ	horse	1942, 54, 66, 78
8.	មមែ	ពពែ	goat	1943, 55, 67, 79
9.	វក	ស្វា	monkey	1944, 56, 68, 80
10.	រកា	មាន់	cock, chicken	1945, 57, 69, 81
11.	ច	ឆ្កែ	dog	1946, 58, 70, 82
12.	កុរ	ជ្រូក	pig	1947, 59, 71, 83

These names are given for reference.

Line 13. The word វស្សា 'rainy season' is used here to mean 'year.'

Line 26. In this sentence អំពី has the same meaning as កាលពី 'when.'

Line 29. Here the word ជាប means ជិត 'near.'

Line 50. In this case the word សត្វ refers to any being with the capacity to understand the Buddha's preaching.

Line 57. Note that the Buddha was born, achieved enligntment, and died (entered Nirvana) on the same day, the 15th day of the waxing moon of the month of ពិសាខ, which corresponds to early May in the solar calendar. This day is celebrated in Buddnist countries as វិសាខបូជា, the anniversary of Buddha's birth, death and enligntment.



DIALOGUE

ចង្ហាន់ទៅលោកនៅវត្ត

		ចានស្រាក់	(see note)
១	កូន	សម្លបាយនៅក្នុងចានស្រាក់ ហ្នឹង ទុកឲ្យអ្នកណា? ម៉ែ។	Who's the food in the carrier for, Mom?
		លូក	to reach
		ទុកឲ្យ	to keep for
		យាយ	grandmother
		វត្ត	wat
២	ម៉ែ	នែ៎ះ កុំលូកណា៎ អាហ្នឹងទុក ឲ្យយាយយកទៅវត្តទេ។	Now, don't touch! That's for grandmother to take to the wat.
		ចាប់	to take
		ផង	(see note)
៣	កូន	ខ្ញុំចាប់បន្តិចបានទេ? នៅក្នុង ឆ្នាំងអត់អីផងមានតែបាយ។	Can I take a little bit? There's nothing in the pot, just rice.
		ឆ្កេសឆ្កាស	silly, mischievous
		ថ្ងៃ៨	(see note)
		គិប + clause	watch out that ..., be careful that
		ក្អែក	crow
		ត្មាត	vulture
៤	ម៉ែ	នែ៎ះ កុំឆ្កេសឆ្កាស ថ្ងៃហ្នឹង ត្រូវថ្ងៃ៨ផង គិបកើតទៅ ជាក្អែក ជាត្មាតទៅ។	Don't be silly. Today is the eighth day. Watch out that you aren't reborn as a crow or a vulture.
		សីល	religious rule, precept, pity, grace
		verb + ទេះ + verb noun + ទេះ + noun	too much
		សីលទេះសីល	too much piety
		ប្រគេន	to give (to a monk)
៥	កូន	សីលទេះសីល បន្តិចសីល៥ បន្តិចសីល៨។ អាណាល្អៗ យកទៅប្រគេនលោកអស់។	There's too much piety around here. If it isn't the 5 precepts, it's the 8 precepts. Anything good gets taken to give to the monks.

ខ្ញាំងរង	to be disobedient, bad (child)
មុខតែ	surely
ចុះ	to descend
នរក	Hell

៦ ឪព ឯង កុំខ្ញាំងរងពេក។ តែ យ៉ាងហ្នឹង មុខតែចុះនរក មិនខានទេហើយ។ — Don't get out of hand, now. If you do like that, you'll surely go to Hell.

ជាតិក្រោយ	next life, next incarnation
ចមោច = ស្រមោច	ant (spoken)
ចស្លាច = សស្លាច	large black ant (spoken)
អីក៏ដោយ	anything
ចុះ	(see note)
ឲ្យតែ	as long as

៧ កូន ជាតិក្រោយទៅជាចមោច ចស្លាចអីក៏ដោយចុះ ឲ្យតែ បានញ៉ាំអីឆ្ងាញ់ទំនេះសិន។ — I don't care if I'm an ant or anything in my next life as long as I get to eat something good right now.

យី	gee!
អានេះ	this (kid)
ថ្លើម	liver
ថ្លើមធំ	fresh, disrespectful
ចេញពី	to originate, come from
កាត់មក/ដោតក	to take after
អាចេះ = អញ្ចេះ	thus (spoken)

៨ ម៉ែ យី អានេះអីក៏ថ្លើមធំម្ល៉េះ? ចេញមកពីណាមក? គ្មាន កាត់មកតែអញទេនោះអាចេះ។ — Gee! this kid - how did he get so disrespectful? Where did he come from? He didn't get it from me, I hope.

អើយ	vocative particle (begging for gentleness)
ខឹងសម្បា	angry, mad
កុំខឹងកុំសម្បា	don't be angry

៩ កូន ខ្ញុំនិយាយលេងទេ ម៉ែអើយ កុំខឹងកុំសម្បាអី។ — I'm just kidding, Mon. Don't get angry.

ឲ្យតែ	whenever
តែ	if

ត្រូវបោក — to be scolded

អស់ចិត្ត — to give up

១០ ន័ប ន័ឯងនេះ ចេះតែនិយាយ ទៀត បើមិនបានត្រូវបោក មិនអស់ចិត្តទេ។ — You! whenever you speak up, if you are not told off, you never give up!

NOTES FOR THE DIALOGUE

SENTENCE NO. 1 A ចានស្រាក់ is a kind of food carrier that consists of nested containers stacked vertically, each serving as cover for the one below it, except for the top one, which has a lid. The stacked containers are held together by a removable handle which has a hinged piece that swings down to keeps the lid in place.



When monks go out in the morning to collect food, they ordinarily carry a large covered rice bowl បាត្រ and a ចានស្រាក់ for the meat and vegetable dishes they may be given. Sometimes the monk carries only the rice bowl, and a young boy living or studying at the wat follows with the ចានស្រាក់.

SENTENCE NO. 3 ផង in this sentence indicates a negative statement which is in some way contrary to previous expectation. It must follow a negative clause to have this meaning. Another example:

ចេះឲ្យដឹងយ៉ាងម៉េច បើខ្ញុំមិនបានទៅផង។

How do you expect me to know, if I didn't even get to go.

SENTENCE NO. 4 In the lunar calendar each month is divided into two periods, the waxing moon and waning moon. Each period consists of 14 or 15 days depending on whether it is a 28-day month or a

30-day month.

ថ្ងៃសីល 'day of abstinence and religious observance' refers normally to the 8th and the 15th day of each period.

ថ្ងៃកោរ 'day to shave' refers to either the day preceding the full moon or the day before the last day of the month when the monks shave their heads.

SENTENCE NO. In this sentence ចំ adds a meaning of 'as a matter of fact' or 'it happens that....' e.g.,

[illegible]

It happens that today is the 8th day (of the lunar month).

SENTENCE NO. Note that the idiom ...ណាស់ ... in this sentence can be used with a noun, with a verb, with a phrase, or with a clause. When it begins with a phrase or clause, the second repetition of the phrase or clause will normally include only the verb, e.g.,

[illegible]

If you go out too much, watch out you don't fail your exam.

[illegible]

My wife keeps following me around, and I can't do anything at all.

SENTENCE NO. 7 The word ចុះ has the connotation of 'go ahead and ...' or 'let (it) ...,' e.g.,

[illegible]

Let my next life be that of an ant! (I don't care.)

SENTENCE NO. The form [illegible], [illegible], [illegible], would only used to or about people who are on intimate terms with the speaker or whom the speaker wishes to insult.

DRILLS

DRILL ONE: Response

គំរូ

ក: សម្លបាយនៅនឹងចានស្រាក់ហ្នឹង ទុកឲ្យអ្នកណា?
(លូក - ជូនយាយយកទៅវត្ត)

ខ: ទេណា កុំលូកណា៎ អាហ្នឹងទុកជូនយាយយកទៅវត្តទេ។

MODEL:

T: Who are you keeping the food in the carrier for?
(reach - for Grandmother to take to the wat)

S: Now don't reach. That's for Grandmother to take to the wat.

ក នំនៅនឹងចានហ្នឹង ទុកយកទៅណា?
(ចាប់ - យកទៅប្រគេនលោកតា)
ទេណា កុំចាប់ណា៎ អាហ្នឹងទុកយកទៅប្រគេនលោកតាទេ។

ចបសហ្នឹងទុកធ្វើអី?
(យកទៅណា - ជូនយាយយកទៅធ្វើបុណ្យ)
ទេណា កុំយកទៅណាណា៎ អាហ្នឹងទុកជូនយាយយកទៅធ្វើបុណ្យទេ។

គ បង្អែមនៅនឹងឆ្នាំងហ្នឹង ទុកប្រគេនលោកណា?
(ប្រគេនលោកណា - ប្រគេនលោកគ្រូ)
ទេណា កុំប្រគេនលោកណាណា៎ អាហ្នឹងទុកប្រគេនលោកគ្រូទេ។

ឃ ម្ហូបទាំងអស់ហ្នឹងទុកធ្វើអី?
(ផ្ដេសផ្ដាស - និមន្តលោកឆាន់ស្អែក)
ទេណា កុំផ្ដេសផ្ដាសណា៎ អាហ្នឹងទុកនិមន្តលោកឆាន់ស្អែកទេ។

ង អីវ៉ាន់នៅលើតុហ្នឹង ទុកជូនអ្នកណា?
(កាន់ - ជូនតាយកទៅសុំសីល)
ទេណា កុំកាន់ណា៎ អាហ្នឹងទុកជូនតាយកទៅសុំសីលទេ។

ច ក្រណាត់នេះទុកកាត់ខោអាវឲ្យអ្នកណា?
(យក - កាត់ធ្វើចីវរលោក)
ទេណា កុំយកណា៎ អាហ្នឹងទុកកាត់ធ្វើចីវរលោកទេ។

DRILL TWO: Substitution

គំរូ

ក: កុំលូកណា៎ ទុកឲ្យយាយយកទៅវត្តទេ។
(ស៊ី - ប្រគេនលោក)

ខ: កុំស៊ីណា៎ ទុកឲ្យយាយប្រគេនលោកទេ។

MODEL:

T: Don't reach (it). I'm keeping it for Grandmother to take to the wat.
(eat - give to the monks)

S: Don't eat (it). I'm keeping it for Grandmother to give to the monks.

កុំស៊ីណា៎ ទុកឲ្យយាយប្រគេនលោកទេ។

ក យកទៅស្ល - ធ្វើបង្វាន់ទៅវត្ត
កុំយកទៅស្លណា៎ ទុកឲ្យយាយធ្វើបង្វាន់ទៅវត្តទេ។

ខ ឲ្យគេខ្ចង - ជូនលោកតា
កុំឲ្យគេខ្ចងណា៎ ទុកឲ្យយាយជូនលោកតាទេ។

គ ប្រើទៀនធូបហ្នឹង - ប្រើនិមន្តលោក

កុំព្រួយខ្វល់នឹងរឿងណា ចុះឱ្យយាយយាយ
ព្រួយនិមន្តលោកទេ។

ឃ សី ដាក់បាត្រលោក
កុំសីណា ចុះឱ្យយាយដាក់បាត្រលោកទេ។

ង យកទៅឱ្យគេ - ពីសា
កុំយកទៅឱ្យគេណា ចុះឱ្យពីសាទេ។

ច ឱ្យអ្នកណា - ឱ្យតាទៅសុំសីល
កុំឱ្យអ្នកណាណា ចុះឱ្យតាទៅសុំសីលទេ។

DRILL THREE: Equivalence

គំរូ

ក នៅក្នុងឆ្នាំងអត់អីអញ្ចឹង មានតែបាយ។

ខ នៅក្នុងឆ្នាំងអត់អីផង មានតែបាយ។

MODEL:

T: There's nothing in the pot, just rice.

S: There's nothing in the pot, just rice.

ក ថ្ងៃហ្នឹង អត់អីញ៉ាំអញ្ចឹង មានតែត្រីងៀត។
ថ្ងៃហ្នឹង អត់អីញ៉ាំផង មានតែត្រីងៀត។

ខ ល្ងាចនេះគ្មានឃើញអ្នកណាអញ្ចឹង ឱ្យខ្ញុំនៅទេម៉ែ។
ល្ងាចនេះគ្មានឃើញអ្នកណាផង ឱ្យខ្ញុំនៅទេម៉ែ។

គ ម៉ែ ខ្ញុំអត់អីស្លៀកអញ្ចឹង ខ្ញុំអត់ទៅវត្តទេ។
ម៉ែ ខ្ញុំអត់អីស្លៀកផង ខ្ញុំអត់ទៅវត្តទេ។

ឃ ព្រឹកមិញ គ្មានអីស្លក់អញ្ចឹង មានតែបន្លែ។
ព្រឹកមិញ គ្មានអីស្លក់ផង មានតែបន្លែ។

ង ខ្ញុំគ្មានអីសងគុណឪពុកម្ដាយខ្ញុំអញ្ចឹង មានតែទៅបួស។
ខ្ញុំគ្មានអីសងគុណឪពុកម្ដាយខ្ញុំផង មានតែទៅបួស។

ច ម៉ោងនេះគ្មានឃើញកូនសិស្សអញ្ចឹង ឃើញតែលោកគប។
ម៉ោងនេះគ្មានឃើញកូនសិស្សផង ឃើញតែលោកគប។

DRILL FOUR: Response

គំរូ

ក ថ្ងៃស្អែក ធ្វើចង្ហាន់ប្រគេនលោកទេ?
(ថ្ងៃ៨)

ខ ថ្ងៃស្អែកត្រូវថ្ងៃ៨ផង ធ្វើចង្ហាន់ប្រគេនលោកម្ដង។

MODEL:

T: Tomorrow are you going to make food for the monks?
(the 8th day)

S: Tomorrow's the 8th day; I'll make food for the monks.

ក ថ្ងៃស្អែក និមន្តលោកឆាន់ទេ?
(ថ្ងៃខួបយាយ)
ថ្ងៃស្អែកត្រូវថ្ងៃខួបយាយផង និមន្តលោកឆាន់ម្ដង។

ខ ថ្ងៃស្អែក ទៅដាក់បាត្រលោកនៅវត្តទេ?
(ថ្ងៃ៨)
ថ្ងៃស្អែកត្រូវថ្ងៃ៨ផង ទៅដាក់បាត្រលោកនៅវត្តម្ដង។

គ ថ្ងៃស្អែក និមន្តលោកទេសនាទេ?
(បុណ្យ១០០ថ្ងៃតា)
ថ្ងៃស្អែកត្រូវបុណ្យ១០០ថ្ងៃតាផង និមន្តលោកទេសនាម្ដង។

ឃ. ស្អែក ធ្វើចង្ហាន់ទៅវត្តទេ?
(ថ្ងៃសីល)
ស្អែកត្រូវថ្ងៃសីលផង ធ្វើចង្ហាន់
ទៅវត្តម្តង។

ង. ស្អែក ទៅលេងលោកតាទេ?
(ថ្ងៃបុណ្យ)
ស្អែកត្រូវថ្ងៃបុណ្យផង ទៅលេង
លោកតាម្តង។

ច. ស្អែក គិតលួចចេញមុនម៉ោងទេ?
(អ្នកគ្រូស្នងបង្រៀន)
ស្អែកត្រូវអ្នកគ្រូស្នងបង្រៀនផង
គិតលួចចេញមុនម៉ោងម្តង។

DRILL FIVE: Double Substitution

គំរូ

ក កុំឆ្កួសឆ្កាស ថ្ងៃហ្នឹងត្រូវថ្ងៃ៨ផង។
(យើង - ចៅជគុណធំ)

ខ កុំឆ្កួសឆ្កាស យើងត្រូវចៅជគុណា
ធំផង។

MODEL:

T: Don't act silly, today's the 8th day.
(we have (as a visitor) - the head monk)

S: Don't act silly, we have the head monk (as a visitor).

កុំឆ្កួសឆ្កាស យើងត្រូវចៅជគុណា
ធំផង។

ក. ថ្ងៃហ្នឹង - ថ្ងៃសីល
កុំឆ្កួសឆ្កាស ថ្ងៃហ្នឹងត្រូវថ្ងៃសីល
ផង។

ខ លោក - ក្រាប់
កុំឆ្កួសឆ្កាស លោកត្រូវក្រាបផង។

គ ស្អែក - ថ្ងៃបុណ្យ
កុំឆ្កួសឆ្កាស ស្អែកត្រូវថ្ងៃបុណ្យផង។

ឃ ស្អែក - វេនយើង
កុំឆ្កួសឆ្កាស ស្អែកត្រូវវេនយើងផង។

ង ថ្ងៃសីលហ្នឹង - វេនឯងផង
កុំឆ្កួសឆ្កាស ថ្ងៃសីលហ្នឹងត្រូវវេនឯង
ផង។

ច យើង - ថ្ងៃសូត្រធម៌
កុំឆ្កួសឆ្កាស យើងត្រូវថ្ងៃសូត្រធម៌
ផង។

DRILL SIX: Transformation

គំរូ

ក កុំឆ្កួសឆ្កាស ប្រយ័ត្នកើតទៅជាក្អែក។

ខ កុំឆ្កួសឆ្កាស គិចកើតទៅជាក្អែក។

MODEL:

T: Don't be silly. Be careful you don't get born as a crow.

S: Don't be silly. Watch out you don't get born as a crow.

ក ខំខ្ជិលរៀន ប្រយ័ត្នដាំបាយ។
ខំខ្ជិលរៀន គិចដាំបាយ។

ខ កុំបើកល្បឿនអញ្ចឹង ប្រយ័ត្នមាន
គ្រោះថ្នាក់។
កុំបើកល្បឿនអញ្ចឹង គិចមានគ្រោះ
ថ្នាក់។

គ កុំញ៉ាំផ្អែមពេក ប្រយ័ត្នឈឺពោះ។
កុំញ៉ាំផ្អែមពេក គិចឈឺពោះ។

ឃ ដេកលេងច្រើន ប្រយ័ត្នតាយំ។
ដេកលេងច្រើន គិចតាយំ។

ង កុំលួចគេ ប្រយ័ត្នបាប។
កុំលួចគេ គិចបាប។

ច កុំមើលងាយលោក ប្រយ័ត្នចុះនរក។
កុំមើលងាយលោក គិចចុះនរក។

DRILL SEVEN: Substitution

Note: (Drill Eight, too)

When the idiom ...ៗ... begins with a phrase or clause, the second repetition will normally include only the verb, e.g.,

Phrase: ដើរលេងច្រើននេះដើរ ប្រយ័ត្ន ប្រមូលឆ្លាក់។

Sentence: ប្រពន្ធខ្ញុំដើរតាមខ្ញុំនេះដើរ ទកទក់ទើសិសិមិនបាន។

គំរូ

ក សីលនេះសីល អន្តិចសីលអន្តិចសីល។
(ស៊ី)

ខ ស៊ីនេះស៊ី អន្តិចស៊ីអន្តិចស៊ី។

MODEL:

T: There's too much piety here, all the time piety!
(eating)

S: There's too much eating here, all the time eating.

ស៊ីនេះស៊ី អន្តិចស៊ីអន្តិចស៊ី។

ក បុណ្យ
បុណ្យនេះបុណ្យ អន្តិចបុណ្យអន្តិចបុណ្យ។

ខ ស្ងួរ
ស្ងួរនេះស្ងួរ អន្តិចស្ងួរអន្តិចស្ងួរ។

គ ដើរលេង
ដើរលេងនេះដើរ អន្តិចដើរលេងអន្តិចដើរលេង។

ឃ ភ្លៀង
ភ្លៀងនេះភ្លៀង អន្តិចភ្លៀងអន្តិចភ្លៀង

ង ទកទឿង
ទកទឿងនេះទក(ទឿង) អន្តិចទកទឿងអន្តិចទកទឿង។

ច ធើ
ធើនេះធើ អន្តិចធើអន្តិចធើ។

DRILL EIGHT: Transformation

គំរូ

ក អន្តិចធើបុណ្យអន្តិចធើបុណ្យ ធើតាប់មិនអស់។

ខ ធើបុណ្យនេះធើ អន្តិចធើអន្តិចធើ។

MODEL:

T: All the time making merit, you do it so much!

S: There's too much merit-making here, all the time merit-making!

ក អន្តិចកាន់សីលអន្តិចកាន់សីល កាន់តាប់មិនអស់។
កាន់សីលនេះកាន់ អន្តិចកាន់អន្តិចកាន់។

ខ អន្តិចសូត្រអន្តិចសូត្រ សូត្រតាប់មិនអស់។
សូត្រនេះសូត្រ អន្តិចសូត្រអន្តិចសូត្រ។

គ អន្តិចសុំសីលអន្តិចសុំសីល សុំតាប់មិនអស់។
សុំសីលនេះសុំ អន្តិចសុំអន្តិចសុំ។

ឃ អន្តិចដាក់បាត្រអន្តិចដាក់បាត្រ ដាក់តាប់មិនអស់។
ដាក់បាត្រនេះដាក់ អន្តិចដាក់អន្តិចដាក់។

ង អន្តិចធើចង្ហាន់អន្តិចធើចង្ហាន់ ធើតាប់មិនអស់។
ធើចង្ហាន់នេះធើ អន្តិចធើអន្តិចធើ។

ច អន្តិចនិមន្តលោកឆាន់ អន្តិចនិមន្តលោកឆាន់ និមន្តតាប់មិនអស់។
និមន្តលោកឆាន់នេះនិមន្ត អន្តិចនិមន្តអន្តិចនិមន្ត។

DRILL NINE: Equivalence

គំរូ

ក ឯង បើមិនបានស្រ្តីវាក មិនអស់ចិត្តទេ។

ខ ឯង ទកមិនបានស្រ្តីវាក មិនអស់ចិត្តទេ។

MODEL:

T: You! If you aren't told off, you never give up.

S: You! If you aren't told off, you never give up.

ក ខ្ញុំ បើមិនបានទៅ មិនសប្បាយទេ។
ខ្ញុំ តែមិនបានទៅ មិនសប្បាយទេ។

ខ យើង បើមិនបានចំណេញ មិនធ្វើទេ។
យើង តែមិនបានចំណេញ មិនធ្វើទេ។

គ គាត់ បើមិនបានស៊ី មិនសុខចិត្តទេ។
គាត់ តែមិនបានស៊ី មិនសុខចិត្តទេ។

ឃ គេ បើមិនបានចេញ មិនអស់ចិត្តទេ។
គេ តែមិនបានចេញ មិនអស់ចិត្តទេ។

ង កូនខ្ញុំ បើមិនស្គាល់ មិននិយាយទេ។
កូនខ្ញុំ តែមិនស្គាល់ មិននិយាយទេ។

ច គាត់ បើមិនបានឃើញ មិនអស់ចិត្តទេ។
គាត់ តែមិនបានឃើញ មិនអស់ចិត្តទេ។

DRILL TEN: Transformation

គំរូ

ក តែថ្ងៃសីល គ្មានម្ហូបឆ្ងាញ់តែម្តង។
ខ ថ្ងៃសីលនេះថ្ងៃ តែថ្ងៃសីល មុខតែគ្មានម្ហូបឆ្ងាញ់តែម្តង។

MODEL:

T: If it's a day of abstinence, there is nothing good to eat.

S: It's always a day of abstinence, and if it's a day of abstinence, there'll surely nothing good to eat.

ក តែថ្ងៃបុណ្យ គ្មានបានទៅផ្ទះសំរាកទេ។
ថ្ងៃបុណ្យនេះថ្ងៃ តែថ្ងៃបុណ្យ មុខតែគ្មានបានទៅផ្ទះសំរាកទេ។

ខ តែភ្លៀង មិនបានដើរលេង។
ភ្លៀងនេះភ្លៀង តែភ្លៀង មុខតែមិនបានដើរលេងទេ។

ឆ តែបើលវាយលោក ចុះនរកមិនខានហើយ។
បើលវាយលោកនេះបើល តែបើលវាយលោក មុខតែចុះនរកមិនខានហើយ។

ជ តែពិបាក ឈប់ទៅធ្វើការតែម្តងហ្នឹង។
ពិបាកនេះពិបាក តែពិបាកមុខតែឈប់ទៅធ្វើការតែម្តងហ្នឹង។

ឈ តែឆ្ងាញ់ មិនទុកជូនលោកតាទេ។
ឆ្ងាញ់នេះឆ្ងាញ់ តែឆ្ងាញ់មុខតែមិនទុកជូនលោកតាទេ។

ញ តែឈប់ ប្រពន្ធមិនជាប់ទេ។
ឈប់នេះឈប់ តែឈប់មុខតែប្រពន្ធមិនជាប់ទេ។

DRILL ELEVEN: Transformation

គំរូ

ក ជាតិក្រោយទៅជាស្រមោចស្វាហើយ។
(ឆ្ងាញ់)
ខ ជាតិក្រោយទៅជាស្រមោចស្វាអីក៏ដោយចុះ ឲ្យតែឆ្ងាញ់ឥឡូវសិន។

MODEL:

T: In your next life you'll become an ant.
(good to eat)

S: Let me become an ant or anything in my next life, just so I eat well now.

ក ជាតិក្រោយចុះនរកហើយ។
(ស្អែកកោះ)
ជាតិក្រោយចុះនរកអីក៏ដោយចុះ ឲ្យតែស្អែកកោះឥឡូវសិន។

ខ ចាប់ជាតិជាឆ្កែស្នាហើយ។
(កុំឲ្យតែតាចរ)
ចាប់ជាតិជាឆ្កែស្នាអីក៏ដោយចុះ ឲ្យតែកុំឲ្យតែតាចរឥឡូវសិន។

គ កើតទៅជាខ្ញុំបំរើគេហើយ ។
(បានលុយចាយ)
កើតទៅជាខ្ញុំបំរើគេអីក៏ដោយចុះ
ឲ្យតែបានលុយចាយខ្លួនឯង ។

ឃ កើតទៅជាស្ត្រីកជាគ្នាគេហើយ ។
(ទៅ[illegible])
កើតទៅជាស្ត្រីកជាគ្នាគេអីក៏ដោយ
ចុះ ឲ្យតែទៅ[illegible]ខ្លួនឯង ។

ង ជាតិក្រោយចាប់ជាតិជាសត្វហើយ ។
(សប្បាយ)
ជាតិក្រោយចាប់ជាតិជាសត្វអីក៏
ដោយចុះ ឲ្យតែសប្បាយខ្លួនឯង ។

ច ជាតិក្រោយកើតមកគ្មានសំណាង
ហើយ ។
(បានរស់ស្រណុក)
ជាតិក្រោយកើតមកគ្មានសំណាងអី
ក៏ដោយចុះ ឲ្យតែបានរស់ស្រណុក
ខ្លួនឯង ។

DRILL TWELVE: Substitution

គំរូ

ក អានេះអីក៏ឡើងមុខម្ល៉េះ ចេញពី
ណាមក ?
(ហ៊ាន - កើតពីពូជ)

ខ អានេះអីក៏ហ៊ានម្ល៉េះ កើតពីពូជ
ណាមក ?

MODEL:

T: This kid! How fresh he is - where
did he come from?
(to dare - come from what line)

S: This kid! How he dares - what line
does he come from?

អានេះអីក៏ហ៊ានម្ល៉េះ កើតពីពូជ
ណាមក ?

ក មិនខ្លាចបាបអីសោះ - មកពីភូមិ
អានេះ អីក៏មិនខ្លាចបាបអីសោះម្ល៉េះ
មកពីភូមិណាមក ?

ខ ចិត្តអាក្រក់ - កើតពី
អានេះអីក៏ចិត្តអាក្រក់ម្ល៉េះ កើតពី
ណាមក ?

គ ចូលចិត្តធ្វើបាបគេ - រៀនពី
អានេះ អីក៏ចូលចិត្តធ្វើបាបគេម្ល៉េះ
រៀនពីណាមក ។

ឃ មិនអៀនមិនអីសោះ - មកពីទិស
អានេះអីក៏មិនអៀនមិនអីសោះម្ល៉េះ
មកពីទិសណាមក ?

ង ចោរកាប - កាត់ពី
អានេះអីក៏ចោរកាបម្ល៉េះ កាត់ពី
ណាមក ។

ច ឡើងមុខ - ចេះពីគ្រូ
អានេះអីក៏ឡើងមុខម្ល៉េះ ចេះពីគ្រូ
ណាមក ?

DRILL THIRTEEN: Response

គំរូ

ក អាហ្នឹង បើមិនបានធ្វើឲ្យអញខឹង មិន
សុខចិត្តទេ ។
(ម៉ែ - ខ្ញុំ)

ខ ម៉ែអើយ កុំខឹងនឹងខ្ញុំអី ។

MODEL:

T: That kid, if he doesn't get me mad,
he doesn't give up.

S (mother - me)

S: Mother, don't get mad at me.

ក ពួកអស់ហ្នឹងត្រូវតែធ្វើបាបវាម្ដង ។
(បង - គ្នា)
បងអើយ កុំធ្វើបាបគ្នាអី ។

ខ អញវាយវាឲ្យងាប់ ។
(លោកគុណ - គ្នា)
លោកគុណអើយ កុំវាយគ្នាអី ។

គ អាហ្នឹង បានតែដេញឲ្យទៅណា
ឲ្យបាត់ ។
(អូន - វា)
អូនអើយ កុំដេញវាអី ។

ឃ អញស្អប់អាលង់ណាស់កាលថ្ងៃហ្នឹង ។
(ម៉ែ - កូន)
ម៉ែអើយ កុំស្អប់កូនអី ។
ង អញឱ្យអាលង់ទៅនៅវត្ត អញឈប់
ឱ្យដើរលេងទៀតហើយ ។
(ឪ - ខ្ញុំ)
ឪអើយ កុំឱ្យខ្ញុំទៅនៅវត្តអី ។
ច ម៉ែឱ្យកូនលង់ទៅនៅនឹងលោកតា ។
(ម៉ែ - កូន)
ម៉ែអើយ កុំឱ្យកូនទៅនៅនឹង
លោកតាអី ។

DRILL FOURTEEN: Substitution

គំរូ
ក ឱ្យតែនិយាយឡើង តែមិនបាន
ត្រូវដាកមិនអស់ចិត្តទេ ។
(ធ្វើម្ហូបប្រគេនលោក - ស៊ីមុន)
ខ ឱ្យតែធ្វើម្ហូបប្រគេនលោក តែមិន
បានស៊ីមុនមិនអស់ចិត្តទេ ។

MODEL:

T: Whenever he speaks up, he doesn't give up until he's told off.
(make food for the monks - eat first)

S: Whenever they make food for the monks, he doesn't give up until he gets to eat (it) first.

ឱ្យតែធ្វើម្ហូបប្រគេនលោក តែមិន
បានស៊ីមុនមិនអស់ចិត្តទេ ។
គ និយាយពីលោកសង្ឃ - គេជេរ
ឱ្យតែនិយាយពីលោកសង្ឃ តែមិន
បានគេជេរមិនអស់ចិត្តទេ ។
ឃ យកម្ហូបទៅវត្ត - ស៊ីបន្តិច
ឱ្យតែយកម្ហូបទៅវត្ត តែមិនបាន
ស៊ីបន្តិចមិនអស់ចិត្តទេ ។
ង មានបុណ្យទាន - ទៅវត្ត
ឱ្យតែមានបុណ្យទានតែមិនបានទៅ
វត្តមិនអស់ចិត្តទេ ។

ឃ ថ្ងៃសីល - និមន្តលោកមកផ្ទះ
ឱ្យតែថ្ងៃសីល តែមិនបាននិមន្ត
លោកមកផ្ទះមិនអស់ចិត្តទេ ។
ង ប្រកែកគ្នាមួយលោកនេន - ឈ្នះ
ឱ្យតែប្រកែកគ្នាមួយលោកនេន តែ
មិនបានឈ្នះមិនអស់ចិត្តទេ ។
ច ទៅលេងលោក - សុំលុយ
ឱ្យតែទៅលេងលោក តែមិនបាន
សុំលុយមិនអស់ចិត្តទេ ។

DRILL FIFTEEN: Equivalence

Note: Do this drill twice, the second time reversing the teacher's and student's sentences.

គំរូ
ក ឯងនេះកាលណានិយាយឡើង ទាល់
តែត្រូវដាក់បានអស់ចិត្ត ។
ខ ឯងនេះ ឱ្យតែនិយាយឡើង តែ
មិនបានត្រូវដាក់មិនអស់ចិត្តទេ ។

MODEL:

T: You! When you speak up, you don't give up until you've been told off.

S: You! When you speak up, you don't give up until you've been told off.

គ គាត់ កាលណារៀនចប់ ទាល់តែ
ចេះបានឈប់ ។
គាត់ ឱ្យតែរៀនចប់ តែមិន
បានចេះមិនឈប់ទេ ។
ឃ យាយខ្ញុំ កាលណាធ្វើបុណ្យ ទាល់
តែអស់លុយបានពេញចិត្ត ។
យាយខ្ញុំ ឱ្យតែធ្វើបុណ្យ តែមិន
បានអស់លុយមិនពេញចិត្តទេ ។
ង លោកតា កាលណានិមន្តលោក
ទាល់តែយើងទៅទទួលបានលោក
និមន្ត ។

លោកតា ឲ្យតែនិមន្តលោក តែ
មិនបានឡើងទៅទទួល លោកមិន
និមន្តទេ ។

៦ តាខ្ញុំ កាលណាទៅសុំសីល ទាល់
តែយប់បានត្រឡប់មកវិញ ។
តាខ្ញុំ ឲ្យតែទៅសុំសីល តែមិន
បានយប់ មិនត្រឡប់មកវិញទេ ។

៧ ប្រុសៗពីដើម កាលណាចង់បាន
ប្រពន្ធ ទាល់តែដែលបួសសិនបាន
បាន ។
ប្រុសៗពីដើម ឲ្យតែចង់បានប្រពន្ធ តែមិនបានដែលបួសសិន មិន
បានទេ ។

៨ អាហ្នឹង កាលណាពឹងជាទៅតាម
លោក ទាល់តែបានស៊ីទើបបានទៅ ។
អាហ្នឹង ឲ្យតែពឹងជាទៅតាមលោក
តែមិនបានបានស៊ីផឹក ក៏មិនទៅទេ ។

READING PASSAGE 2

ពុទ្ធសាសនា ឬ ពុទ្ធលទ្ធិ

ពុទ្ធលទ្ធិ ជាទស្សនៈ ទ្រឹស្ដី របស់ព្រះពុទ្ធ កើតមានឡើងតាំងដំបូង នៅប្រទេសឥណ្ឌា ក្នុងសតវត្សទី ៦ មុន គ.ស មានគោលច្បាប់សម្រាប់ប្រព្រឹត្តប្រតិបត្តិ ចំនួន ៨៤០០០ ធម្មក្ខន្ធដែលមានចារឹកក្នុងគម្ពីរព្រះត្រៃបិដក ។ បច្ចុប្បន្ននេះ អ្នកដែលគោរពជឿកាន់ព្រះពុទ្ធសាសនា ហៅថា ពុទ្ធសាសនិក មានចំនួន ៥០០.០០០.០០០ នាក់ មាននៅក្នុងប្រទេស ខ្មែរ សៀម លាវ ចិន យួន ភូមា ឥណ្ឌា លង្កា នេប៉ាល់ ទីបេត៍ ជប៉ុន ម៉ុងហ្គោលី ។ល។

ពុទ្ធសាសនា បែកចេញទៅជានិកាយផ្សេងៗ ក្រោយពេលដែលព្រះពុទ្ធបរិនិព្វាន ប្រមាណជាង៦០០ឆ្នាំ តែនិកាយដែលធំៗ មាន២ គឺ:

— មហាយាន (ឧត្តរនិកាយ - អាចរិយវាទ)

– ហីនយាន (ទក្ខិណនិកាយ - ថេរវាទ) ។

១– មហាយាន

យានធំ ទូលាយអាចផ្ទុកមនុស្សសត្វបានច្រើនគ្នា ដឹកនាំឆ្ពោះទៅកាន់ទីរំលត់ទុក្ខគឺព្រះនិព្វាន ។ និកាយមហាយានមានវិន័យធូរស្រាល ស្លៀកខោ ពាក់អាវ ឆាន់លៀង ។ និកាយនេះ សង្កត់យ៉ាងខ្លាំង ឬ ឱ្យតម្លៃទៅលើការអប់រំចិត្ត ។ និកាយមហាយាន គោរពតាមលទ្ធិអាចរិយវាទ គឺប្រព្រឹត្តប្រតិបត្តិតាមគ្រូអាចារ្យរបស់ខ្លួនៗគ្នា មិនប្រតិបត្តិតាម

គោលព្រះត្រៃបិដក ដូចនិកាយហីនយានទេ ។ អ្នកប្រាជ្ញនៃនិកាយមហាយាន បានបង្កើតគម្ពីរដីកាឡែកស់ពីគម្ពីរព្រះត្រៃបិដកគឺ :

- គម្ពីរ សទ្ធម្មបុណ្ឌរីក
- គម្ពីរ លង្កាវតារសូត្រ
- គម្ពីរ ប្រជ្ញាបារមិតា ជាដើម ហើយសុទ្ធតែចារឹកជាអក្សរភាសា សំស្ក្រឹត ទាំងអស់ ។ និកាយនេះលើកយកភាសា សំស្ក្រឹត ជាធំ ជាយានសម្រាប់សិក្សា ។ បច្ចុប្បន្ននេះ និកាយមហាយាន មានរីកនៅក្នុងប្រទេសចិន យួន ជប៉ុន ទីបេត៍ មុងហ្គោលី ។ល។

និកាយមហាយានគោរព ពោធិសត្វ ៣ អង្គ គឺ :

១- អវលោកិតេស្វរៈ

២- មញ្ជុស្រី

៣- មៃត្រេយ្យៈ ឬ ព្រះស្រីអារ្យមេត្រី ។

២- ហីនយាន

យានតូច យានចង្អៀត ផ្ទុកមនុស្សសត្វបានតិច មានវិន័យតឹងតែង មានការគោរពវិន័យយ៉ាងម៉ត់ចត់ ជាបឋម ជាធំ ។ និកាយនេះ ឲ្យតម្លៃទៅលើវិន័យ ការអប់រំខ្លួនកាយ វាចា ចិត្តឲ្យបានល្អត្រឹមត្រូវ ស្រគត់ស្រគំ រៀបរយ ។ បព្វជិតគ្រងឃុំ ស្បង់ចីពរ ពណ៌លឿង ។ និកាយហីនយានគោរព ប្រព្រឹត្ត ប្រតិបត្តិតាមគម្ពីរព្រះត្រៃបិដក ដោយយកភាសាបាលី ជាធំ ជាយាន ក្នុងការសិក្សា ពុទ្ធ

ថេរៈ ។ បច្ចុប្បន្ន ពុទ្ធសាសនានិកាយហីនយាន មាន
ចិតនៅប្រទេស : ខ្មែរ សៀម លាវ ភូមា លង្កា
ឥណ្ឌា នេប៉ាល ។ល។ និកាយនេះ គោរព ព្រះពុទ្ធ
តែមួយព្រះអង្គគឺ ព្រះសមណគោតម និង ព្រះធម៌ ព្រះ
សង្ឃ ។ 45

Names in Reading Passage 2

Three important Bodhisattvas:

អវលោកិតេស្វរ	/aave?lookateesvaara?/
មញ្ជុស្រី	/məñco?srεy/
មៃត្រេយ្យ:	/maitreyé?/
or ព្រះស្រីអារ្យមេត្រី	/préh srεyaariyé?meetrεy/

NOTES FOR READING PASSAGE 2

Line 13. Cambodian is a member of the Mon-Khmer language family, which is unrelated to the Indo-European language family (of which English is a member). However, it has borrowed many words from Sanskrit and Pali, both of which are Indo-European languages, especially in its religious vocabulary. Pali and Sanskrit bear much the same relations to Cambodian as Latin and Greek bear to English. That is, they are the classical languages from which neologisms are coined. They are also liturgical languages for major religions (Pali is used in Theravada Buddhism, and Sanskrit is used in Hinduism and in much of Mahayana Buddhism). All three of these religions are or have been important in Cambodian history, so it is not surprising that there are many words borrowed from both languages.

Lines 16, and 38

These lines describe the dress of the monks of the two major sects.

VOCABULARY

កាត់ទម្រង់ កាត់ឫកពារ	to take after, to inherit someone's characteristics
កាន់សីល	to observe religious precepts (including abstinence)
* កើត	refers to the waxing moon in lunar dates
ក្រណាត់	cloth
ក្អែក	crow
* ខឹងសម្បា	to be angry, mad
ខ្ជាំងខ្ជើ	to be disobedient, bad, naughty
* គោតម, -ន៍ /koodɔɔm/	family name of the Buddha
គោលច្បាប់	main law, rule
គ្រង	to wear (clerical); to reign
ឃ្លុំ	to cover, to wear a monks outer garment
* ច (ឆ្កែ)	dog (name of 11th year of 12-year cycle)
ចានស្រាក់	a kind of food carrier
ចារឹក	to write down
ចីវរ	monk's outer garment
ឆ្នេរ	edge (of a body of water), shore
ឆ្ពោះទៅ	to, towards
* ជន្ម /cún/	age (royal)
ឈាន	step, stage of enlightment
ឈឺចាប់ (ចាប់ AC)	to hurt, to feel acute pain
ដាក់បាត្រ	to give food to a monk
* ដីកា	exegesis
តស៊ូ	to struggle
តម្រូវ (< ត្រូវ)	to enforce, to require

តាបស (< តបៈ)	a Hindu ascetic, hermit
តឹងតែង (តែង AC)	critical, strict
ត្មាត	vulture
ត្រាស់	to be enlightened, achieve enlightenment
ត្រូវបាក់	to be scolded, told off
* ត្រៃវេទ	an important Hindu scripture
ត្រៃ	three (literary)
* វេទ	knowledge, Veda
ថេរវាទ	Theravada (name of the type of Buddhism practised in Cambodia)
* ថេរៈ /theeréʔ/	an elder, a senior Buddhist monk
* ថោះ	rabbit (name of 4th year of 12-year cycle)
ថ្ងៃខួប	anniversary
ថ្ងៃសីល	day of abstinence and religious observance
ថ្លើមធំ	fresh, disrespectful
* ទក្ខិណានិកាយ (ទក្ខិណា = ទក្សិណា)	southern sect
* ទត	to look (royal)
ទស្សនកិច្ច /tuohsənaʔkec/	tour, trip
ទីបេ, ទីបេត៍	Tibet
ទុក្ករកិរិយា /tukkəraʔkeriyaa/	doing what few others can do, struggling for enlightment, practicing asceticism
* ទុក្ករៈ /tukkaʔraʔ/	that which is difficult to achieve, rarely achieved
ទូន្មាន	to remind, to give advice
ទៀន	candle
ទេសនា	a sermon, to preach
ទ្រឹស្ដី	theory

ធម្ម /thómé?/ = ធម៌	
ធម្មខន្ធ /thómməkhan/	items of Buddhist teaching in the ត្រៃបិដក
* ធម្មចក្កប្បវត្តនសូត្រ /thómmé?cakkappa?vatta?na?sout/	name of Buddha's first sermon
* ធម្មចក្ក	wheel of dharma
ធម្មចក្រ /thómməca?/	the wheel of dharma (name of Buddha's first sermon)
ធូប	incense
ធូរ	relaxed, easy, loose
នរក	Hell
និកាយ	sect
នេន	a postulant monk
នេប៉ាល់	Nepal
verb + នែះ + verb noun + នែះ + noun	too much
បង្អែម (< ផ្អែម)	dessert, sweet
បញ្ចវគ្គីយ /pañca?vokii/	Buddha's first 5 disciples
បញ្ច	five (literary)
* វគ្គី	an advanced disciple
បព្វជិត /bɔppəcɨt/	clergy (formal)
បរិនិព្វាន /bare?nipian/	to achieve Nirvana
និព្វាន	Nirvana
បុណ្យ១០០ថ្ងៃ	a ceremony performed 100 days after a person's death
ធ្វើបុណ្យ	to celebrate; to make merit
ប្រសូត	to be born (royal, divine)
ប្រៀនប្រដៅ	to teach manners to, to give advice
* ប្រាជ្ញាបារមីតា /pracñaabaarəmɛytaa/	name of a Mahayana Buddhist scripture

ប្រោស	to inspire; to revive (from death)
ផ្តេសផ្តាស	silly, useless, pernicious, mischievous
ពុទ្ធវចនៈ	utterance of Buddha
* វចនៈ	utterance (lit.)
ពុទ្ធសាសនិក	Buddhist (excluding clergy)
ពោធិព្រឹក្ស /poothiprɨk/	Bo tree (a kind of tree)
* ព្រឹក្សា	vegetation
ពោធិសត្វ	Bodhisattva (a future Buddha. a Buddhist divinity considered to be a saving spiritual force)
* ពោធិ (H)	enlightment
ព្យាយាម	to strive, struggle
* ព្រះជន្មាយុ /- cunəmiayu?/	age (royal)
ព្រះសមណគោតម /saməna?koodɔɔm/	the Buddha Siddhartha
* សមណៈ /saməna?/	one who follows the dharma, who strives to live in accord with Buddhist principles; a monk
មហាយាន	Mahayana (branch of Buddhism)
មហេសី	queen, wife (royal)
មាគ៌ា /miakia/	route, way, road; approach, policy (literary)
ម៉ង្គោលី	Mongolia
មោក្ខធម៌ /mookhəthóa/	the truth that leads to elimination of suffering
* មោក្ខៈ /mookha?/	elimination of suffering, Nirvana
ម្ល៉ោះហើយ	therefore
* ម្សាញ់ (ពស់)	snake (name of 6th year of 12-year cycle)
យោជន៍	distance the eye can see

រករឿង	to make trouble, start a fight
* រកា (មាន់)	cock, chicken (name of 10th year of 12-year cycle)
រុនទុំ /runtum/	to be restrained in movement
រាជសម្បត្តិ /riacsambat/	throne, royal property
រាត្រី	evening (formal)
រាវរក	to search, research
រាវ	to grope
រូប	form, shape, classifier for persons
* រោច	refers to the waning moon in lunar dates; to pull away
រំលត់	to extinguish, put out
រំលាយ	to melt (trans.), liquidate, do away with
រំហើយ	to cool (off), relax
លង្កា	Ceylon (Srilanka)
* លង្កាវតារសូត្រ /laŋkaavətaasout/	name of a Mahayana Buddhist scripture
លទ្ធិ /lethi?/	philosophy, ideology, régime
លោកតា	way of referring to an elderly monk
វាចា	speech, utterance
វិសាខ /visaak/ = ពិសាខ	name of 6th lunar month (mid April to mid May)
សងគុណ	to repay a moral debt
សង្វេគយល់	to feel empathy
សង្វេគ	to feel pity
* សង្ហារ (= ចង្ហារ)	large black ant
សច្ចៈធម៌ /sacca?thóə/	the truth
* សច្ចៈ /sacca?/	truth, certainty

* សទ្ធម្មបុណ្ឌរិក /sɔnthəma?bonda?rika?/	name of a Mahayana Buddhist scripture
សម្មាសម្ពោធិញ្ញាណ /sɔmaasɔmpoothəñian/	enlightment
* សម្មា	true, correct, good
* សម្ពោធិ	enlightment
ញាណ	consciousness, mind, intelligence, knowledge
សហការី	colleague, co-worker
សាងផ្នួស (បួស)	to become a monk, give up worldly life
* ផ្នួស	act of giving up the world, one who gives up the world
* សាលព្រឹក្ស /saal prɨk/	a bayan tree under which Buddha was born and died
សិទ្ធត្ថ (= សិទ្ធាថ) /sɨthót/	Siddhartha (given name of the Buddha)
សីល /səl/	religious rule, precept, piety, holiness, grace
សុំសីល	to go to the wat on a day of abstinence to participate in prayers
ស្ងាត់	quiet, alone, without people
ស្បង់	monk's sarong-like garment
ស្រគត់ស្រគំ	to be quiet (speech); conservative (manner)
ស្រមោច	ant
ហីនយាន /hinəyian/	Hinayana (branch of Buddhism)
* ហីន	small, lesser, cheap, all gone

អស់ចិត្ត	to give up, to stop hoping, to be fed up
* អាចារិយវាទ /aacare?yəviət/	philosophy of the teachers
* អាចារិយ /aacare?ye?/ (H)	teacher
* វាទ	philosophy, utterance
* អាសាឍ /aasaat/	8th lunar month (mid June - mid July)
* អាហារតាបស	a stage of asceticism involving deprivation of food
* អាហារ	food (literary)
ឥណ្ឌា	India
*ឧត្តរនិកាយ	the northern sect
*ឧទកតាបស /u?té?kataaboh/	a stage of asceticism involving deprivation of water
* ឧទក	water
ឧទ្យាន	garden, park (royal)
អ្នកប្រាជ្ញ	genius

APPLICATIONS

1. Find the word(s) that fit(s) the following definitions.

១ ដាក់គំនិតបន្តិចៗទៅក្នុងយានណាមួយ

២ ពាក្យសំដីរបស់ព្រះពុទ្ធ

៣ ប្រដាប់មួយដែលលោកសង្ឃប្រើដើម្បីដាក់សម្លបានច្រើនមុខ

៤ ម្ហូបលោកសង្ឃ

៥ ដាក់ទុក - ដើងទៅក្នុងអីមួយ

៦ កន្លែងដែលមនុស្សល្អធ្វើអាស្រមបានក្បួរកើតនៅជាតិក្រោយ

៧ សំលៀកបំពាក់លោកសង្ឃ

៨ កើតឡើងម្តងទៀតនៅជាតិក្រោយ

2. Correct the following sentences by adding the proper words.

១ អានៅលើហ្នឹងឧកស្នកណា ។

២ ប្រយ័ត្នកើតទៅសត្វ ។

៣ សង សង អន្តិចសង់អន្តិចសង់ ។

៤ វីតកើតមុខយ៉ាងមុខស្លាប់មិនបានហើយ ។

៥ លោកសង្ឃពីបាននិមន្តចេញពីវត្តនេះ ។

៦ អាហ្នឹងមិក៏ហ៊ាន ?

៧ ព្រះអង្គពុំអាចកេរឃើញសច្ចធម៌ ។

៨ ព្រះអង្គបានទេះដឹងយល់ស្គាល់សព្វគ្រប់តាំងអស់ដែលទៅហៅត្រាស់ដឹង ។

3. Define the following words.

ប្រទេន ខ្លាំងវត្ត ជាតិក្រោយ អស់សេចក្តី វត្ត

ផ្តើមដ៏
ពុទ្ធសាសនិក
សង្វេគ
គ្រូវហាត
ប្រទេស
ចេញបួស
ព្យាយាម
សោយរាជ្យ
ត្រាស់
សតវត្ស
ទស្សនកិច្ច
ទិលក
ទេសនា
ប្រាសាទ

4. Find the synonyms of the following words.

ប្រសូត
ទត
សាងផ្នួស
(ព្រះ)នាម
អភិសេក
សត្វ
ទៀង
បុត្រ
ជន្មាយុ
សោយ
មហេសី
បរិនិព្វាន
សិក្សា
សាង
បង់ម

5. Describe briefly the life of a major religious with whom you are familiar, e.g., Jesus or Moses. (In Cambodian, of course.)

6. Describe the organization of Christianity, Judaism, or Islam in the same way as Reading Passage 2 describes Buddhism.

7. Try to get a fuller explanation of the following words. Ask any questions that are prompted by your teacher's explanations.

វេន
សម្មប្រក
សច្ចធម៌
ត្រាស់ដឹង
ពោធិសត្វ
សីល
បញ្ញាត្តិ
មោក្ខធម៌
និព្វាន
គេងវត្ត
សង្កុណ
បុណ្យ១០០ថ្ងៃ

8. Do the words សាងផ្នួស and បួស have exactly the same meaning?

9. Have the student discuss the following topics.
១ ព្រះយេស៊ូគ្រិស្តជាអ្នកណា?
២ ព្រះពុទ្ធជាអ្នកណា?
៣ មានត្រង់ណាដែលពុទ្ធសាសនានិងសាសនាគ្រិស្តស្របគ្នា? តើស្របយ៉ាងណា?
៤ ហេតុអ្វីបានជាយើងត្រូវមានសាសនា?
៥ ហេតុអ្វីបានជាយើងត្រូវការសាសនា?

10. Questions for the teachers to ask.
១ នៅស្រុកអាមេរិកមានវិហារពុទ្ធសាសនាទេ?
២ បើមានវិហារពុទ្ធសាសនា តើអាមេរិកាំងគោរពពុទ្ធសាសនាតាមលទ្ធិមហាយាន ឬហីនយាន?
៣ គ្រិស្តសាសនាមាននិកាយដូចពុទ្ធសាសនាទេ?
៤ អាមេរិកាំងភាគច្រើនបានមើលគម្ពីរគ្រិស្តសាសនា (Bible) ។ តើលោកជឿទេ?
៥ នៅក្នុងសាលា តើកូនសិស្សអាមេរិកាំងរៀនអំពីគ្រិស្តសាសនាទេ?
៦ ហេតុអ្វីបានជានៅមុនពេលញ៉ាំបាយ អាមេរិកាំងភាគច្រើនសូត្រធម៌?

តើគេសូត្រធម៌មិនដូចគ្នាទេ ពួកកាតូលិក និងប្រូតេស្តង់ ?

៧ ពួកហិណ្ឌូ (ហិណ្ឌូ) មានប្រហែលនឹងការគោរពទេវតាច្រើន ហេតុអ្វីបានជាសាសនាហិណ្ឌូ ចាត់ទុកជាសាសនាតែមួយដូចសាសនាកាតូលិកនិងប្រូតេស្តង់ដែរ។

៨ ការបរិភោគហិណ្ឌូដែលត្រូវគេមើលងាយ ដាក់ទោសដោយរបៀបណាមួយទេ?

៩ តើការបរិភោគភាគច្រើនយល់យ៉ាងម៉េចអំពីពួកហិណ្ឌូ ?

11. Questions for the student to ask.

a. We know that popular Buddhist belief includes lives after death. Did the Buddha teach that there is any life after death? If not, what happens to people after they die. If so, what is it like?

b. What is the consequence of evil deeds in Buddhist theology? In popular belief?

c. When the Buddha deserted his family to search for truth, he caused them suffering, which is presumably sinful. How do Buddhists account for this? Do they believe that the Buddha suffered any consequences?

d. If the Buddha entered Nirvana and no longer exists, why do people still pray to the Buddha?

e. Have there ever been female equivalents of the Buddhist monks (ភិក្ខុនី)? Why are there none today?

f. What is done on ថ្ងៃសីល?

g. In an observant household, does ថ្ងៃសីល effect small children? Students?

h. Is fasting a frequent practice for layman?

i. What is meant by the term កាន់សីល? What does it involve? Can it be done on days other than ថ្ងៃសីល?

j. What is popularly believed to be the reward of កាន់សីល? Is there believed to be a punishment for its omission?

LESSON TWELVE

BUDDHISM: PRESENT PRACTISES

a. What are the rules which every Buddhist should follow?

b. How do the rules which monks must follow differ from those for laymen?

c. Has the observance of some such rules had to be altered because of the demands of modern life?

ព្រះពុទ្ធសាសនា

ចំពោះមនុស្សពុទ្ធជន

ដូចយើងគេពោលគ្នា កម្មរបស់យើងដែលយើងប្រព្រឹត្តទៅជានិច្ចនិរន្តរ៍ នៅក្នុងអនន្តភពវដ្តសង្សារនេះ ឥតមានផលណាមួយដែលបានជាកម្មនោះឲ្យផលនៅពេលណាទេ ប៉ុន្តែដោយយកពុទ្ធសាសនាមកជាសំខាន់ យើងនិយាយបានថា:

១– កម្មពីអតីត និងកម្មបច្ចុប្បន្ន អាចនាំមកនូវការផ្លាស់ប្រែដល់គ្នាបាន ។ ដូច្នេះ ត្រូវយើងប្រឹងប្រយ័ត្ន ហើយតាំងសតិអារម្មណ៍ ញុំាងខ្លួនឲ្យទៅកាន់ផ្លូវសុចរិត ដោយវៀរចេញនូវអកុសលកម្មតាំងពីតូច ៗ ឯលទ្ធផលដែលកើតពីការព្យាយាមនេះ ជួនកាលយឺតយូរ ជួនកាលឆាប់រហ័ស ស្រេចហើយតែកម្លាំងក្នុងការប្រព្រឹត្តិរបស់យើង ។ បើពុំអាចកើតចេញឲ្យឃើញទាន់ក្នុងភពនេះ កម្មនោះក៏នឹងនាំផលទៅអនាគតជាតិជាទៀងទាត់ គេចមិនផុតសោះឡើយ ។

២– ដោយសារកម្មបច្ចុប្បន្ន យើងអាចនឹងដំរង់តាមគន្លងផ្លូវល្អ ដើម្បីអនាគតជាតិបាន ក្នុងការធ្វើឲ្យសម្រេចតាមគោលដៅនេះ បុគ្គលម្នាក់ ៗ ជាជាងរចនានូវអនាគតរបស់ខ្លួន ឥតមានបុគ្គលដទៃណាអាចនឹងកសាងជំនួសខ្លួនបានឡើយ ។ យើងនឹងបានទៅដល់ទីដៅដូចបំណងរបស់ខ្លួន គឺល្អ ឬអាក្រក់ ។ ការត្រង់នេះ សេរីភាពដើម្បីជ្រើសរើសផ្លូវល្អ ឬអាក្រក់ មានដាច់ខាតក្នុងខ្លួនយើងម្នាក់ ៗ ស្រាប់ហើយ ។

៣– ដោយកម្មមានទីបំផុតរបស់វា គឺជាទីដែលព្រះសម្ពុទ្ធបរមគ្រូ ឬព្រះអរហន្តលោកបានទៅដល់ហើយ នៅ (ក្រោយការនិព្វាន) ផ្តាច់បង់ជាសមុច្ឆេទប្បហាន នូវបដិសន្ធិ ។

ពោលមកដល់ត្រង់នេះ កើតជាបញ្ហាមួយឡើងថា «ខ្ញុំស្រឡាញ់ការរស់នៅជាមនុស្ស ដែលពេញទៅដោយសោមនស្ស និងទោមនស្ស ខ្ញុំចង់ឲ្យស្លាប់ហើយចាប់ជាតិថ្មីជាមនុស្សទៀតទៅ ប៉ុន្តែ ចង់ឲ្យបានជាមនុស្សថ្លៃថ្នូរជាងក្នុងជាតិនេះតែប៉ុណ្ណោះ» ។ ការណ៍ត្រង់នេះ ដូចបានប្រាប់ស្រាប់ ខ្លួនអ្នកជាម្ចាស់, ជានាយទៅហ្វាយរបស់អ្នក បុគ្គលដទៃពុំអាចធ្វើជាម្ចាស់, ជានាយលើព្រេងវាសនាក្នុងបច្ចុប្បន្ន និងអនាគតរបស់អ្នកបានទេ ។ បើអ្នកចង់ចាប់ជាតិថ្មី ក៏តាមតែចិត្តរបស់អ្នកចង់ទៅចុះ គ្មាននរណាមានអំណាចហាមឃាត់បានទេ ។ ឯត្រង់ដែលថាថ្លៃថ្នូរ ឬថោកទាប នោះសោតក៏ស្រេចហើយលើខ្លួនអ្នកដែរ ។ សេចក្តីអធិប្បាយពន្យល់ពីកម្មនេះ គ្រាន់តែជាមគ្គុទ្ទេសក៍ចង្អុលច្រកផ្លូវអ្នកឲ្យដើរតែប៉ុណ្ណោះទេ ។

តាមទំនងដូចរៀបរាប់មកនេះ គេគប្បីសំគាល់ថា កម្មជាបច្ច័យនាំទៅរកទុក្ខ, ជាបណ្តាលនាំឲ្យកើតទុក្ខ ។ ចំពោះបញ្ហានេះ ឥតនៅសង្ស័យជាមួយនឹងការបាត់បង់ជីវិតដែលជាមរណៈនៃយើងឡើយ ក្នុងករណីមរណៈនឹង [illegible] កម្មចាស់នេះឆ្លងទៅតាមកម្មថ្មីបច្ចុប្បន្ន ដើម្បីបង្កើតការដុះដាលក្នុងការប្រែផ្លាស់ឡើងវិញ ដោយអំណាចកម្លាំងកម្មចាស់ដែលសន្សំទុកមក ។

ព្រោះហេតុនេះបានជាថា: គ្មានទីណាមួយអាច

និយាយបានថា កម្មណាមួយដែលនៅពីខាងក្រោយមនុស្សនីមួយ ៗ ឬកម្មនោះនឹងលេចផុសចេញនៅពេលណាឡើយ ។ គឺប៉ុន្តែដែលដឹងប្រាកដគួរឲ្យកក់ក្តៅ នឹងគួរឲ្យទុកចិត្តនោះ គឺថា បុគ្គលម្នាក់ៗ ចេះតែនៅជាប្រក្រតី ឬនៅស្ងៀមមួយកន្លែងនោះឡើយ ។ កម្មនេះមនុស្សម្នាក់ៗ អាចនឹងកែខ្លួនធ្វើឲ្យប្រសើរឡើង ពីអាក្រក់ឲ្យទៅជាល្អវិញបាន ។ អាស្រ័យដោយហេតុនេះហើយ បានជាពុទ្ធសាសនិក ឬពួកមនុស្សក្នុងលោក ទោះជនណាក៏ដោយ ត្រូវតែប្រព្រឹត្តកាន់យកនូវអធ្យាស្រ័យជាអ្នកមានចិត្តទូលាយក្នុងទាន, មានមេត្តាករុណាចេះសង្គ្រោះដល់អ្នកដទៃ ព្រោះថាមនុស្សល្អក្លាយទៅជាអាក្រក់វិញ មនុស្សអាក្រក់ក្លាយទៅជាល្អវិញ ក៏មានដែរ ។ ធម្មតាមនុស្សពុំមែនជាវត្ថុទេ តែនឹងក្លាយទៅជាអ្វីៗបាន ។ មនុស្សពុំមែនល្អឬអាក្រក់ស្រាប់ទេ តែនឹងក្លាយទៅជាល្អ ឬអាក្រក់តាមយថាកម្មរបស់ខ្លួនបាន ។ ដោយហេតុនេះ ៖ យើងមិនត្រូវភ្លើតភ្លើនដោយការតែមានគុណសម្បត្តិខាងផ្លូវចិត្ត មានសក្តិយសខ្ពស់ធ្វើឲ្យគេសន្ធឹម ឬដោយការលើទ្រព្យធនស្តុកស្តម្ភ ហើយមិនត្រូវមើលងាយអ្នកដទៃ ដោយឃើញគេទន់ទាបជាងខ្លួននោះឡើយ ។ កម្មនេះមិនត្រឹមតែជាសការដល់នូវវិបល្លាសទេ គឺអាចប្រែសភាពពីកុសលទៅជាអកុសលបាន ស្រេចហើយតែខ្លួនយើងជាអ្នកកសាងសន្សំពីក្នុងអតីតជាតិមក ។ ក្នុងពេលសព្វថ្ងៃ អ្នកដទៃគេចូលអ្នកជាបុគ្គលគួរដល់ការគោរព ហើយដល់ថ្ងៃស្អែក ខ្លួនអ្នកអាចទៅជាមនុស្សអាក្រក់ដូចគេវិញ ក៏សឹងតែមានដែរ សេចក្តីនេះយ៉ាងណាមិញ មនុស្សឧក្រិដ្ឋក្នុងពេលជាបច្ចុប្បន្ន អាចនឹងទៅជាមនុស្សល្អសុចរិតនៅថ្ងៃមុខបាន ។

កម្មមានគុណនៃក្រៃលែងជាងអ្វីៗទាំងអស់ ឥតមានអ្វីប្រៀបបានឡើយ ។ កម្មពុំមែនឲ្យផលត្រឹមតែដល់អ្នកប្រព្រឹត្តនោះទេ សូម្បីតែអ្នកដទៃក្រៅក៏សឹងបានទទួលផលរបស់វាដែរ ទោះបីណាក់ខ្លួននៅក្នុងទីណាក៏ដោយ ទាំងខាងផ្លូវល្អ ទាំងខាងផ្លូវអាក្រក់ ។ ភស្តុតាងយ៉ាងច្បាស់ក្នុងរឿងនេះ គឺដូចជាសង្គ្រាមសព្វយ៉ាង ដែលតែងតែកើតមកតែពីតណ្ហារបស់បុគ្គលម្នាក់ ឬក្រុមពួកណាមួយ ហើយកលជាលជាសេចក្តីអន្តរាយ, ជាអំណត់អត់ឃ្លាន នឹងជាសេចក្តីវិនាសស្លាប់ដល់ជីវិតមនុស្សរាប់សែនលាន ។

NOTES FOR READING PASSAGE 1

Column 1 Line 9. As you know from the preceding lesson, Sanskrit and Pali, from which Cambodian has borrowed many words, are related to English, though Cambodian itself is not. For this reason, from time to time you will run across Cambodian words or prefixes that have a strong similarity to English for the very good reason that they ultimately come from the same ancestor word. In this line, the prefix អ /a?-/ 'not' is a good example. It is the same as a- of 'atheist' or 'amoral' (these words come from Greek, which is also related to English). An even clearer example is ទ្វេ 'two' or ត្រៃ 'three.' These are Indic loans which are used in elevated contexts and which are directly related to their English equivalents.

Column 1 Line 11. [illegible] is equivalent to [illegible]

Column 1 Line 16. It may help you in reading this sentence if you remember that ជាង is a noun ('artisan, craftman').

Column 2 Line 1. The parentheses here indicate material that is to be emphasized. English text would use italics instead. This use of parentheses is not common.

Column 2 Line 10. Note that អ្នក here is used as an impersonal pronoun, much like English 'one' or 'you.'

Column 2 Line 27. The word គេ refers to អ្នកដទៃ and need not be translated.

Column 2 Line 27. The phrase [illegible] is the same as [illegible] ។

DIALOGUE

ពុទ្ធសាសនានិងកូនខ្មែរ

...ក្ដី ...ក្ដី	whether ... or
អើពើ	to be concerned, interested in
វត្តវ៉ា (វ៉ា AC)	wat (colloquial)
១ សែម. ស្រីក្ដី ប្រុសក្ដី បែបឈប់អើពើ ទៅវត្តទៅវ៉ាអស់ហើយ មើលទៅ ?	Both men and women seem to have lost all interest in going to the wat.
ហួសចែកបួង	completely shot, forget it, no way
២ សន នៅស្រុកស្រែចំការមិនសូវអីប៉ុន្មានទេ តែនៅទីក្រុងហួសចែកបួងហើយ ។	In the country it's not so bad, but in the city, forget it.
លោកសង្ឃ	Buddhist monk
អ៊ីចេះអ៊ីចុះ	this and that, thus and so
មុខតែ	certainly
ត្រូវ	(see note)
៣ សែម. ចាស់ៗភូមិខ្ញុំមិនបាននោះ តិចទៅនិយាយពីលោកសង្ឃអ៊ីចេះអ៊ីចុះ មុខតែត្រូវហើយ ។	With the old folks in my village, don't speak ill of the monks, or you'll get it.
សីល	holiness, virtue, supernatural force
រក្សាសីល	to live piously, visit the wat, keep Buddhist precepts, practise religion
ស្ថិតស្ថេរ	firm, stable
ដដែល	likewise, the same as before
៤ សន នៅទីក្រុង ចាស់ៗច្រើននៅតែស្រឡាញ់ទៅរក្សាសីលជាប់ស្ថិតស្ថេរដដែល ។	In the city, the old people are still firmly pious, the same as before.
ឆាន់	to eat (clerical)
៥ សែម ក្មេងៗបើឲ្យរៀបចំខាងសាសនា មុខតែលោកសង្ឃដាំបាយឆាន់ខ្លួនឯងហើយ ។	If you let the young people take care of religious matters, the monks would have to cook for themselves.

៦ សខ គេគោរព គេជឿ គេគោរព គេជឿហើយ តែឲ្យគេទៅវត្ត បែបគ្មានសង្ឃឹមទេ ។	There's no doubt that they respect and believe (the religion), but don't expect to see them in the wats.
បួស	to become a monk
សឹក	to leave the clergy
អន្តិត (បណ្ឌិត)	title given to a young person who has been a monk
សូម្បី(តែ) ក៏ { ផង ដែរ ទេ:	even
៧ សែម បួស សឹកមក គេហៅអន្តិត តែឥឡូវអន្តិតគ្មានតម្លៃ សូម្បីតែបន្តិចក៏គ្មាន ។	If you've been a monk, they call you antit, but now the title has no value, not even a little bit.
អាស្រ័យយ៉ាងណាក៏ដោយ	nevertheless, anyway
៨ សខ តែអាស្រ័យយ៉ាងណាក៏ដោយ ក៏ខ្មែរនៅតែស្គាល់ថាជាអ្នកកាន់ពុទ្ធសាសនាដរាប ។	But anyway, the Khmer will still be known as Buddhists forever.
៩ សែម នេះគឺយើងជឿថាពុទ្ធសាសនាធ្វើឲ្យមនុស្សស្លូតត្រង់ ។	That's because we believe that Buddhism makes people lead good lives.
ក៏ដោយ ក៏ដោយ	whether ... or ...
បុណ្យ	good deed, merit
បាប	sin
១០ សខ ម្យ៉ាងទៀត ជាអ្នកស្រែក៏ដោយ ជាអ្នកក្រុងក៏ដោយ គេតែងជឿ ថា ធ្វើបុណ្យបានបុណ្យ ធ្វើបាប បានបាប ។	Also, whether they come from the country or the city, they believe that if you do good, you receive good; and if you do evil, you will receive evil back.

NOTES FOR THE DIALOGUE

SENTENCE NO. 3 The term ត្រូវ is that of ត្រូវគ្រាប់ 'to be struck by a bullet', ត្រូវដាក់ 'to be scolded', or ត្រូវគេវាយ 'to be hit by them.' That is, it the ត្រូវ of 'to undergo an experience', and in this context, the implication is that the experience will be an unpleasant one.

SENTENCE NO. 5 According to Buddhist monastic discipline, monks are supposed to be totally dependent on the alms of the laymen around them. Normally they are supplied with rice and cooked food, which they collect in the early morning or which is brought to them at the wat.

DRILLS

DRILL ONE: Transformation

គំរូ

ក គេឈប់ទៅវត្តទាំងអស់ហើយ ។
(ប្រុស . ស្រី)

ខ ប្រុសក្ដី ស្រីក្ដី បែបឈប់ទៅវត្តទាំងអស់ហើយ មើលទៅ ។

MODEL:

T: They've all stopped going to the wat.
(men - women)

S: Whether women or men, they seem to have all stopped going to the wat.

ក គេមិនសូវជឿព្រះសាសនាទេ ។
(ក្មេង . ចាស់)
ក្មេងក្ដី ចាស់ក្ដី បែបមិនសូវជឿព្រះសាសនាទេ មើលទៅ ។

ខ គេលែងឲ្យកូនទៅរៀននៅវត្តហើយ ។
(អ្នកទីក្រុង . អ្នកស្រែចំការ)
អ្នកទីក្រុងក្ដី អ្នកស្រែចំការក្ដី បែបលែងឲ្យកូនទៅរៀននៅវត្តហើយ មើលទៅ ។

គ គេឈប់ដាក់បាត្រឲ្យលោកហើយ ។
(នៅទីក្រុង . នៅស្រែចំការ)
នៅទីក្រុងក្ដី នៅស្រែចំការក្ដី បែបឈប់ដាក់បាត្រឲ្យលោកហើយ មើលទៅ ។

ឃ ឥឡូវគេចូលធ្វើនយោបាយទាំងអស់គ្នា ។
(សង្ឃ . សិស្ស)
សង្ឃក្ដី សិស្សក្ដី បែបចូលធ្វើនយោបាយទាំងអស់គ្នា មើលទៅ ។

ង ខ្មែរមិនសូវយកចិត្តទុកដាក់និងបុណ្យទំនៀមទម្លាប់ទេ ។
(ចាស់ទុំ . ក្មេងក្មាង)
ចាស់ទុំក្ដី ក្មេងក្មាងក្ដី បែបមិនសូវយកចិត្តទុកដាក់និងបុណ្យទំនៀមទម្លាប់ទេ មើលទៅ ។

ច ខ្មែរលែងបញ្ជូនកូនឲ្យទៅបួសហើយ ។
(អ្នកទីក្រុង . អ្នកស្រែចំការ)
អ្នកទីក្រុងក្ដី អ្នកស្រែចំការក្ដី បែបលែងបញ្ជូនកូនឲ្យទៅបួសហើយ មើលទៅ ។

DRILL TWO: Transformation

គំរូ

ក គេឈប់ទៅវត្តទាំងអស់ហើយ ។
(នៅស្រុកស្រែចំការ . នៅទីក្រុង)

ខ នៅស្រុកស្រែចំការ មិនសូវទៅវត្តទេ តែនៅទីក្រុង ឈប់តែម្ដងហើយ ។

MODEL:

T: They've stopped going to the wat.
(in the country - in the city)

S: In the country they don't go to the wat much, but in the city they don't go at all.

ក គេមិនជឿព្រះសាសនាប៉ុន្មានទេ ។
(ចាស់ល្មមៗ . ក្មេងៗ)
ចាស់ល្មមៗមិនសូវជឿព្រះសាសនាទេ តែក្មេងៗ ឈប់តែម្ដងហើយ ។

១ គេមិនឲ្យកូនទៅរៀននៅវត្តទេ ។
(នៅស្រែចំការ . នៅទីក្រុង)
នៅស្រែចំការមិនសូវឲ្យកូនទៅរៀននៅវត្តទេ តែនៅទីក្រុង ស្រេចតែម្តងហើយ ។

២ គេច្រើនចូលធ្វើនយោបាយទាំងអស់ ។
(អ្នកទីក្រុង អ្នកស្រែចំការ)
អ្នកទីក្រុងមិនសូវចូលធ្វើនយោបាយទេ តែអ្នកស្រែចំការ ស្រេចតែម្តងហើយ ។

៣ ខ្មែរយកចិត្តទុកដាក់នឹងព្រះពុទ្ធសាសនាណាស់ ។
(ចាស់ទុំ . ក្មេងក្មាង)
ចាស់ទុំមិនសូវយកចិត្តទុកដាក់នឹងព្រះពុទ្ធសាសនាទេ តែក្មេងក្មាង ស្រេចតែម្តងហើយ ។

៤ គេមិនបញ្ជូនកូនឲ្យទៅបួសទៀតទេ ។
(អ្នកស្រែចំការ . អ្នកទីក្រុង)
អ្នកស្រែចំការមិនសូវបញ្ជូនកូនឲ្យទៅបួសទេ តែអ្នកទីក្រុង ស្រេចតែម្តងហើយ ។

៥ យើងមិនចូលចិត្តគោរពលោកសង្ឃទេ ។
(នៅខេត្ត . នៅភ្នំពេញ)
នៅខេត្តមិនសូវចូលចិត្តគោរពលោកសង្ឃទេ តែនៅភ្នំពេញ ស្រេចតែម្តងហើយ ។

DRILL THREE: Response

គំរូ
ក នៅស្រុកស្រែចំការមិនសូវទៅវត្តទៀតទេ ។
(នៅទីក្រុង , សោះ)
ខ បើនៅទីក្រុងវិញ ស្រេចតែម្តងហើយ មិនទៅសោះ ។

MODEL:

T: In the country they don't go to the wat.
(in the city - at all)

S: If (you talk about) the city, forget it. They don't go at all.

៦ ចាស់ៗគេមិនសូវជឿសាសនាទេ ។
(ក្មេងៗ , សោះ)
បើក្មេងៗវិញ ស្រេចតែម្តងហើយ មិនជឿសោះ ។

១ តែថ្ងៃបុណ្យ មានក្មេងច្រើនណាស់ ។
(ថ្ងៃក្រោយបុណ្យ .. សោះ)
បើថ្ងៃក្រោយបុណ្យវិញ ស្រេចតែម្តងហើយ គ្មានសោះ ។

២ ពេលសប្បាយ គ្មាននឹកគេបន្តិចទេ ។
(ពេលមានអាសន្ន , គ្មានភ្លេចទេ)
បើពេលមានអាសន្នវិញ ស្រេចតែម្តងហើយ នឹកគេគ្មានភ្លេចទេ ។

៣ ស្រុកអត់ចំបាំង គ្មានអ្នកចង់បួសទេ ។
(ស្រុកមានចំបាំង , រាប់មិនអស់ទេ)
បើស្រុកមានចំបាំងវិញ ស្រេចតែម្តងហើយ បួសរាប់មិនអស់ទេ ។

៤ ស្រុកមានចំបាំង គ្មានលោកណាចង់សឹកទេ ។
(ស្រុកសាន្តត្រាណ, យកមិនអស់ទេ)
បើស្រុកសាន្តត្រាណវិញ ស្រេចតែម្តងហើយ ចង់យកមិនអស់ទេ ។

៥ កាលណាមានទុក្ខ ចាំបន់ព្រះ ។
(កាលណាសប្បាយ , មិនទេ)
បើកាលណាសប្បាយ ស្រេចតែម្តងហើយ មិនបន់មិនទេ ។

DRILL FOUR: Substitution

គំរូ
ក ពិតទៅនិយាយពីលោកសង្ឃ ប្រាកដតែត្រូវហើយ ។
(ស៊ីចង្ហាន់លោក , បាបជាតិជាសត្វ)
ខ ពិតទៅស៊ីចង្ហាន់លោក ប្រាកដតែបាបជាតិជាសត្វហើយ ។

MODEL:

T: If you say anything (bad) about the monks, you'll surely get it.

(eat the monk's food - to be reborn as an animal)

S: If you eat the monk's food, you will surely be reborn as an animal.

គិតទៅស៊ីចង្ហាន់លោក មុខតែចាប់ជាតិជាសត្វហើយ ។

ក ពាក់មួកក្នុងវត្ត , អស់សក់
គិតទៅពាក់មួកក្នុងវត្ត មុខតែអស់សក់ហើយ ។

ខ សម្លាប់សត្វ , មានកម្មជាតិក្រោយ
គិតទៅសម្លាប់សត្វ មុខតែមានកម្មជាតិក្រោយហើយ ។

គ ធ្វើបាបគេ , មានកម្ម
គិតទៅធ្វើបាបគេ មុខតែមានកម្មហើយ ។

ឃ ពាល់ក្បាលចាស់ , បាប
គិតទៅពាល់ក្បាលចាស់ មុខតែបាបហើយ ។

ង អង្គុយខ្ពស់ជាងលោក , បាប
គិតទៅអង្គុយខ្ពស់ជាងលោក មុខតែបាបហើយ ។

ច សម្លាប់មាន់ , ទៅជាមាន់ជាតិក្រោយ
គិតទៅសម្លាប់មាន់ មុខតែទៅជាមាន់ជាតិក្រោយហើយ. ។

DRILL FIVE: Equivalence

គំរូ

ក គិតទៅសម្លាប់សត្វ មុខតែមានកម្មជាតិក្រោយហើយ ។

ខ គិតទៅសម្លាប់សត្វ មុខតែមានកម្មហើយជាតិក្រោយ ។

MODEL:

T: If you kill, you'll surely have consequences in your next life.

S: If you kill, your next life you will surely have consequences.

ក គិតទៅអង្គុយខ្ពស់ជាងលោក មុខតែបាបជាតិក្រោយហើយ ។
គិតទៅអង្គុយខ្ពស់ជាងលោក មុខតែបាបហើយជាតិក្រោយ ។

ខ គិតទៅសម្លាប់គេ មុខតែគេសម្លាប់វិញថ្ងៃក្រោយមិនខាន ។
គិតទៅសម្លាប់គេ មុខតែគេសម្លាប់វិញមិនខានថ្ងៃក្រោយ ។

គ គិតទៅពាក់មួកក្នុងវត្ត មុខតែអស់សក់ពេលណាមួយមិនខាន ។
គិតទៅពាក់មួកក្នុងវត្ត មុខតែអស់សក់មិនខានពេលណាមួយ ។

ឃ គិតទៅស៊ីចង្ហាន់លោក មុខតែទៅជាសត្វហើយដល់កើតម្តងទៀត ។
គិតទៅស៊ីចង្ហាន់លោក មុខតែទៅជាសត្វហើយដល់កើតម្តងទៀត ។

ង គិតទៅធ្វើបាបគេ មុខតែមានកម្មទៅឋាននរកមិនលែង ។
គិតទៅធ្វើបាបគេ មុខតែមានកម្មមិនលែងទៅឋាននរក ។

ច គិតទៅលួចមើលគេ មុខតែធ្លាក់គុកថ្ងៃណាមួយមិនលែង ។
គិតទៅលួចមើលគេ មុខតែធ្លាក់គុកមិនលែងថ្ងៃណាមួយ ។

DRILL SIX: Transformation

គំរូ

ក គិតទៅអង្គុយខ្ពស់ជាងលោក មុខតែបាបហើយជាតិក្រោយ ។

ខ គិតទៅអង្គុយខ្ពស់ជាងលោកទៅចុះ មុខតែបាបហើយ ។

MODEL:

T: If you sit higher than a monk, you will surely be in sin (and have to pay for it) in your next life.

S: If you go ahead and sit higher than a monk, you will surely be in sin.

ក គិតទៅសម្លាប់សត្វ មុខតែមានកម្ម ហើយជាតិក្រោយ ។
គិតទៅសម្លាប់សត្វទៅចុះ មុខតែមានកម្មហើយ ។

ខ គិតទៅតាកប្លុកក្នុងវត្ត មុខតែសសសក មិនខានថ្ងៃណាមួយ ។
គិតទៅតាកប្លុកក្នុងវត្តទៅចុះ មុខតែសសសកមិនខាន ។

គ គិតទៅលួចមើលគេ មុខតែខ្វាក់ភ្នែកមិនលែងថ្ងៃណាមួយ ។
គិតទៅលួចមើលគេទៅចុះ មុខតែខ្វាក់ភ្នែកមិនលែង ។

ឃ គិតទៅស៊ីចង្ហាន់លោក មុខតែទៅជាសត្វហើយដល់កើតខ្លួនទៀត ។
គិតទៅស៊ីចង្ហាន់លោកទៅចុះ មុខតែទៅជាសត្វហើយ ។

ង គិតទៅធ្វើបាបគេ មុខតែមានកម្មមិនលែងទៅអនាគត ។
គិតទៅធ្វើបាបគេទៅចុះ មុខតែមានកម្មមិនលែង ។

ច គិតទៅស៊ីបាយមុនលោក មុខតែកើតជាសត្វមិនខានជាតិក្រោយ ។
គិតទៅស៊ីបាយមុនលោកទៅចុះ មុខតែកើតជាសត្វមិនខាន ។

DRILL SEVEN: Transformation

គំរូ

ក ចាស់ៗអញ្ជើញទៅវត្ត ។
(និមន្តលោកមកផ្ទះបាន)

ខ និមន្តលោកមកផ្ទះបានដែរ អញ្ជើញទៅវត្តធ្វើអី ?

MODEL:

T: The old people go to the wat.
(invite the monks to the house)

S: They can invite the monks to the house, so why should they go to the wat?

ក ទៅវត្តធ្វើបុណ្យ ។
(បើធ្វើបុណ្យបានតែបាប)
បើធ្វើបុណ្យបានតែបាបដែរ ទៅវត្តធ្វើអី ?

ខ បួសសងគុណឪពុកម្ដាយ ។
(បើបួសទៅមិនបានសងគុណ)
បើបួសទៅមិនបានសងគុណដែរ បួសធ្វើអី ?

គ ទៅបួសបំរុងរៀនបាលី ។
(បួសមិនបានរៀន)
បួសមិនបានរៀនដែរ ទៅបួសធ្វើអី ?

ឃ កសាងដើម្បីឲ្យបានកុសល ។
(កសាងមិនបានអី)
កសាងមិនបានអីដែរ កសាងធ្វើអី ?

ង ឲ្យទៅវត្តដើម្បីរៀនធម៌ ។
(បើអត់ប្រយោជន៍)
បើអត់ប្រយោជន៍ដែរ ឲ្យទៅធ្វើអី ?

ច ជួយលោកដើម្បីឲ្យបានបុណ្យ ។
(មិនបានបុណ្យ)
មិនបានបុណ្យដែរ ជួយធ្វើអី ?

DRILL EIGHT: Response

គំរូ

ក ឥឡូវពាក្យបណ្ឌិតគ្មានតំលៃទេ ។
(និយាយ)

ខ ឥឡូវពាក្យបណ្ឌិតគ្មានតំលៃទេ សូម្បីតែនិយាយក៏មិននិយាយដែរ ។

MODEL:

T: Nowadays the tern antit has no value.
(say)

S: Nowadays the tern antit has no value ; they don't even say it (any more).

ក ខ្ញុំមិនសូវទៅវត្តទៅវាទេ ។
(ធ្វើបុណ្យធ្វើបាប)
ខ្ញុំមិនសូវទៅវត្តទៅវាទេ សូម្បីតែធ្វើបុណ្យធ្វើបាបក៏មិនធ្វើដែរ ។

ខ ក្មេងឥឡូវមិនសូវរៀនសាសនាទេ ។

(ចង់យល់)
ក្មេងក្រុងមិនសូវរៀនសាសនាទេ សូម្បីតែចង់យល់ក៏មិនចង់ដែរ ។

គ ធ្វើបុណ្យនេះមិនបានហៅអ្នកណាទេ ។
(ហៅញាតិ)
ធ្វើបុណ្យនេះមិនបានហៅអ្នកណាទេ សូម្បីតែហៅញាតិក៏មិនហៅដែរ ។

ឃ សឹកមកវិញមិនដែលផឹកស្រាទេ ។
(ទៅដើរតៀមស្រា)
សឹកមកវិញមិនដែលផឹកស្រាទេ សូម្បីតែទៅដើរតៀមស្រាក៏មិនទៅដែរ ។

ង លោកសង្ឃមិនឆាន់ល្ងាចទេ ។
(ឆាន់ទឹកដោះគោ)
លោកសង្ឃមិនឆាន់ល្ងាចទេ សូម្បីតែឆាន់ទឹកដោះគោក៏មិនឆាន់ដែរ ។

ច លោកនេនខ្ញុំខ្ជិលធ្វើការណាស់ ។
(កាប់ដី)
លោកនេនខ្ញុំខ្ជិលធ្វើការណាស់ សូម្បីតែកាប់ដីក៏មិនកាប់ដែរ ។

DRILL NINE: Transformation

គំរូ
ក ខ្មែរមិនចូលចិត្តទៅវត្តទេ ។
(គេកាន់ពុទ្ធសាសនាដរាប)
ខ ខ្មែរមិនចូលចិត្តទៅវត្តទេ តែអាស្រ័យយ៉ាងណាក៏ដោយក៏គេនៅតែកាន់ពុទ្ធសាសនាដរាប ។

MODEL:

T: The Khmer don't like to go to the wat.
(they'll always be Buddhists)

S: The Khmer don't like to go to the wat, but nevertheless they'll always be Buddhists.

ក ឪពុកខ្ញុំរក្សាសីលរាល់ថ្ងៃសីល ។
(គាត់ពិសាស្រាដរាប)
ឪពុកខ្ញុំរក្សាសីលរាល់ថ្ងៃសីល តែអាស្រ័យយ៉ាងណាក៏ដោយក៏គាត់នៅតែពិសាស្រាដរាប ។

ខ បងខ្ញុំជឿបុណ្យជឿបាបណាស់ ។
(គាត់លួចគេ)
បងខ្ញុំជឿបុណ្យជឿបាបណាស់ តែអាស្រ័យយ៉ាងណាក៏ដោយក៏គាត់នៅតែលួចគេ ។

គ ហៀងនិងបាន[illegible]ល្អ ។
(ហៀងមិនធ្វើការ)
ហៀងនិងបាន[illegible]ល្អ តែអាស្រ័យយ៉ាងណាក៏ដោយក៏ហៀងនៅតែមិនធ្វើការ ។

ឃ ក្មេងៗគោរពលោកសង្ឃ ។
(គេមិនជឿពុទ្ធសាសនា)
ក្មេងៗគោរពលោកសង្ឃ តែអាស្រ័យយ៉ាងណាក៏ដោយក៏គេនៅតែមិនជឿពុទ្ធសាសនា ។

ង ខ្ញុំចូលចិត្តស្ដាប់អំពីសាសនាគ្រិស្ត ។
(ខ្ញុំមិនជឿ)
ខ្ញុំចូលចិត្តស្ដាប់អំពីសាសនាគ្រិស្ត តែអាស្រ័យយ៉ាងណាក៏ដោយក៏ខ្ញុំនៅតែមិនជឿ ។

ច ឪពុកម្ដាយខ្ញុំជឿពុទ្ធសាសនា ។
(គាត់មិនឲ្យកូនគាត់បួស)
ឪពុកម្ដាយខ្ញុំជឿពុទ្ធសាសនា តែអាស្រ័យយ៉ាងណាក៏ដោយក៏គាត់នៅតែមិនឲ្យកូនគាត់បួស ។

DRILL TEN: Equivalence

គំរូ
ក ទាំងអ្នកស្រែ ទាំងអ្នកក្រុង តែងតែជឿបុណ្យជឿបាប ។
ខ អ្នកស្រែក៏ដោយ អ្នកក្រុងក៏ដោយ គេតែងជឿបុណ្យជឿបាប ។

MODEL:

T: Both country and city people usually believe in merit and sin.

S: Whether country or city people, they

usually believe in merit and sin.

១ ទាំងភិក្ខុទាំងនេន និមន្តទាំងអស់ ។
ភិក្ខុក៏ដោយ នេនក៏ដោយ និមន្ត
ទាំងអស់ ។

២ ទាំងកូនស្តេច ទាំងកូនរាស្ត្រ ធ្លា
ប់ត្រូវរៀនក្នុងវត្ត ។
កូនស្តេចក៏ដោយ កូនរាស្ត្រក៏ដោយ
ធ្លាប់ត្រូវរៀនក្នុងវត្ត ។

៣ ទាំងឪពុកខ្ញុំ ទាំងម្តាយខ្ញុំ ចង់ឲ្យ
ខ្ញុំទៅបួសទាំងអស់ ។
ឪពុកខ្ញុំក៏ដោយ ម្តាយខ្ញុំក៏ដោយ ចង់
ឲ្យខ្ញុំទៅបួសទាំងអស់ ។

៤ ទាំងប្រុស ទាំងស្រី សុំសីលបាន
ដូចគ្នា ។
ប្រុសក៏ដោយ ស្រីក៏ដោយ សុំសីល
បានដូចគ្នា ។

៥ ទាំងព្រះសង្ឃ ទាំងទាហាន មិន
អាចបោះឆ្នោតបានទេ ។
ព្រះសង្ឃក៏ដោយ ទាហានក៏ដោយ
មិនអាចបោះឆ្នោតបានទេ ។

៦ ទាំងអ្នកមាន ទាំងអ្នកក្រ ខំធ្វើបុណ្យ
ណាស់ ។
អ្នកមានក៏ដោយ អ្នកក្រក៏ដោយ ខំ
ធ្វើបុណ្យណាស់ ។



Venerable Huot Tath, Supreme Head Monk of the Mohanikay Order, looks on the books exhibition with, on his left (in white shirt), Mr. Maing Mory, Under-Secretary of State for Religion.

READING PASSAGE 2

ពុទ្ធសាសនានិងយុវជនខ្មែរ

ប្រជាជនខ្មែរអប់រំកូនចៅតាមប្រពៃណីបូរាណ គឺឱ្យកូនចៅទៅរៀននៅវត្ត ។ កូនខ្មែរទោះជាព្រះរាជបុត្រក្តី បុត្រមន្ត្រីក្តី កូនចៅប្រជានុរាស្ត្រក្តី ទាំងអស់ទៅរៀននៅវត្ត យកវត្តជាសាលារៀន ។ វត្តមួយៗ ត្រូវបង្រៀនមុខវិជ្ជាបានគ្រប់យ៉ាង បង្រៀនអក្សរ នព្វន្ត ការរចនា ការស្ថាបនា ច្បាប់សីលធម៌ និងធម៌គាថាពុទ្ធសាសនា ។

កូនខ្មែរដែលបានរៀនសូត្រចេះដឹងគួរសមហើយត្រូវបួសជាសាមណេរ ជាភិក្ខុ កើតទៅជាទំនៀមថា កូនប្រុសអាយុ១២ឆ្នាំ ត្រូវបួសជាសាមណេរសងគុណមាតា, អាយុ២១ឆ្នាំ ត្រូវបួសជាភិក្ខុសងគុណបិតា, បួសហើយត្រូវរៀនសូត្រវិជ្ជាខ្ពង់ខ្ពស់តទៅទៀត រៀនបាលី រៀនធម៌គាថាពុទ្ធវចនៈ ។ល។

កូនចៅខ្មែរ, បើបានបួសជាសាមណេរ ជាភិក្ខុហើយ សឹកមកវិញ ទើបគេរាប់ថាជាមនុស្សពេញអង្គ. សឹកមកវិញភ្លាម គេឲ្យនាមថា បណ្ឌិត ប្រែថា អ្នកប្រាជ្ញគេលែងហៅ អា មឹង ដូចពីដើមហើយ ។ បើមិនបានបួសទេ គេហៅ អា មឹង មួយជាតិ ហើយគេមិនរាប់ជាក្រីមុខទេ ។

បើបានបួសហើយ តែខ្ជិលរៀនសូត្រទៀត ច្បាប់ក្រមខ្មែរបន្ទោសថា «កំផិលគៀនប្រៀន បួសហើយមិនរៀនបន្ទោសថាខ្លៅ» ។ អាស្រ័យដោយការអប់រំប្រសើរនេះហើយទើបបានជាប្រជាជនខ្មែរមានចរិយាសុភាព រាបសាស្លូតត្រង់ចិត្តថ្លើមល្អ មិន

សូវចេះបៀតបៀនគ្នីគ្នាទេ ។

សព្វថ្ងៃនេះ កូនប្រុសពុំសូវចូលជាភិក្ខុ ជាសាមណេរដូចជំនាន់មុនទេ ព្រោះមានសាលារៀនកើតនៅក្រៅវត្តច្រើន តែទោះម្ដេចក្ដី ព្រះរាជរដ្ឋាភិបាលក៏ព្យាយាមបង្កើតសាលានៅតាមវត្តដូចបុរាណកាលវិញជាបំផុត ។ សូម្បីមានសាលារៀននៅក្រៅវត្ត តែសិស្សច្រើនគ្នាណាស់ដែលពឹងពាក់អាស្រ័យនៅតាមវត្តជាឱកាសល្អបានសេពគប់ព្រះសង្ឃ ។

NOTE FOR READING PASSAGE 2

Line 18 Like many proverbs and old sayings, this is in verse. Most Cambodian literature produced before the 19th and 20th centuries is in verse.

VOCABULARY

កក់ក្ដៅ		warm (emotion); to hope, secure; cordial
កម្ម	/kam/	actions (good and bad), (often used in negative sense to indicate the effects and consequences of the bad actions for the perpetrator), karma
ករុណា		to forgive
កាន់ក្បាលចាស់		to touch the head of an older person (considered to be a sin)
[illegible]		in this matter
* កែខៃ		to correct, amend, fix
ខៃ		to drill, extreme (fine)
ខជិល (ខ្ជិល)		laziness; lazy person
* ក្មេងក្មាង (ក្មាង AC)		youngsters, children
* ក្លា		clear, sure
ខ្លៅ		stupid, ignorant
ខ្វាក់		blind
គូរ		to draw, to sketch
គោលដៅ		purpose, goal
ចរន្ត	/ca?ron/	current, movement
ចរិយា	/ca?riyaa/	character, attitude (literary)
ចាប់ជាតិ		to be reborn
ចិត្តថ្លើម		one's heart and mind
ចិត្តទូលាយ		generous, broad-minded
ឆន្ទ	/chanté?/	will, desire
ជានិរន្តរ៍	/ciani?rondɔɔ, - ni?ron/	forever, in the future
ជាបំផុត		especially, last of all
[illegible]		crude, vulgar, disrespectful
ជៀសវាង	(L)	to avoid
ញ៉ាំងឲ្យ		to cause to
ដរាប		always
ដុះដាល		to prosper, flourish
ដាល		to expand (in an undesirable way)
ដោះស្រាយ		to solve (a problem)
ណេន (នេន)		novice monk
[illegible]		respectable, good
ត្រើយខាងនាយ		the next life, the other bank (river)
ទាន់ភ្នែក		immediate, tragic
តៀមស្រា		stall that sells liquor by the drink; bar
តៀម		stall, small shop
ទីបំផុត		last phase, last level, finally
ទោមនស្ស	/toomenah/	to be concerned, disappointed; upset
ទោះ[illegible]		in any case, nevertheless, anyway, anyhow
ទាំងស្រុង		all; every one
ធន	/thɔ́n/	property, capital (money)
[illegible]	/thoń aa/	([illegible] CC) = [illegible]
* នព្វន្ត	/nopún/	arithmetic (literary)
និរន្តរ៍		see ជានិរន្តរ៍
* បដិសន្ធិ	/pa?de?sonthi?/	life, incarnation
បណ្ឌិត		title for a learned person, doctor (e.g., of philosophy), title for a young man who has been a monk
បន់		to wish, pray for
បន្ទោស	ទោស	to blame
បុគ្គល		individual
* [illegible]	/pathoccún/	(= [illegible]) original sin, emergent

បុព្វកម្ម	/boppukam/	karma from a previous life (see កម្ម)
បុរាណ		ancient, old, classical, old fashioned
បៀតបៀន		to interfere with other, violate the rights of others, to injure another
បោះឆ្នោត		to vote, to hold an election
ប្រក្រតី	/prokrodey/	usual, ordinary
ប្រជារាស្ត្រ		the common people
ប្រព្រឹត្ត		to do, perform
ប្រព្រឹត្តទៅ		to happen, carry on
ផុស		to arise, appear, emerge
ផ្តាច់ (ដាច់)		to cut, to cause to break
ពៀរ		refers to bad actions that will have bad consequences (see កម្ម)
ពេញសង្គ		fully
ព្រេងវាសនា		fate since former times
* ព្រេង		relating to earliest times
* ព្រះសម្ពុទ្ធបរមគ្រូ		the Buddha
* សម្ពុទ្ធ		one who is enlightened
ភស្តុតាង	/phɔhtaaŋ/	proof, evidence
ក្អើកក្អើន		proud, arrogant
* មគ្គុទេស	/méʔkuʔteeh/	guide (literary)
មរណ	/mɔrənaʔ/	to die
មិនរំលង		without fail
មុខវិជ្ជា		field of knowledge
មួយជាតិ		all one's lifetime
យថាកម្ម	/yéʔthaakam/	fate, destiny
* យថា	(H)	along with, following
យឺតយូរ		slow, long time

យុវជន		youth, young people
* យុវ	/yuvéʔ/ (H)	young
រក្សាសីល		to live piously, to visit the wat, keep Buddhist precepts, practise religion
រង់ចាំ		to wait
* រង់		to wait (for royalty or clergy)
រចនា		decoration, pattern, to make a pattern, to think in an organized way
រារាំង	(រាំង CC)	to obstruct, hinder
រា		to obstruct, hinder
រាបសា		knows right from wrong, well-bred, polite
រាល់គ្នា		all (together), every one
រាលដាល		all over, everywhere
លទ្ធផល	/lattephɔl/	result, product, outcome
លទ្ធ	/ləttéʔ/	decision, result
លាងបាប		to cleanse of sin
ល្បែងស៊ីសង		gambling
* វដ្តសង្សារ	/vattəsɔŋsaa/	a cycle of birth-death-rebirth
វត្តវា	(វា AC)	wats (colloquial)
វិនាស		to be destroyed, to ruin
* វិបល្លាស	/vɨppəllaah/	change
វិហារ	/vihia/ (L)	church, sanctuary (of a wat), temple
* វៀរបង់	(វៀរ CC)	to discard, give up, throw out
សតិអារម្មណ៍		thought, idea
* សតិ	/səteʔ/	thought (lit.)
អារម្មណ៍		impression, thought, contemplation
សន្តោស		to forgive
សន្សំ		to save up

សភាវ	/sa?phiavé?/(=សភាព)	aspect, state of being, appearence (literary)
* សមុច្ឆេទប្បហាន	/samu?cheetəpa?haan/	to give up desire completely
* ប្រហារ		to attack, beat, kill (formal)
ស័ក្តិ	/sa?/(=ស័ក្ដិ)	rank
សាន្តត្រាណ (ត្រាណAC)		peaceful, calm
		a novice monk
សេពគប់	/saep kúp/	to associate with, to be members of the same crowd
* សេព		to eat, live off
គប់		to associate with (obsolete)
សោមនស្ស		to like, be interested, curious, happy (formal)
សំអាង (<អាង)		something on which one relies
ស្តុកស្តម្ភ	/sdoksdɔm/	a lot, much (used to refer to wealth)
ស្តុក		much (wealth)
* ស្តម្ភ	/sdɔm/	column, firm
ស្ថាននរក	/thaannərú?/ (L)	Hell
ស្ថានសួគ៌	/thaansuo/ (L)	Heaven
ស្ថិតស្ថេរ	/thətthee/	firm, stable
[illegible]		forget it, no way, that's the end of it, completely shot
ស្លូតត្រង់		decent, of good character
ស្លូត		docile, tame
អកុសល	/a?kəsɔl/	unfortunate, unlucky
អ		not (like English un-, in-, a-, am-)
កុសល		good fortune (formal); lucky, fortunate
អត់ឃ្លាន		to starve
អធ្យាស្រ័យ		mutual understanding; to be understanding
អនាគតជាតិ		future life
អនាគត	/a?naakút/	future
អន្ទិត (បណ្ឌិត)		title given to a young person who has been a monk (spoken version)
អន្លង់		hole, ditch
អរហន្ត	/arəhɔn/	one who has succeeded in detaching himself from worldly desire
អាត្មា		self; I, me (clergy)
អាទឹង		refers to intimate or contemptuous words like អាឯង, វា etc.
អាសន្ន	/əsɔn/	emergency (adj. or n.)
អាស្រ័យដោយហេតុនេះហើយ		for this reason
អាស្រ័យយ៉ាងណាក៏ដោយ		nevertheless, anyway
អ៊ីចេះអ៊ីចុះ		this and that, thus and so
អ៊ីចេះ		like this, thus
អ៊ីចុះ		like that, thus
ឧក្រិដ្ឋ	/okrət/(H)	serious (formal), criminal
អើពើ		to be concerned, to pay attention, be interested in
អៀនប្រៀន (ប្រៀនAC)		to be shy, asnamed
អៀន		to be shy
អំណត់ (<អត់)		patience, endurance

APPLICATIONS

1. Find words or phrases that fit the following definition or sentence.

១ ដើម្បីថាអ្នកនេះអាក្រក់ អ្នកនោះល្អ លោកត្រូវមានអ្វីមួយជាក់ច្បាស់បង្ហាញឲ្យឃើញ យ៉ាងនោះ ។
២ មនុស្សម្នាក់ធ្វើអាក្រក់ មនុស្សនោះនឹងទទួលទោសរបស់ខ្លួន ។
៣ ទទួលសេចក្ដីស្លាប់ ។
៤ សៀវភៅដែលបង្ហាញប្រាប់ឲ្យលោកធ្វើយ៉ាងនេះយ៉ាងនោះ ។
៥ សប្បាយចិត្ត ពេញចិត្ត ឬ មិនសប្បាយចិត្ត មិនពេញចិត្ត ។
៦ ស្លាប់ទៅ កើតជាថ្មីជាតិក្រោយក៏កើតទៅចុះប្រសិនដែលបុណ្យបាបយើងបានកសាង ។
៧ ដើម្បីសងគុណឪពុកម្ដាយ កូនប្រុសត្រូវទៅបួសធ្វើជាសង្ឃ ។
៨ គេមិនដែលបាននិមន្តលោកមកពិសាបាយទេ ។
៩ បោះបង់ភេទសង្ឃមកវិញ ។

2. Correct the following sentences by adding the proper words.

១ ចំពោះមនុស្សបុថុជ្ជន ដូចយើងគ្នា ។
២ [illegible] អាចនាំមកការផ្លាស់ប្រែបាន ។
៣ រឿងនេះញាំងយើងទៅកាន់ផ្លូវសុចរិត ។
៤ លទ្ធផលកើតពីការព្យាយាម និងនាំឲ្យទៅកាន់សេចក្ដីសុខ ។
៥ យើងស្រឡាញ់ការរស់នៅដែលពេញទៅសេចក្ដីសុខ ។
៦ ខ្ញុំចង់តែស្លាប់ ហើយចាប់ជាតិនិងគ្រួសារអ្នកមាន ។
៧ កម្មនិយមសេចក្ដីចេញមិនទៀងទេ ។
៨ យើងអាចធ្វើកម្មប្រែត្រឡប់វិញបាន គឺពីអាក្រក់ឲ្យទៅជាល្អ ។
៩ នេះគ្រាន់តែប្រាប់យើងដើរតាមផ្លូវចិត្តប៉ុណ្ណោះ ។
១០ យើងត្រូវកសាងកុសលទៀង ។

3. Define the following words.

បុថុជ្ជន ឬ ប្រថុជ្ជន
សាសនា
បុព្វកម្ម
សន្ដោស
ភស្តុតាង
ស្ដុកស្ដម្ភ
សន្សំ
និមន្ត
សុចរិត
ព្យាយាម
បុគ្គលដទៃ
សាងបាប
អាត្មា
ស្ថានសួគ៌
ស្ថាននរក

4. Find the synonyms of the following words.

សោមនស្ស
កម្ម
ចរន្ត
សាសនា
មរណា
សុចរិត
ប្រពៃ
ឆាន់
និមន្ត

5. Give an opposite for each of the following.

ខ្មៅ [illegible] បន្ទាស ល្ងង់ ស្ថាននរក កុសល សក្តិ

[illegible] [illegible] បុរាណ [illegible] សុខ [illegible] រៀន

6. Have the student discuss the following situations.

១ បើគ្មានសាសនា មនុស្សទៅជាយ៉ាងមេច ?

២ ហេតុដែលធ្វើឲ្យមនុស្សកាន់សាសនាផ្សេងៗ ។

៣ សាសនាក្នុងពិភពលោក

៤ ស្ថាបសាសនា

៥ ទ្រឹស្ដីព្រះពុទ្ធនិងទ្រឹស្ដីយេស៊ូ

7. If you are familiar with it, explain the concept of original sin to your teacher. What is this concept meant to account for in the human condition?

8. Question for the teacher to ask.

១ អាមេរិកាំងច្រើនកាន់សាសនាអី ?

២ តាមយោបល់លោក តើមនុស្សដែលកាន់សាសនានោះមាន[illegible] ?

៣ នៅស.រ.អ. មានសាសនាពីរដែលប្រកាន់ជាងគេ ។ សាសនាទីមួយអ្នកជឿមិនត្រូវជក់បារី ផឹកស្រា លេងល្បែងស៊ីសង (gambling) ឬ[illegible] ។ល។ ហើយសាសនាមួយទៀត អ្នកជឿមិនអាចឲ្យបញ្ចូលឈាម ទោះជាគេឈឺយ៉ាងខ្លាំងត្រូវការឈាមយ៉ាងណាក៏ដោយ ។ ខ្ញុំសុំលោកនិយាយប្រាប់ឲ្យបានច្រើនទៀតអំពីសាសនាទាំងពីរនេះ ។

៤ ក្រៅពីសាសនាកាតូលិក និងប្រូតេស្តង់ តើមានសាសនាណាទៀតទេដែលជនជាតិអាមេរិកាំង គេកាន់ ទេ ។

៥ វិហារកាតូលិកដែលធំជាងគេនៅស្រុកអាមេរិក នៅទីក្រុងណា រដ្ឋណា ? ចុះវិហារប្រូតេស្តង់ ?

៦ តាមយោបល់លោក វិហារណាខ្លះដែលអ្នកដំណើរគួរទៅលេង ?

៧ នៅក្បែរ ឬជិតផ្ទះលោក មានវិហារទេ ?

៨ លោកកាន់សាសនាណា ? ទៅវិហារណា ?

៩ នៅស.រ.អ. មានសាសនាណាដែលជាសាសនាជាតិទេ ?

9. Questions for the student to ask.

a. What are the rules which every Buddhist should follow?

b. In Buddhist theory (as opposed to popular religion), why should people feed the monks and visit the wat?

c. In popular belief, what is the reason for these actions?

d. In theory, can a person be cleansed of sin? Is popular belief different in this respect?

e. Is free will a meaningful concept, or do Buddhists believe that everything one does is determined by one's កម្ម ?

f. What are some of the important rules that govern the lives of monks that are different from those that affect layman?

g. Has the observance of some such rules had to be altered because of the demands of modern life?

h. If one becomes a monk, is it for life? If not, how many times can one enter and leave the monkhood? Can a married man become a monk?

i. Can a wat own property (e.g., land that was willed to it)? If so, who is responsible for such wordly affairs?

j. What are the main reasons for becoming a monk? For leaving the monkhood?

LESSON THIRTEEN

THE NEW YEAR HOLIDAY

a. Is there such a thing as a New Year's resolution in Cambodia?

b. Are there ceremonies and holidays in which monks do not participate? If so, what are they?

c. Do individuals celebrate their birthdays? If so, how?

ចូលឆ្នាំថ្មី

ក្នុងឱកាសសង្ក្រាន្តចូលឆ្នាំតាមទំនៀមហោរាចាប់កំណត់ទុកជា ៣ ថ្ងៃ ។ ដំបូងហៅថ្ងៃមហាសង្ក្រាន្ត ថ្ងៃទី ២ ហៅជាថ្ងៃវណ្ណបតថ្ងៃទី ៣ ហៅជាថ្ងៃឡើងស័កជាស្ដេចថ្ងៃ ជាថ្ងៃល្អ ទោះបានលើថ្ងៃអាទិត្យ ឬចន្ទ អង្គារជាដើមក៏ដោយ សឹងមានសេចក្ដីពន្យល់ច្បាស់លាស់ទៅតាមក្បួនហោរាស្រាប់ ។

ឯទំនៀមចូលឆ្នាំទាំង ៣ ថ្ងៃនោះ សូមឲ្យមហាជនប្រជាពលរដ្ឋរៀបចំតាក់តែងរូបកាយខ្លួនប្រាណ នឹងសំពត់ខោអាវសារ៉ៃស្យប្រដាប់ប្រើប្រាស់ផ្ទះលំនៅជាដើម គឺឲ្យបោសប្រាសដុសលាងជូតសំអាត ហើយឲ្យរកផ្កាទៀនធូបជាដើមធ្វើជាសក្ការបូជាព្រះរតនត្រ័យនឹងបូជាទេវតាថ្មី ហើយនឹងតាំងចិត្តឲ្យបានរក្សាសីលធ្វើកាយវាចាចិត្តឲ្យសុចរិតក្នុងឆ្នាំថ្មីតទៅទៀត ។

រីឯពិធីនិងទំនៀមចូលឆ្នាំតាមប្រពៃណីខ្មែរយើង សឹងមានសេចក្ដីជា ២ ប្រការគឺ ៖

១– ប្រពៃណីពុទ្ធសាសននិយម

២– ប្រពៃណីលោកនិយម

ក)– ឯប្រពៃណីពុទ្ធសាសននិយមនោះ បើកាលណាដល់ពេលចូលឆ្នាំគេតែងនាំគ្នាទៅកាន់វត្តអារាម គឺបើពេលព្រឹកគេតែងយក

ចង្ហាន់ទៅប្រគេនលោក ឬ វេរភត្តាហារឧទ្ទិសផលតាមទៀងដល់ញាតិកាទាំង ៧ សន្តានមានមាតាបិតាជីដូនជីតាជាដើម ។ ពេលរសៀលល្ងាច គេតែងនាំយកគេបដ្ឋៈទៀនធូបតែស្ករផ្កាស្លាជាដើមទៅប្រគេនលោកសង្ឃផង អ្នកខ្លះគេនិមន្តលោកសង្ឃទៅបង្សុកូលឧទ្ទិសភាគផលជូនដល់ញាតិ ។ អ្នកខ្លះគេដងទឹកស្រង់ព្រះពុទ្ធរូបនិងស្រង់ព្រះសង្ឃ ។ អ្នកខ្លះនាំគ្នាជញ្ជូនដីដាក់ទីវត្តត្រង់ដែលមានក្រហែងក្រហូង អ្នកខ្លះទៀតជញ្ជូនខ្សាច់យកមកពូនកធ្វើជា «វាលុកចេតិយ» ធ្វើទង់ធ្វើព្រះភជ៌តិផ្សេង ៗ ហើយនិមន្តលោកសូត្រមន្តទេសនា ជាវត្ថុបុណ្យកុសលរបស់ខ្លួនគ្រប់ ៗ គ្នា ។

១)– ឯប្រពៃណីលោកនិយមនោះ កាលណាបើជិតដល់ពេលចូលឆ្នាំម្តងៗ គេតែងប្រឹងប្រើយកចិត្តការងារបន្តិចបន្តួច បើការនោះធំ ឬ ច្រើនគេក៏ផ្អាកបង្អង់ទុកចូលឆ្នាំរួចទើបចាប់ធ្វើតទៅទៀត ។

ឯត្រង់កិច្ចដែលកំពុងចូលឆ្នាំទាំង ៣ ថ្ងៃ គេមិនត្រូវប្រកបរបរអ្វីទាំងក្រៅអំពីការធ្វើបុណ្យនិងលេងល្បែងកំសាន្តឡើយ ពោលគឺគេត្រូវស្លដណ្តាំ ធ្វើនំចំណីចែកជូនម៉ែឪញាតិមិត្ត ខ្លះដងទឹកជូនចាស់ទុំ ខ្លះជូនសំលៀកបំពាក់ម៉ែឪ ខ្លះនាំគ្នាលេងល្បែងកំសាន្ត គឺបោះឈូងប្រលែង ទាញព្រ័ត្រ·លេងអង្គុញ អន្ទាក់កាច់-ស្តេចចង់·ចាប់កូនខ្លែង - បន្ទង់កូនទាទជាដើម ។

រួមទំនៀមប្រពៃណីទាំងពីរប្រការដែលបុរាណខ្មែរធ្លាប់និយមកាន់តមកហើយនេះ ជាការចាំបាច់របស់ជាតិខ្មែរ ក្នុងប្រទេសជារៀងរាល់ឆ្នាំមក ទើបហៅថា បុណ្យចូលឆ្នាំ ឬ ហៅថា «ជីវិតមហាគម្ម» ប្រែថាធ្វើបុណ្យធ្វើជីវិត ដោយមានអត្ថន័យថា ជីវិតគឺអាយុនៃយើងដែលរស់នៅគ្រប់គ្នា បានពេញ ១ ឆ្នាំ ទុកជាជីវិតមានភ័ព្វសំណាងល្អណាស់

ដោយ គ្មានគ្រោះថ្នាក់ ឬ ឧបស័គ្គអ្វីមួយ មកបំផ្លាញឲ្យអន្តរាយបាន ឡើយនោះ ។

សេចក្ដីនេះហើយ ទើបយើងគ្រប់គ្នាត្រូវតែធ្វើបុណ្យឆ្លងជីវិតរបស់ខ្លួនទុកប្រចាំ ជាការចាំបាច់ ដើម្បីសំដែងឲ្យឃើញសេចក្ដីអំណររបស់ខ្លួនផង ដើម្បីកំណត់សំគាល់អាយុកាលរបស់ខ្លួនផង ។

NOTES FOR READING PASSAGE 1

Line 1. Sunday, Monday, and Tuesday are considered to be unlucky days by astrologers.

Line 19. The seven groups refered to here are the seven generations including one's own generation plus three ascending and three descending generations (through great grandparents and great grandchildren). (The names of the members of the seven generations are given in the Grammatical Sketch section U.2.)

Line 30. Note that here ចូលឆ្នាំ is a verb, not the name of a holiday.

Line 36. The phrase បុរាណខ្មែរ is equivalent to ខ្មែរបុរាណ 'the ancient Khmer.'

Line 38. The word ទើប here means 'and so.'

DIALOGUE

សង្ឃទាន

ករុណា = ខ្ញុំករុណា	I, me (to monk)
និមន្ត	to invite (a monk)
ទាន	alms
សង្ឃទាន	(see note)
ខានស្អែក	day after tomorrow
១ ខុន ម៉ែករុណាឲ្យករុណាមកនិមន្តលោកពីរអង្គទៅសង្ឃទានខានស្អែក ។	My mother sent me to invite two monks to have a meal the day after tomorrow.
ញោម	you, he, she (see note)
អាត្មា	I, me (by monk)
២ តាក់ ញោមប្រាប់អាត្មាដែរ ។ អាត្មានិមន្តលោកឲ្យហើយ ។	She told me, too. I've already invited them.
កុដិ /kot/	monk's quarters
តេជគុណ	you (to monk)
៣ ខុន កុដិតេជគុណមានលោក៨អង្គដដែលឬ តេជគុណ?	Are there still 8 monks in your quarters?
ចំរើនពរ	yes (by monk)
ភិក្ខុ	Buddhist monk
៤ តាក់ ចំរើនពរ មានដដែល តែភិក្ខុមួយអង្គនិមន្តទៅស្រុក១អាទិត្យហើយ ។	Yes, the same as before, but one has gone home for a week.
អាសន្ន	urgent
៥ ខុន មានការណ៍ធុរៈអីជាអាសន្ន តេជគុណ?	Was there some emergency?
ញោមប្រុស	male layman
៦ តាក់ ញោមប្រុសឈឺខ្លាំងណាស់ ។ ហើយញោមធ្វើសង្ឃទានឲ្យអ្នកណា?	His father is very sick... And for whom is your mother inviting the monks?
ករុណា (ករុណា)	yes (see note)
៧ ខុន ករុណា ម៉ែករុណាធ្វើឲ្យយាយ ។	She's doing it for grandmother.

លោក	he, they (referring to monks)
៨ ភគ. ខានស្អែក ម៉ោងប៉ុន្មាន? ចាំអាត្មាប្រាប់លោកឱ្យម្ដងទៀត ។	Day after tomorrow, what time? I'll tell the monks again for her.
៩ ទុន. ម៉ោង៨ព្រឹក ហើយចាំកូនណា មកទទួល ។	Eight in the mroning, and I'll come to get them.
ថ្ងៃក្រោយ	next time, some other day
១០ ភគ. អញ្ចឹងស្រួលហើយ ហើយប្រាប់ញោមផង ថ្ងៃក្រោយអាត្មានិមន្តទៅម្ដង ។	Good. And tell your mother that next time I'll go there (myself).

NOTES FOR THE DIALOGUE

SENTENCE NO. 1 A សង្ឃទាន is a ceremony at someone's house at which monks are invited to chant. As part of the ceremony the monks are given a meal. Such a ceremony is usually arranged for someone who can not get to the wat, such as an old person or an invalid.

SENTENCE NO. 2 The term ញោម is used by a monk for his relatives of both sexes who are of an older generation than he. It is also used for acquaintances in the approproate age range. Strangers and younger people are addressed in the usual ways.

SENTENCE NO. 4 Note that ចំរើនពរ (or just ពរ) is used by a monk the way a layman would use បាទ . However, he will use (ចំរើន)ពរ less often than the layman uses ករុណា (± បាទ) to him.

SENTENCE NO. 4 The term ស្រុក means 'the place where one comes from' in this sentence.

SENTENCE NO. 7 Note that ករុណា is the appropriate replacement for បាទ or ចា៎ when a layman talks to a monk. The usual fast speech pronunciation of this word is /kənnaa/.

Other term used to, about, and by monks are given in the following table.

Used by Clergy to Layman	Used by Layman to Layman	Used by Layman to Clergy
ញោមប្រុស, ញោមស្រី	ឪពុកម្តាយ, មាមីង	លោក, តេជគុណ
ជីដូនជីតា, តាយាយ	ជីដូនជីតា	លោកតា, លោកគ្រូ
ចាស់ទុំ	ចាស់ទុំស្រីប្រុស	
អាត្មា, អាត្មាភាព	ខ្ញុំ	ខ្ញុំករុណា, ទូលបង្គំ
ចំរើនពរ, អ៊ឺ អើ(ទៅក្មេង)	បាទ, ចា៎, អ៊ឺ អើ	ករុណា
ចំរើនពរ, ចំរើនពរលា	ជំរាបសួរ, ជំរាបលា	(ក្រាប)ថ្វាយបង្គំ, -លា
(ញោម) ទៅ, មក, ដើរ	ទៅ, មក, ដើរ	និមន្តទៅ, មក, ដើរ
(អាត្មា) និមន្តទៅ, មក, ដើរ		
អញ្ជើញ	អញ្ជើញ	និមន្ត
ឆាន់ [1]	ញ៉ាំ ។ល។	ឆាន់
មានពុទ្ធដីកា [1]	មានប្រសាសន៍, និយាយ	មានពុទ្ធដីកា
ប្រគេន [1]	ឲ្យ, ជូន	ប្រគេន
កុដិ [1]	ផ្ទះ	កុដិ
បច្ច័យ [1]	លុយ	បច្ច័យ
អាពាធ [1]	ឈឺ	អាពាធ
សឹង [1]	ដេក, គេង	សឹង
បិណ្ឌបាត្រ [1]	សុំ(ទាន)	បិណ្ឌបាត្រ
ញោម	លោក	លោក, តេជគុណ
ស្បង់ចីពរ [1]	សំលៀកបំពាក់, ខោអាវ	ស្បង់ចីពរ
	(សុំ)អញ្ជើញចូល(លោក)	សុំនិមន្តចូលតេជគុណ
គង់ [1]	នៅ	គង់
ស្រង់, ស្រង់ទឹក [1]	ងូតទឹក	ស្រង់, ស្រង់ទឹក
សុគត [1]	ស្លាប់, ងាប់	សុគត
គាត់, គេ, វា	គាត់, គេ, វា	ព្រះអង្គ, លោក, តេជគុណ
នាគ	នាគ	អង្គ

---

[1] These are used by the monk when speaking of himself, e.g., អាត្មាឆាន់ 'I eat,' ប្រគេនអាត្មា 'for me.'

DRILLS

DRILL ONE: Substitution

គំរូ

ក ករុណាមកនិមន្តលោកទៅសង្ឃទាន ខានថ្ងៃស្អែក។

(ទេសនា)

ខ ករុណាមកនិមន្តលោកទៅទេសនា ខានថ្ងៃស្អែក។

MODEL:

T: I came to invite some monks to a ceremony at the house day after tomorrow.

(to preach)

S: I came to invite some monks to preach day after tomorrow.

ករុណាមកនិមន្តលោកទៅទេសនា ខានថ្ងៃស្អែក។

ក សូត្រមន្ត

ករុណាមកនិមន្តលោកទៅសូត្រមន្ត ខានថ្ងៃស្អែក។

ខ ស្រោចទឹកឲ្យខ្ញុំ

ករុណាមកនិមន្តលោកទៅស្រោចទឹកឲ្យខ្ញុំ ខានថ្ងៃស្អែក។

គ ឆាន់

ករុណាមកនិមន្តលោកទៅឆាន់ ខានថ្ងៃស្អែក។

ឃ បង្សុកូល

ករុណាមកនិមន្តលោកទៅបង្សុកូល ខានថ្ងៃស្អែក។

ង ទេសនា

ករុណាមកនិមន្តលោកទៅទេសនា ខានថ្ងៃស្អែក។

ច ឆាន់ព្រឹក

ករុណាមកនិមន្តលោកទៅឆាន់ព្រឹក ខានថ្ងៃស្អែក។

DRILL TWO: Transformation

Change from clerical style to layman style or vice versa as appropriate.

គំរូ

ក ញោមប្រុសអាត្មាបានប្រាប់អាត្មាដែរ។

(ខ្ញុំ)

ខ ឪពុកខ្ញុំបានប្រាប់ខ្ញុំដែរ។

MODEL:

T: My father told me also.

(I)

S: My father told me also.

ក ខ្ញុំបានអញ្ជើញលោកសុខមកដែរ។

(អាត្មា)

អាត្មាបានអញ្ជើញលោកសុខមកដែរ។

ខ ខ្ញុំបានអញ្ជើញលោកសុខមកដែរ។

(ភិក្ខុសុខ)

ខ្ញុំបាននិមន្តភិក្ខុសុខមកដែរ។

គ លោកសុខបានមានប្រសាសន៍រួចមកហើយ។

(ភិក្ខុសុខ)

ភិក្ខុសុខបានមានពុទ្ធដីការួចមកហើយ។

ឃ អាត្មាភាពបានអញ្ជើញលោកគ្រូសុខដែរ។

(ភិក្ខុសុខ)

អាត្មាភាពបាននិមន្តភិក្ខុសុខដែរ។

ង អាត្មាបានប្រគេនសំបុត្រនោះឲ្យភិក្ខុសុខហើយ។

(ខ្ញុំ)

ខ្ញុំបានប្រគេនសំបុត្រនោះឲ្យភិក្ខុសុខហើយ។

ច ខ្ញុំនិមន្តលោកគ្រូសង្ឃពងហើយ។

(តាអាចារ្យ)

ខ្ញុំអញ្ជើញតាអាចារ្យហើយ។

DRILL THREE: Transformation

Note: In the student sentence, a layman is talking to clergy. The students should substitute clerical words for ordinary ones.

គំរូ

ក ម្ដាយខ្ញុំឱ្យខ្ញុំមកអញ្ជើញលោកសុខ។
(ភិក្ខុសុខ)

ខ ម្ដាយករុណាឱ្យករុណាមកនិមន្តភិក្ខុសុខ។

MODEL:

T: My mother had me come to invite Mr. Sok.
(the monk Sok)

S: My mother had me come to invite the monk Sok.

ក ឪពុកខ្ញុំថាគាត់បានឱ្យទៅមីងសុខហើយ។
(ភិក្ខុសុខ)
ឪពុកករុណាថាគាត់បានប្រគេនទៅភិក្ខុសុខហើយ។

ខ អ្នកស្រុកភូមិខ្ញុំគិតសង់ផ្ទះមួយឱ្យគ្រូបង្រៀន។
(លោកសង្ឃ)
អ្នកស្រុកភូមិករុណាគិតសង់កុដិមួយប្រគេនលោកសង្ឃ។

គ ថ្ងៃស្អែក ខ្ញុំត្រូវអញ្ជើញភ្ញៀវ ១០នាក់។
(លោកសង្ឃ)
ថ្ងៃស្អែក ខ្ញុំត្រូវនិមន្តលោកសង្ឃ ១០អង្គ។

ឃ ម្ដាយខ្ញុំសុំឱ្យលោកគ្រូទៅសុំគេឯទៀតទៅ។
(តេជគុណ)
ម្ដាយករុណាសុំនិមន្តតេជគុណនិមន្តបិណ្ឌបាត្រគេឯទៀតទៅ។

ង ខ្ញុំត្រូវទំរលុយទិញខោអាវឱ្យអ្នកទៀសខ្លួន។
(លោកសង្ឃ)
ករុណាត្រូវទំរលុយទិញស្បង់ចីពរប្រគេនលោកសង្ឃ។

ច ម្ដាយខ្ញុំសុំខ្ចីទូកមួយពីលោកពូ។
(លោកតាសង្ឃរាជ)
ម្ដាយករុណាសុំខ្ចីទូកមួយពីលោកតាសង្ឃរាជ។

DRILL FOUR: Transformation

Note: Clergy is talking to layman. The students play the role of a monk.

គំរូ

ក ផ្ទះលោកសុខឱ្យកូនសិស្ស២នាក់នៅ។
(អាត្មា)

ខ កុដិអាត្មាឱ្យកូនសិស្ស២នាក់នៅ។

MODEL:

T: Mr. Sok allows two students to stay in his house.
(I (monk))

S: I allow two students to stay in my quarters.

ក លោកអញ្ជើញទៅតែម្នាក់ឯងមិនបានទេ។
(អាត្មា)
អាត្មានិមន្តទៅតែអាត្មាមិនបានទេ។

ខ ចាំលើកក្រោយខ្ញុំទៅលេងម្ដង។
(ភិក្ខុសុខ)
ចាំលើកក្រោយភិក្ខុសុខនិមន្តទៅលេងម្ដង។

គ ខ្ញុំចង់ឱ្យលោកអញ្ជើញទៅម្ដង។
(ភិក្ខុសុខ)
អាត្មាចង់ឱ្យភិក្ខុសុខនិមន្តទៅម្ដង។

ឃ បើខ្ញុំទៅបាន ខ្ញុំនឹងទៅ។
(អាត្មា)
បើអាត្មានិមន្តបាន អាត្មានឹងនិមន្តទៅ។

ង. ខ្ញុំអញ្ជើញលោកចៅហ្វាយដែរ តែគាត់មិនចង់មក។
(ភិក្ខុ១)
អាត្មានិមន្តភិក្ខុ១ដែរ តែលោកមិនចង់និមន្តមក។

ច. ផ្ទះហ្នឹងជាផ្ទះរបស់ខ្ញុំ ខ្ញុំចង់លក់ ស្រេចតែខ្ញុំ។
(កុដិ)
កុដិហ្នឹងជាកុដិរបស់អាត្មា អាត្មាចង់លក់ ស្រេចតែអាត្មា។

ឃ អាត្មាបានឲ្យលោកតាអាចារ្យហើយ។
(លោកគ្រូសង្ឃរាជ)
តេជគុណបានប្រគេនលោកគ្រូសង្ឃរាជទេ?

ង អាត្មានិមន្តលោកគ្រូសូត្រស្តាំឲ្យញោមហើយ។
(តាអាចារ្យ)
តេជគុណអញ្ជើញតាអាចារ្យទេ?

ច បើនិមន្តអាត្មា អាត្មាគិតយកភិក្ខុ១ទៅ។
(ក្មេងម្នាក់)
បើនិមន្តតេជគុណ តេជគុណគិតយកក្មេងម្នាក់ទៅទេ?

DRILL FIVE: Response

Layman to clergy.

គំរូ

ក កុដិអាត្មាមានលោក៨អង្គ។
(សិស្សសាលា)

ខ កុដិតេជគុណមានសិស្សសាលាទេ?

MODEL:

T: There are 8 monks in my quarters?
(students)

S: Are there any students in your quarters?

ក ថ្ងៃអាត្មាត្រូវការតាអាចារ្យម្នាក់។
(លោកនេន)
ថ្ងៃតេជគុណត្រូវការលោកនេនទេ?

ខ អាត្មាចង់ឲ្យភិក្ខុ១និមន្តទៅស្រុកលោក២ថ្ងៃ។
(អាខាង)
តេជគុណចង់ឲ្យអាខាងទៅស្រុកតាទេ?

គ លោកតាអាចារ្យបានប្រាប់អាត្មាម្ដងហើយ។
(ភិក្ខុ១)
ភិក្ខុ១បានមានពុទ្ធដីកាប្រាប់តេជគុណទេ?

DRILL SIX: Response

Layman to clergy.

គំរូ

ក ញោមប្រុសញោមស្រីធ្វើសង្ឃទានឲ្យអ្នកណា?
(លោកយាយ)

ខ ពុកម្ដាយកូណាធ្វើសង្ឃទានឲ្យលោកយាយ។

MODEL:

T: For whom are your parents giving the ceremony?
(grandmother)

S: My parents are giving it for grandmother.

ក លោកបាននិមន្តលោកគ្រូសូត្រឆ្វេងហើយឬនៅ?
(ហើយ)
កូណាបាននិមន្តលោកគ្រូសូត្រឆ្វេងហើយ។

ខ កុដិលោកគ្រូឯងមានកូនសិស្សសាលាប៉ុន្មាននាក់?
(២នាក់)

កុដិលោកគ្រូ ករុណាមានកូនសិស្ស
សាលា២នាក់។

គ ឯងចង់ទៅនៅកុដិលោកណា?
(លោកគ្រូសូត្រស្តាំ)
ករុណាចង់ទៅនៅកុដិលោកគ្រូសូត្រ
ស្តាំ។

ឃ លោកតាអាចារ្យត្រូវនិមន្តលោកពី
កុដិណា?
(លោកគ្រូសូត្រឆ្វេង)
ករុណាត្រូវនិមន្តលោកពីកុដិលោក
គ្រូសូត្រឆ្វេង។

ង ចុះញោមត្រូវនិមន្តលោកឆាន់ប៉ុន្មាន
អង្គ?
(៤អង្គ)
ចុះករុណាត្រូវនិមន្តលោកឆាន់៤អង្គ។

ច តាអាចារ្យចង់ឲ្យភិក្ខុសុខនិមន្តទៅ
ណា?
(វិហារ)
ករុណាចង់ឲ្យភិក្ខុសុខនិមន្តទៅ
វិហារ។

BEST COPY AVAILABLE

READING PASSAGE 2

សេចក្ដីជូនដំណឹងពី ប្រធានគណៈកម្មការ រៀបចំបុណ្យចូលឆ្នាំ

បងប្អូនរួមជាតិទាំងឡាយ

កាលពីបុណ្យចូលឆ្នាំខ្មែរក្នុងនាមគណៈកម្មាធិការ រៀបចំបុណ្យចូលឆ្នាំ ខ្ញុំបានអំពាវនាវដូចតទៅ :

១— នាំគ្នាធ្វើបុណ្យ គ្រប់វត្តអារាម តាមប្រពៃណីព្រះពុទ្ធសាសនា

២— នាំគ្នាសំអាតផ្ទះភូមិ វត្តអារាម ប្រជុំគ្នាលេងកំសាន្ត តាមរបៀបប្រពៃណី

៣— នាំគ្នា រៀប ចំ ជា អំណោយ ផ្សេងៗ ដើម្បីចែកចាយផ្សព្វផ្សាយ ឲ្យបានសប្បាយរីករាយទាំងអស់គ្នា ។

៤— រួបរួមគ្នាតាមភូមិ និងគណៈកម្មាធិការប្រជាធិយមភូមិ រៀបចំរើសដីព្រៃណាមួយ សម្រាប់ ធ្វើ ជានាទីស្រែរួមមួយ ដើម្បីសហការណ៍គ្នាទៅថ្ងៃក្រោយ ដើម្បីនឹងយកស្រូវដាក់ជង្រុករួម សម្រាប់ជួយ គ្នាជា សហ សង្គ្រោះទៅវិញទៅមក ក្នុងគ្រាដែលលំបាកម្ដងៗ ។

ខ្ញុំមានសេចក្ដីរីករាយជាអតិបរមា ដោយបានពត៌មានថា ជនរួមជាតិយើង បានរួបរួមគ្នាពិតប្រាកដ បានធ្វើបុណ្យធ្វើអំណោយ លេងកំសាន្តសប្បាយយ៉ាងស្និទ្ធស្នាលជាទីបំផុត ក្នុងឱកាសចូលឆ្នាំកន្លងទៅនេះ ។

តែមានចំណុចមួយដែលបងប្អូននៅស្រុកស្រែបានចាប់អារម្មណ៍ ជាពិសេសគឺចំណុចទី ៤ ដែលថា បងប្អូនស្រុកស្រែត្រូវរួបរួមគ្នា តាមភូមិ និងគណៈកម្មាធិការប្រជាធិយមភូមិ រៀប ចំ រើសដីព្រៃ ដីណាមួយ សម្រាប់ធ្វើជានាទីស្រែរួមមួយ ដើម្បីសហការគ្នាទៅថ្ងៃក្រោយ ដើម្បីនឹងយកស្រូវដាក់ជង្រុករួម សម្រាប់ជួយគ្នាជាសហសង្គ្រោះទៅវិញទៅមក ក្នុងគ្រាដែលពិបាកម្ដងៗ ។

ត្រង់ចំណុចនេះ បងប្អូនខ្លះឆ្ងល់ថា ម្ដេចក៏អំពាវនាវឲ្យយកស្រូវដាក់ជង្រុករួម ថាដាក់រួមម្ដេចកើត បើខ្លះខំធ្វើផលបានច្រើន ខ្លះបានមធ្យម ខ្លះបានតិច ខ្លះគ្មានទាំងធ្វើផលផង ។

ចំពោះចំណុចនេះ ខ្ញុំសុំជំរាបបញ្ជាក់ថា រដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលមានឯកឧត្ដម ឧត្ដមសេនីឯក លន់ នល់ ជាប្រធាន មានគោលបំណងដូចតទៅនេះ :

១ — ចង់ឲ្យបងប្អូនក្នុងភូមិនីមួយៗ បើអាចធ្វើទៅបាន រួមគ្នាជាមួយគណៈកម្មាធិការប្រជាធិយមភូមិ ជ្រើសរើសរកដីព្រៃណាមួយ កន្លែង ដែល នៅ ទំនេរ ជិតភូមិ ហើយនាំគ្នារួមកំឡាំងគ្នាកាប់គាស់រៀបចំ ធ្វើដីមួយកន្លែងនោះឲ្យទៅជាទីដីស្រែមួយ ហៅថាស្រែរួមរបស់ភូមិ ។

២ — បើអាចរៀបចំបានជាស្រែហើយ អ្នកភូមិនាំគ្នាធ្វើផលរួមគ្នាលើស្រែ

នោះ ដូចបងប្អូនយើងធ្លាប់បានជីកអណ្ដូង ជីកស្រះរួមគ្នា ធ្វើសាលារួមគ្នា លើកផ្លូវរួមគ្នា សាងវត្តរួមគ្នា ។ល។

៣ — ស្រូវដែលបានពីស្រែរួមរបស់ភូមិនេះ អាចយកទៅទុកក្នុងជង្រុកមួយ ទុកសម្រាប់ដោះស្រាយជាសហសង្គ្រោះក្នុងគ្រាដែលពិបាកផ្សេងៗ។ ម្ល៉េះក៏មិនមែន ប្រមូលផល ពីស្រែ រួមទៀត មកដាក់ជង្រុករួមនោះទេ ។

សេចក្ដីអំពាវនាវនេះ គឺធ្វើឡើង ដោយមានការព្រមព្រៀងជាក់ ហើយមានចិត្តពិតបរិសុទ្ធ ដែលខ្មែរយើងធ្លាប់តែមានក្នុងការរួបរួមគ្នា ជួយជុំគ្នា លើកដៃគ្នា ធ្វើសហប្រតិបត្តិការ ។ ក្នុងរឿងនេះមានកន្លែងខ្លះអាចធ្វើទៅបាន ដោយមានដីទំនេរ កន្លែងខ្លះមិនអាចធ្វើទៅបាន ព្រោះគ្មានដីទំនេរនៅជិតភូមិ ។

រដ្ឋលេខាធិការក្រសួងអប់រំជាតិ និងវិចិត្រសិល្បៈ ប្រធានគណៈកម្មាធិការរៀបចំបុណ្យភ្ជុំបេណ្ឌថ្មី ។

NOTE FOR READING PASSAGE 2

Line 56. The reason that Cambodian says លើកផ្លូវ rather than សង់ផ្លូវ is that country roads are built up on a raised bed of dirt to keep them open during the flood season.

VOCABULARY

គ	to build, add, to form
ករុណា (= ខ្ញុំករុណា)	I, me, yes (like បាទ, ចាស) (used in talking to a monk)
កាប់គាស់	to clear (land)
គាស់	to dig up
កាលណា ... ក្ដី	whenever
កុដិ /kot/	monk's quarters
កុសល	merit, fortune
* កុរណា (= ករុណា)	yes (like បាទ, ចាស) (to a monk)
កំសាន្ត	to enjoy, for fun, amusement, relaxing; to entertain
ក្នុងនាម	in the name of
ក្មេងវត្ត (L)	a boy who lives at a wat and serves the monks in exchange for room and board
គ្រហេងគ្រហូង	uneven, rough, full of holes (land)
ខក (L)	to miss out on, be too late for
ខានស្អែក	the day after tomorrow
ខ្ញុំករុណា	I, me (used in talking to a monk or royalty; formerly used by a servant to his employer or master)
ខ្នុរ /khnol, khnao/ (L)	jackfruit
ខ្សាច់	sand
គង់	to stay, wait (clerical, royal)
គ្រូសូត្រឆ្វេង	one of two elected assistants to the abbot of a wat (ranks slightly lower than គ្រូសូត្រស្ដាំ)

គ្រូសូត្រស្តាំ	one of two elected assistants to the abbot of the wat (ranks slightly higher than គ្រូសូត្រឆ្វេង)
ងុយ(គេង,ដេក)	(L)sleepy
*ចាប់កូនខ្លែង	name of a traditional game
* ខ្លែង	hawk
ចាប់អារម្មណ៍	to be interested, to be of interest
ចូលឆ្នាំ	New Year
ចែកចាយ	to distribute, give out
ចំណី	snack, food
ចំរើនពរ (or ពរ)	yes (like ចាស)(used by a monk)
ចំរើនពរលា	goodbye (used by a monk)
*ឆ្លងជីវិត	a fresh start of one's life, a new lease on life
ឆ្លងបុណ្យ	to gain merit, to pass merit to
ជង្រុក	granary, reserve, store
ជាអតិបរិមា	/cia aʔteʔpaʔrəmaa/ to the maximum extent (literary)
ជើងវត្ត (L)	near the wat
ជឿជាក់	to really believe
*ឈូង	a traditional game
ញាតិកា	family and close friends
ញោម	you, he, she (used by monk to adult layman older than he)
ដង	to dig up, draw up (liquid)
*ដណ្ដាំ (< ដាំ)	to cook (rice)
ដរាប + noun	all during, throughout
ដារ	name of a minor Buddhist ceremony for the dead involving offering food to monks, who chant

ដឹងខ្លួន (L)	to be aware, to realize, to feel
តាក់តែង(តាក់AC)	to arrange, decorate, set up
តេជគុណ	you (used to a monk); he, him
តាំងចិត្ត + verb	to decide to + verb
ថ្វាយបង្គំ	to say hello (to royalty or clergy)
ថ្វាយបង្គំលា	goodbye (to clergy)
ទង់	a long white cloth displayed on a pole outside the house of a person who has recently died until he is cremated; flag
**ទាញព្រ័ត្រ	tug-of-war
* ព្រ័ត្រ/prót/	rope, line (made of animal skin)
ទីវត្ត:វត្ត	pagoda, wat
ទូលបង្គំ	I, me (used by layman to high-ranking monk or to royalty)
ទៅវិញទៅមក	back and forth, reciprocal
ទំនំទំនៀម(ទំនំAC)	custom, habit
នាទី	a delineated section of land
ធុំក្លិន (L)	to smell (trans., and intrans.)
បង្សុកូល /baŋskoul/	to chant for the dead as part of a ceremony including the offering of food to the monks who do the chanting
បង្ហើយ (<ហើយ)	to complete, finish
បង្អង់	to stop and wait, to take a rest, halt, hesitate, slow down
បច្ច័យ	things used by a monk; money (monk)
បុណ្យចំរើនអាយុ	birthday
បលែងកូនមាន់	a traditional game
* បលែង	to play

បរិសុទ្ធ		pure, faithful
ពោសព្រាស(ព្រាសAC)		to sweep out, clean up
ប្រការ		kind, type
ប៉ះ		to touch, come into contact with; affect (usually adversely)
ប្រចាំ(<ចាំ)		for the ..., stationed at; regular
ប្រជានិយម		popular (of the people)
* ប្របន៉ក		a traditional song
ប្រើប្រាស់(ប្រាស AC)		to use
ផ្អាក		to postpone, put off, call a truce
* ពាន		to walk against, to bump into
ពិតប្រាកដ		for sure; certain
ពុទ្ធសាសននិយម		Buddhism
ពូន		to build up, pile up (pyramid)
ពោលគឺ		that is to say
ព្រះរតនត្រ័យ, ព្រះត្រៃរតន៍		the three precious gems (Buddha, dharma, and sangha)
* រតន	/rótənaʔ/	gem, precious metal; precious thing or person
* ព្រះរាជវ័តិ		an enclosure where a major holiday is celebrated
* វ័តិ		fence (literary)
ជយ(=ជយ្យ)		victory, success well-being; victorious, well, successful
ភេសជ្ជ	/pheesacéʔ/	drinks, beverages
មន្ត	/mún/	a spell blessing
មហាជន	/məhacún/	the people
* មហាសង្ក្រាន្ត		name of the first day of 3-day new year holiday
មានពុទ្ធដីកា		to say, speak (used of monk)
រដ្ឋលេខាធិការ		secretary of state (a high government official below cabinet rank)
* រដ្ឋាភិបាលស្រោចស្រង់ជាតិ		Government of National Salvation (name of the government that was in power before , during , and after the overthrow of Norodom Sihanouk in 1970)
ស្រោចស្រង់		to save, to rescue
ស្រង់		to pick out, extract, especially from water
រាប់អាន		to be friendly to, to seek out
រីករាយ		happy
លិទ្ធ	(L)	to lick
លើកដៃគ្នា		to help each other
លើកផ្លូវ		to build a road
លោកគ្រូសង្ក្រាជ(=សង្ក្រាជ)		superior of a wat
លោកនិយម		secular
ល្បែង (<លេង)		game
* វណ្ណបត, វ័នបត, វណាបត	/vanəbot/	name of 2nd day of 3-day new year holiday
* វាលុកចេតិយ, ពាលុកចេតិយ		a stupa made of sand
* វាលុកា, ពាលុកា		sand (literary)
ចេតិយ		stupa
វិចិត្រសិល្ប	/viʔcət seləpaʔ/	fine arts
* វិចិត្រ		mixed, colorful
សិល្ប		art
* វេរភត្តាហារ	/veephótaahaa/	food for monks
វេរភត្ត	/veephót/	to offer or give to clergy (formal)
សង្ក្រាន្ត		departure; arrival (formal), completion of a solar year; new year holiday

សង្ឃទាន		a ceremony in which monks are invited to the house so that a person who cannot get to the wat can offer food
សន្តាន	/sɔndaan/	family, breed, state, state of mind
សន្តានចិត្ត		state of mind, attitude
សហការណ៍		to work together, cooperate
សហប្រតិបត្តិការ	/saʔhaʔprɔtibatkaa/	cooperation (formal)
សហសង្គ្រោះ		Joint welfare
សង្គ្រោះ		help, saving; to help, save
ស័ក		time, era, the progression of years
សឹង		to sleep (clerical)
សុគត		to die (clerical)
* សោត៌ស្ស		clothing (literary)
* ស្តេចចង់		a traditional game
* ស្តេចថ្ងៃ		the main day (of the New Year)
ស្និទ្ធស្នាល(ស្នាលAC)		sincere, on close terms
ស្និទ្ធ	/snət/	to be on intimate term with
ស្រង់(ទឹក)		to wash (a Buddha statue, divinity, clergy)
ស្រះ		pond
ស្លា		areca (tree)
ហោរ		astrologer
អង្គុញ		a kind of fruit, name of a game played with this fruit
អត្ថន័យ	/attanɛy/	meaning, definition
* អន្ទាក់កាប់		a traditional game
អាត្មា		self, I, me (used by a monk)
អាត្មាភាព		I, me (used by a monk)
អាពាធ		to be ill (clerical)
ឧទ្ទិស		to wish, to send (by wish) (literary)
ឯកឧត្តម		(his) excellency, your excellency
អំណរ(<អរ)		happiness
អំណោយ(ឲ្យ)		gift
អំពាវនាវ(នាវAC)		to appeal, to ask
អំពាវ		to appeal

APPLICATIONS

1. Define the following words or phrases.

តាំងចិត្តឲ្យល្អ	ញាតិកាតាំងពីសន្តាន	ភត្តាសនា	ចាស់ទុំ
ល្បែងកំសាន្ត	ប្រកបរបរ	ប្រពៃណីលោកនិយម	បំផ្លាញ
សំដែងឲ្យឃើញ	បង្អង់	ដីក្រហើងក្រហូង	ជញ្ជូន
បញ្ជូន	ប្រពៃណី	ទំនំទំនៀម	សក្ការបូជា
មហាសង្ក្រាន	បន្តុល ផល	បង្ហើយ	ចំណី
ពូន	ឆ្លងបុណ្យ	ទឹកសន្ទួន	ចង់

2. Find the synonym of the following word.

ប្រគេន	ពាន	បន្តុល	សំនៅ	ក្យោ
ចង្ហាន់	សន្តាន	ម៉ាស	ប៉ិស	ស្រង់ទឹក

ស្បង់ចីពរ	សង្គ្រោះ	សំពាក	ស្និទ្ធស្នាល	មធ្យម
ស្លាក	ប្រការ	បុរាណ	សំណាង	ឆាន់
សឹក	និមន្ត	សាស្នា	គង់	បច្ច័យ

3. Find a word that fits the following definition.

១ គ្រឿងទឹកសម្រាប់ទទួលទាន
២ ធ្វើឲ្យខ្លួនល្អដោយប្រើវត្ថុផ្សេងៗឬសំលៀកបំពាក់
៣ ឈប់មួយភ្លែតហើយចាប់ផ្តើមម្តងទៀត
៤ ខ្សែមួយដែលមានមនុស្សពីរទាញខ្សែទល់គ្នា
៥ អ្នកដែលអាចទាយភាសាមនុស្សឬពិភពលោក
៦ កន្លែងសម្រាប់ដាក់ស្រូវ
៧ លោកសង្ឃដែលមានអំណាចជាងលោកឯទៀតក្នុងវត្ត
៨ អ្នករៀបចាត់ចែងធ្វើបុណ្យទានទៅក្នុងវត្ត (ជាស្ត្រីធម្មតា)
៩ ការធ្វើឲ្យសប្បាយ
១០ អ្វីដែលយើងបរិភោគទាំងពេលបាយ
១១ ដើរកាត់កន្លែងមួយ
១២ អ្វីដែលយើងលេងធ្វើឲ្យសប្បាយ
១៣ យកពីកន្លែងទៅដាក់កន្លែងទៀត ច្រើនដង

4. You have been asked to interview a prominent monk for a brief news article. Find out his biography and what he is concerned with now. When you have finished write down or narrate back what you have learned, using the appropriate words. (The teacher plays the part of the monk.)

5. Have the student discuss the following situations.

១ នៅពេលចូលឆ្នាំបារាំង គេធ្វើអ្វីខ្លះ? នៅផ្ទះធ្វើអី? នៅវិហារគេធ្វើអី?
២ ជំនឿ និងសាសនា ខុសគ្នាទេ?
៣ ការទាក់ទងរវាងប្រពៃណី និងសាសនា
៤ តាមសាសនាគ្រិស្ត គេដែលធ្វើបុណ្យឧទ្ទិសកុសលដល់អ្នកដែលចែកឋានទៅ ហើយទេ? ហេតុអី?

6. Find out from your teacher how the following games are played. Get enough detail so that you can write a description in English for people who wish to play these games. បោះឈូង ទាញព្រ័ត្រ អង្គុញ សន្ទាក់កាច់ ស្តេចចង់ ចាប់កូនខ្លែងបន្លែងកូនមាន់ លេងប៊ី

7. Describe in Cambodian some American games that you have played (e.g., Mother-May-I, Red Rover, Murder).

8. Questions for the teacher to ask.

    ១ នៅស្រុកខ្មែរ តើគេអាចដូរសាសនាទេ?
    ២ នៅពេលណាខ្លះ អាមេរិកាំងអាចដូរសាសនា?
    ៣ តើមនុស្សពីរនាក់ (ស្រីនិងប្រុស) ដែលកាន់សាសនាផ្សេងគ្នា អាចយកគ្នាជាប្ដីប្រពន្ធបានទេ?
    ៤ ទាក់ទងទៅសំនួរទី៣ បើគេត្រូវដូរ គេរើសយកសាសនាណា? ហេតុអ្វី?
    ៥ នៅស្រុកខ្មែរ មនុស្សម្នាក់ៗអាចកាន់ អាចជឿទៅលើសាសនាណាមួយបានទេ? ហេតុអ្វីបានជាគេដូរសាសនាដើម្បីការជាប្ដីប្រពន្ធ?
    ៦ តើអ្នកកាន់សាសនាគាត់គិតចង់ឲ្យកូនគេការជាមួយអ្នកកាន់សាសនាឯទៀតទេ? បើមិនឲ្យ ហេតុអ្វី?
    ៧ មានសាសនាមួយដែលមិនអនុញ្ញាតឲ្យប្ដីប្រពន្ធលែងលះគ្នា។ ហេតុអ្វី? បើគេនៅតែលែងគ្នា តើមានហេតុអ្វីទេ?
    ៨ តើអ្វីទៀតដែលសាសនានេះហាមមិនឲ្យធ្វើ?
    ៩ តាមពុទ្ធសាសនា លោកសង្ឃមិនត្រឹមតែមិនមានប្រពន្ធទេ លោកមិនអាចចាប់កាន់ឬប៉ះ(to touch) ស្រីផង។ នៅស្រុកខ្មែរ តើអ្នកបួសអាចមានប្រពន្ធទេ?
    ១០ អ្នកបួសនៅស្រុកខ្មែរ អាចធ្វើអ្វីបានខ្លះ? ហាមអ្វីខ្លះ? សឹកតាមចិត្តបានទេ?

9. Questions for the student to ask.

    a. When a layman meets a monk, is there any special behavior that is expected of him?
    b. Since Heaven, Hell, and the transmittal of merit to the dead are not part of pure Buddhist theology, how do the more educated monks feel about ceremonies like បង្សុកូល and the like?
    c. Does every wat have an achar? Is he a monk? Can he have a family?
    d. How does one become an achar? Is there an apprenticeship?
    e. What are the duties and functions of an achar in the wat? Outside the wat?
    f. Are there achars who are not associated with a wat? (In private practise, so to speak.)
    g. Are there some ceremonies and holidays in which monks do not participate? What are they?
    h. Is there such a thing as a New Year's resolution in Cambodia?
    i. When the young people are playing games on New Year's Day, what do the older people do?
    j. Do individuals celebrate their birthdays(បុណ្យចំរើនអាយុ)? If so, how?

LESSON FOURTEEN

IN HONOR OF THE ANCESTORS

a. Is it believed that the living can curse others? Under what circumstances is such a curse effective?

b. Is Pchum Ben considered the most important holiday of the year? If not, what is, if any?

c. If one is reborn as a vicious ghost, is there any way to make merit in this form so that one can be reborn in a higher form? Or do ghosts die and achieve rebirth?

បុណ្យភ្ជុំបិណ្ឌ

បុណ្យនេះប្រទេសខ្មែរបានប្រកាន់យក និងប្រតិបត្តិតាមអស់រយៈពេលដ៏យូរអង្វែងណាស់មកហើយ តែប្រសិនគេស្រាវជ្រាវរកក្នុងគម្ពីរខាងព្រះពុទ្ធសាសនានូវពិធីនេះ ទាំងក្នុងព្រះត្រៃបិដក ទាំងក្នុងអដ្ឋកថាដិកាយោជនា ក៏មិនឃើញមានសោះតែម្តង ។ ដូច្នេះបុណ្យភ្ជុំបិណ្ឌតាមការស្មានរបស់យើង ជាបុណ្យកើតឡើងដោយសារអ្នកប្រាជ្ញជំនាន់ណាក៏មិនដឹង បានត្រិះរិះបង្កើតឲ្យមានឡើង ដើម្បីពុទ្ធសាសនិកខ្មែរគោរពប្រតិបត្តិយកផលានិសង្ស ព្រមទាំងដើម្បីឧទ្ទិសផលានិសង្សនេះ ជូនទៅបុព្វបុរសឬមាតាបិតានិងញាតិកា ដែលចែកឋានទៅហើយនោះ ។

ម្ល៉ោះហើយក្នុង ១ ឆ្នាំៗ ដែលដល់រដូវភ្ជុំបិណ្ឌម្តងៗ ជនជាតិខ្មែរគ្រប់អាត្មាមិនដែលហ៊ានខាននៅវត្តសោះទេ យ៉ាងហោចណាស់ក៏ទៅដាក់បិណ្ឌម្តងដែរ ដែលថាឲ្យខានសោះនោះឥតអ្នកមានឡើយ ។ តើការណ៍ដែលមិនហ៊ានខាននេះ បណ្តាលមកពីអ្វី ? គឺបណ្តាលមកពីខ្លាចពាក្យប្រទេចផ្តាសាពីសំណាក់នៃមាតាបិតា និងញាតិកាទាំង ៧ សន្តាន ដែលបានចែកឋានទៅហើយៗ ដល់រដូវភ្ជុំបិណ្ឌតែងតែនាំគ្នាមករកកូនចៅនិងបងប្អូន ដើម្បីទទួលមគ្គផលពីបុណ្យភ្ជុំបិណ្ឌដែលកូននិងបងប្អូនបានទៅធ្វើនៅវត្ត រួចហើយមកដើររកគ្រប់ ៧ វត្តហើយនៅតែមិនឃើញកូន និងបងប្អូនទៅដាក់បិណ្ឌឧទ្ទិសផលានិសង្សទៅឲ្យទេ នោះអ្នកចែកឋានទាំងនេះគឹងយំខ្សឹកខ្សួល ព្រមទាំងអាក់អន់ចិត្ត ទើបប្រទេចផ្តាសាចំពោះកូន និងបងប្អូន ឲ្យបានជួបប្រទះតែនឹង

សេចក្ដីទុក្ខលំបាក តោកយ៉ាកគ្រប់ប្រការ រួចក៏នាំគ្នាវិលត្រឡប់ទៅកាន់ទីឋានរៀង ៗ ខ្លួនវិញ រីឯអ្នកដែលបានមកជួបកូនចៅនិងបងប្អូនដែលបានទៅវត្តដាក់បិណ្ឌនោះ រមែងមានទឹកមុខញញឹមញញែម ព្រោះបានទទួលផលានិសង្ស ហើយក៏ឲ្យពរសព្ទសាធុការ សូមឲ្យកូនចៅនិងបងប្អូនរកស៊ីកើតការ[illegible] បានសេចក្ដីសុខសេចក្ដីសប្បាយ ចូលក្នុងមូលចោ[illegible] ។

ដូច្នេះបុណ្យភ្ជុំបិណ្ឌនេះ ឥឡូវប្រែក្លាយទៅជាពិធីទំនៀមទម្លាប់ តែជាទំនៀមទម្លាប់ដ៏ប្រសើរសម្រាប់ពុទ្ធសាសនិក និងសម្រាប់បុព្វបេតបុគ្គល ។ កាលណាព្រះសង្ឃចូលវស្សាបានពីរខែ ហើយនៅថ្ងៃចាប់ពី ១ រោចខែភទ្របទទៅទល់នឹងថ្ងៃខែដាច់ ក្នុងរយៈនេះគេចាត់ទុកជាថ្ងៃភ្ជុំបិណ្ឌ ហើយនៅសល់កន្លះខែទៀតទើបដល់ថ្ងៃចេញវស្សា ។

តើការណ៍ដែលពួកពុទ្ធសាសនិកទៅដាក់បិណ្ឌឲ្យទៅហ្នឹង ព្រោះតែខ្លាច ពាក្យប្រទេចផ្ដាសាពីសំណាក់នៃប្រេតទាំងឡាយជាមាតា បិតា និងពួកញាតិទាំងឡាយនោះ មានសភាពសមហេតុសមផលឬទេ ? ចំពោះរឿងនេះ យើងយល់ថាវាសមខ្លះវាមិនសមខ្លះ ។ ហេតុអ្វីក៏បានជាថាយ៉ាងនេះ ? ថាពីព្រោះអ្នកជាសាច់ញាតិទាំងឡាយ ដែលចែកឋានទៅនោះ មិនមែនសុទ្ធតែទៅកើតជាប្រេតទាំងអស់ទេ គឺមានខ្លះក៏ទៅកើតជាប្រេតអ៊ីចឹងដែរ មានខ្លះទៅកើតឋាននរក មានខ្លះទៅកើតជាតិរច្ឆាន មានខ្លះទៅកើតជាអសុរកាយ មានខ្លះទៀតទៅកើតនៅសុគតិភព គឺឋានសួគ៌និងឋានមនុស្សយើងនេះ ។

បើយកតាមព្រះពុទ្ធដីកាដែលថា : « ឋានំ ខោ អឋានំ ខោ » បានសេចក្ដីថា ការឧទ្ទិសផលពីមនុស្សនេះទៅ ដើម្បីបញ្ជូនទៅបុព្វបេតបុគ្គល មានបានដល់ខ្លះ មានមិនដល់ខ្លះ ។ ចុះហេតុអ្វីក៏យ៉ាងនេះទៅវិញ ? ថាត្បិតសត្វដែលទៅកើតនៅនរកក្ដី នៅតិរច្ឆានក្ដី សត្វទាំងនេះមិនបានដឹងនឹងមិនបានទទួលផល ដែលបងប្អូនកូនចៅបញ្ជូនទៅឲ្យនោះទេ ព្រោះសត្វនរករស់តែសោយទុក្ខវេទនាខ្លាំងពេក រកឱកាសនឹងទទួលផលមិនបាន ព្រោះសត្វតិរច្ឆានក៏រវល់ណាស់ដែរ ដើម្បីរកស៊ីចិញ្ចឹមជីវិត គ្មានពេលនឹងទទួលផលនោះទេ ។ រីឯទេវតានិងមនុស្សក៏គ្មានឱកាសនឹងទទួលផលដែរ ព្រោះទេវតារស់តែសប្បាយតែនឹងសម្បត្តិ រាំច្រៀងលេងសប្បាយជារាល់ថ្ងៃ ព្រោះមនុស្សជាអ្នកប្រកប

មុខរបរចិញ្ចឹមជីវិត ដូចយើងគ្រប់គ្នាឃើញស្រាប់ ព្រលឹមបាត់ ព្រលប់ចូល ហើយម្យ៉ាងទៀត ការឲ្យទានចំពោះព្រះសង្ឃ សម្រេចកើតជាផល គឺថាត្រូវកើតជាបាយ ជាសម្ល ជាសំពត់ស្លៀកពាក់ ជាផ្ទះ ជាវិមាន ។ល។ ដែលកើតឯង ៗ ជាសម្បត្តិទិព្វ ហើយនៅឋានមនុស្ស ផលរបស់នោះនឹងមកសម្រេចដូច្នេះទៅមិនកើត ព្រោះមនុស្សឥតបានអនុមោទនា ទទួលយកផលនោះឯណា ។ តាមព្រះពុទ្ធដីកា សត្វដែលអាចទទួលបាន គឺសំដៅយកប្រេតឬបិសាចជាញាតិដែលឋិតនៅក្បែរ ៗ នោះ ។ ត្រង់នេះហើយដែលយើងថាមិនសមនោះ ហើយដែលយើងថាសមនោះ គឺសំដៅយកតែប្រេតឬបិសាចតែប៉ុណ្ណោះ ។

ក៏ប៉ុន្តែ កុំចិណ្ណា ទោះបីព្រះសង្ឃបញ្ជូនផលទៅមិនដល់ក្តី គួរតែយើងជាពុទ្ធសាសនិកត្រូវតែធ្វើដែរ ព្រោះបើផលនោះទៅមិនដល់សាមីបុគ្គល ផលនោះនឹងត្រូវត្រឡប់មករកអ្នកធ្វើវិញតែដដែល ។ ហេតុអ្វីក៏ថាដូច្នេះ ? ជាព្រោះឧបមា ដូចយើងរៀបបាយទទួលភ្ញៀវ ប្រសិនបើភ្ញៀវមិនទទួលទានទេ បាយនោះមុខជាត្រូវបានមកអ្នកម្ចាស់ដើមតែដដែល ។

NOTES FOR READING PASSAGE 1

Line 1. The word អាត្មា 'self' is used in this sentence as a classifier like រូប for people.

Line 12. The clause ដែលបរាជ័យខាងនេះនោះ គតសង្ឃឹមានឡើយ means 'as far as failure is concerned it never happens.' Ordinarily នោះ goes with a negative, but here it follows ខាន , which has a negative meaning.

Line 41. The Pali phrase ' ឋានំខោ អឋានំខោ ' is pronounced /thaanaŋ khao a?thaanaŋ khao/ and means 'some (of the merit) reaches and some (of it) doesn't'

Line 52. The phrase សម្រេចកើតជា is equivalent to ក្លាយទៅជា

DIALOGUE

ក្មេងវត្ត

(Two temple boys have a conversation)

ភ្ជុំ	Pchum Ben (holiday for the dead)
១ ប៉ុច ឆ្នាំនេះ ដល់ភ្ជុំកុំទៅផ្ទះអីអ្ហ ?	This year now about not going home at Pchum Ben time?
ទំបន្ត : ហេមន្ត	autumn
សន្តរដូវ : វសន្តរដូវ	rainy season
វរ	to be in trouble
វរ ៗ	if you don't watch out ...
ដូនតា	ancestors
ដាក់បណ្ដាសា	to put a curse on
បណ្ដាសា	a curse
ងាប់	a lot, really (familiar)
២ ហាយ ទេ មិនទៅទេ ទំបន្តសន្តរដូវ ផង វរ ៗ ដូនតាដាក់បណ្ដាសា ងាប់ ។	No, I'm not staying. It's the time for families to get together. I'm afraid my ancestors will really curse me.
៣ ប៉ុច ហ្អឹងមិនដឹងទេហ្អឹង ។ នៅនេះ ភ្ជុំម្ដងៗសប្បាយណាស់ ។	Don't you know? Pchum Ben here is a lot of fun.
បណ្ដែត	to float (trans.)
ទូកដូនតា	(see note)
ត្រពាំង	pond
៤ ហាយ សប្បាយអី ? បណ្ដែតទូកដូន តាក្នុងទឹកត្រពាំងអញ្ចឹងនោះ ។	What's fun about floating a boat with offerings for the ancestors on a pond like that?
អាណុង	that (colloquial)
គិត	think about
ក្រមុំ	young girl
ជើង	bottom, edge, near by
ជើងវត្ត	settlement around a wat
គី	form, shape, mark; brand, quality
៥ ប៉ុច ទេ អាណុងគេមិនគិតទេ អា	No, I'm not thinking of that stuff.

		ស្រីសប្បាយបរនោះគឺស្រីក្រុមជុំវិញវត្ត ពិសាគឺមានទាំងនោះទេ ។	What's fun is the girls in the village around the wat. There's every kind.
		មា	(indicates contempt)
		ភ្នាល់	to bet, wager
		ឥតភ្នាន	no comparison
៦	ចាយ	សប្បាយអី មាអាត្រាច់តែដើរ មើលគេ ។ នៅស្រុក ខ្ញុំគេភ្នាល់ទូក ភ្នាល់គោ សប្បាយឥតភ្នាន ។	What's so great about just wandering around and looking? Where I come from, there are boat and cattle races - there is nothing like it.
		ប្រគេន	to give (to monk)
		នំគម	(see note)
		នំអន្សម	(see note)
		នំងាល	(see note)
៧	ប៉ុន	មិនត្រាន់តែមើលគេសប្បាយនោះទេ គេប្រគេននំគម នំអន្សម និង ងាលលោកច្រើនណាស់ ។	You don't just watch people; they offer lots of sweets to the monks, too.
		ណ្ហើយ	that's enough
		បញ្ចុះបញ្ចូល	to persuade
៨	ចាយ	ណ្ហើយ, កុំបញ្ចុះបញ្ចូលអី ខ្ញុំ នឹកម៉ែឪបងប្អូនណាស់ ។	That's enough. Don't persuade me. I really miss my mother and my father and brothers and sisters.

NOTES FOR THE DIALOGUE

SENTENCE NO. 1 The final particle ម៉ិយ makes the sentence into a suggestion.

SENTENCE NO. 2 According to the lunar calendar there three seasons:

ហេមន្ត (or ហេមន្តរដូវ) autumn, the cool season, which begins in mid កត្តិក and ends in mid ផល្គុន (that is, roughly November through February)

គិម្ហ (or គិម្ហរដូវ) summer, the hot season, which begins in mid ផល្គុន and ends in mid អាសាឍ (that is, roughly March through June)

វស្សាន (or វស្សានរដូវ) the rainy season, which begins in mid អាសាឍ and ends in mid កត្តិក (that is, roughly July through October).

These names are literary and used in speech far less than រដូវច្រូតកាត់ , ប្រាំង , ភ្លៀង.

Traditionally, the early autumn is a time when families get together, in part at least because of the Pchum Ben holiday.

SENTENCE NO. 4 A ទូកក្ទូងចេក is a small boat made of banana growth ring. Offerings to the ancestors, usually of food, are placed in it in the evening, and then, the following morning, the boat is floated off.

SENTENCE NO. 5 Note that គេ , normally third-person form, can be used as first person form. When so used, it has a slightly impersonal and generalizing connotation, somewhat like the British usage of 'one' as a first person form, e.g., 'one doesn't like to complain, but ....' គេ would not be used as first-person pronoun in a formal conversation.

SENTENCE NO. 7 The three kinds of pastry mentioned in this sentence are:

នំគម is made of sticky rice flour surrounding a filling made of sweet bean paste, wrapped in a piece of banana leaf and steamed.

នំអន្សម is made of sticky rice and coconut milk around a filling made of pork or pieces of banana, wrapped in banana leaf and steamed.

នំគាល is a kind of unleavered pound cake made of sticky rice and plain rice flour.

DRILLS

DRILL ONE: Response

គំរូ

ក ភ្ជុំ គ្នាយើងនាំកូនទៅណាទេ ?
(ទៅលេងជីដូនជីតា)

ខ ដល់ភ្ជុំ គ្នាយើងនាំកូនទៅលេងជីដូនជីតា ។

MODEL:

T: At Pchum Ben, do you plan to take your children anywhere?
(to visit their grandparents)

S: At Pchum Ben, we'll take our children to visit their grandparents.

ក ចូលឆ្នាំបារាំង លោកនាំគ្នាទៅណាដែរ ?
(ទៅសមុទ្រ)
ដល់ចូលឆ្នាំបារាំង ខ្ញុំនាំគ្នាទៅសមុទ្រ ។

ខ ចូលឆ្នាំខ្មែរ យើងនាំគ្នាធ្វើអី ?
(ដងទឹកស្រង់ព្រះពុទ្ធរូប)
ដល់ចូលឆ្នាំខ្មែរ យើងនាំគ្នាដងទឹកស្រង់ព្រះពុទ្ធរូប ។

គ បុណ្យ ១០០ ថ្ងៃ ធ្វើអីដែរ ?
(ធ្វើបង្សុកូលឲ្យគាត់)
ដល់បុណ្យ ១០០ ថ្ងៃ ធ្វើបង្សុកូលឲ្យគាត់ ។

ឃ ថ្ងៃក្រោយ យើងនាំគ្នាធ្វើអីឲ្យខ្មោចដែរ ?
(សង្ឃទានឲ្យខ្មោចឪពុក)
ដល់ថ្ងៃក្រោយ យើងនាំគ្នាធ្វើសង្ឃទានឲ្យខ្មោចឪពុក ។

ង លោកនិមន្តមកដល់ ត្រូវធ្វើយ៉ាងម៉េច ?
(និមន្តលោកចូល)
ដល់លោកនិមន្តមកដល់ ត្រូវនិមន្តលោកចូល ។

ច លោកនិមន្តទៅវត្តវិញ យើងត្រូវប្រគេនអីខ្លះ ?
(បច្ច័យខ្លះ)
ដល់លោកនិមន្តទៅវត្តវិញ យើងត្រូវប្រគេនបច្ច័យខ្លះ ។

DRILL TWO: Equivalence

គំរូ
ក ភ្ជុំបិនទៅវត្ត ប្រយ័ត្នដូនតាដាក់បណ្ដាសាសាងាប់ ។
ខ ភ្ជុំបិនទៅវត្ត ក្រែងដូនតាដាក់បណ្ដាសាសាងាប់ ។

MODEL:

T: If you don't go to the wat at Pchum Ben, be careful ancestors don't really curse you.

S: If you don't go to the wat at Pchum Ben, watch out ancestors don't really curse you.

ក លួចស៊ីចង្ហាន់លោក ប្រយ័ត្នជាតិក្រោយធ្លាក់នរក ។
លួចស៊ីចង្ហាន់លោក ក្រែងជាតិក្រោយធ្លាក់នរក ។

ខ យកទាំងអស់អញ្ចឹង ប្រយ័ត្នគេដឹង ។
យកទាំងអស់អញ្ចឹង ក្រែងគេដឹង ។

គ ដល់ភ្ជុំ នាំគ្នាមិនទៅលេងវត្ត ប្រយ័ត្នវ៉េបទឹង ។
ដល់ភ្ជុំ នាំគ្នាមិនទៅលេងវត្ត ក្រែងវ៉េបទឹង ។

ឃ យកបិណ្ឌឲ្យគាត់ផង ប្រយ័ត្នគាត់ជេរ ។
យកបិណ្ឌឲ្យគាត់ផង ក្រែងគាត់ជេរ ។

ង បើទៅលេងអញ្ចឹង ប្រយ័ត្នដល់ភ្ជុំមិនបានទៅណា ។
បើទៅលេងអញ្ចឹង ក្រែងដល់ភ្ជុំមិនបានទៅណា ។

ច សប្បាយក្លូវ ប្រយ័ត្នគេសើចក្រោយ ។
សប្បាយក្លូវ ក្រែងគេសើចក្រោយ ។

DRILL THREE: Transformation

គំរូ
ក ភ្ជុំ នៅវត្តខ្ញុំ មានមនុស្សច្រើនណាស់ ។
ខ ភ្ជុំម្ដងៗ នៅវត្តខ្ញុំ មានមនុស្សច្រើនណាស់ ។

MODEL:

T: At Pchum Ben there are many people at my wat.

S: Whenever it's Pchum Ben, there are many people at my wat.

ក ខ្ញុំនិយាយជាមួយលោកសង្ឃច្រើនតែខុស ។
ខ្ញុំនិយាយជាមួយលោកសង្ឃម្ដងៗច្រើនតែខុស ។

ខ ធ្វើចង្ហាន់ទៅវត្ត មិនដែលទុកឲ្យខ្ញុំទេ ។
ធ្វើចង្ហាន់ទៅវត្តម្ដងៗមិនដែលទុកឲ្យខ្ញុំទេ ។

គ លោកនិយាយ គ្មានអ្នកណាយល់ទេ ។

លោកនិយាយម្តងៗ គ្មានអ្នកណាយល់ទេ ។

ខ បញ្ជាក់ ចំណាំរាល់តែលើ ។

បញ្ជាក់ម្តងៗ ចំណាំរាល់តែលើ ។

គ ការកូនចៅ ចំណាយតែរៀបការរលីងទេ ។

ការកូនចៅម្តងៗ ចំណាយតែរៀបការរលីងទេ ។

ឃ ឡើងបណ្ដូល ចំបិនតែលបាងទំនេរទេ ។

ឡើងបណ្ដូលម្តងៗ ចំបិនតែលបាងទំនេរទេ ។

DRILL FOUR: Transformation

Note: The students are to complete the second clause using the cus given.

គំរូ

ក ធ្វើចង្ហាន់ប្រគេនលោក មិនដែលទុកខ្លះ ។
(លើកក្រោយបទតែ)

ខ បើធ្វើចង្ហាន់ប្រគេនលោកម្តងៗមិនដែលទុកខ្លះ លើកក្រោយបទតែ(លួចសិនហើយ) ។

MODEL:

T: When they make food for the monks, they never keep some (for us). (next time surely)

S: Whenever they make food for monks, they never keep some (for us), next time surely (I'll steal some).

ក យកចង្ហាន់ទៅវត្ត លួចតែស៊ី ។
(ជាតិក្រោយ)
បើយកចង្ហាន់ទៅវត្តម្តងៗ លួចតែស៊ី ជាតិក្រោយ ... ។

ខ យកអីទៅ មិនយកមកវិញ ។
(ជាប់បណ្ដាសា)
បើយកអីទៅម្តងៗ មិនយកមកវិញ ជាប់បណ្ដាសា ... ។

គ ភ្ជុំ មិនដែលទៅដើរទៅវត្ត ។
(ខ្មោចដូនតា)
បើភ្ជុំម្តងៗ មិនដែលទៅដើរទៅវត្ត ខ្មោចដូនតា ... ។

ឃ និយាយពីលោកសង្ឃ គិតតែពីរឿង ។
(ស្លាប់ទៅ)
បើនិយាយពីលោកសង្ឃម្តងៗ គិតតែពីរឿង ស្លាប់ទៅ ... ។

ង ការកូន អស់តែលុយរង់ ។
(កូនស្រីក្រោយ)
បើការកូនម្តងៗ អស់តែលុយរង់ កូនស្រីក្រោយ ... ។

ច ពន្យល់គេ គេមិនស្តាប់ ។
(ប្រហែល)
បើពន្យល់គេម្តងៗ គេមិនស្តាប់ប្រហែល ... ។

DRILL FIVE: Transformation

គំរូ

ក សប្បាយណាស់ ភ្ជុំមានមនុស្សច្រើន ។
(មានស្រីក្រមុំៗ)

ខ សប្បាយនោះ មិនមែនមកពីមានមនុស្សច្រើនទេ គឺមានស្រីក្រមុំៗនោះទេ ។

MODEL:

T: It's a lot of fun at Pchum Ben; there are lot's of people. (there are (lots of) girls)

S: It's a lot of fun not because there are a lot of people but because there are (lots of) girls.

ក ត្រូវបណ្ដាសាហើយ បើភ្ជុំមិនធ្វើចង្ហាន់ប្រគេនលោក ។
(មិនទៅវត្ត)
ត្រូវបណ្ដាសានេះ មិនមែនមកពីមិនធ្វើចង្ហាន់ប្រគេនលោកទេ គឺមិនទៅវត្តនោះទេ ។

ខ ចុះនរកហើយ បើនៅតែសម្លាប់សត្វ ។
(មិនជឿព្រះធម៌)
ចុះនរកនោះ មិនមែនមកពីសម្លាប់សត្វទេ គឺមិនជឿព្រះធម៌នោះទេ ។

គ ត្រូវប្រទេចផ្តាសាហើយ បើយកចង្ហាន់ទៅវត្តក្រោយរៀងគ្រង់ ។
(លួចស៊ី)

ត្រូវប្រទេចផ្ដាសានោះ មិនមែនមកពីយកចង្ហាន់ទៅវត្តក្រោយថ្ងៃត្រង់ទេ គឺលួចស៊ីនោះទេ ។

ឃ ទឹកមុខញញឹមតែម្ដង បានត្រូវឆ្នោត ។
(បានជួបកូនចៅ)
ទឹកមុខញញឹមនោះ មិនមែនមកពីត្រូវឆ្នោតទេ គឺបានជួបកូនចៅនោះទេ ។

ង យំខ្សឹកខ្សួលយ៉ាងខ្លាំង ព្រោះមិនបានជួបកូនចៅ ។
(គ្មានលុយទិញម្ហូប)
យំខ្សឹកខ្សួលនោះ មិនមែនមកពីមិនបានជួបកូនចៅទេ គឺគ្មានលុយទិញម្ហូបនោះទេ ។

ច តាមិនបានទទួលកុសល ព្រោះកូនចៅមិនបានធ្វើបុណ្យឲ្យ ។
(លោកសង្ឃមិនបញ្ជូនឲ្យ)
តាមិនបានទទួលកុសលនោះ មិនមែនមកពីមិនបានធ្វើបុណ្យឲ្យទេ គឺលោកសង្ឃមិនបញ្ជូនឲ្យនោះទេ ។

DRILL SIX: Transformation

គំរូ
ក សប្បាយនោះ មិនមែនមកពីមានមនុស្សច្រើនទេ គឺមានស្រីៗនោះទេ ។
ខ មានស្រីៗនោះទេ ដែលធ្វើឲ្យសប្បាយនោះ ។

MODEL:
T: It's a lot of fun not because there are a lot of people but because there are (lots of) girls.
S: It's because there are (lots of) girls that makes it fun.

ក ត្រូវបណ្ដាសានោះ មិនមែនមកពីមិនធ្វើចង្ហាន់ប្រគេនលោកទេ គឺមិនទៅវត្តនោះទេ ។
មិនទៅវត្តនោះទេ ដែលធ្វើឲ្យត្រូវបណ្ដាសានោះ ។

ខ ចុះនរកនោះ មិនមែនមកពីសម្លាប់សត្វទេ គឺមិនជឿព្រះពុទ្ធនោះទេ ។
មិនជឿព្រះពុទ្ធនោះទេ ដែលធ្វើឲ្យចុះនរកនោះ ។

គ ត្រូវប្រទេចផ្ដាសានោះ មិនមែនមកពីយកចង្ហាន់ទៅវត្តក្រោយថ្ងៃត្រង់ទេ គឺលួចស៊ីនោះទេ ។
លួចស៊ីនោះទេ ដែលធ្វើឲ្យត្រូវប្រទេចផ្ដាសានោះ ។

ឃ ទឹកមុខញញឹមនោះ មិនមែនមកពីត្រូវឆ្នោតទេ គឺបានជួបកូនចៅនោះទេ ។
បានជួបកូនចៅនោះទេ ដែលធ្វើឲ្យទឹកមុខញញឹមនោះ ។

ង យំខ្សឹកខ្សួលនោះ មិនមែនមកពីមិនបានជួបកូនចៅទេ គឺគ្មានលុយទិញម្ហូបនោះទេ ។
គ្មានលុយទិញម្ហូបនោះទេ ដែលធ្វើឲ្យយំខ្សឹកខ្សួលនោះ ។

ច តាមិនបានទទួលកុសលនោះ មិនមែនមកពីមិនបានធ្វើបុណ្យឲ្យទេ គឺលោកសង្ឃមិនបញ្ជូនឲ្យនោះទេ ។
លោកសង្ឃមិនបញ្ជូនឲ្យនោះទេ ដែលធ្វើឲ្យតាមិនបានទទួលកុសលនោះ ។

DRILL SEVEN: Transformation

គំរូ
ក នៅស្រុកខ្ញុំ គេភ្នាល់ទូកភ្នាល់គោសប្បាយណាស់ ។
ខ នៅស្រុកខ្ញុំ គេភ្នាល់ទូកភ្នាល់គោសប្បាយគេគ្មាន ។

MODEL:
T: Where I come from, there are boat and cattle races - it's lots of fun.
S: Where I come from, there are boat and cattle races - there's nothing like it.

ក ក្រមុំស្រុកចំការមួយៗស្អាតណាស់ ។

ក្រមុំស្រុកចំការមួយៗស្អាតរកគ្មាន ។

ខ ពិធី[illegible]ណាស់ ។

ពិធី[illegible]រកគ្មាន ។

គ កើត[illegible]ណាស់ ។

កើត[illegible]រកគ្មាន ។

ឃ លោកគ្រូស្រុកខ្ញុំកាចណាស់ ។

លោកគ្រូស្រុកខ្ញុំកាចរកគ្មាន ។

ង លោកសង្ឃស្រុក[illegible]ណាស់ ។

លោកសង្ឃស្រុក[illegible]រកគ្មាន ។

ច ដូនតា[illegible]ណាស់ ។

ដូនតា[illegible]រកគ្មាន ។

BEST COPY AVAILABLE

READING PASSAGE 2

ម្យ៉ាងទៀត យើងសូមសរសើរចំពោះគំនិតអ្នកប្រាជ្ញដែលប្រតិស្ឋជាបុណ្យភ្ជុំបិណ្ឌនេះឡើង ដើម្បីជាប្រយោជន៍ដល់ជនជាតិខ្មែរពុទ្ធសាសនិក ព្រោះថាពិធីនេះសព្វថ្ងៃក្លាយទៅជាពិធីទំនៀមទម្លាប់ខានពុំបានឡើយ ត្រង់ខានពុំបាននេះហើយដែលត្រូវចាត់ទុកជាការណ៍សំខាន់ ។ ជនជាតិខ្មែរទាំងមូលក្នុងសាធារណរដ្ឋ មិនមែនសុទ្ធតែអ្នកនៅទំនេរ ហើយគិតតែពីធ្វើបុណ្យទេ មានអ្នកខ្លះរវល់រកទទួលទាន ខ្លាចក្ដីក្រវាតាមទាន់ ម្ល៉ោះហើយមិនសូវគិតគូរពីរឿងធ្វើបុណ្យអ្វីទេ តែដល់ភ្ជុំបិណ្ឌហើយ ទោះបីអ្នកនោះមានកិច្ចរវល់យ៉ាងណាក៏ត្រូវតែឆ្លៀតធ្វើចង្ហាន់យកទៅប្រគេនព្រះសង្ឃ ដោយហោចណាស់ក៏បានម្ដងដែរ ។ ត្រង់នេះទុកជាការណ៍សំខាន់សម្រាប់ពញាក់ស្មារតីនៃពុទ្ធបរិស័ទ ដែលជាប់រវល់ក្នុងកិច្ចការរកទទួលទាន ឲ្យភ្ញាក់រលឹកថាជារដូវបុណ្យហើយ។

តាមធម្មតាបុណ្យត្រូវតែធ្វើ កាលណាសទ្ធាចិត្តកើតឡើងហើយ មធ្យោបាយក៏មានព្រមផង នេះចំពោះតែអ្នកដែលពុំសូវមានជាប់រវល់ ព្រោះការធ្វើបុណ្យ ថ្ងៃណាក៏ចេះតែធ្វើបាន ហើយពេលណាក៏ចេះតែបញ្ជូនមគ្គផលឲ្យទៅបុព្វបេតបុគ្គលបានដូចគ្នា មិនចាំតែភ្ជុំបិណ្ឌទេ ។

ពាក្យថាភ្ជុំបិណ្ឌនេះបើគិតឲ្យម៉ត់ចត់ គួរហៅថាបុណ្យបិណ្ឌភ្ជុំវិញ ហេតុអ្វីក៏និយាយដូច្នេះ? ព្រោះថារាប់ពីថ្ងៃ ១ រោច ខែភទ្របទ ទៅទល់នឹងថ្ងៃ១៤រោច គេមិនទាន់ធ្វើបុណ្យភ្ជុំទេ គឺគេធ្វើបុណ្យដាក់បិណ្ឌ ក្នុង១ថ្ងៃគេពូតបាយដំណើប ១ ដុំដាក់ជាចំណាំ ២ ថ្ងៃដាក់ ២ ពំនូត រហូតដល់ថ្ងៃ ១៤ រោច គេត្រូវដាក់ ១៤ ពំនូត រួចនៅថ្ងៃ ១៥ រោចដែលជាថ្ងៃភ្ជុំនោះគេត្រូវដាក់ ១៥ ពំនូត ដូច្នេះហើយទើបនៅថ្ងៃ ១៥ រោច គេហៅថាថ្ងៃភ្ជុំបិណ្ឌ គឺជាថ្ងៃភ្ជុំដុំបាយដាក់រួម ១៥ ដុំនេះឯង ។ ដោយថ្ងៃនេះជាថ្ងៃបញ្ចប់ការដាក់បិណ្ឌ ទើបមនុស្សទាំងឡាយជាពុទ្ធបរិស័ទ ឥតហ៊ានខាន ត្រូវតែធ្វើចង្ហាន់ទៅវត្ត ព្រោះអស់ថ្ងៃដាក់បិណ្ឌទៀតហើយ ។ ដល់យូរៗមក ពាក្យថាថ្ងៃភ្ជុំនេះប្រែទៅជាថាថ្ងៃភ្ជុំមនុស្សទៅវិញ តែតាមការណ៍ពិត គឺជាថ្ងៃភ្ជុំបាយបិណ្ឌ ដែលគេបានដាក់មកអស់រយៈ ១៤ ថ្ងៃ ហើយនោះឯណោះទេ ។ ដូច្នេះហើយ ទើបយើងយល់គួរហៅថ្ងៃ ១៥ រោចខែភទ្របទនេះ ថាជាថ្ងៃបិណ្ឌភ្ជុំទៅវិញទើបសម ព្រោះថាគេ

ដាក់បិណ្ឌហើយ ទើបគេភ្ជុំបាយបិណ្ឌទាំងអស់នោះបញ្ចប់តែម្តង ។

ពីសម័យបុរាណ គេធ្វើបិណ្ឌមិនមែនធ្វើជាវេនដូចសព្វថ្ងៃនេះទេ គឺច្រើនតែយាយៗ តាៗ ដែលធ្វើការងារមិនសូវមាំមួន ក៏បបួលគ្នាទៅនៅឯសាលាវត្តដើម្បីដាក់បិណ្ឌ ឯគ្រឿងស្បៀងអាហារផងទាំងពួង គឺកូនចៅរៀបចំដឹកជញ្ជូនយកទៅទុកឲ្យសាលាជាស្រេច ហើយកូនចៅទាំងនោះគិតតែពីធ្វើការងាររៀងខ្លួនទៅ ខ្លះមានធនធានច្រើនក៏ទៅដាក់បិណ្ឌតាំងពីបិណ្ឌ១ ខ្លះមិនមានភោគទ្រព្យក៏ទៅដាក់បិណ្ឌ ចាប់ពីថ្ងៃ ៥ រោចក៏បាន ១០ រោចក៏មាន តាមកម្លាំងសទ្ធានិងធនធានដែលខ្លួនមាន ។ តែកាលណាដល់ថ្ងៃ ១៥ រោច នោះគ្រប់មនុស្សទាំងអស់ត្រូវតែឈប់ធ្វើការ ហើយនាំគ្នាធ្វើបាយសម្ល ធ្វើនំក្រៀម នំដាល នំអន្សម នំគម ។ល។ យកទៅប្រគេនព្រះសង្ឃ ព្រោះរដូវបិណ្ឌត្រូវបញ្ចប់នៅថ្ងៃនោះហើយ។ ដល់មកឥឡូវរឿងបុណ្យដាក់បិណ្ឌនេះ បានប្រែក្លាយមកជាដាក់វេនទៅវិញ គឺថាពុទ្ធបរិស័ទជើងវត្តត្រូវចែកគ្នាជា១៤ក្រុម រួចចាប់ឆ្នោតក្រុមណាត្រូវថ្ងៃណា ក៏នាំគ្នាធ្វើចង្ហាន់ប្រគេនព្រះសង្ឃនៅថ្ងៃនោះទៅ ចំណែកថ្ងៃ ១៥ រោច ឥតមានក្រុមទេ ព្រោះជាថ្ងៃភ្ជុំហើយ ។ នៅថ្ងៃភ្ជុំនេះ អ្នកណាក៏ត្រូវតែទៅវត្តខានពុំបានឡើយ ម្ល៉ោះហើយបានជាមិនចាំបាច់ឲ្យមានក្រុម ហើយនៅថ្ងៃភ្ជុំនេះបាយនិងម្ហូបមានច្រើនពន់ពេកណាស់ គឺថាបាយសល់ទាំងកញ្ជើៗ ។ កាលពីដើមថ្ងៃភ្ជុំហ្នឹង សុទ្ធតែឲ្យលោកនិមន្តបិណ្ឌបាតផង ម្ល៉ោះហើយដោយលោកសង្ឃមានចំនួនតិចជាងឧបាសកឧបាសិកា តោងតែចាត់រកកញ្ចេសម្រាប់យកបាយពីបាត្រលោកសង្ឃមកចាក់ ព្រោះមនុស្សរាប់ម៉ឺននាក់ ហើយព្រះសង្ឃមានចំនួនយ៉ាងច្រើនតែត្រឹម ៣០-៥០ អង្គប៉ុណ្ណោះ ។

បុណ្យភ្ជុំបិណ្ឌឬបុណ្យបិណ្ឌភ្ជុំនេះ ដែលអ្នកប្រាជ្ញពីបុរាណបានប្រតិស្ឋបង្កើតឡើងនេះ មានប្រយោជន៍ច្រើនយ៉ាងណាស់ដែរ ព្រោះទី១ នាំឲ្យពុទ្ធបរិស័ទដែលរវល់ជាប់កិច្ចការ មានសតិសម្បជញ្ញៈនឹករលឹកដល់ឪពុកម្តាយ ជីដូនជីតា ញាតិកាទាំង ៧ សន្តាន ដែលចែកឋានទៅហើយ ពុំហ៊ានខានក៏នាំគ្នាធ្វើនំចំណីនិងចង្ហាន់យកទៅប្រគេនព្រះសង្ឃ ទី២នាំឲ្យពុទ្ធបរិស័ទដែលអាល័យតែជាប់ដៃក្នុងមុខរបរ បានមកជួបជុំគ្នាម្តងដើម្បីសួរសុខទុក្ខគ្នា ទី៣ នាំឲ្យពុទ្ធបរិស័ទដែលរវល់តែជាប់ដៃក្នុងមុខរបរ បានទទួលទានឆ្ងាញ់ បានស្លៀកពាក់ស្អាតបាត បាននំចំណីប្លែកៗទទួលទាន ទី៤ បើនៅតាមដងស្ទឹងទន្លេ នាំឲ្យពួកពុទ្ធបរិស័ទបាន

សប្បាយ និងអុំទូកងប្រណាំងគ្នា គឺជាកាលលោកឆាន់រួចស្រេចហើយ នៅពេលរសៀលប្រហែលជាម៉ោង ២ គេរមែងតែបង្កើតពិធីប្រណាំងទូកងជានិច្ចពុំសូវដែលខានឡើយ ដែលជាហេតុនាំឲ្យមានមនុស្សអ៊ូអរដ៏យ៉ាងអ៊ឹកធឹកក្រៃលែង ទាំងនាំឲ្យបានជួបក្រុមញាតិសន្តានដែលបែកទៅនៅរកស៊ីនៅភូមិឆ្ងាយៗ ពីគ្នា បានជួបជុំគ្នាជាថ្មី ដែលជាហេតុធ្វើឲ្យចំណងមិត្តភាពកាន់តែមាំឡើងជាភិយ្យោភាព ។

បុណ្យភ្ជុំបិណ្ឌ ឬបុណ្យបិណ្ឌភ្ជុំនេះ មានសភាពប្លែកពីបុណ្យចូលឆ្នាំ គឺជាបុណ្យបិណ្ឌភ្ជុំ គឺជាបុណ្យដែលកូនចៅត្រូវធ្វើដើម្បីឧទ្ទិសផលានិសង្ស ជូនចំពោះបុគ្គលទាំងឡាយ មានមាតាបិតាជាដើម ដែលចែកឋានទៅហើយនោះ ក្រែងលោមានញាតិណាភ្លាត់ខ្លួនទៅកើតជាប្រេត ឬអសុរកាយ កាលណាបានទទួលផលកុសលនេះហើយ នឹងត្រូវរំដោះចេញពីទីដ៏ទំនាបឡើងទៅកាន់ទីដ៏ខ្ពស់បាន ។ ដូច្នេះបុណ្យបិណ្ឌភ្ជុំជាបុណ្យដ៏ឧត្តមណាស់ ។ ព្រោះជាបុណ្យប្រកបដោយសីលធម៌ ប្រកបដោយមនុស្សធម៌ រកប្រទេសណាធ្វើដូចគ្មាន ។ ចំណែកបុណ្យចូលឆ្នាំ គឺជាបុណ្យសម្រាប់ចំរើនអាយុរបស់ខ្លួន គឺជាបុណ្យផ្ទាល់ខ្លួន ហើយនរណាចង់ធ្វើក៏ធ្វើទៅ នរណាមិនចង់ធ្វើក៏ហើទៅ ឥតមានសតិសម្បជញ្ញៈបន្ទោស ដូចជាបុណ្យបិណ្ឌភ្ជុំឡើយ ។

NOTES FOR READING PASSAGE 2

Line 22. At the end of the sentence, the word នេះឯង (or នោះឯង) indicates that what precedes it has already been introduced into the discourse. That is, នេះឯង in this case is something like English 'mentioned above,'

e.g., ...គឺថ្ងៃភ្ជុំដុំបាយជាគំរប់ ១៥ ដុំនេះឯង ។

...that is, it's the day of gathering the full 15 balls of rice (that we have already described).

Line 4[illegible]. You will find this passage easier to read if you insert a ។ (end-of-sentence marker)at the end of this line after ទៅ .

Line 75 In this line you learn the patterns:

verb + ក៏ + verb + ទៅ 'if yes, it's all right'

and មិន + verb + ក៏ហើទៅ 'if no, it's all right'

Both indicate some degree of dismissal or washing one's hands of the matter. The expression verb + ក៏ + verb + ទៅ is ordinarily used when

dismissing a positive action, e.g.,

បើគេធ្វើក៏ធ្វើទៅ។

If they do it, it's all right.

verb + is used when the action being dismissed is negated, e.g.,

បើគេមិនធ្វើក៏ហីទៅ។

If they don't do it, it's all right.

VOCABULARY

clause + ក៏ហីទៅ	too bad, to heck with it
* កញ្ជើ	a kind of basket
កញ្ជេរ	a large basket (sometimes used for collecting garbage)
កើតកាលសាលក្ដុម្ភ	prosperity, success
ក្រីក្រ	poverty
ខែដាច់	last day of the month (cf. ដាច់ខែ)
ខ្សឹកខ្សួល	to sob
គិតគូរ	to ponder
* គិម្ហ, គិម្ហរដូវ	summer, hot season (lunar calendar)
គួរតែ	should, it is right to
គំរប់ (< គ្រប់)	to complete
ដាប់	a lot, really
ចាប់ឆ្នោត	to draw lots
ឆ្នោត	a lot (in a lottery)
ចិញ្ចឹមជីវិត	to make a living
ចូលឆ្នាំបារាំង	European New Year (January 1)
ចូលវស្សា /coul vənsaa/	to enter the rainy season retreat (monk)
ចេញវស្សា	to leave the rainy season retreat (monk)
ចែកឋាន	to die (may include the period until rebirth)
ឋាន (= ស្ថាន)	place
ចំណាំ (< ចាំ)	to remember (after thinking about); reminder
* ជាភិយ្យោភាព	exceedingly, greatly
* ភិយ្យោភាព /phiʔyoophiap/	muchness
* ភិយ្យោ (H)	much, large quantity
ជាវេន	in turns
ជាស្រេច	to be completed; as completed
ជាប់ដៃ	to be busy with, concerned with (to the exclusion of other things)
* ញញឹមញញែម (ញញែម AC)	to smile
ជើង	near by
ដល់យូរៗមក	In the course of time (to the present)
ដាក់បណ្ដាសា	to put a curse on
ដាក់បិណ្ឌ	to take food to the wat as part of the observance of the ភ្ជុំបិណ្ឌ holiday
ដូនតា	ancestors
ដំណើប	refers to glutinous grain

ត្បិត		because
ឋាននរក	/thaan nərúʔ/	Hell
ឋានសួគ៌	/thaan suo/	Heaven
ល្ហើយ		stop there!, that's enough
តាមទាន់		to catch up with
តោកយ៉ាក		to be poverty-stricken
ត្រិះរិះ	(ត្រិះ RC)	to think up
ទិព្វ	/tɨp/	magic
*ទូកង		a long dragon-shaped boat
*ទូកដូនតា		a boat made of banana growth ring with offerings to one's ancestors put in in the evening and floated off the following morning
ទោះបី...ក៏		even though, although
ធនធាន	/thúnthian/ (ធាន AC)	property
ធី		form, shape, mark, brand, type, quality
នំក្រៀប		hard cakes
នំគម		a kind of sweet
នំធាល		a kind of sweet
បណ្តាសា	/pədahsaa/	curse
បណ្តែត		to cause to float, to permit to float, to float
បបួលគ្នា	+ verb	to ask each other to do together, to do as a group
បបួល		to invite, ask
បានស៊ីបានចុក	(L)	to get to eat
បិសាច		a kind of ghost, some forms of which suck blood, others make people ill, others live off corpses

*បុព្វបេតបុគ្គល	/boppəbeetəboʔkúl/	the dead
*បុព្វប្រេត	/boppəpraɛt/	the dead
ប្រកាន់យក		to establish, maintain
ប្រឌិត	/prɔdɨt/	to originate, think up, invent
ប្រទេច	/bantɨc/	to curse
ប្រសិន		if
ប្រេត	/praɛt/	a ghost, one who has died, slimy form of life that lives in muddy, dirty places; a creep
ប្រែក្លាយ		to change
ផលានិសង្ស		merit, benefit of merit that one has made, merit that comes from good deeds
ផ្តាសា	/phdahsaa/ (= បណ្តាសា)	curse
*ពញ្ញាក់ (< ភ្ញាក់)		to rouse, cause to wake up
*ពន់ពេក		exceedingly, a great deal, much
ពរ		good wishes, blessing; yes (like បាទ , used by a monk)
ពុទ្ធបរិស័ទ		Buddhist (including clergy)
* បរិស័ទ		crowd, meeting, people
ពូត		to form into balls in the hand; to squeeze out (water)
បំនូត (< ពូត)		a ball (of food, etc.) made in the hand
ព្រលប់		dusk
ព្រលឹម		early morning; early in the morning
ព្រះពុទ្ធដីកា		Buddha's utterance
ភោគទ្រព្យ	/phook trɔ́p/	property, resources
ភ្ជុំបិណ្ឌ	/phcum ben/	annual holiday in honor of one's ancestors

ភ្ជុំ (< ជុំ)		to gather, bring together; short for ភ្ជុំបិណ្ឌ Phcum Ben holiday
ជុំ		to gather (intrans (intrans.); a round (classifier for movement around something)
ភ្ញៀវ		guest
ភ្នាល់		to bet, wage
ភ្លាន់ខ្លួន		to be mistaken (intrans.); by accident
មគ្គផល	/meʔkaphɔl/	merit, benefit of good deeds; a way of referring to the fourfold path (leading to Nirvana)
* មគ្គ	/meʔkéʔ/	way, road, gate
ម៉ា		indicates contempt
មុខរបរ		occupation
មូលកូនមូលចៅ		the assembled descendants, family
ម៉ាំមួន (មួន AC)		firm
ម៉ាំ		definite, strong, firm
រកគ្មាន		there's no comparison, there's nothing like it
រកទទួលទាន		to earn a living (polite form of រកស៊ី)
រលឹក (= រឭក)		to miss, remember, feel nostalgic
រឭក	/rəlɨk/	to feel nostalgic, miss
រៀងៗខ្លួន		each one
វរៗ		if you don't watch out...
វសន្ត, វសន្តរដូវ	/vənsɔn/	rainy season (lunar calendar)
វិមាន		edifice, state building, monument
* សតិសម្បជញ្ញៈ	/səteʔsampaññəñéʔ/	awareness, mind
* សម្បជញ្ញៈ		awareness, mind
សទ្ធាចិត្ត		believing in merit, sin, and karma; generosity
សទ្ធា		belief, especially in merit, sin, and karma
សមហេតុសមផល		appropriate
សរសើរ		to praise, to congratulate
សាច់ញាតិ		relatives
សាមី		the very ..., the one concerned, onself
សុគតិភព	/sokəteʔphúp/	Heaven (literary)
* សុគតិ		good actions, just behavior (lit.)
* ភព		world; birth; progress (lit.)
សោយទុក្ខ		to have trouble, grief (ordinary style)
ស្មារតី, ស្មាត្តី	/smaarədɛy/	imagination, memory, conciousness
ស្អាតបាត (បាតAC)		clean, attractive, smart, well (dressed)
ហត់ (L)		tired, fatigued
*ហេមន្ត, ហេមន្តរដូវ	/heemɔn, heemɔntaʔ/	autumn, cool season (lunar calendar)
(ខ្សោយ)ហោចណាស់		at least
(យ៉ាង)ហោចណាស់		at least
*អដ្ឋកថាដីកាយោជនា	/attaʔkəthaadɛykaayoocənia/	name of a Buddhist scripture
* យោជនា		name of a Pali grammar (in Pali)
អនុមោទនា	/aʔnumootənia/	to be happy; happiness, to be happy for, to share happiness; happiness for, sharing of happiness (lit.)
អនុ (H)		under, lesser; along with; constant

* សោមនា	happiness (lit., rare)
អសុរកាយ	a ghost which walks at night, lives on unclean things, and haunts people
អសុរ	bad thoughts, evil person, enemy of the gods
អាក់អន់ចិត្ត	to feel bad, humiliated, have hurt feelings
* អាក់	to miss out, give up on
អាក់ចិត្ត	to feel bad and not want to meet someone
អន់ចិត្ត	to feel bad, have hurt feelings
អាណុង	that one (colloquial)
ឥតរង្គើ	emphatic negative: not ... in any way
រង្គើ	to shake, tremble
អ៊ីចឹង	thus, like that
* អ៊ឹកធឹក /ɨkəthɨk/	impressive and well attended (used of religious ceremonies)
ឧត្តម /udom/	high, exalted, good
ឧបាសក	layman
ឧបាសិកា	laywoman
អ៊ូអរ	crowded, filled with people
ឯងៗ	automatically, by one's self
ឲ្យ(សព្ទ)សាធុការ	to say សាធុ
សាធុការ	act of saying សាធុ
សាធុ	good, well-done!, bravo

APPLICATIONS

1. Fill in the blanks with the proper words provided.

១ យើងត្រូវតែទៅភ្ជុំនៅវត្ត, ... ខ្មោចនឹងតាមប្រទេចផ្តាសា។
(ប្រហែល ទទៗ ទំ)

២ នៅភូមិខ្ញុំ កាលណាមានបុណ្យទាន..., អ្នកភូមិនាំគ្នាដាក់ទានលើកចង្ហាន់ទៅវត្ត។
(ម្តងៗ ទទៗ ជានិច្ច)

៣ ...ថ្ងៃបញ្ចប់ភ្ជុំបិណ្ឌ ត្រូវរៀបចំខ្លួនឱ្យស្អាតបាតទៅវត្តហើយ។
(ឯ បើ ដល់)

៤ អារឿងហ្នឹងត្រូវកុំយកមកនិយាយ គេចង់ដឹងរឿងស្រីស្អី...ទេ។
(សោះ នោះ ម្តង)

៥ ទំប្រើអ្នកណាឱ្យយកចង្ហាន់ទៅ...លោកតាសង្ឃរាជ។
(និមន្ត ប្រគេន ជូន)

៦ ខ្ញុំថាឆ្នាំនេះមិនសូវមានមនុស្សមកភ្ជុំច្រើនទេ តែខ្ញុំមិន...ទេ។
(ថា ស្គាល់ ស្មាន)

៧ តើអ្នក...ហើយឬទេ? ចូរនាំគ្នាទៅដាក់បិណ្ឌម្តង។
(ចាប់ ចំណេរ ដល់)

៨ ត្រូវជូនទៅវត្តផង មិនមែនចាំតែទៅយកពីវត្តវិញ...ទេ។
(សោះ នោះ ហើយ)

៩ មួយឆ្នាំទៅទៀត ... ដូចជាក្នុងរឿងកសិណោះ នៅតែដដែល។
(ម្ដងៗ ម្ដង ទេ)

2. Define the following words, and use them in a sentence.

បុណ្យចំរើនអាយុ ដាក់បណ្ដាសា សមហេតុសមផល បញ្ចុះបញ្ចូល
ដាប់ទង ទីកបាន ស្គាល់ ប្រតិដ្ឋ ស្រាវជ្រាវ អាក់អន់ចិត្ត

3. Find the opposite of the following word.

យំ បន្ទោស ថ្មី ចំណេញ ឋានសួគ៌
បញ្ចូល ប្រទេចផ្ដាសា ឧបាសក បញ្ចប់ បុរាណ

4. Describe as well as you can the American and European traditions of belief in ghosts. If you are familiar with them, describe the ghosts that are believed in by the people in the ethnic group your family originally came from (e.g., Irish, Spanish, West African, Japanese, etc.)

5. What practises does your family (or its original ethnic group) have to honor the dead?

6. Questions for the teacher to ask.

១ ខ្ញុំតែងតែនឹកឆ្ងល់ឃើញថាថ្ងៃបុណ្យអាមេរិកាំងច្រើនធ្លាក់ទៅលើថ្ងៃច័ន្ទ ហេតុអ្វី?
២ នៅ ស.រ.អ មានបុណ្យជាតិនិងបុណ្យទំនៀមទម្លាប់ច្រើនទេ? អ្វីខ្លះ?
៣ នៅរដ្ឋនីមួយៗ តើអាមេរិកាំងនាំគ្នាគោរពបុណ្យជាតិឬបុណ្យទំនៀមទម្លាប់នៅថ្ងៃជាមួយគ្នាទេ?
៤ អាមេរិកាំងធ្វើបុណ្យថ្ងៃកំណើតប្រធានាធិបតីខ្លះ ដូចជាលោកវ៉ាស៊ីនតោន។ ចុះប្រធានាធិបតីឯទៀត គេធ្វើដែរទេ? ហេតុអ្វី?
៥ អាមេរិកាំងមានទំនៀមទម្លាប់ច្រើនទេ? អ្វីខ្លះ? ហេតុអ្វីបានជាគេធ្វើបុណ្យនោះ?
៦ បុណ្យណាខ្លះដែលគ្រួសារអាមេរិកាំងអញ្ជើញភ្ញៀវមកផ្ទះរបស់គេ?
៧ ការរៀបការ អាមេរិកាំងច្រើនធ្វើនៅថ្ងៃសៅរ៍ឬថ្ងៃអាទិត្យ នេះជាទំនៀមទម្លាប់មួយដែរឬ?
៨ បុណ្យណាខ្លះគេចងទង់ជាតិនៅតាមផ្ទះ?

ខាងក្រោមជាឈ្មោះបុណ្យខ្លះនៅ ស.រ.អ ៖ (សូមនិយាយពីប្រវត្តិ)

Christmas	Dec.	Labor Day	Sept.
Columbus Day	Oct.	Lincoln's Birthday	Feb.
Father's Day	Nov.	Memorial Day	May
Halloween day	Oct.	Mother's Day	May
Independence Day	July	New Year's Day	Jan.

Saint Patrick's Day	Mar.	Veteran's Day	Oct.
Thanskgiving Day	Nov.	Washington's Birthday	Feb.
Valentine's Day	Feb.		

7. Questions for the student to ask.
   - a. What is meant by ចូលវស្សា ? How is the life of a monk different during the rainy season from the rest of the year?
   - b. Is ចូលវស្សា marked by a special holiday? What about ចេញវស្សា?
   - c. Why are ghosts like អសុរកាយ and បិសាច billeved to be vicious? Is a បិសាច vicious?
   - d. Is it possible to be possessed by a ghost or other evil spirit? If so, what is normally done to end the possession?
   - e. Is it considered worse to be born as a lowly type of animal or as a ប្រេត, បិសាច, etc.?
   - f. If one is reborn as a vicious ghost, is there any way to make merit in this form so that one can be reborn in a nigher form? Or do ghosts die and achieve rebirth?
   - g. Is it believed that the living can curse others? Under what circumstances is such a curse effective?
   - h. Has your teacher ever seen a ghost? Does he or she know someone who has?
   - i. Is Pchum Ben celebrated the same way in the city and in the country?
   - j. Are there some portions of the Pchum Ben festival that are being given up?
   - k. Is Pchum Ben considered the most important holiday of the year? If not, what is?

BEST COPY AVAILABLE

LESSON FIFTEEN

RITES AND HOLIDAYS, ANCIENT AND MODERN

a. Is there any holiday on which people give each other gifts (like Christmas)?
b. Can one make offerings to the spirits in the presence of monks?
c. Do most Cambodians try to observe the five precepts? Do they usually succeed?

ពុទ្ធសាសនា និង សង្គមខ្មែរ

ឥទ្ធិពល ពុទ្ធសាសនា បានចាក់គ្រឹះយ៉ាងមាំ ក្នុងចិត្ត គំនិតខ្មែរ សង្គមខ្មែរ ទំនោរខ្មែរ មនោគមខ្មែរ តាំងពីយូរអង្វែងណាស់មកហើយ ។ មានវត្តអារាម ជាច្រើន ប្រកបទៅដោយវិហារ កុដិ សាលា ដ៏ល្អៗ ជាច្រើន ដែលពុទ្ធបរិស័ទ មានសទ្ធាជ្រះថ្លា បានកសាង ធ្វើជាសេនាសនៈ សំរាប់ព្រះសង្ឃគង់នៅ ដែលនិមន្តមកអំពីទិសទាំង ៤ និងជាទីសំរាប់ធ្វើបុណ្យឲ្យទាន សមាទាន រក្សាសីល ជាដើម ។ ប្រជាជនខ្មែរ ទាំងប្រុស ទាំងស្រី ភាគច្រើន តែងតែជាឧបាសក ឧបាសិកា អ្នកកាន់ពុទ្ធសាសនា ធ្វើបុណ្យឲ្យទាន រក្សាសីល ៥ សីល ៨ សីល ១០ ធ្វើសមាធិកម្មដ្ឋាន ជាដើម ។ កាលសម័យមុនណា ក្មេងៗ កូនចៅ អ្នកស្រុក តែងបានចូលទៅសិក្សារៀនសូត្រ អក្សរសាស្ត្រ នព្វន្តសាស្ត្រ សិល្បៈ គុណធម៌ គុណជាតិ ជាដើម នៅក្នុងទីវត្តអារាម ដែលមានព្រះសង្ឃជាគ្រូបាធ្យាយ ។ អ្នកខ្លះ ក៏បានសុំផ្នួសបួសជាសាមណេរ ឬ ជាភិក្ខុ សិក្សា រៀនសូត្រ ធម៌អាថ៌ ក្នុងព្រះពុទ្ធសាសនា ។

ជាពិសេស ឥទ្ធិពលពុទ្ធសាសនា បានចូលស៊ុបសួន

ចាក់ឫសយ៉ាងមាំ ក្នុងសង្គមខ្មែរ ទំនោរខ្មែរ ព្រលឹងខ្មែរ មនោគមខ្មែរ តាំងតែពីព្រេងសតវត្សណាស់មកហើយ ដែលមានជាអាទិ៍ ក្នុង:

- ជំនឿ **Croyance**
- ប្រពៃណី ទំនៀមទម្លាប់ **Coutume · Mœurs**
- សិល្បៈ **Art**
- អក្សរសិល្ប៍ **Littérature**

ក – ជំនឿ Croyance

ឥទ្ធិពល ពុទ្ធសាសនា បានបណ្ដាល បង្កើតឲ្យមាន

- ជំនឿ បុណ្យ បាប ។
- ជំនឿ កម្ម ផល ។
- ជំនឿ សច្ចៈ សុចរិត យុត្តិធម៌ ។
- ជំនឿ ឋានសួគ៌ ឋាននរក ។ល។

ដែលបានជាកត្តាដ៏ធំមួយ ជួយរុញច្រានសង្គមខ្មែរ មនុស្សខ្មែរ ឲ្យមាន សីលធម៌ មនុស្សធម៌ ស្គាល់បុណ្យបាប ហើយខំប្រឹងធ្វើ ខំប្រឹងកសាងអំពើល្អ គ្រប់ៗគ្នា ។

Continued at Reading Passage 2

NOTES FOR READING PASSAGE 1

Line 1. The សាលា in a wat is a large meeting hall, often with open or latticed sides. In the country it often serves as the main meeting place for the village or town for secular as well as religious matters.

Line 10. A pious Buddhist may observe a number of prohibitions. Religious laymen observe five in particular (សីល៥):

1. refrain from killing

2. refrain from stealing
3. refrain from lying
4. refrain from adultery
5. refrain from consuming intoxicants

A person who wishes to live more religiously, especially on a ថ្ងៃសីល or other day of religious observance, may observe eight (សីល៨) adding to the above:

6. refrain from eating after noon
7. refrain from entertainments like plays or dancing
8. refrain from adorning oneself and using perfumed things

An even more pious person or a សាមណេរ(novice monk) will observe ten precepts(សីល១០), adding:

9. refrain from sleeping or sitting on a cushion, mattress, or raised place
10. refrain from dealing in any business transaction

A monk is expected to observe these ten plus another 217 precepts for a total of 227 precepts.

BEST COPY AVAILABLE

DIALOGUE

បុណ្យទាន

	អន្តិច + V. + អន្តិច + verb	to do often
១. សុខ	ស្រុកយើងចូលចិត្តធើបុណ្យណាស់ អន្តិចធើអន្តិចធើ។	In our country we like to have holidays often.
	មិនចេះអស់មិនចេះហើយ	endlessly
២. ស្រី	ហ៊ឹងហើយ ធើមិនចេះអស់ មិនចេះហើយទេ។ តែបុណ្យម្តងៗ សប្បាយណាស់។	That's right. We have them endlessly. But every holiday is quite a lot of fun.
	លុប	to eliminate
	ទំនៀម	custom
៣. សុខ	និយាយពីសប្បាយអញ្ចឹង កុំតែលុបបុណ្យទំនៀមខ្លះចោល កុំអីរឹតតែសប្បាយណាស់ទៅទៀត។	Speaking of fun, if they hadn't eliminated some of the traditional festivals, it would be even more fun.
	តាំងតុ	(see vocabulary)
	អុំទូក	(see vocabulary)
	ច្រត់	to lean on, to support oneself
	នង្គ័ល	plow
	ច្រត់នង្គ័ល	(see vocabulary)
៤. ស្រី	និយាយអញ្ចឹង ឥឡូវគេឈប់ធើបុណ្យតាំងតុ អុំទូក ច្រត់នង្គ័លអស់ហើយ។	Talking of that, they've stopped celebrating Tang Tok, Om Tuuk, and Chrot Nongkol.
	តាមត្រូវ	in fact, actually
	អ៊ូអរ	crowded
	មាត់ទន្លេ	edge of the river
	កកកុញ	many, crowded
៥. សុខ	ហ្នឹងហើយ ប៉ុន្តែតាមត្រូវ ត្រូវទុកបុណ្យអុំទូក ព្រោះអុំទូកម្តងៗ ភ្នំពេញមនុស្សអ៊ូអរកកកុញមាត់ទន្លេ សប្បាយណាស់។	Yes, but actually they should have kept Om Tuuk, because during the boat races in Phnom Penh the people crowd onto the edge of the river and have a great time.

		និយាយៗទៅ	in fact
		បុណ្យជាតិ	national holiday
៦	ស្រី	និយាយៗទៅ យើងធ្វើបុណ្យច្រើនមែន គឺតាំងពីបុណ្យជាតិរហូតដល់បុណ្យប្រចាំគ្រួសារ។	In fact, we really do have a lot of holidays, ranging from national holidays to family holidays.
		ម្លឹងៗ	thus, like that
		ជៀស	to avoid
		ថាឲ្យ	to scold, criticize
៧	សុខ	មែន ខ្លួនថែមខ្មែរក្រទៀត ហើយធ្វើទៅដល់ម្លឹងៗ ជៀសពីគេថាឲ្យមិនរួចទេ។	True, in addition, the Khmer are poor but still celebrate all those holidays. There's no way to avoid criticism for that.
៨	ស្រី	ថាអី? ថាក្រមកពីធ្វើនោះ? ទេ បើខ្មែរក្រ ក៏មិនមែនមកពីធ្វើបុណ្យច្រើនដូចពាក្យគេនិយាយថានោះទេ។	What criticism? Do they say we're poor because of that? No, if the Khmer are poor, it's not because of the many holidays the way they say.

DRILLS

DRILL ONE: Response

គំរូ

ក. ស្រុកយើងចូលចិត្តធ្វើបុណ្យណាស់។
(ហ្នឹងហើយ)

ខ. ហ្នឹងហើយ អត្តិចធ្វើអត្តិចធ្វើ។

MODEL:

T: In our country we like to have holidays very much.
(right)

S: Right. We have them often.

ក. យាយខ្ញុំនិមន្តលោកសឹងតែរាល់អាទិត្យ។
(មែន)
មែន អត្តិចនិមន្តអត្តិចនិមន្ត។

ខ. នៅស្រុកយើង យើងឧស្សាហ៍ឈប់បុណ្យណាស់។
(អញ្ចឹងមែនហើយ)
អញ្ចឹងមែនហើយ អត្តិចឈប់អត្តិចឈប់។

គ. លោកឧស្សាហ៍និមន្តទៅវត្តណាស់។
(សឹងរាល់ថ្ងៃ)
សឹងរាល់ថ្ងៃ អត្តិចនិមន្តអត្តិចនិមន្ត។

ឃ. ក្មេងភូមិហ្នឹងចូលចិត្តសូត្រធម៌ណាស់។
(ឯងក៏ឃើញដែរ)
ឯងក៏ឃើញដែរ អត្តិចសូត្រអត្តិចសូត្រ។

ង. តាទៅរាំវង់ចាស់ទៅហើយ។
(តាចូលចិត្តសប្បាយណាស់)
តាចូលចិត្តសប្បាយណាស់ អត្តិចរាំវង់អត្តិចរាំវង់។

ច ផ្ទះហ្នឹងឧស្សាហ៍និមន្តលោកឆាន់ណាស់ ។
(គេទៅវត្តមិនរួច   បានជា)
គេទៅវត្តមិនរួច   បានជាបន្តិចនិមន្ត
បន្តិចនិមន្ត ។

DRILL TWO: Response

គំរូ
ក. ស្រុកយើងចូលចិត្តធ្វើបុណ្យណាស់ ។
(ហ្នឹងហើយ - ទេ)
ខ. ហ្នឹងហើយ   ធ្វើមិនចេះអស់មិនចេះ
ហើយទេ ។

MODEL:

T: In our country we like to have holidays very much.
(right)

S: Right. We have them endlessly.

ក ផ្ទះនោះមានភ្ញៀវចេញចូលសឹងរាល់
ថ្ងៃ ។
(គេចូលចិត្តធ្វើបុណ្យ   បានជា - នោះ)
គេចូលចិត្តធ្វើបុណ្យ   បានជាមាន
មិនចេះអស់មិនចេះហើយនោះ ។

ខ ស្រុកយើងឈប់បុណ្យច្រើនណាស់ ។
(ខាតពេលណាស់ - អញ្ចឹង)
ខាតពេលណាស់   ឈប់មិនចេះអស់
មិនចេះហើយអញ្ចឹង ។

គ ជីដូនខ្ញុំចូលចិត្តទៅបុណ្យណាស់ ។
(ធម្មតាទេចាស់ៗ - ទេ)
ធម្មតាទេចាស់ៗទៅមិនចេះអស់មិន
ចេះហើយទេ ។

ឃ ជីតាខ្ញុំសូត្រធម៌រាល់ព្រឹកមុនគាត់
ធ្វើអ្វីៗឯទៀត ។
(ចាស់ណាដូចចាស់ណាទេ - អញ្ចឹង)
ចាស់ណាដូចចាស់ណាទេ   សូត្រមិន
ចេះអស់មិនចេះហើយអញ្ចឹង ។

ង គាត់ចូលចិត្តដាក់ទានណាស់ ។
(គាត់ - អញ្ចឹងបានជាគាត់មាន)
គាត់ដាក់មិនចេះអស់មិនចេះហើយ
អញ្ចឹងបានជាគាត់មាន ។

ច លោកសំអាតវត្តសឹងរាល់ថ្ងៃ ។
(លោក - អញ្ចឹងបានជាគេចូលចិត្ត)
លោកសំអាតមិនចេះអស់មិនចេះ
ហើយអញ្ចឹងបានជាគេចូលចិត្ត ។

DRILL THREE: Response

គំរូ
ក. បុណ្យម្តងៗសប្បាយណាស់ ។
(លុបបុណ្យទំនៀមខ្លះចោល)
ខ. កុំតែលុបបុណ្យទំនៀមខ្លះចោល   កុំអី
រឹតតែសប្បាយណាស់ទៅទៀត ។

MODEL:

T: Every celebration is a lot of fun.
(eliminate some traditional holidays)

S: If we hadn't eliminated some traditional holidays, it would be even more fun.

ក. ស្រុកយើង   គេធ្វើបុណ្យច្រើនណាស់ ។
(បានឯករាជ្យ)
កុំតែបានឯករាជ្យ   កុំអីរឹតតែច្រើន
ណាស់ទៅទៀត ។

ខ. លោកនិមន្តមកតិចណាស់ ។
(បានយាយទៅនិមន្ត)
កុំតែបានយាយទៅនិមន្ត   កុំអីរឹត
តែតិចណាស់ទៅទៀត ។

គ. បុណ្យនោះធំណាស់ ។
(បាសកជើងវត្តចាស់)
កុំតែបាសកជើងវត្តចាស់   កុំអីរឹតតែ
ធំណាស់ទៅទៀត ។

ឃ. មនុស្សចូលបុណ្យតិចណាស់ ។
(លោកគ្រូធំចូលមុនគេ)
កុំតែលោកគ្រូធំចូលមុនគេ   កុំអី
រឹតតែតិចណាស់ទៅទៀត ។

ង បុណ្យនោះមានមនុស្សកកកុញសម្បើម។
(មិនចំទូឈប់)
កុំតែមិនចំទូឈប់ កុំអីតែគេកកកុញសម្បើមទៅទៀត។

ច បង្ហាន់លោកមិនគ្រប់គ្រាន់ទេ។
(លោកតាជួយ)
កុំតែលោកតាជួយ កុំអីតែតែមិនគ្រប់គ្រាន់ទៅទៀត។

DRILL FOUR: Equivalence

គំរូ

ក គេលែងធ្វើបុណ្យអុំទូក ច្រត់នង្គ័លទៀតហើយ។

ខ គេឈប់ធ្វើបុណ្យអុំទូក ច្រត់នង្គ័លអស់ហើយ។

MODEL:

T: They've given up celebrating Om Tuuk and Chrot Nongkol.

S: They've stopped celebrating Om Tuuk and Chrot Nangkol.

ក ក្មេងភាគច្រើនលែងទៅនៅវត្តដូចមុនទៀតហើយ។
ក្មេងភាគច្រើនឈប់ទៅនៅវត្តដូចមុនអស់ហើយ។

ខ មនុស្សទូទៅលែងជឿថាមានស្ថានសួគ៌ទៀតហើយ។
មនុស្សទូទៅឈប់ជឿថាមានស្ថានសួគ៌អស់ហើយ។

គ ខ្មែរខ្លះលែងគោរពប្រពៃណីនិងទំនៀមទម្លាប់ខ្មែរទៀតហើយ។
ខ្មែរខ្លះឈប់គោរពប្រពៃណីនិងទំនៀមទម្លាប់ខ្មែរអស់ហើយ។

ឃ គេលែងបូជាសពដូចមុនទៀតហើយ។
គេឈប់បូជាសពដូចមុនអស់ហើយ។

ង គេលែងជឿកម្មផលដូចជំនាន់ដើមទៀតហើយ។
គេឈប់ជឿកម្មផលដូចជំនាន់ដើមអស់ហើយ។

ច យើងលែងមានសុចរិតយុត្តិធម៌ទៀតហើយ។
យើងឈប់មានសុចរិតយុត្តិធម៌អស់ហើយ។

DRILL FIVE: Response

គំរូ

ក ឥឡូវគេឈប់ធ្វើបុណ្យតាំងតុ អុំទូក ច្រត់នង្គ័លអស់ហើយ។
(ត្រូវ - ទុកបុណ្យអុំទូក)

ខ ហ្នឹងហើយ ប៉ុន្តែតាមត្រូវ ត្រូវទុកបុណ្យអុំទូក។

MODEL:

T: Now they've stopped celebrating Tang Tok, Om Tuuk and Chrot Nangkol. ((in) fact - keep Om Tuuk)

S: Right, but in fact they should keep Om Tuuk.

ក ឧបាសកឧបាសិកាមិនសូវទៅរក្សាសីលនៅវត្តទៀតទេ។
(យល់ - ទៅរក្សាសីលនៅវត្តយូរៗម្ដង)
ហ្នឹងហើយ ប៉ុន្តែតាមយល់ ត្រូវទៅរក្សាសីលនៅវត្តយូរៗម្ដង។

ខ លោកឱ្យច្បាប់គាត់ឈប់មួយខែឬ?
(ថា - ឱ្យឈប់តែមួយអាទិត្យបានត្រូវ)
ហ្នឹងហើយ ប៉ុន្តែតាមថា ត្រូវឱ្យឈប់តែមួយអាទិត្យបានត្រូវ។

គ គាត់ចង់បួសប៉ុន្មានឆ្នាំ?
(ឪពុកម្ដាយគាត់ចង់ - បួសរហូត)
ហ្នឹងហើយ ប៉ុន្តែតាមឪពុកម្ដាយគាត់ចង់ ត្រូវបួសរហូត។

ឃ នៅវត្តឈប់បង្រៀនកូនដំបង កូនចៅអស់ហើយ ។
(ក្រុងការ - ភុករបស់អស់ហ្នឹងខ្លះ)
ហ្នឹងហើយ ប៉ុន្តែតាមក្រុងការ ត្រូវភុករបស់អស់ហ្នឹងខ្លះ ។

ង បុណ្យហ្នឹង យើងបានឈប់ពីរថ្ងៃ មែនទេ ?
(ច្បាប់ - ឈប់តែមួយថ្ងៃទេ)
ហ្នឹងហើយ ប៉ុន្តែតាមច្បាប់ ត្រូវឈប់តែមួយថ្ងៃទេ ។

ច គេថាលោកនិមន្តទៅ ១០អង្គ មែនទេ ?
(ពិត - និមន្តទៅតែ៥អង្គទេ)
ហ្នឹងហើយ ប៉ុន្តែតាមពិត ត្រូវនិមន្តទៅតែ៥អង្គទេ ។

DRILL SIX: Transformation

គំរូ
ក យើងធ្វើបុណ្យច្រើនណាស់ ។
(បុណ្យជាតិ - បុណ្យប្រចាំគ្រួសារ)
ខ យើងធ្វើបុណ្យច្រើនមែន គឺតាំងពីបុណ្យជាតិរហូតដល់បុណ្យប្រចាំគ្រួសារ ។

MODEL:

T: We have a lot of holidays.
(national holidays - family holidays)

S: We do indeed have a lot of holidays, ranging from national holidays to family holidays.

ក ពុទ្ធសាសនាបានចាក់គ្រឹះមាំណាស់ ។
(សម័យអង្គរវត្ត - សព្វថ្ងៃនេះ)
ពុទ្ធសាសនាបានចាក់គ្រឹះមាំមែន គឺតាំងពីសម័យអង្គរវត្តរហូតដល់សព្វថ្ងៃនេះ ។

ខ ឥទ្ធិពលនេះមានយូរអង្វែងមកហើយ ។
(កើតស្រុកខ្មែរ - ឥឡូវ)
ឥទ្ធិពលនេះមានយូរអង្វែងមកមែន គឺតាំងពីកើតស្រុកខ្មែររហូតដល់ឥឡូវ ។

គ គាត់កាន់បុណ្យបានយូរអង្វែងមកហើយ ។
(ម្ដាយគាត់ស្លាប់ - គាត់ស្លាប់)
គាត់កាន់បុណ្យបានយូរអង្វែងមកមែន គឺតាំងពីម្ដាយគាត់ស្លាប់រហូតដល់គាត់ស្លាប់ ។

ឃ លោកគង់នៅវត្តហ្នឹងច្រើនឆ្នាំហើយ ។
(បួស - សឹក)
លោកគង់នៅវត្តហ្នឹងច្រើនឆ្នាំមែន គឺតាំងពីលោកបួសរហូតដល់លោកសឹក ។

ង មនោគមនេះចូលស៊ីបហើយ ។
(សតវត្សទី១ - ទី១៥)
មនោគមនេះចូលស៊ីបមែន គឺតាំងពីសតវត្សទី១រហូតដល់ទី១៥ ។

ច គាត់រក្សាសីលជាប់ច្រើនឆ្នាំហើយ ។
(គាត់ឈឺខ្លាំងនោះ - ថ្ងៃនេះ)
គាត់រក្សាសីលជាប់ច្រើនឆ្នាំមែន គឺតាំងពីគាត់ឈឺខ្លាំងនោះរហូតដល់ថ្ងៃនេះ ។

READING PASSAGE 2

ប្រពៃណី ទំនៀមទម្លាប់

មានប្រពៃណី និងទំនៀមទម្លាប់ ជាច្រើន ស្ទើរតែគ្រប់តែកកើតពីនៃ វប្បធម៌ អរិយធម៌ សុទ្ធតែមានទំនាក់ទំនង នឹងពុទ្ធសាសនា ដូចជា :

- ពិធីចំរើនជន្មាយុ (ចំរើនអាយុ)
- ពិធីអាពាហ៍ពិពាហ៍
- ពិធីបូជាសព ហែសព
- ពិធីកោរជុក ។
- ពិធី អភិសេក ព្រះពុទ្ធរូប ។

និងមានប្រពៃណីខ្លះទៀត ជាបែបពុទ្ធសាសនាសុទ្ធៗ ដូចជា :

- ពិធីចូលវស្សា
- ពិធីចេញវស្សា
- ពិធីបុណ្យកឋិន
- ពិធីបុណ្យផ្កា
- ពិធីភ្ជុំបិណ្ឌ .
- ពិធីបុណ្យបច្ច័យ ៤
- ពិធីបុណ្យនាគ មហាបង្សុកូល
- ពិធីបុណ្យ ទេសនាមហាជាតក ។ល។

ប៉ុន្តែ ដោយហេតុថា ខ្មែរបានទទួលឥទ្ធិពលសាសនាព្រាហ្មណ៍ផង ពុទ្ធសាសនាផង ទើបហើយក្នុងប្រពៃណី

ទំនៀមទម្លាប់ខ្មែរ ក៏មានលាយចម្រុះ ដោយធាតុទាំងពីរ ព្រាហ្មណ៍និយម ពុទ្ធនិយម ជាមួយនឹងខ្មែរនិយម ។

ហេតុនេះ ពិធីបុណ្យទានផ្សេងៗ ដែលជាប្រពៃណី ច្រើនតែមានធាតុទាំង ៣ លាយគ្នាដូចជា:

- ពិធីបុណ្យចំរើនបរិត្ត : គេនិមន្តព្រះសង្ឃចំរើនបរិត្ត ផង ធ្វើស្វាធ៌ បាយសី ឬ ស្វាធ៌ជូន ផង តាមបែបបុរាណ ។

VOCABULARY

កត្តា	/kattaa/	factor
កឋិន		an annual festival to donate to the wat toward the end of the three month rainy season retreat of the monks
កោរជុក		to shave the tuft of hair that a male child wears until about age seven
ជុក		a long tuft of hair that a male child wears until age seven
ខាតពេល		to waste time
* គិលានភេសជ្ជ		medicine, drugs (liquid)
គុណដាវ		the art of sword-fighting
ដាវ		sword
គុណដំបង		the art of fighting with staves or cudgels
ដំបង		a stick, staff (weapon), cudgel
គ្រោះ		danger
ចម្រុះ		to mix, to be mixed
តាំងគ្រឹះ		to become established, to form firm foundation
គ្រឹះ		house, foundation, pillar
តាំងឫស		to put down roots, to root
ឫស		root
ចំរើនបរិត្ត		to chant a blessing to avert danger
ច្រត់នង្គ័ល		a ceremony formerly performed by the king on the 4th day of the waning moon of Pisak (early May) to assure fertility of crops
ច្រត់		to lean on, support oneself, a walking stick
នង្គ័ល	/núŋkol/	a plow
ឆាក		to recite a blessing over the remains of the dead, which are tied up with raw cotton or cloth
ជៀស		to avoid
ជ្រះ		clean, scoured
ឈប់បុណ្យ		to get off work for a holiday

តាំងតុ	to exhibit, set up; name of a holiday celebrated on the king's birthday for which each province set up an exhibition in the palace
ថាឲ្យ	to blame, pick on, scold, criticize
ទំនោរ	tendency, inclination
ទោរ	to bend, soft, flexible
ធាតុ /thiat/	element, temperament
បច្ច័យ៤(=ចតុបច្ច័យ)	the four necessities for a monk (ចីវរ clothing, បិណ្ឌបាត food, សេនាសនៈ housing, គិលានភេសជ្ជៈ medicine
បច្ច័យ	money (monk)
បន្តិច + verb + បន្តិច + verb	to do often
បាយសី	a tiered ceremonial ornament made of banana tree components
បាសក(=ឧបាសក)	layman (spoken)
បុណ្យជាតិ	national holiday
បុណ្យទាន(=បុណ្យ)	alms-giving, merit making
បុណ្យផ្កា	a ceremony of giving gifts to monks
បូជាសព	to cremate a corpse
ប្រហែលៗគ្នា	alike, similar
ព្រលឹង	soul
មនោគម	ideology
* មនោ	mind, spirit, feelings (lit.)
មហាជាតក៍ /məhaaciadɔʔ/	name of a Buddhist scripture telling the story of Preh Vehsandor, a favorate story of Khmer Buddhists
មិនចេះអស់មិនចេះហើយ	endlessly
ម្លឹងៗ	thus, like that
វ៉ាកង់	to take a vacation (French: vacances)
សន្និដ្ឋាន	to guess
សមាទាន /saʔmaatian/	to express submission, to accept
សមាធិកម្មដ្ឋាន	worship
សមាធិ	devotion, self possession
កម្មដ្ឋាន /kammathaan/	prayer
សីលធម៌ /sələthóa/	manners and behavior that lead one to do good and avoid doing bad, precepts of rightousness, holiness and virtue (of people)
* សុន្ទរទាន /sontian/	a good, welcome gift
* សុន្ទរ /sontéʔréʔ, sontoó/	good, melodic, lovable, attractive, pleasing
ស៊ីបស្សន (ស្សន AC)	to infiltrate, be saturated
* សេនាសនៈ	a place to sleep and sit (often clerical)
សែនព្រេន	to sacrifice to spirits
សែន	to sacrifice to spirits, to give a bribe (to spirits)
* ព្រេន (H)	to make small offerings to spirits
* ស្មាទាន	see សមាទាន
ស្រោចទឹកសំរោះគ្រោះ	a ceremony in which monks sprinkle with water and chant to avert foreseen danger or bad luck
គ្រោះ	danger
ស្លាធ៌	a ceremonial ornament made with a banana tree trunk base
ស្លាធ៌ដូង	a ceremonial ornament made with a coconut base

ហែសព	/haɛ sɔp/ to have a funeral procession	ឯករាជ្យ	independent
ហែ	to accompany in a procession	ឱ្យច្បាប់	to give permission
អភិសេក	/aʔphiseek/ a ceremony honoring a new Buddha image	អុំទូក	to row boats, name of a holiday in honor of the beginning of the flood season

APPLICATIONS

1. Find the word(s) that fit(s) each of the following definitions.

example: ការធ្វើស្រែចំការ

answer : កសិកម្ម

១. កម្លាំងនៃអំណាចអ្វីមួយឬមនុស្ស ។
២. ពួកឬក្រុមមួយនៃជាតិមួយដែលប្រកបការរស់នៅដូចគ្នា ។
៣. ដុះជាប់នៅនឹងអ្វីមួយ ។
៤. អ្នកកាន់សាសនាព្រះពុទ្ធទាំងព្រះសង្ឃទាំងគ្រហស្ថ ។
៥. ផលល្អដែលយើងបានទទួលក្រោយពេលយើងបានធ្វើអ្វីមួយ ។
៦. ផលអាក្រក់ដែលផ្តល់ក្រោយធ្វើអំពើអ្វីមួយ ។
៧. ចាស់ពីដើមយូរណាស់មកហើយ ។
៨. ការផ្សាយឬធ្វើឱ្យមានធម៌ ។
៩. លោកសង្ឃមានពុទ្ធដីកា ពន្យល់ពុទ្ធសាសនាពុទ្ធាសិការនៅពេលបុណ្យមួយ ។
១០. សិល្បៈម្យ៉ាងដែលប្រើដំបង ។

2. Correct the following sentences by adding the porper words.

១. គាត់ចូលចិត្តទៅកន្លែងហ្នឹងណាស់ អត្ថិចទៅទៅ ។
២. គាត់រក្សាសីលមិនចេះអស់[illegible]ចេះទេ ។
៣. កុំតែមិនដាក់បាត្រលោក បានឡើងស្ថានសួគ៌ហើយ ។
៤. យើងពិតតែមានកម្មណាស់ទៅ ។
៥. ស្រុកយើងឥឡូវនេះសប្បាយទៀត ។
៦. ខ្មែរយើងចូលធ្វើបុណ្យច្រើនណាស់ បុណ្យប្រចាំគ្រួសារ បុណ្យតាមទំនៀមទម្លាប់
និងបុណ្យច្រើនទៀត ។
៧. យាយខ្ញុំសុំសីលតាំងពីខ្ញុំកើត គាត់ស្លាប់ ។
៨. ប្រជាជនខ្មែរទាំងប្រុសស្រីចូលចិត្តធ្វើបុណ្យណាស់ ។
៩. អ្នកពុទ្ធសាសនាជឿបុណ្យជឿបាបណាស់ ។
១០. ហេតុនេះរឿងផ្សេងៗដែលកើតរឿងយើង យើងត្រូវតែដឹង ។

3. Find the synonyms of the following words.

ឥទ្ធិពល ចាក់គ្រឹះ ពុទ្ធបរិស័ទ សក្ការៈបូជា គង់
និមន្ត ស្ថាន សព និយម ម្ល៉ោះហើយ
ដោយហេតុថា

4. Have the student discuss the following situations.

១ បុណ្យជាតិរបស់គេ (សិស្ស) ។
២ បុណ្យទំនៀមទម្លាប់របស់គេ (សិស្ស) ។
៣ បុណ្យសាសនារបស់គេ (សិស្ស) ។

5. Questions for the teacher to ask.

១. ពេលបុណ្យធំៗ លោកធ្វើអី? មនុស្សទូទៅចូលចិត្តធ្វើអី?
២ ជាតិលោកប៉ុន្មានភាគរយជឿថាមានស្ថានសួគ៌និងស្ថាននរក? ហេតុអី?
៣ ហេតុអីបានជាមានបុណ្យ? ដើមកំណើតនៃបុណ្យ?
៤ តើលោកជឿថាមានស្ថានសួគ៌ទេ? ហេតុអី?
៥. សព្វថ្ងៃគេធ្វើបុណ្យនៅឯណា?
៦ កាលណាមានបុណ្យសព គេធ្វើយ៉ាងម៉េចខ្លះ?
៧ មានពេលណាដែលគេធ្វើបុណ្យនៅផ្ទះទេ?
៨ ដើម្បីឲ្យបានបុណ្យកុសលដល់ពុកម្ដាយដែលស្លាប់ តើគេធ្វើបុណ្យអីខ្លះ?
៩ ដើម្បីឡើងស្ថានសួគ៌ ក្នុងសាសនាលោក គេធ្វើអីខ្លះ?
១០ គេសប្បាយនៅពេលបុណ្យ តើស្រុកលោក គេសប្បាយយ៉ាងម៉េចខ្លះ?

6. Questions for the student to ask.

a. Are there any holidays that the past several lessons have neglected to describe or mention? What are they?
b. Why are អុំទូក, ច្រត់នង្គ័ល, etc. no longer celebrated?
c. Is there any holiday on which people give each other gifts (like Christmas)?
d. On what occasions are the បាយសី, ស្លាធម៌, and ស្លាធម៌ខ្ទង់, used? What is their significance?
e. Can one make offerings to the spirits in the presence of monks?
f. Does religion enter into family celebrations like births, deaths, weddings etc.? How?
g. Are there coming-of-age rites? What are they like?
h. Do most Cambodians try to observe the five precepts (សីល៥)? Do they usually succeed?
i. Under what circumstances would one observe eight or ten precepts?
j. What are some of the additional 217 precepts that monks must follow?
k. Does following the five precepts make merit for one?

ANSWERS TO THE APPLICATION EXERCISES

LESSON ONE

2. ១ កុមារដ្ឋាន ២ បួន ៣ មធ្យមសិក្សា ៤ យក
៥ ឡើង ៦ មធ្យមសិក្សា ៧ ជាប់បាក់ទី២ ៨ ចុងឆ្នាំថ្នាក់ទី៣
៩ ទើប ១០ បាន

6. ១ ដែរ ២ យក ៣ ម្ដង ៤ ឲ្យ - ហើយ
៥ (ទើប) - ឡើយ ៦ តទេ ៧ ដិល - ទៅ ៨ ម្យ៉ាង
៩ ឲ្យ ១០ ឲ្យ

LESSON TWO

3. ១ ក៏ដោយ ២ ក៏ ៣ សោះ - ដែរ ៤ ឲ្យ - កុំឲ្យ
៥ ឲ្យ ៦ ឲ្យ ៧ ឲ្យ ៨ ស្រាប់
៩ ក៏ ១០ ជា

7. ១ ឲ្យ ២ នៅ ៣ ឲ្យ ៤ ដែរ
៥ ឲ្យ ៦ ហើយ ៧ ឯ ៨ តាម
៩ ទើប ១០ ក៏ដោយ

LESSON THREE

2. ១ ផលិតផល ២ ប្រភេទ ៣ ផ្លូវជាតិ ៤ ផែ - កំពង់ផែ
៥ អាកាសយាន ៦ អាជីវកម្ម ៧ សិក្ខណា ៨ ក្លាសាន
៩ ទំនិញ ១០ ចលនា

3. ១ ដើម្បី ២ ប្រភេទ ៣ បានជា ៤ ទៅ
៥ ផង - ផង ៦ មក ៧ មក ៨ ក៏
៩ ម្ដង ១០ ផង ម្ដងដែរ

LESSON FOUR

2. ១ អំពិល ២ រសេះរសោះ; អន្ទះអន្ទែង ៣ សាច់ដុំ ៤ វេទនា
៥ អាសន្នរោគ ៦ ត្រាបាសរោគ ៧ ដេកពេទ្យ ៨ គ្រូ
៩ ខ្មោចកាច ១០ ទៀបអន្សា

5. ១ ថា ២ ឲ្យ ៣ ឲ្យ - ផង ៤ ជាតិ
៥ ថា ៦ ទើប ៧ ទៀត ៨ ទៀត
៩ ប៉ុណ្ណឹង ១០ ផង

LESSON FIVE

1. ១ ផ្ដល់កំណើត ២ រយៈពេល ៣ សម្រាលកូន ៤ ការពិបាក
៥ ផ្ចិតតាំ, ផ្ចិតក្បាល ៦ ជំនាញ ៧ ជីកជ័រស្មើម ៨ ផុតក្បាល
៩ ហ៊ាន, ក្លាហាន ១០ ទិះកក ១១ ស្លាប់, ងាប់ ១២ មានផ្ទៃពោះ

3. ១ ទឹក ២ ឱ្យ ៣ ទឹក ៤ តាំង
៥ មាន ៦ អស់ ៧ ឱ្យ ៨ ឱ្យ
៩ ឱ្យ ១០ នាំ

LESSON SIX

1. ១ កំសត់ ២ ហ៊ុតចក់ ៣ ជំពាក់ ៤ មេបា
៥ អកតញ្ញូ ៦ ដាច់ចិត្ត ៧ កម្មករ ៨ អង្វរ
៩ អភ័យទោស ១០ ទំនួក

2. ១ ទេ ២ មិនបាន ៣ មី ៤ ទេច
៥ ឱ្យ ៦ ឱ្យ ៧ ការ ៨ ក៏
៩ នាក់ ១០ ទើ ១១ បើក

LESSON SEVEN

1. ១ សន្ទុក(រលឹង) ២ ស្ដាប់ ៣ បំពេញចិត្ត ៤ ពេញចិត្ត
៥ ហើយ ៦ ញូញើក ៧ ស្អាប ៨ ស្ទាក
៩ អន្តាយ ១០ សុភាព

2. ១ ឱ្យ ២ នឹង ៣ ឱ្យ ៤ ឱ្យ
៥ ថា ៦. នឹង ៧ ថា ៨. ណាយ
៩ តាម ១០ ឱ្យ

LESSON EIGHT

1. ១ ក៏ ២ សម្បូរទឹក ៣ សុទ្ធទឹក ៤ ទាំងអស់
៥ ទើប ៦ ក៏ដូច ៧ ក៏មាន ៨. កុំថាតែ
៩ ប៉ុន ១០ ពោះជា

LESSON NINE

1. ១ ទន្ទឹងថ្មី ២. មុខថាជា ៣ សារ ៤ ទេសភ
៥ បង់ពែក - ក៏ ៦ ស្លៀក ៧ ពោះ - ក៏ ៨ តាំង
៩ ក៏ ១០ ក៏

4. ១ ណា - ទឹក ២. កុំ ៣ គ្នា ៤ គ្នា
៥. តាំង ៦. បាន - ក៏ ៧. អស់ ៨ មន្ទុល

៩ សន្ត ១០ ដល់

LESSON TEN

1. ១ សំបូរ ២ ការសើបឡើយ ៣ ក្រោយមក ៤ សំដៅទៅ
៥ ទស្សកាល ៦ ក្រុមក្រា ៧ សាសនាព្រាហ្មណ៍ ៨ ទំដោះ, ដោះ
៩ និម ១០ ករស(ស៊ីប) ១១ (ចុះ) ចំណោះ

2. ១ តើ ២ ដោយ - ទៅ ៣ ក្នុង ៤ នៅ
៥ ក៏ - ជា ៦ ឲ្យ, មក, ទៅ ៧ ជាមួយ, និង ៨ ជា
៩ ជា ១០ មក

LESSON ELEVEN

1. ១ ស្ទូក ២ ពុទ្ធដីកា ៣ ចានស្រាក់ ៤ ចង្ហាន់
៥ សួគ ៦ នរក ៧ ស្បង់ចីវរ ៨ ចាប់ជាតិ

2. ១ ឲ្យ ២ ជា ៣ នេះ ៤ ហ្នឹង - ជា
៥ សន្ត ៦ ម្ល៉េះ ៧ នូវ ៨ ចា

LESSON TWELVE

1. ១ ភស្តុតាង ២ កម្ម, ចាប, ទៀង ៣ មរណា ៤ មគ្គទេស, ក្បួន
៥ សោមនស្សឬទោមនស្ស ៦ យថាកម្ម, តាមតា ៧ បួស
៨ ឆាន់ ៩ សឹក

2. ១ ចាប់, ក្រប់ ២ ទទ ៣ ឲ្យ ៤ ដែល
៥ ដោយ ៦ ឲ្យ ៧ មួយៗ ៨ ឲ្យ
៩ ឲ្យ ១០ វិញ

LESSON THIRTEEN

3. ១ ភេសជ្ជៈ ២. តាក់តែង ៣ ស្លាក ៤ [illegible] ៥. ហោរ
៦ ដង្រិក ៧ លោកព្រះសង្ឃរាជ ៨ អាចារ្យ ៩. កំសាន្ត
១០ ចំណី ១១ ស្លូង ១២ ទស្សង ១៣ ជញ្ជូន

LESSON FOURTEEN

1. ១. ទទៗ ២ ម្ដងៗ ៣ ដល់ ៤ នោះ
៥ ប្រគេន ៦ ផ្លាស់ ៧ ជាប់ ៨ នោះ
៩. ម្ដង

LESSON FIFTEEN

1. ១ ឥទ្ធិពល ២ សង្គម ៣ ចាក់គ្រឹះ ៤ ពុទ្ធបរិស័ទ
៥ បុណ្យ ៦ កម្ម, បាប ៧ បុរាណ ៨ វប្បធម៌
៩ ទេសនា ១០ កុនសំបង

2. ១ សាទិប ២ ហើយ ៣ កុំអី ៤ ទៀត
៥ ហើយ ៦ បិត្ត - គឺ ៧ ដល់, ទៀតដល់ ៨ ទាំង
៩ កាន់ ១០ ជា

BEST COPY AVAILABLE

សទ្ទានុក្រម

ខ្មែរ-អង់គ្លេស

CAMBODIAN-ENGLISH GLOSSARY

INTRODUCTION

This glossary contains approximately 3500 entries introduced in the 60 lessons of *Contemporary Cambodian: Introduction*, and in the fifteen lessons of the *Social Institutions* module.

Entries for words whose pronunciation is not predictable from the Cambodian orthography include romanization.

Abbreviations and Signs Used in This Glossary

v.	verb
n.	noun
adj.	adjective
adv.	adverb
esp.	especially
fig.	figuratively
intrans.	intransitive
lit.	literary
mil.	military
trans.	transitive
B.	Introduction
S	Social Institutions
R	reading passage
L	listening passage
AC	alliterating compound (of compound)
CC	component of compound with no independent meaning
RC	rhyming component (of compound)
(H)	bound form occurring only as part of a word
(= ...)	can also be written as ..., equivalent to ...
(< ...)	is a derivation of ...
... (...)	the word in the parentheses is optional
1, 2, 3, ...	the number found after B or S refers to the lesson number in that module, e.g., S4 is lesson 4 in the *Social Institutions*; B33R is lesson 33 in the *Introduction* (reading passage)

ក

ក	S13	to build, add; to form
កសាង	S8	to build
ក	B23L	collar
ក	B19	the neck
កក	B19	neck
ក៏	B17	so, then
ក៏ ដែរ	B28L	any ...
ក៏ដោយ ក៏ដោយ	B47R	whether ... or...
ក៏បាន	B20	is O.K., will do
ក៏មាន	B55R	even, it (sometimes) happens that ...
ក៏ម្យ៉ាងដែរ		that's one way
ក៏ហើយទៅ		too bad
កកកុញ	S4	many, a lot
កក់ក្ដៅ	S12	fervent
កក្កដា	/kaˀkədaa/ B30	July
កង	B49	unit (military)
កងទ័ព	B49	troops, armed forces
កងទ័ពពិសេស	B49	special forces
កងទ័ពព្រៃ	B49	guerrilla forces
កងពលតូច	B49	brigade
កងពលធំ	B49	division (mil.)
កងយកការសម្ងាត់	B49	reconnaissance platoon, intelligence company
កងវរសេនាតូច	B49	battalion
កងវរសេនាធំ	B49	regiment
កងវិស្វករ	B49	engineer corps
កងអនុសេនាតូច	B49	platoon
កងអនុសេនាធំ	B49	company
កង់	B13	bicycle
កង់	B13	wheel
កង់(ឡាន)	B14	tire, wheel
កង់តុង	S10	Canton
កញ្ចប់	B34	pack, bag (grocery)
កញ្ចែ	B60	a whistle
កញ្ឆា	B36L	marijuana
កញ្ជេរ	S14	a large basket (sometimes used for collecting garbage)
កញ្ជើ	S14	a kind of basket
កញ្ជ្រិល	B20	a kind of rash that does not suppurate
កញ្ញា	B10	Miss (title)
កញ្ញា	B30	September
កណ្ដាល	B15	middle
កណ្ដាប់	S10	classifier for measuring of quantities of things held in the hand, a handful
កណ្ដាប់ដៃ	S10	grip
កណ្ដាប់ចក្រវាល	S9	enclosing the world (refers to a mythical mountain range believed to encircle the world)
កត	/kaˀtaˀ/ S5	repayment
កតវេទិតា	S5	act of having repaid (literary)
កត់	S1	to make a note, note
កត់ត្រា	S9	to note, make a note
កត់សំគាល់	S8	to notice, to single out
កត្តា	S15	factor
កត្តិក	/kaˀdɨk/ S11	name of twelfth lunar month (mid-October to mid-November)
កឋិន	S15	an annual festival

		to donate to the wat toward the end of the three month rainy season retreat of monks
កន្ត្រក	B55R	a (marketing) basket
កន្ទេល	B23	a (sleeping) mat
កន្លង	S7	to pass (usually used for time), exceed
កន្លែង	B7	place
កន្លែងធ្វើការ	B7	office, place of work
កន្លះ	B7	half
កន្សែង	B22	a towel
កន្សែងដៃ		handkerchief
កន្សែងចាយ		napkin
កន្សែងយ័ន្ត	B57R	a scarf over which spells have been said which protects the wearer from harm
កប់	B53	to bury, to be buried or hidden
កប់មីន	B53	to set a mine
កប៉ាល់	B11	boat
កប៉ាល់ហោះ	B10	airplane
កប៉ាល់ហោះប្រតិកម្ម	B55	jet plane
កម្ពុជរាជ	S8	the kingdom of Cambodia
កម្ពុជា	S5	Cambodia
កម្ពុជាក្រោម	S10	Lower Cambodia (portion of S. Vietnam that was formely) Cambodian territory
កម្ម		action, consequence, result
កម្មករ	S6	laborer, coolie
កម្មការ	S2	result of work
កម្មវត្ថុ	S2	objective, subject
កម្មវិធី	S1	program
កម្មដ្ឋាន	S15	prayer
កម្រិត (<ក្រិត)	S4	limit
កម្លាំង (<ខ្លាំង)	B33	strength, power
កម្លោះ	S6	young man, bachelor
ករ (H)	S6	agentive suffix with certain bases
ករណីយ	S2	duty, something required, matter, act, cause, reason
ករណីយកិច្ច	S2	duty, function, role
ករុណា (ខ្ញុំករុណា)	S13	I, me; yes (like)(used in talking to a monk)
កល	S6	trick
កលល្បិច	S10	trick
កល់	S8	to make even, level
កសិ (H)	S6	pertaining to land and farming
កសិកម្ម	S3	agriculture
កសិករ	S6	farmer, peasant (formal)
កាច	B55	fierce, mean
កាច	S4	to kill, to break (a stick); to snap off
កាចពោត (បេះពោត)		to pick corn
កាណាដា	B4	Canada
កាណុង	B47	cannon
កាណូត	B35L	motorboat
កាត	B6	card; ID card
កាត់	B28	to cut; briefly
កាត់ចិត្ត	S7	to make a definite decision
កាត ដាច់	S7	to be able to decide
កាត់តំរាក	S11	to take after, to inherit someone's characteristics

កាត់សក់	B28	to cut hair, get a hair cut
កាត់សេចក្តី	B55L	to render a judgment, give a verdict, to sentence
កាន់	B56	to grasp, carry in the hand, to hold
កាន់	S3	towards, to
កាន់កាប់	B56	to be in charge of, to run (e.g., a business)
កាន់ការ	S2	to be in charge
កាន់តែ	B38	increasingly
កាន់តែ ឡើងៗ	B38	increasingly
កាន់សាសនា	S8	to have a religion, to believe in a religion
កាន់សីល	S11	to observe religious precepts (including abstinence)
កាប់	B33L	to cut, hack (with an ax or cleaver)
កាប់គាស់	S13	to clear (land)
កាប៉ូរ៉ាល់	S6	corporal, foreman, strawboss ([illegible]n official [illegible]le)
កាមតណ្ហា	S9	passion, sexual desire, love
កាយ	S4	body (formal)
ការ	B30	to marry, wedding, affair
ការ	B9	work, matter; nominalizes verbs
ការខូចខាត	B52	damage, casualty
ការងារ	B38L	labor, work, job
ការជប់លៀង	B38R	a party
ការបាត់បង់ជីវិត		casualty (life)
ការផ្សាយពាណិជ្ជកម្ម	S3	advertisement, commercial
ការពិសោធន៍	B48L	experience, experiment
ការសិក្សាជាន់ខ្ពស់	S1	higher education
ការហាត់	B3	a drill
ការណ៍	B9L	business
ការពារ	B41L	to defend, to protect, to protect from
ការពារកុំឲ្យ	B52L	to prevent ... from + verb
កាល	B12	when (past); time
កាល + clause + កាលណា	S7	when
កាលដើមឡើយ	S10	originally
កាលណា	B20	when, whenever
កាលណា ម្តងៗ	S13	whenever
កាលណោះ	S8	at that time, then
កាលបើ	S4	if, when, whenever
កាលពីប៉ុន្មាន នេះ	B50	in the past few
កាសែត	B6	newspaper
កាហ្វេ	B4	coffee
កិច្ចការ	B49	job, work, matter
កិត្តិយស	B57R	honor; of honor, honored
កិន	S6	to grind, mill
កិរិយា	S1	actions, behavior, personal characteristics
កិរិយាមារយាទ	S1	behavior, character
កីឡា	B43	sports
កុដិ	/kot/ S13	monk's quarters
កុន	B5	moving picture
កុមារ	S1	child (literary)
កុម្ភៈ	/kompéʔ/ B39	February
កុម្មុយនិស្ត	B57	communist
កុរ (ជ្រូក)	/kao/ S11	pig (name of the 12th year of 12-year cycle)
កុសល	S12	merit, good fortune (formal); lucky, fortunate

កុហក	S6	to lie; a lie
កូន	B8	child, small
កូនក្មេង		children
កូនខ្ចី	S5	infant, new born, baby
កូនចៅ	S10	descendants
កូនទាហាន	B47	enlisted man
កូនប្រសា	B18	son or daughter-in-law
កូនភូមិ	B25	villagers
កូនសិស្ស	B3	student, pupil
កូនសោ	B42	key
កូរណា (= ករុណា)	S13	yes (like ចាស,បាទ) (to a monk)
កូសាំងស៊ីនក្រោម	S10	Lower Cochin China (the Mekong delta area)
កុលាប	B45	rose (flower)
កើត	B13	can, to be able, possible (resultative verb)
កើត	B51	east
កើត	S11	refer to the waxing moon in lunar dates, e.g., ថ្ងៃសុក្រ១៥កើតខែវិសាខ Friday the 15th day of the first half (waxing moon) of the month of Visakh
កើត	B8	to be born
កើតកាលទាលក្ក	S14	to prosper, success, prosperity, success
កើតរោគ	S4	to have a disease
កើតឡើង	B50R	to arise, to come about
កើតអី	B19	what's the matter
កើន	S10	to increase, to become more
កៀក	B60F	to be close, adjacent
កៀកដៃ	B60F	to put an arm over another's shoulder, link arms, hold hands
កេណ្ឌ	B38	to draft, mobilize
កេរ្តិ៍	/kee/ S7	heritage, inheritance, personal secret
កេរ្តិ៍ឈ្មោះ	S7	reputation
កេរ្តិ៍មរតក	/kee moradə?/ S10	inheritance, heritage
កែងដៃ	B57	elbow
កែន	B38	to draft, mobilize
កែប	S6	seat of a bicycle
កែវ	B7	glass
កែវយឺត	B60	binoculars, spy-glass
កោដិ	/kaot/ S5	ten million
កោត	S1	to be in awe of
កោតតែ	S6	I can't believe that..., how can ... (happen)?
កោរ	B22	to shave, to cheat (colloquial)
កោរជុក	S14	to shave the tuft of hair that a male child wears until age 7
កោលាហល	S10	tense and angry
កោស	S10	to scrape off
កោសល្យ	S2	skill, profession
គរុកោសល្យ		profession of pedagogy
កៅសិប	B6	ninety
កៅស៊ូ	B44	rubber
កៅអី	B18	chair
កុំ	B6	don't
កុំ+ clause	S6	indicates warning or concern
កុំតែ កុំអី	S9	if it were not for...
កុំថាតែ A សូម្បីតែ B	S3	even (B) let alone (A); (even) (B)..., to say nothing of (A)

កុំបាន កុំអី	S10	if it were not for ...
កុំអាលទាន់	B27	don't ... yet
